សួន សុរិន្ទ

# ព្រះអាទិត្យថ្មី

## រះលើផែនដីចាស់

រង្វាន់ឥន្ទ្រទេវី លេខ១ ក្នុងការប្រឡងប្រលោមលោកប្រចាំឆ្នាំ ១៩៦០_៦១



# ព្រះអាទិត្យថ្មីរះលើដែនដីចាស់

## លំនាំរឿង

ថ្ងៃទី ១៩ កុម្ភៈ ឆ្នាំ ១៩៦០

រថអ័យ បានដឹកនាំអ្នកដំណើរចេញពីស្ថានីយ៍បាត់ដំបង ហើយបោលយ៉ាងលឿនសំដៅទៅទីក្រុងភ្នំពេញដោយបញ្ចេញសន្ទឹកសន្ធាប់ខ្ទ័រខ្ទារស្ទើរញាប់ញ័រប្រថពី។

ពួកអ្នកជិះភាគច្រើនបាននាំគ្នាធ្វើដំណើរទៅកាន់រាជធានី ដើម្បីចូលរួមក្នុងពិធីសមាជជាតិលើកទី៩។ ពួកគេមានចិត្តសប្បាយរីករាយរកអ្វីប្រៀបគ្មាន ខ្លះនិយាយសើចដាក់គ្នាខ្លះសើចក្អាកក្អាយ។សមាជជាតិ១ សមាជជាតិលើកទី៩ដែលនឹងត្រូវធ្វើនូវថ្ងៃស្អែក។ នេះជាពាក្យដែលអ្នកដំណើរទាំងនោះចង់ចាំគ្រប់គ្នា ហើយដែលគេបន់ស្រន់បន់ឲថ្ងៃស្អែកមកដល់ឆាប់ៗ។

ក្នុងចំណោមអ្នកដំណើរ ដែលកំពុងសប្បាយរីករាយទាំងនេះបើគេពិនិត្យមើលមត់ចត់ទៅ គេនឹងឃើញបុរសម្នាក់រាងធំដំបង សម្បុរសណ្ដែកបាយ សក់រួញមុខរាហ៍ មានភ្នែកខូងរូងកប់ទៅក្រោមរោមចិញ្ចើមដ៏ក្រាស់ ដែលជាលក្ខណះសំដែងឲឃើញថាបុរសនេះជាអ្នកម៉ឹងម៉ាត់ក្នុងការងារតែមានការគិតច្រើន។ បុរសនេះមានឈ្មោះថាសួន សម មានអាយុប្រហែល២៨ឆ្នាំ។ សួន សមស្លៀកខោជើងវែងកាគីពណ៌ប្រផេះ ពាក់អាវសឺមីសដៃវែងពណ៌ស អង្គុយបឺតបារីផ្សែងហុយផ្លុំចោលភ្នែកក្រលេកមើលទេសភាពទាំងឡាយតាមបង្អួចរថអ័យដោយការសង្កេត ពិនិត្យ ។

ខណះនោះជាចុងហេមន្តរដូវ ព្រះដ៏ត្រជាក់បានបោកបក់យ៉ាងខ្លាំងចូលមកតាមចន្លោះតបង្អួចនៃរថអ័យ ហាក់ដូចជាចង់មកកាត់ស្បែកចុងច្រមុះ និងត្រចៀករបស់អ្នកអើតមកតាមបង្អួច។ សម សង្កេតមើលឃើញរុក្ខជាតិទាំងឡាយពណ៌ស្រស់បំព្រង មានសភាពហាក់បីដូចជាជួយអបអរសាទរជូនដំណើរប្រជាជនដែលធ្វើដំណើរទៅចូលរួមពិធីសមាជជាតិលើកទី៩ សំឡេងព្រះពាយដែលបោកបក់ជ្រៀតចូលទៅក្នុងមែករុក្ខជាតិស៊ុបទ្រុបដោយសន្លឹក ក៏លាន់ឮឡើងគួរឲ្យរំភើបចិត្តជាសំលេងតូរ្យតន្ត្រីដែលពោលពេញទៅដោយភាពរីករាយ ដែលបានបន្លឺឡើងជាសញ្ញាថាជាសំលេងរបស់ធម្មជាតិដ៏ស្រស់ និងពិរោះសំរាប់មនុស្សលោក។សភាពគ្រប់យ៉ាងកំពុងឋិតនៅក្នុងសេចក្តីសុខក្សេមក្សាន្ត......រយះចំងាយគ្រប់ៗគីឡូម៉ែតដែលរថអ័យបានផុតទៅ រុក្ខជាតិទាំងឡាយហាក់ដូចជាខំសប្បាយប្រណាំងគ្នា ផ្ដាំហេមន្តរដូវ ហាក់ដូចជាគិតថាជិតដល់ពេលផុតហេមន្តរដូវហើយព្រោះចុងខែកុម្ភះនៅពេលដែលរុក្ខជាតិទាំងឡាយ កំពុងតែជិតដល់ពេលស្រពោនក្រៀមក្រំ

ដោយសារកំដៅព្រះអាទិត្យក្នុងគិម្ហន្តរដូវដែលនិងត្រូវមកដល់ក្នុងពេលឆាប់ៗនេះ តែសភាពពិតប្រាកដនៃការសប្បាយរីករាយ ឬការសោកសៅរបស់ជីវិតធម្មជាតិនេះមនុស្សធ្លាប់បានជួបប្រទះមកហើយ ដោយសារមនុស្សលោកជួយបណ្តាលឲ្យតឡើងដោយស្នាដៃរបស់មនុស្ស សមនឹករលឹកដល់ការចំរើនក្នុងបច្ចុប្បន្ន នឹងការវិនាសនានាប្រការក្នុងអតីត ដែលកើតឡើងព្រោះអសន្តិសុខសូម្បីវាលស្រែនឹងព្រៃភ្នំដ៏ល្វឹងល្វើយដែលពោលពេញទៅដោយសេចក្តីបរិសុទ្ធរបស់ចិត្តិថ្លើម វាលស្រែនិងព្រៃភ្នំពោរពេញដោយទឹកចិត្តិដ៏ស្មោះត្រង់ដូចទឹកចិត្តិរបស់បុព្វបុរសខ្មែរសម័យអង្គរ វាលស្រែនឹងព្រៃភ្នំដ៏ស្ងប់ស្ងៀម នឹងស្រស់បំព្រងទៅដោយពណ៌ នឹងសំឡេងរបស់ធម្មជាតិ សមនឹករលឹកដល់សម័យដែលប្រទេសកម្ពុជាត្រូវពួកចក្រពត្តិនិយមបារាំងជិះជាន់ សម័យដែលប្រទេសខ្មែរត្រូវជួបប្រទះនឹងអសន្តិសុខ សម័យដែលប្រជាជនខ្មែរទូទាំងប្រទេសបាត់បង់សេរីភាពក្នុងពេលអសន្តិសុខ ហើយនឹងសេក្តីទុក្ខវាទនាដែលប្រជាជនខ្មែរត្រូវជួបប្រទះក្នុងពេលសន្តិសុខនោះ។

សមបោះកន្ទុយបារីចោលហើយបញ្ជូញចិត្តឲ្យគិតតទៅទៀត។

សមគិតថា៖

ជីវិតរបស់មនុស្សមិនទៀងទាត់ តែជីវិតដែលមិនទៀងទាត់នេះជាមេរៀនមួយដ៏ប្រសើរលើសលប់សំរាប់ប្រដៅយើងឲ្យស្គាល់នូវតំលៃរបស់មនុស្សឲ្យចេះអត់ធន់នឹងសេចក្តីទុក្ខលំបាកនឹងសេចក្តីខុសបំណងទាំងឡាយ ជីវិតរបស់មនុស្សយើងជាគ្រឿងប្រៀបធៀបឲ្យយើងឃើញនូវសេចក្តីល្អ និងសេចក្តីអាក្រក់ គ្រឿងជំនួយម្យ៉ាងដែលធ្វើឲ្យយើងអាចវិនិច្ឆ័យឃើញថា ពេលនេះមនុស្សលោកល្អ ឬ អាក្រក់ជាសាក្សីសំរាប់សំដែងឲ្យយើងឃើញយ៉ាងច្បាស់ថាសម័យថ្មីដែលយើងគិតថាបានកន្លងផុតយូរយារណាស់មកហើយនោះ ការពិតវាបានឃ្លាតឆ្ងាយចេញពី សម័យយើងនេះត្រឹមណា ហើយជីវិតរបស់យើងក្នុងអតីតកាល ការដាស់តឿនយើងឲ្យតាំងខ្លួននៅក្នុងសេចក្តីមិនប្រមាថបានដាស់តឿនយើងថា យើងមិគួរស្រែកអំពាវនាវសុំនូវសេចក្តីយុត្តិធម៌ពីជោគវាសនាជាដាច់ខាតព្រោះថាជោគវាសនាជាចៅហ្វាយនាយរបស់ជីវិតដែលពោរពេញទៅដោយការស្មាក់ស្មើរកន្លះវាយកអ្វីមកធ្វើជាការពិតប្រាកដមិនបាន បង្រៀនយើងឲ្យដឹងច្បាស់ថា អំពើរល្អមិនមែនជាអំពើរដែលមនុស្សលោកសុទ្ធតែត្រូវការគ្រប់ពេលវាលាទេព្រោះថា អំពើអាក្រក់ជូនការប្រសើរជាងអំពើល្អក៏មាន។

សមស្មើរតែរកគិតមិនយល់ថា អំពើល្អនិងអំពើអាក្រក់នេះ ជាអ្វីពិតប្រាកដ? មានអ្នកណាអាចតាំងទ្រឹស្តីឡើងបានឬទេថា អំពើល្អគឺអ្វី? អំពើអាក្រក់គឺអ្វី? ព្រោះវាចេះតែមានបញ្ហាចោទឡើង

ជានិច្ចឧបមាថា យើងតាំងទ្រឹស្តីឡើងបានហើយថាអំពើល្អ គឺយ៉ាងនេះហើយ ហើយយើងប្រតិបត្តិតាមទ្រឹស្តីនោះយ៉ាងទៀងទាត់ល្បងមើលដើម្បីជាគ្រឿងបញ្ជាក់ថា ការធ្វើយ៉ាងនោះវាមុខជានឹងធ្វើឲ្យលទ្ធផលយើងពិតប្រាកដឬ? រឿងនេះសមដែលធ្លាប់ហែលក្នុងអន្លង់ជីវិតចំពោះការគ្រប់យ៉ាងយល់ថាការធ្វើល្អនេះមិនមែនចេះតែមានលទ្ធផលដល់អ្នកធ្វើជានិច្ចនោះទេ ធ្វើល្អបានល្អ ជាសុភាសិតដែលងាយស្តាប់តែពិបាកយល់ ជួនកាលទាល់តែយើងក្លាយជាអ្នកប្រាជ្ញសិន ទើបអាចយល់ដល់ជំរៅនៃសុភាសិតថាដែលងាយស្តាប់តែពិបាកយល់ ជួនកាលទាល់តែយើងក្លាយជាអ្នកប្រាជ្ញសិន ទើបអាចយល់ដល់ជំរៅនៃសុភាសិតថា៉ធ្វើល្អបានល្អ ៉នេះថាប្រែដូចម្តេច សមធ្លាប់គិតថាការធ្វើនេះអាចត្រូវការនុវចង្វាក់ខ្លះទេដឹង ទើបវាអាចផ្តល់លទ្ធផលល្អដល់អ្នកធ្វើ? ប្រសិនបើគំនិតដូចច្នេះជាការពិតត្រូវវិញនោះទ្រឹស្តីពិតប្រាកដរបស់អំពើល្អ ក៏ដូចជារកទុកចិត្តទុកថ្លើមមិនបានដែល ព្រោះអំពើល្អវាក្លាយទៅជាសភាពមិនពិតទៅវិញ។ ក្នុងករណីដូចច្នេះអំពើរល្អគឺជាព្រឹត្តិការណ៍ម្យ៉ាងដែលត្រូវប្រតិបត្តិឲ្យសមតាមកាលវេលា ទើបវាអាចហុចលទ្ធផលល្អឲ្យអ្នកធ្វើតែយ៉ាងណាក៏ដោយចុះក៏នូវតែជឿថា លោកនេះជាលោករបស់ចង្វាក់ សភាពគ្រប់បែបយ៉ាងសុទ្ធតែត្រូវការចង្វាក់ទាំងអស់ ការពិរោះរងំរបស់តូរ្យតន្ត្រីដែលនឹងកើតឡើងបានក៏ព្រោះចង្វាក់ នេះជាសភាពពិតប្រាកដរបស់ជីវិត គឺជាសភាពពិតប្រាកដដែលគ្មាននរណាប្រកែកបាន សមគិតថាខ្លួនគេធ្លាប់បានស្គាល់នូវចង្វាក់នោះខ្លះៗហើយ ចង្វាក់ដែលគួរអស់សំនើចយ៉ាងក្រៀមក្រំ....។

នឹកដល់រឿងត្រង់នេះសមចង់តែស្រែក...ស្រែក...ស្រែកអំពាវនាវក្នុងសករាជថ្មីនេះ ដើម្បីឲ្យមហាជនបានឮ ដើម្បីឲ្យទំងន់នៃមហាទុក្ខ ដែលគ្របសង្កត់លើបេះដូងបានធូរស្បើយ បើមិនច្រើនក៏តិច....។

សមនឹករលឹកដល់មហាទុក្ខក្នុងមហាសាគរ...គឺជីវិតក្នុងគ្រាអតិត ដែលខ្លួនធ្លាប់បានហែលឆ្លងកាត់មកទាំងប្រផាត់ប្រផើយកាលពី ៧ ៨ឆ្នាំមុននឹកដល់សេចក្តីសុខសប្បាយក្នុងគ្រាបច្ចុប្បន្ន....។

សមបានទាញយកជីវភាពកាលពី ៧ ៨ឆ្នាំមុន មកប្រៀបធៀបគ្នាមើលនឹងជីវភាពក្នុងបច្ចុប្បន្ន.....សមឃើញការរស់នៅរបស់ខ្លួនទាំងពីរសម័យនេះខុសគ្នាដូចមេឃនឹងដី ព្រោះជីវិតក្នុងគ្រាអតីត សមស្ទើរតែយោងខ្លួនមិនរួច តែនៅគ្រាបច្ចុប្បន្ន សមបែជាបានទទួលនូវសេចក្តីចំរើន និងសុខសប្បាយដ៏គួរពេញចិត្ត.....។

នឹកឃើញជីវិតក្នុងគ្រាអតីត សមចង់តែស្រែកប្រកាសប្រាប់មហាជនឲ្យបានដឹងទូទៅព្រោះថាជីវិតពោរពេញទៅដោយសេចក្តីទុក្ខព្រួយ.......។

ឆឆឆឆឆឈឈឈឈ

## ភាគទី១ គ្រកូលកសិករកំសត់

គ្រកូលរបស់ សួន សម ជាកសិករសាមញ្ញ។ បុព្វបុរសរបស់សួន សម ខាងឪពុកក្តី ខាងម្តាយក្តី ជាអ្នកស្រែទាំងអស់ជាអ្នកស្រែទាល់តែមាននិស្ស័យដក់ជាប់ទៅនឹងស្រែ ដែលគួរណាស់តែបានទទួលនូវការលើកតំកើងក្នុងឋានៈជាអ្នកសាបព្រោះនូវស្រូវ សំរាប់ចិញ្ចឹមជីវិតប្រជាជនទូទាំងប្រទេស តែថាមានអ្នកស្រែណាមួយបានទទួលលើកតំកើងនោះ? ព្រោះអ្នកស្រែ ជាអ្នកក្រីក្រស្លៀកពាក់រហែកលេចមុខលេចក្រោយ ហើយខ្វះការសិក្សា។ ដូច្នោះក្នុងសម័យអាណានិគមនិយមពួកអ្នកស្រែភាគច្រើនតែងតែត្រូវគេមើលងាយ ត្រូវគេជិះជាន់សង្កត់សង្កិន ពីលោកអ្នកធំ អ្នកមានខ្លះនូវតាមនិគមជនបទ ហើយរហូតមកដល់សព្វថ្ងៃនេះ ដោយសារការជាប់កំអែលអាណានិគមនិយមនោះ បើមានអ្នកណាមួយមិនពេញចិត្តនឹងអ្នកណាមួយទៀតនោះ គេតែងស្តីឲ្យគ្នាថា«អាអ្នកស្រែ» ឬ «មីអ្នកស្រែ»។ ក្រៅពីនេះពួកអ្នកស្រែនៅត្រូវធ្លាក់ខ្លួនទៅជាខ្ញុំកំដររបស់ពួកនាយទុន ឬជនបរទេស ដែលវាមានឧបាយកលជាច្រើនក្នុងផ្លូវជំនួញទៀតផង។

សួន សម ជាកូនប្រុសតែមួយគត់របស់ សួន សុខ និង នាង សន នៅឃុំបរិល ស្រុកសង្កែ ខេត្តបាត់ដំបង។ កាលពីឆ្នាំ ១៩៤៩ សួន សុខ គឺជាឪពុករបស់សួន សម ដោយគេចោទថា ចូលដៃជាមួយនឹងពួកឥស្សរៈ ពួកទាហានបារាំងបានចាប់ចងយកទៅធ្វើទារុណកម្មផ្សេងៗនៅឯស្តុកអាចម៍រមាស ហើយក៏ត្រូវស្លាប់បាត់បង់ជីវិតនៅទីនោះ ដោយទុក្ខឲ្យនាងសននៅមេម៉ាយក្នុងលោក។ ខណៈនោះសមដែលកំពុងនូវរៀនថ្នាក់ឧត្តមដ្ឋាន ក៏ត្រូវលាដៃលាចាកដំបូលសាលារៀនដែលជាកន្លែងសំរាប់គ្រេបជញ្ជក់យកនូវចមនេះវិជ្ជាកគ្រប់យ៉ាងទាំងអាល័យដើម្បីត្រលប់ទៅនៅជួយធ្វើការងារម្តាយមេម៉ាយវិញ។ ក្រោយពីនោះមកមួយឆ្នាំ សមក៏ត្រូវឥស្សរៈសង្ស័យថា ជាអ្នកចូលដៃជាមួយនឹងពួកបារាំងទៅវិញ។ ការនេះបានធ្វើឲ្យ សួន សម មានសេចក្តីភិតភ័យ និងព្រួយបារម្ភជាខ្លាំង ។ សមត្រូវលាម្តាយជាទីស្រលាញ់ស្មើដល់ជីវិត ធ្វើដំណើរទៅកាន់ទីក្រុងបាត់ដំបងដើម្បីគេចខ្លួនពីពួកឥស្សរៈ តែឆ្នាំនោះជាឆ្នាំដែលសមបានទទួលនូវគ្រោះអាក្រក់ជាទីបំផុត ព្រោះក្រោយពេល

គេបែកមក៤ថ្ងៃ ម្ដាយរបស់សមក៏ត្រូវស្លាប់ដោយជំងឺអាសន្នរោគទៅទៀត ។ សម ត្រូវត្រលប់ទៅស្រុកកំណើតវិញ ដើម្បីចាត់ការការធ្វើបុណ្យសពម្ដាយទាំងប្រថុយស្លាប់ ។ លុះបានធ្វើបុណ្យសពម្ដាយរួចហើយ សមកំលោះអភ័ព្វ ដែលទើបតែមានអាយុ ១៨ ឆ្នាំ ក៏ដាច់ចិត្តធ្វើដំណើរទៅកាន់រាជធានីភ្នំពេញ ដើម្បីស្វះស្វែងរកការងារធ្វើ។

សមនៅសល់ខោអាវត្រឹមតែមួយបន្លាស់ប៉ុណ្ណោះ។ សម បានចូលទៅក្នុងសំណាក់អាស្រ័យជាមួយនឹងភិក្ខុមួយអង្គ នៅក្នុងវត្តមហាមន្រ្តី ដែលលោកក៏បាននិមន្តមកពីខេត្តបាត់ដំបងដែរ។ ព្រះភិក្ខុសៅបានជួតជ្រោមជ្រែងយកសមទៅផ្ញើរឲ្យធ្វើការជាកម្មករលីសែងនៅក្នុងហាងជំនួញមួយមានតំលៃឈ្នួលត្រឹមតែ ១៥ រៀលប៉ុណ្ណោះក្នុងមួយថ្ងៃ ។

នេះជាគ្រាតំបូងក្នុងជីវិត ដែលសមធ្វើការបានប្រាក់ខែ ។ សម តែងគិតថា ខ្លួនគេមុខជានឹងបានទទួលនូវសេចក្ដីសុខកាយសប្បាយចិត្តតរៀងទៅ តែទីបំផុតចាប់តាំងពីកាប៉ូរ៉ាល់ រហូតដល់ភ្នាក់ងារអ្នកធ្វើការក្នុងហាងនោះ បានសំដែងនូវសេចក្ដីមើលងាយ មើលថោកសមជាខ្លាំង ទាល់តែសមទ្រាំនូវធ្វើការតទៅទៀតមិនបាន ។ សមត្រូវ កាប៉ូរ៉ាល់ជេរម្ដាយកាយឪពុក កាលបើធ្វើការយឺតយុរ បន្តិចបន្តួច ឬ ក៏មិនពេញចិត្តគេ ។ សមត្រូវភ្នាក់ងារស្មៀនខ្លះហៅ«អា»ឬក៏ជេរដោយពាក្យអសុរស ដែលជាហេតុធ្វើអោយសមនឹងតូចចិត្ត តូចថ្លើមជាខ្លាំង ។

សមតែងគិតថា ខ្លួនគេមិនគួរជាធ្លាក់ទៅជាខ្ញុំកញ្ជះនៃអំណាចទឹកប្រាក់សោះគួរតែមានសភាពជាមនុស្ស ស្មើគ្នានឹងមនុស្សទាំងអស់។ គិតយូរៗទៅ សមរឹតតែតូចចិត្តខ្លាំងឡើងៗ.....តែថាអ្នកក្រនឹងទៅឈ្លោះជាមួយនឹងអ្នកណាឈ្នះ ? ព្រោះការក្ដីក្ដាំងក្នុងសម័យអាណានិគមនិយមបារាំង តែពោរពេញទៅដោយអំពើអយុត្តិធម៌ យ៉ាងអស្ចារ្យ.....។ដូចច្នោះគ្មានការអ្វីល្អជាជាងការលាលែងឈប់ធ្វើការ នោះឡើយ ។

តពីនោះមកសមខំដើរស្វះស្វែងរកការងារធ្វើតទៅទៀត ។ សមខំចូលទៅសុំធ្វើការជាកម្មករនៅតាមហាងជំនួញ និងកន្លែងធ្វើការនៃរាជការខ្លះៗ តែគ្រប់ទីកន្លែងទាំងនោះសមតែងបានទទួលនូវពាក្យល្វីងជូរចត់អ្នកត្រួតត្រាចាត់ដូចៗគ្នា ។ សមអត់ទ្រាំនឹងពាក្យសំដី អាក្រក់មិនបានក៏តែងផ្លាស់ទីកន្លែងធ្វើការជារឿយៗ ។ សមនឹកអានិតមិត្តកម្មករ អ្នកក្រលំបាកគ្រប់ៗគ្នា ដែលត្រូវធ្លាក់ខ្លួនទៅជាខ្ញុំកំដររបស់អំណាចទឹកប្រាក់.....ត្រូវគេជេរប្រទេច..... ត្រូវគេមើលថោកគ្រប់បែបយ៉ាងដែលមិខុសពីសត្វតិរិឆ្ឆាន ។ សម បានធ្វើដំណើរការនៃជីវិតអោយប្រព្រឹត្តិទៅក្នុងផ្នែកផ្សេងៗ...ទីបំផុតសមក៏បានធ្លាក់ខ្លួនទៅជាកម្មករត្រីចក្រយាន ។

ឥឡូវនេះសមលែងសំណាក់អាស្រ័យនៅក្នុងវត្តទៀតហើយ ដោយសារសមមានប្រពន្ធ ។ នាង សយ ប្រពន្ធរបស់សម គឺជាស្រីបំរើរបស់គេហដ្ឋានរបស់ធនបតីម្នាក់ ។ សមបាននាំប្រពន្ធកំសត់របស់ខ្លួន ទៅជួលខ្ទមមួយតូចនៅជិតផ្សារសួនថ្មី ក្នុងសភាពជាកម្មកររកព្រឹកស៊ីល្ងាច ដោយត្រីចក្រយានគួជីវិត ដែលសមត្រូវបង់ថ្លៃ ឈ្នួលអោយម្ចាស់ត្រីចក្រយាននោះ ៣០ រៀលក្នុងមួយថ្ងៃ ។

ឋានៈរបស់សមក្រីក្រលំបាកវាទនាជាទីបំផុត។ មានថ្ងៃខ្លះសមរកប្រាក់បានត្រឹមថ្លៃឈ្នួលត្រីចក្រយានតែប៉ុណ្ណោះ។ សមនឹងនាងសយសុខចិត្តអត់អាហារ ដើម្បីរកប្រាក់ទៅបង់ថ្លៃឈ្នួលត្រីចក្រយាន ព្រោះអ្នកម្ចាស់ត្រីចក្រយានធនបតីមុខក្រាស់ជាទីបំផុត មិនដែលបន្ធូបន្ថយ ឬ លោះលាអត់អោនអោយកម្មករត្រីចក្រយានណាសោះឡើយ ទោះកម្មករនោះរកប្រាក់បានក៏ដោយមិនបានក៏ដោយ ។កម្មករណាខានបង់ថ្លៃឈ្នួលត្រីចក្រយានត្រឹមតែមួយប៉ុណ្ណោះ ក៏ត្រូវតែអូស យកត្រីចក្រយានទៅវិញភ្លាម ហើយគ្មានសង្ឃឹមថា នឹងបានត្រីចក្រយានមកធាក់ទៀតឡើយ ។ អំពើបែបនេះធនបតីម្ចាស់ត្រីចក្រយានច្រើនតែប្រព្រឹត្តជានិច្ច ដោយឥតអាសូរកម្មករត្រីចក្រយានបន្តិចបន្តួចសោះឡើយ។

ឆឆឆឆឆឈឈឈឈឈ

**ភាគទី២** **ជីវិតកម្មករនៅទីក្រុង**

នាកណ្តាលរវស្សាន្តរដូវ ភ្លៀងធ្លាក់ចុះជោគជាំផែនដីស្ទើររាល់ថ្ងៃជាហេតុធ្វើឲ្យកម្មករត្រីចក្រយាន រកប្រាក់មិនសូវបាន ព្រោះមិនសូវមានអ្នកជិះ ។

សមត្រូវនាំយកប្រាក់ដែលខ្លួនបានសន្សំទុកមកពីពេលមុនខ្លះៗ ទៅបង់ថ្លៃឈ្នួលត្រីចក្រយាន ដែលក្នុងពេលតៗមកសមបានប្រើប្រាស់អស់ពីខ្លួនអស់ពីប្រាណ ។

ផ្ទៃមេឃសៅម៉ងដោយគ្រាប់ភ្លៀងតាំងពីរបីថ្ងៃមកហើយ។

ភ្លៀងធ្លាក់សស្រាក់ស្រាំស្ទើរតែមិនដាច់គ្រាប់.....។

ព្រឹកនេះភ្លៀងធ្លាក់ជោគជាំទៀត។ សមអង្គុយអោបក្បាលជង្គង់នៅក្នុងកូនខ្ទមតូចរបស់គេ ហើយកំពុងតែព្រួយចិត្តជាមួយ និងនាងសយជាប្រពន្ធកំសត់កម្រ ។ នៅក្នុងកូនខ្ទមនោះគ្មានសម្បត្តិអ្វីក្រៅពីកន្ទេល ខ្នើយនិងមុងចាស់ៗនោះឡើយ ត្រីចក្រយានចតចោលនៅពីមុខកូនខ្ទម

នោះ។ ទឹកមុខរបស់សមសៅហ្មងដោយការព្រួយបារម្ភណ៍....សមខានបង់ថ្លៃឈ្នួលត្រីចក្រយានថ្ងៃម្សិលមិញនេះមួយថ្ងៃទៅហើយ ។ សមគិតថា ខ្លួនគេត្រូវធ្វើយ៉ាងណាស្រួលប្រសិនបើម្ចាស់ត្រីចក្រយានមកអូសយកទៅវិញ....ព្រោះការស្វែងរកជួលត្រីចក្រយានពីអ្នកដ៏ទៃទៀតនោះជាការពិបាកណាស់ ដោយត្រូវមានអ្នកធានា និងមានប្រាក់កក់បញ្ចាំទៀតផងទើបបាន ។

"យើងគិតធ្វើយ៉ាងម៉េចទៅសយ" សមនិនាយទៅប្រពន្ធដោយការព្រួយចិត្ត "សយប្រហែលជាគិតថា បងខំរកប្រាក់ហើយក៏ទៅឈប់សីក្លូត្រង់ណាលេង តែតាមពិតបងខំធាក់សីក្លូស្ទើរតែមិនបានសំរាក តែគ្មាននរណាជិះសោះ ហើយបើភ្លៀងអញ្ចឹងទៀតផងនោះវារឹតគ្មានអ្នកជិះសោះទៅទៀត ព្រោះគេមិនសូវដើរលេង"។

នាងសយជាស្រីដែលចាត់ថា មានរូបឆោមស្អាតបាតម្នាក់ ។ នាងមានអាយុប្រហែល១៧ឆ្នាំ ។ នាងជាស្រីមានសាច់ឈាមសស្អាត មានអាធ្យាស្រ័យល្អ ជាទីស្រលាញ់របស់ញាតិមិត្តជិតខាង និងជាស្រីស្ងប់ស្ងៀមមិនសូវនិយាយស្តី តែពេញទៅដោយការស្មោះត្រង់ចំពោះប្តី។

ពាក្យសំដីរបស់ប្តីបានធ្វើឲ្យនាងសយព្រួយចិត្តជាខ្លាំង"ទេបង!" នាងសយឆ្លើយឡើង " អូនមិនដែលបងខំលរកប្រាក់កាក់នោះទេ ព្រោះការធាក់ស៊ីក្លូក៏ដូចជាការផ្សងព្រេងដែរកាលបើវាសយហើយ ក៏គ្មាននរណាជិះទេបង ! ថ្ងៃនេះបងត្រូវរកប្រាក់យ៉ាងតិចឲ្យបាន៦០រៀល ដើម្បីយកទៅឲ្យថ្លៃស៊ីក្លូគេ បងឆាប់ចេញស៊ីក្លូទៅចុះ បើលោកស្រីថៅកែមករក ខ្ញុំនិងកុហកគាត់ថា ពីម្សិលមិញបងមិនស្រួលខ្លួន ទើបមិនបានយកថ្លៃស៊ីក្លូទៅជូនគាត់ សូមបងប្រញាប់ប្រញាល់ចេញស៊ីក្លូទៅចុះ"

"មើលទៅក្នុងថ្ងៃនេះ" សមនិយាយទាំងដកដង្ហើមវែង " បើបងរកប្រាក់មិនបាន៦០រៀលទេ លោកស្រីប្រហែលជាមកអូសយកស៊ីក្លូទៅវិញមិនខានទេមើលទៅ ហើយយើងទាំងពីរនាក់ប្រហែលជាអត់បាយស្លាប់ក៏មិនដឹង" ។

នាងសយដកដង្ហើមធំ សំលឹងមើលមុខប្តី ដោយសេចក្តីនឹកអាណិតអាសូរ ផ្សងព្រេងទៅចុះបង ក្រែងលោថ្ងៃនេះហេងគ្រាន់បើបន្តិច" ។

សមញញឹមទៅរកប្រពន្ធហើយឆ្លើយថា៖

"បើអញ្ចឹងបងចេញទៅហើយអូន រវល់តែអង្គុយចាំអោយរាំងភ្លៀងមុខជាថ្ងៃត្រង់ហើយ ហើយបើថ្ងៃនេះបងត្រលប់មកផ្ទះយប់បន្តិច សុំអូនកុំព្រួយបារម្ភណ៍អីនឹងបងណា៎" និយាយចប់សមចុះដើរចេញពីខ្ទមទៅ ។

ពេលនោះសមធាក់ត្រីចក្រយានគូកំសត់របស់គេចេញពីមុខកូនខ្ទម ក្រោមតំនក់ភ្លៀង ។ ផ្លូវនៅពីមុខកូនខ្ទមនេះ កាលបើមានភ្លៀងធ្លាក់ជោគជាំក៏មានភក់ល្បប់ជ្រៅៗ ។ ខណៈនោះត្រីចក្រយានរបស់សមក៏ផុងកង់ខាងមុខម្ខាងជាប់នឹងជង្ហុកមួយ ។ សមត្រូវចុះពីលើកែបទៅទាញត្រីចក្រយាននៅខាងមុខដើម្បីអោយរួចផុតពីជង្ហុកនោះ ពេលនោះក៏ស្រាប់តែមានរថយន្តគ្រីស្លែរមួយបានបើកបរមកដល់កន្លែងនោះដែរ ។ ម្ចាស់រថយន្តបានអើតក្បាលចេញមកក្រៅ សម្លឹងមើលមុខសមក្នុងទំនងដូចជាខឹង សម្បារហើយស្រែកគំរាមថាៈ

"នែ អានេះ! ម៉េចក៏ឈប់ស៊ីក្លូអ៊ីភ្លីភ្លើអញ្ចឹង តិចអញបុខងាប់ឥឡូវហ្នឹង ទៅ ! ទៅអោយលឿនទៅ យី...!មើលមុខអញផង សមប្រឹងញញឹមទាំងតូចចិត្ត កិរិយាខ្លាំង ។ សម ចង់តែនិយាយពាក្យមិនសមគួរឆ្លើយតបទៅវិញតែសមគិតទាន់ថាគេជាអ្នកមាន ប្រសិនបើមានរឿងរ៉ាវកើតឡើងខ្លួនមុខជានឹងចាញ់ប្រៀបជាដរាប ។ ដោយសារការគិតដូចច្នេះ សមក៏ទ្រាំនូវស្ងៀមមិនឆ្លើយថាអ្វី ។ សមប្រញាប់ប្រញាល់ទាញត្រីចក្រយានចេញដើម្បីចៀសផ្លូវអោយរថយន្តគេបរទៅ ។ សមលោតជិះលើកែបហើយក៏នាំត្រីចក្រយានគូកំសត់ចេញពីទីនោះតទៅមុខទៀត ។ ក៏ប៉ុន្តែខណៈនោះសមប្រែរជាស្រឡាំងកាំង ព្រោះសមចោលភ្នែកក្រឡេកមើលទៅ ឃើញស្រីម្នាក់ឈរច្រត់ចង្កេះនៅពីមុខទៀមកាហ្វេចឹកឈឿង ។ នុះគឺលោកស្រី គឹម លៀង ជាប្រពន្ធលោក គិម ឈុន ជាអ្នកមានម្នាក់ដែលមានត្រីចក្រយានប្រហែលជា ៣០ សម្រាប់ជួល ហើយជាម្ចាស់នៃ ត្រីចក្រយានដែលសមកំពុងតែធាក់នោះ ។

លោកស្រីគឹម លៀង មានរូបរាងតូចទាប ។ លោកស្រីមិនសូវជាតែងខ្លួនហ៊ឺហាប៉ុន្មានទេ តែរបស់ដែលលោកស្រីត្រូវការលេខមួយគឺលេខមួយនោះគឺប្រាក់ ។

នៅពេលនោះ សមស្ទើរតែគ្មានវិញ្ញាណនៅក្នុងខ្លួន ព្រោះខ្លាចក្រែងលោកស្រីអូសយកត្រីចក្រយានទៅវិញ ដែលជាការកាត់ផ្តាច់នូវមុខរបររបស់ខ្លួន ។ កាលបើបានជួបនឹងលោកស្រីនៅកណ្តាលផ្លូវដូច្នេះ សមក៏ត្រូវតែឈប់ ហើយចុះទៅអង្វរករដោយការគោរព ។

"យ៉ាងម៉េចទៅឯង ! ឯងមិនដែលអញ្ចឹងសោះ ពីម្សិលមិញម៉េចក៏មិនយកប្រាក់ទៅបង់ថ្លៃស៊ីក្លូអោយអញ ! " លោកស្រីនិយាយដោយទឹកមុខដែលពោរពេញទៅដោយការកោងកាច ។

"សុំទោសលោកស្រី" សមឆ្លើយតបទៅវិញ ព្រមទាំងលើកដៃសំពះ "ពីម្សិលមិញនេះ ខ្ញុំបាទរកប្រាក់បានតែ ១០ រៀលប៉ុណ្ណោះ ល្ងាចនេះចាំខ្ញុំបាទយកប្រាក់ទៅជូន"។

លោកស្រី គឹម លៀង សើចទាំងឃ្នាន់ខ្នាញ់ ហើយនិយាយថា៖

"ពួកឯងនេះវាសុទ្ធតែអញ្ចឹង យី ! អញដូចជាធុញទ្រាន់ណាស់រើយ ! រកស៊ីជាមួយពួកឯងនេះ" ។

សម លើកដៃសំពះលោកស្រីម្នាក់ទៀត ។ ពាក្យសំដីរបស់លោកស្រី គឹម លៀងនេះបានធ្វើអោយរំខានដល់ត្រចៀកសមជាទីបំផុត ។ "ឯង អញ "សុទ្ធតែជាពាក្យរំលោភ ពាក្យមាក់ងាយទាំងអស់ ។ ពួកកម្មកររដែលជួលត្រីចក្រយានរបស់លោកស្រីទាំងអស់ សុទ្ធតែទទួលបាននូវពាក្យសំដីបែបនេះ ពីលោកស្រីគ្រប់ៗគ្នា ។

"ណ្ហើយចុះ" លោកស្រីនិយាយតទៅទៀត ឯងមិនដែលធ្វើអ្វីអាក្រក់នឹងអញមកពីមុនទេ ឯងប្រាប់អញថារកប្រាក់មិនបាន អញប្រថុយជឿម្តងចុះ តេបើល្ងាចនេះ ឯងមិនយកប្រាក់ទៅបង់អោយអញនោះទេ អញនឹងអោយមនុស្សមកអូសស៊ីក្លូយកទៅវិញភ្លាម និយាយអោយទៀងណា ! កុំចាំបាច់អោយអញខាតពេលតាមមករកឯងទៀត មើលទៅអញដូចជាចង់ឈប់រកស៊ីជាមួយនឹងពួកឯងហើយរ៉ើយ" ។

សមញញឹមទាំងតូចចិត្ត ។

"សុំអរគុណលោកស្រីហើយ ! ល្ងាចនេះខ្ញុំបាទនឹងយកប្រាក់ទៅបង់ជូន"

"អើទៅចុះ ! អញទៅវិញហើយ"និយាយចប់លោកស្រី គឹម លៀង ក៏ដើរចេញពីទីនោះទៅ ។

សមព្រួយចិត្តយ៉ាងខ្លាំង លោតឡើងទៅលើកែប ហើយក៏ធាក់ត្រីចក្រយានចេញតទៅភ្លាម ។តាំងពីព្រឹកដល់ថ្ងៃត្រង់ ភ្លៀងនៅតែរលឹបស្រិចៗ មិនទាន់ដាច់គ្រាប់នូវឡើយ។ សមខំធាក់ត្រីចក្រយានស្ទះស្វែងរកជិះខ្វាត់ខ្វែងពេញព្រះរាជធានី សមទើបតែរកប្រាក់បាន ២០ រៀលប៉ុណ្ណោះតែសមត្រូវបង់ថ្លៃឈ្នួលត្រីចក្រយានល្ងាចនេះទៅដល់ ៦០ រៀល ។ ដោយគិតដូច្នោះ សមក៏មិនព្រមឈប់សំរាកសោះចេះតែខំធាក់ត្រីចក្រយានខ្ចីសៗ តទៅទៀត ហើយភ្នែកចេះតែរំពៃរកមើលក្រែងមានអ្នកហៅជិះ ។ សមត្រូវរកប្រាក់អោយបានយ៉ាងតិច ៦០ រៀល ដើម្បីអោយគ្រប់ថ្លៃឈ្នួលត្រីចក្រយានឯថ្លៃអាហារសំរាប់ខ្លួន និងប្រពន្ធនោះសមមិនាព្រួយទេព្រោះនូវឯផ្ទះនៅមានសល់អង្ករនិងប្រហុកល្មមបរិភោគបាន ២ ឬ៣ ថ្ងៃទៀតដែរ....សមបរិភោគដើម្បីរស់នៅសំរាប់ធាក់ត្រីចក្រយានតទៅទៀត មិនមែនបរិភោគដើម្បីសង្ឃឹមនូវឱជារសឆ្ងាញ់ពិសារអ្វីឡើយ....។

សមប្រឹងធាក់ត្រីចក្រយានគួកំសត់ទៅតាមវិថី អូហ៊ីយ៉េរ ។ សមត្រេកអរយ៉ាងខ្លាំងក្នុងការក្រលេកមើលទៅឃើញចិនម្នាក់បាយដៃហៅ ។ សមខំប្រឹងធាក់ត្រីចក្រយានយ៉ាងលឿនសំដៅទៅរកចិននោះ ។

ក៏ប៉ុន្តែ.....សមត្រូវចាប់ហ្វ្រាំងឈប់ភ្លាមព្រោះមានភ្នាក់ងារប៉ូលីសម្នាក់ជិះទោចក្រយានមកអែបជិត ហើយប្រាប់អោយសមឈប់ ។

នែ ម៉េចក៏ធាក់ស៊ីក្លូបញ្ច្រាសផ្លូវអញ្ចឹង ? ប៉ូលីសសួរ។

សមស្រងាកចិត្ត....សេចក្តីត្រេកអរក្នុងការបានទទួលអ្នកជិះនោះមានធ្វើអោយសមមិនបានជាសង្កេតមើលផ្លូវស្របនិងផ្លូវបញ្ច្រាស់ហើយខណៈនោះ សមក៏បានធាក់ត្រីចក្រយានលូតចូលជ្រលំចូលហួសប្រហែលជា ៧ ម៉ែត្រទៅហើយ។

សមប្រញាប់ប្រញាល់ចុះពីលើកែបត្រីចក្រយាន ហើយលើកដៃសំពះភ្នាក់ងារប៉ូលីសព្រមទាំងនិយាយសុំទោស៖

"សុំមេត្តាអត់ទោសផងចុះទានប្រោស ខ្ញុំបាទមិនបានជាមើល" ។

ភ្នាក់ងារប៉ូលីសមានទឹកមុខក្រញូវ គ្រវីក្បាល ហើយក៏ឆ្លើយមកវិញភ្លាមថា៖

"ពួកអាឯងនេះ វាចេះតែមានផ្លូវដោះសារ ហើយប៉ាយគេជាសញ្ញាប៉ុណ្ណាប៉ុណ្ណឹម៉េចក៏មិនមើល? "ភ្នាក់ងារប៉ូលីសនិយាយដោយតឹងរឹង"មើលយកសៀវភៅស៊ីក្លូមកមើល"

សម លូកយកសៀវភៅត្រីចក្រយានហុចទៅអោយភ្នាក់ងារប៉ូលីសដោយដៃទាំងពីរ ។ ប៉ូលីសកំលោះនេះមិនដែលអភ័យទោសអោយដល់អ្នកណាសោះឡើយ ។ គេពិនិត្យមើលសៀវភៅត្រីចក្រយានដោយហ្មត់ចត់ ហើយក៏ទាញកូនសៀវភៅមួយចេញមក ។ សមឃើញដូច្នោះ ក៏ភិតភ័យជាខ្លាំងព្រោះដឹងថាត្រូវបង់ប្រាក់ពិន័យ បើតិចណាស់ក៏ ២៥រៀលដែរ ។

"ព្រះតេជៈគុណ ! សមនិយាយដោយសំលេងញ័រៗ ភ្នែកសំលឹងមើលភ្នាក់ងារប៉ូលីសដោយសភាពអង្វរករសូមមេត្តាអត់ទោសអោយខ្ញុំបានម្តងទានប្រោស"។

ភ្នាក់ងារប៉ូលីសគ្រវីក្បាល

"អញមិនដែលអត់ទោសអោយអ្នកណាធ្វើខុសទេ ឯងក៏ប្រហែលជាដឹងច្បាប់ខ្លះៗដែរហើយកាលបើឯងធ្វើខុសអញក៏ត្រូវតែចាត់ការធ្វើទៅតាមនាទីរបស់អញ" ។

សមនឹកតូចចិត្តជាខ្លាំង .........របររកស៊ីត្រីចក្រយាននេះ ត្រូវងូតញើសតាងទឹកដើម្បីប្តូរយកប្រាក់ ដែលតាមធម្មតា ក៏មានចំណូលមិនគ្រប់គ្រាន់នឹងចំណាយទៅហើយៗមិនតែប៉ុណ្ណោះ នៅត្រូវប្រុងប្រយ័ត្នខ្លួនដើម្បីកុំអោយខុសនឹងច្បាប់ចរាចរណ៍ ទៀតផង ព្រោះកាលបើបានទទួលនូវបង្កាន់ដៃពីភ្នាក់ងារប៉ូលីសដូច្នេះក៏ប្រែសេចក្តីថានឹងត្រូវបង់ប្រាក់ពិន័យ ។ សមលែងអង្វរករថាអ្វីទៀត ដោយនៅធ្វើព្រងើយទាល់តែភ្នាក់ងារប៉ូលីសសរសេរបង្កាន់ដៃចប់ស្រេចបាច់ហើយហើយហែកហុចមកអោយ ។

"ទៅចុះ ! "ភ្នាក់ងារប៉ូលីសប្រាស់" ស្អែកនេះត្រូវចូលខ្លួនទៅបកលេខ ២។

ល្ងាចនេះសមត្រឡប់មកផ្ទះវិញមុនពេលម៉ោង ១៩ បន្តិច ។ ក្នុងហោប៉ៅអាវរបស់សម មានប្រាក់ត្រឹម ៣០ រៀលប៉ុណ្ណោះ ។ ខោអាវរបស់សមទទឹកជោគដោយញើស ។ សមដូចជាអស់កម្លាំងរហិតរហៃព្រោះធាក់ត្រីចក្រយានតាំងពីព្រឹកទល់ល្ងាច រកអ្នកជិះមិនបាន ហើយបានប្រាក់មិនគ្រប់ថ្លៃឈ្នួលត្រីចក្រយានផង ។មិនតែប៉ុណ្ណោះភ្នាក់ងារប៉ូលីសនៅឆ្លៀតពិន័យថែមទៀត ។ នាងសយអង្គុយនៅមាត់ទ្វារទ្វម ចាំមើលផ្លូវប្តីដោយសេចក្តីទុក្ខព្រួយ ។ លុះក្រលេកភ្នែកមើលឃើញត្រីចក្រយានចូលមក នាងក៏នឹកអរព្រួច ហើយក៏ស្ទុះក្រោកឡើងទទួលប្តី ។ សមបញ្ឈប់ត្រីចក្រយាននៅមុខផ្ទះ ហើយក៏ចុះដើរមកដោយសេក្តីអស់សង្ឃឹម ។ ទឹកមុខរបស់សមបានសំដែង នូវអាការៈអោយនាងដឹងថា មុខជា បានប្រាក់មកមិនគ្រប់ថ្លៃឈ្នួលត្រីចក្រយានឡើយ ។

"សយ អូន ! "សមនិយាយប្រាប់ប្រពន្ធ" បងបានប្រាក់មកតែ ៣០រៀលប៉ុណ្ណោះយើងធ្វើម៉េចទៅអូន ? បងដូចជាសយពេកតែម្តងហើយ ហើយត្រូវប៉ូលីសផាកថែមទៀត ស្អែកព្រឹកបងនឹងត្រូវទៅផ្ទះបក ហើយបង់ផាកយ៉ាងតិចក៏ ២៥ រៀលដែរ" ។

នាងសយដូចស្រងាកចិត្តភ្លាម ៖

"ម៉េចអញ្ចឹងបង ! ធ្វើយ៉ាងម៉េចបានជាប៉ូលីសផាក ?"

"បងធាក់ស៊ីក្លូបញ្ច្រាសផ្លូវ" ។

នាងសយមិននិយាយថអ្វីតទៅទៀត ។ នាងដើរនាំមុខប្តីនៅក្នុងខ្ទមសមសម្រុតខ្លួនអង្គុយជិតប្រពន្ធ ហើយអោបក្បាលជង្គង់ដូចពេលមុនៗ ។

"មើលទៅយើងដូចជាអស់ផ្លូវហើយអូន ! មិនដឹងពេលណាយើងបានធូរដូចគេទេ " សមនិយាយផងក្រឡេកមើលមុខម្ហូបអាហារផង ដែលប្រពន្ធដួសដោះទុកអោយនៅជិតខ្លួន ។ ម្ហូប

អាហារនោះគ្មានអ្វីក្រៅពីបាយមួយចាន និងប្រហុកមួយចានឡើយ ។ ឋានៈរបស់ប្ដីប្រពន្ធពីរនាក់នេះ ដូចជាតឹងតែងណាស់ហើយ ។ បញ្ហាដ៏សំខាន់នៅត្រង់ប្រាក់ពិន័យ ដែលនឹងត្រូវយកទៅបង់នៅពេលព្រឹកស្អែកនេះ ។

សមដង្ហើមធំ៖

"ថ្លៃផាកខាងប៉ូលីសសំខាន់ជាង ព្រោះបើយើងគ្មានប្រាក់បង់អោយគេ បងនឹងត្រូវជាប់គុកមិនខាន"

នាងសយបើកភ្នែកធំៗ៖

"ជាប់គុកឬ" នាងសួរដោយការងឿងឆ្ងល់

"ហ្នឹងហើយ !"សម ឆ្លើយ គេមុខជានឹងបញ្ជូនបងទៅបញ្ជូនបងទៅបញ្ចូលគុកជំនួសប្រាក់បង់ផាក ស្អែកនេះបងមុខជានឹងអង្វរករលោកកុម្មិសៀរ ជម្រាបលោកតាមត្រង់ថាបងមានប្រាក់ត្រឹមតែ៣០រៀលប៉ុណ្ណោះ លោកមុខជាអាណិតអាសូរមិនផាកលើសពីនេះទេមើលទៅ ឯស៊ីក្លូនេះវាគ្មានបញ្ហាទេ បងអស់សង្ឃឹមថា នឹងបានធាក់វាទៀតហើយទុកអោយលោកស្រីមកអូសយកទៅវិញចុះមើលទៅ បើទុកជាអង្វរករគាត់យ៉ាងណា ក៏គាត់មិនព្រមដែរ ព្រោះលោកស្រីដូចជាមិនដែលយោគយល់ដល់អ្នកនាសោះ" ។

ទឹកភ្នែករបស់នាងសយក៏ហូរធ្លាក់ចុះមកច្រោកៗ ។

"ដល់ពេលហើយបង ខ្ញុំនឹងសម្ងំនៅស្ងៀមមិនបានទេ ខ្ញុំត្រូវតែរកផ្លូវជួយរកស៊ីបង ខ្ញុំនឹងធ្វើការគ្រប់បែបគ្រប់យ៉ាង ដើម្បីយកប្រាក់មកចិញ្ចឹមជីវិត បង ! បងចេះតែមិនអោយខ្ញុំមិនធ្វើការ ឬលក់អីបន្តិចបន្តួចសោះតែនូវពេលនេះ បងកុំជំទាស់ខ្ញុំធ្វើអ៊ី យើងត្រូវជួយរកស៊ីគ្នា ខ្ញុំអាចទៅនៅស៊ីឈ្នួលឯណាក៏បានដែរ...ព្រោះសព្វថ្ងៃនេះនៅផ្ទះគ្មានអ្វីធ្វើសោះ "។

សយយកដៃអង្អែលខ្នងប្រពន្ធតិចៗដោយការអាណិត និង ស្រលាញ់ ។មុននឹងនិយាយការឆ្លើយប្រាប់ទៅប្រពន្ធ សមក៏បានលឺសំលេងរបស់ស្រីម្នាក់នៅខាងមុខខ្ទមស្រែកហៅឈ្មោះគេ ។សមត្រជាក់ខ្លួនស្រិប ព្រោះសមស្គាល់ច្បាស់ថា សម្លេងនេះជាសម្លេងរបស់លោកស្រី គិម លៀង ។សមក្រោកឈរឡើងហើយដើរចេញពីខ្ទមនោះមកក្រៅដោយចិត្តរំភើបជាខ្លាំង ព្រោះលោកស្រី គិម លៀង កំពុងតែច្រត់ចង្កេះជិតប្រុសម្នាក់ ។

"យ៉ាងម៉េចទៅឯង ? "លោកស្រី គិម លៀង សួរ ៖

សម ឯងបានសន្យាថា យកប្រាក់ថ្លៃឈ្នួលស៊ីឈ្នួលទៅបង់អោយអញល្ងាចនេះ អញនៅចាំមើលផ្លូវឯងទាល់តែព្រលប់ធំ អញមិនត្រូវការស្តាប់ពាក្យដោះសារអំពីឯងទាំងអស់ មក! យកប្រាក់បកអោយអញ ពួកឯងនេះវាសុទ្ធតែអញ្ចឹងវាគ្មានអាណាមួយមានចិត្តសោះមិនថាអាណាជាអាណាទេ វាសុទ្ធតែជំពាក់ថ្លៃស៊ីក្លូ ទាល់តែអញទៅទារដល់ផ្ទះ ព្រោះវាអាងថាមិនសូវស្រួលខ្លួនខ្លះ ប្រពន្ធកូនមិនសូវជាខ្លះ ។

" ខ្ញុំបាទគ្មានពាក្យអីដោះសារទេលោកស្រី ក្រៅពីអង្វរករលោកស្រីថា ខ្ញុំបាទរកប្រាក់មិនបានមែនៗលោកស្រីសុំលោកស្រីមេត្តាទៅចុះ..។

លោកស្រី គិម លៀង លើកដៃវាឡើង

"ទេ អញមេត្តាបានតែអ្នកណាដែលបង់លុយថ្លៃឈ្នួលស៊ីក្លូអោយអញ ស៊ីក្លូមួយៗអញទិញមកទាំងពាន់ទាំងម៉ឺនអោយឯងធាក់ទទេៗយ៉ាងម៉េចបាន អញត្រូវការប្រាក់ បើឯងគ្មានក៏លែងធាក់ទៅ ទៅរកជួលស៊ីក្លូគេដំទៃទៀតចុះ ពួកឯងនេះអាក្រក់ណាស់រកប្រាក់បានមកយកទៅលេងបៀរ ជក់កញ្ឆារ ផឹកស្រា គ្មានគិតគូរដល់ម្ចាស់ស៊ីក្លូសោះ "និយាយចប់ហើយ លោកស្រីក៏បែរមុខមករកបុរសម្នាក់ដែលឈរនៅជិតគាត់ "ទៅអាគុច ! យកស៊ីក្លូទៅផ្ទះវិញ" ។

អ្នកបម្រើបានប្រតិបត្តិតាមពាក្យបញ្ជារបស់លោកស្រី គិម លៀង ភ្លាមហើយ លោកស្រីក៏ដើរតាមក្រោយទៅ ។ សម ឈរសម្លឹងមើលតាមក្រោយដោយមានទឹកមុខហូរធ្លាក់ចុះមកច្រោកៗ ។ សមខាំធ្មេញណែននៅស្ងៀមមួយសន្ទុះទើបនិយាយចេញមកតិចៗថា ៖

"ឱព្រះអើយ ! ព្រះអង្គគ្មានអាណិតអាសូរអ្នកក្រផងសោះ....."។

នាងសយដើរចូលមកជិតប្តី ហើយនិយាយថា ៖

"បង ! បើទុកជាយ៉ាងម៉េចក៏យើងមិនដល់ទៅដាច់ពោះស្លាប់ដែរ បើគេអូសយកស៊ីក្លូយកទៅវិញ ក៏គង់មានការងារដ៏ទៃទៀតធ្វើដែរ "

"អូន ! សមនិយាយទាំងក្រៀមក្រំ" បងបានប្រកាន់ភ្ជាប់នៅក្នុងសម្មាអាជីវ:បងសុខចិត្តក្រពិបាកមិនព្រមប្រព្រឹត្តិខុសចរិតពីផ្លូវច្បាប់ តែសេចក្តីល្អដែលបងខំថែរក្សាទុកមកយ៉ូហើយនោះ វា

មិនបានជួយបងអោយបានសេក្តីសុខសប្បាយប្តូងណាសោះអូន ! បងចង់តែធ្វើចោរប្លន់ទេអូន ក្រែងវាបានស្រួលជាងនោះបន្តិច” ។

“បង ! នាងសយឃាត់” កុំគិតអញ្ចឹងបង បងត្រូវតែប្រកាន់អោយខ្ជាប់ខ្ជួននូវសេចក្តីល្អតរៀង ទៅគង់មានថ្ងៃមួយ ព្រះជាម្ចាស់នឹងជួយយើងមិនខាន ” ។

សមសើចទាំងចិត្តមួហ្មងចំពោះជីវិត ដែលងងឹតងងល់គ្មានអ្នកណាជួយឧបត្ថម្ភគ្មានញាតិ មិត្តណាល្មមពឹងពាក់បាន ហើយសំខាន់បំផុត គឺគ្មានប្រាក់កាក់ចាយវាយ......សមត្រូវតែទទួលនូវ សេចក្តីទុកលំបាកនេះអស់មួយជីវិតទៅ ឬ?

“បង ! នាងសយនិយាយ “ផ្លាស់អាវងូតទឹក ហើយញ៉ាំបាយសិនទៅបង យើងនឹងនុំគ្នាមើល ថា យើងគួរធ្វើយ៉ាងណាអោយបានប្រាក់យកមកចិញ្ចឹមជីវិតតទៅទៀត ”។

ក្នុងពេលទុក្ខលំបាកដូច្នេះ មានតែប្រពន្ធម្នាក់ប៉ុណ្ណោះដែលអាចលួងលោមធ្វើអោយសម មានកំលាំងចិត្តគ្រាន់បើ ។

សមបែរទៅនិយាយនឹងប្រពន្ធថា៖

“សយ អូន !បងអាណិតអូនណាស់ អូនមិនគួរមកពិបាកជាមួយនឹងបងសោះតាំងពីពេល បានគ្នាជាប្តីប្រពន្ធមក យើងចេះតែបានជួបប្រទះនឹងសេចក្តីទុក្ខវាទនាជានិច្ចជួនកាលរហូតអត់ បាយក៏បានដែរ ”

“បង !បងគួរតែយល់ចិត្តអូនអោយជ្រៅជាងនេះទៀត ” នាងសយឆ្លើយឡើងទាំងគ្រៀមក្រំ” សេចក្តីសុខរបស់អូនមិនមែននៅត្រង់ប្រាក់នោះទេបង តែវានៅត្រង់ការដែលបងស្រឡាញ់ និង អាណិតអាសូរអូនដោយទ្បែកឯណោះទេតើ ខ្ញុំធ្លាប់បានប្រាប់បងច្រើនលើកថា បើទុក្ខជាញ៉ាំដុំ អំបិល ខ្ញុំក៏នូវតែទ្រាំបាន សុំអោយតែបងស្រលាញ់ និង អាណិតអាសូរខ្ញុំតែប៉ុណ្ណោះបានហើយ”។

សមទះស្មាប្រពន្ធហើយញញឹមទាំងមុខក្រៀមក្រំ

“ពិតណាស់ហើយអូន ! អូនជាដួងចិត្តរបស់បង ក្នុងលោកគ្មានអ្វីដែលបងស្រលាញ់ជាង សយទេ បើបងមានឋានៈគ្រាន់បើជាងនេះឡើងពាលណាពេលនោះបងនឹងខំប្រមូលនូវសេចក្តីសុខ យកមកប្រគល់អោយអូន ” ។

បង នាងសយ ឆ្លើយឡើង ជីវិត និងរាងកាយរបស់ខ្ញុំនឹងក្លាយទៅជារបស់បងអស់ហើយ ខ្ញុំស៊ូទ្រាំទៅរួមសុខតទុក្ខជាមួយបង ជាប្រពន្ធដ៏ល្អរបស់បង សុំបងកុំគិតច្រើនពេក សុំបងគិតថាជីវិតអ្នកក្រវាតែងតែអញ្ចឹង យើងត្រូវខំាធ្មេញអត់ធន់តស៊ូរហូតដល់ថ្ងៃស្លាប់ ថ្ងៃនេះយើងរចខ្លួនផុតពីសេចក្តីស្លាប់ ព្រោះយើងបានញាំបាយគ្រន់តែប៉ុនេះក៏រាប់ថាគ្រាន់បើណាស់ហើយ ហើយយើងកុំអាលគិតទៅដល់ថ្ងៃស្អែកនោះអី អ្នកក្រគ្មានអនាគតទេ ព្រោះយើងរស់នៅសំរាប់តែមួយថ្ងៃប៉ុណ្ណោះ ។

សមងក់ក្បាលយឺតៗពេញចិត្តនឹងពាក្យដាស់តឿនរបស់ប្រពន្ធកំសត់កំរជាខ្លាំង"សយ អូន " អូននិយាយនេះត្រូវមែនជីវិតគឺជាការតស៊ូ តែស្វះស្វែងរកការងារធ្វើថ្មីទៀត ។

ꕥꕥꕥꕥꕥꕥꕥꕥꕥ

## **ភាគទី៣** ទំនេរគ្មានការងារធ្វើ

ត្រីចក្រយានគូកំសត់ត្រូវនាយទុនជាម្ចាស់អូសយកទៅវិញហើយ ព្រោះសមខានបង់ថ្លៃ ឈ្នួលត្រឹមតតែពីថ្ងៃប៉ុណ្ណោះ ។ ឥឡូវសមបានក្លាយខ្លួនទៅជាកម្មករគ្មានការងារធ្វើ ។ ប្រាក់ចុងក្រោយថបំផុត មានចំនួនត្រឹមតែ៣០រៀលប៉ុណ្ណោះហើយប្រាក់នេះនឹងត្រូវយកទៅបង់ថ្លៃផាកពិន័យក្នុងថ្ងៃស្អែកនេះទៀតផង ព្រោះខ្លួនធាក់ត្រីចក្រយានបញ្ច្រាសផ្លូវ ។

មួយអាទិត្យបានកន្លងផុតទៅហើយ ។ របស់របរនៅក្នុងខ្ទមដែលល្មមនឹងលក់បញ្ចាំបាន សមក៏ត្រូវតែចិត្តលះបង់វា ដើម្បីញុំជីវិតឲ្យបានរួចផុតពីសេចក្តីស្លាប់ទៅមួយថ្ងៃៗ។ សមបានខំ ខ្វះខ្វែងរត់រកការងារធ្វើ សមខំដើរចូលទៅក្នុងទីកន្លែងផ្សេងៗមានហាងលក់ទំនិញ កំពង់កប៉ាល់

ឃ្លាំងដាក់អីវ៉ាន់ជាដើម តែគ្រប់ទីន្លែងបានបដិសេធមិនព្រមទទូល ហើយមានកន្លែងខ្លះត្រូវគេគំហកឲ្យថា៖

ឯងមានប្រាក់កក់ទេបើឯងមាន ៥០០រៀល មកកក់ ស្អែកមកធ្វើការចុះ ។

សមត្រូវតែត្រឡប់មកខ្ទមវិញដោយសេចក្តីអស់សង្ឃឹម ។ ក្នុងពេលល្ងាចនោះខណៈ ដែលសមត្រឡប់មកខល់ខ្ទមវិញ សមក៏បានជួបមុខនឹងបុរសចំណាស់ម្នាក់ដែលជាម្ចាស់ខ្ទមនោះ ។ តាសានមានផ្ទះឈ្នួលជាច្រើន តែជាមនុស្សដែលមានចិត្តប្រាសចាកសេចក្តីមេត្តាករុណា ចំពោះអ្នកទីទាល់ក្រីក្រ ។ អ្នកជិតខាងតែងដឹងថា៖ តានាយទុននេះមិនដែលព្រមបន្ធូរបន្ថយ ឬ លោះលាឲ្យដល់អ្នកណាដែលជំពាក់ថ្លៃឈ្នួលផ្ទះកាត់សូម្បីតែមួយថ្ងៃឡើយ ។ តាមពិតខ្ទមដែល សមជួលនៅ

សព្វថ្ងៃនេ ជាខ្ទមដែល តាសានសង់បណ្ដោះអាសន្ននៅលើដីឡូត៍ដែលគាត់ទើប នឹងទិញថ្មី ហើយជាខ្ទមសំរាប់ឲ្យអ្នកថែរក្សាដីគាត់នៅ តែលុះសមទៅជួលនៅ តាសានក៏បានចំណេញពីរផ្លូវគឺ ទីផ្លូវនៃមួយបានចំណេញឈ្នួលខ្ទម ហើយទីពីរមិនបាច់ខាត់ ប្រាក់ជួលមនុស្សឲ្យនៅចាំរក្សាដីនោះ ។ល

"ម៉េចអាសម !" តាសាននិយាយឡើងក្នុងបែបភាពជាអ្នកអាងអំណាចទឹកប្រាក់ "ឯង ធ្លាប់បង់ថ្លៃឈ្នួលផ្ទះឲ្យអញទៀតទាត់ណាស់ តែខែនេះម៉េចក៏ហួសពេលវេលាដល់ទៅ ៧-៨ ថ្ងៃ អញ្ចឹង-តើឯងគិតយ៉ាងម៉េច ? "

សមឆ្លើយនឹងតាសាននាយទុនដោយសេចក្ដីគោរពះ

"សុំលោកតាមេត្តាខ្ញុំបាទម្ដងទៅចុះ!"

មេត្តាអី? មេត្តាបន្ធូរបន្ថយពន្យារពេលបង់ថ្លៃឈ្នួលផ្ទះនោះឬ?

"បាទលោកតា" "ទេ! មិនបានទេ! មិនបានទេ!" តាសានឆ្លើយឡើយ" ផ្ទះដែលអញសង់នេះអស់ប្រាក់កាសច្រើនណាស់ហើយនៅបង់ពន្ធទៀតផង ឯងត្រូវដឹងថា បើឯងគ្មានថ្លៃឈ្នួលឲ្យ អញទេ ឯងត្រូវតែចុះចេញពីផ្ទះអញទៅ ។

សមងើបមុខឡើងមើលមុខតាសាន ហើយញញឹមទាំងក្រៀមក្រំ ។

"ខ្ញុំបាទមិនដែលអាក្រក់នឹងលោកតាទេ សុំលោកតាមេត្តាពន្យារពេលឲ្យខ្ញុំបាទបាន ១៥ថ្ងៃទៀតទានប្រោស" ។

"ទេ! មិនបានទេអាសម" តាសាននិយាយខ្លាំងៗ" អញពន្យារពេលឲ្យឯងបានត្រឹមតែមួយ ថ្ងៃទៀតប៉ុណ្ណោះ" ។

"លោកតាម..." សមនិយាយទាំងអួលដើមក តាសានមិនត្រូវការស្ដាប់នូវពាក្យសំដីអង្វរកររបស់សមឡើយ ។ គាត់ប្រញាប់ដើរចេញពីកន្លែងនោះទៅវិញភ្លាមសមសម្លឹងតាមមើលនាយទុនចាស់ទាល់តែផុតកន្ទុយភ្នែក ហើយសមក៏ងាកមកក្រោយរកប្រពន្ធដែលឈរនៅពីក្រោយខ្នង ។

"បង ! " នាងសយនិយាយនឹងប្ដី" បើអញ្ចឹងយើងគិតធ្វើយ៉ាងម៉េចទៅ !

សមខាំធ្មេញណែននឹកតូចចិត្តនឹងសេចក្ដីអភ័ព្វនៃជីវិតរបស់ខ្លួន ។ សមគិតថាផ្លូវជីវិត របស់គេងងឹតជិតឈឹងមែនទែនហើយ ។

"សយអូន ! បងដូចជាទល់ប្រាជ្ញហើយ" សមនិយាយនឹងប្រពន្ធ" ប្រាក់ថ្លៃឈ្នួលផ្ទះដល់ ទៅ ១០០រៀលយើងនឹងទៅយកពីណាមកឲ្យគេ... ។

នាងសយធ្វើភ្លឹះៗដូចជាចង់យំហើយនិយាយថា៖

"យប់គ្រង់ណាដេកត្រង់ហ្នឹង" សមឆ្លើយឡើងទាំងមួរម៉ៅ" តែបងគិតថាយើងត្រូវតែបម្រះ ននៀលតស៊ូនឹងជីវិត ឲ្យទាល់តែថ្ងៃស្លាប់-អ្នកយើងគ្មានសង្ឃឹមថានឹងបានសេចក្តីសុខសប្បាយ ទេ អូន...។

"បើទុកជាពិបាកយ៉ាងណា" នាងសយនិយាយឡើង" ខ្ញុំចេះតែទ្រាំជាមួយនឹងបងតទៅ ទៀត ដែរ" ។

មុនពេលដែលនិយាយថាអ្វីថាអ្វីទៅទៀត សមក៏បានឮសម្លេងបុរសម្នាក់ស្រែកហៅឈ្មោះ " អ៊ើយអាសម !" ។

សម ងាកមុខមើលទៅឃើញបុរសម្នាក់មុខមាត់ស្អាតបាត ទុកពុកមាត់យ៉ាងតូចឆ្មារត្រឹម ធេងនៅលើបបូរមាត់ខាងលើ ។ បុរសនេះស្លៀកពាក់ហ៊ីហា សិតសក់វែកចំហៀងឈរនៅលើមុខ ខ្ទម ។ បុរសកម្លោះនេះឈ្មោះសៅ ជាអ្នករកស៊ីឆក់លួច យ៉ាងប៉ិនប្រសប់ម្នាក់ ។សៅសំណាក់ អាស្រ័យនៅក្នុងផ្ទះមួយជិតខ្ទមរបស់សម ជាមួយនឹងមិត្តភក្តិកម្លោះៗច្រើននាក់ ។ សៅមានប្រាក់ កាសចាយវាយយ៉ាងបរិបូណ៌ ស្លៀកពាក់សុទ្ធតែខោអាវថ្លៃៗ ។ ការដែលសៅមកផ្ទះត្រង់នេះ ក៏ ព្រោះជាកន្លែងស្ងាត់ហើយមនុស្សភាគច្រើនដែលនៅត្រង់នេះច្រើនជាកម្មកររកព្រឹកស៊ីល្ងាច គ្មាន អ្នកណានឹកនារ វីរវល់ចាប់អារម្មណ៍នឹងមុខការរបស់សៅឡើយ។ សមក្រោកឡើងហើយដើរ ចេញ ទៅរកសៅ ។ បុរសកម្លោះមានពុកមាត់ញញឹមហើយទះស្មាសមតិចៗ ។

"ម៉េចអាសម អាឯងទៅធ្វើយ៉ាងម៉េចបានជាតាសានគាត់ឡូឡាអញ្ជឹងឯងជំពាក់ថ្លៃឈ្នួល ផ្ទះ គាត់ឬ ?"

សមងក់ក្បាល ហើយមុនពេលឆ្លើយថាដូចម្តេចនោះ សៅក៏ដឹកដៃសមនាំទៅអង្គុយលេង ឯ ផ្ទះគេ ។ សៅនាំសមនិយាយលេងពីនេះពីនោះ ដែលក្នុងខណៈនោះមិត្តភក្តិរបស់សៅទាំង ប៉ុន្មាន បាននាំគ្នាចេញទៅរកស៊ីតាមផ្សារ ។

"អាសម!" សៅនិយាយឡើង អញអាណិតអាឯងណាស់ ឥឡូវនេះឯងឈប់ធាក់ស៊ីក្លូ ហើយ ឬ?"

អើសៅ "សមឆ្លើយឡើង" គ្នាជំពាក់ថ្លៃឈ្នួលស៊ីក្លូគេ ឥឡូវម្ចាស់គេមកអូសស៊ីក្លូយកទៅ វិញហើយ" ចុះសព្វថ្ងៃឯងធ្វើការអី ?" សមសើចទាំងក្រៀមក្រំ ។

"គ្នាកំពុងតែដើររកការងារធ្វើស្អីក៏គ្នាធ្វើដែរឲ្យតែការងារសុចរិត" ។

អាសមអើយ ! "សៅនិយាយទាំងញញឹម" ឯងល្ងង់ភ្លីភ្លើណាស់ ល្ងង់ទាល់តែអញមិនអាចជួយអីឯងបាន អញធ្លាប់បបួលឯងច្រើនដងហើយថា ឲ្យរកស៊ីដូចអញទៅ ព្រោះវាងាយហើយស្រួលផងបើវាគម្រក់ណាស់ក៏គង់រកបានក្នុងមួយថ្ងៃ ១០០រៀលដែរ បើវាហេងបានរាប់ពាន់តែ ម្តង-ឯងគិតមើល ! យើងជាអ្នកក្ររស់តែគិតដល់កិត្តិយស និងសេចក្តីល្អ វាមុខជាដាច់ពោះងាប់ ហើយឯងគិតមើលអាសម ! ប្រាក់គឺជាព្រះ...គឺជាកែវមណីជោតិ...គេតែងនិយាយថា អ្នកមានល្អ អ្នកក្រអាក្រក់ បើឯងមានប្រាក់អ្នកណាក៏គេលើកតំកើងគោរពកោតក្រែងឯងថាជាមនុស្សល្អ តែ ថាឋានៈរបស់ឯងសព្វថ្ងៃនេះ បើទុកជាឯងមានសិលធម៌យ៉ាងណាក្តី ឯងក៏គង់តែគេចមិនផុតពី ការមើលងាយមើលថោករបស់អ្នកប្រាក់បានដែរ ដែលគេតែងលើកតំកើនខ្លួនគេថា ជាមនុស្ស ប្រសើរហើយគេយលថាអ្នកក្រដូចជារូបឯងនេះ ជាខ្ញុំកញ្ជះបាតជើងរបស់គេ-អាសមអើយ ! ពួក នាយទុននិងពួកព្រះតេជៈគុណភាគច្រើន ច្រើនសាងសេចក្តីសុខ និងអំណាចរបស់ខ្លួននៅខ្នង ប្រជារាស្រ្តអ្នកក្រ វាប្លន់រាស្រ្តខ្មែរ និងជាតិខ្មែរ បើតាមចិត្តអញៗគិតឃើញថា យើងគួនាំគ្នាប្លន់អា អស់នោះមកវិញអញពេញចិត្តនឹងនិស្ស័យស្ងប់ស្ងៀមរបស់ឯងណាស់ ឥឡូវនេះឯងកំពុងគ្មាន ការធ្វើអញចង់បបួលឯងឲ្យរកស៊ីជាមួយអញណាអាសម... ។

សមញញឹមទៅរកសៅទាំងទុកព្រួយ ។

អរគុណនឹងឯងណាស់ហើយសៅ ដែលឯងចង់ជួយជ្រោមជ្រែងគ្នានោះតែគ្នាធ្វើដូចឯង មិនបានទេសៅ... ។

ព្រោះឯងយល់ឆ្គួតក្នុងរឿងសីលធម៌នោះមែនទេ ? គ្មានបានការអីទេអាសមគ្មានអ្នកណា គេមើលឃើញសីលធម៌របស់អ្នកក្រទេ គ្មានមុខរបរ បានស៊ីម្ហូបចំណីឆ្ងាញ់ៗមានខោអាវល្អៗ ស្លៀកពាក់បានមើលកុនល្ខោនគ្រប់រោង... ។

"ការពេញចិត្តរបស់ឯង និងអញ វាសផ្សេងគ្នាណាសៅ" សមឆ្លើឡើងឯងមានសេចក្តីសុខក្នុងជីវិតដោយការឆក់លួច តែរូបគ្នាវិញគ្នាមានសេចក្តីសុខនៅត្រង់មានការងារសុចរិតធ្វើ បើទុក ជា

ការងារនោះតម្រូវឲ្យគ្នាបែកញើសហូរដញើសយ៉ាងណាក៏ដោយនៅតែសម្បាយចិត្តនឹងធ្វើវា គ្នាប្រាប់ឯងឲ្យត្រង់ទៅចុះថាក្នុងមួយជីវិតនេះគ្នាមិនដែលធ្វើការងារទុច្ចរិតខុសពីគន្លងច្បាប់ទេ ។

"បើអញ្ចឹងក៏ស្រេចតែឯងទៅចុះអាសម" សៅនិយាយ "បើឯងសុខចិត្តដាច់ពោះងាប់ក៏តាមចិត្តឯងទៅចុះ តែសម្រាស់ខ្លួនអញ អញអាចធ្វើបានគ្រប់បែបគ្រប់យ៉ាងឲ្យតែបានប្រាក់... ។

"តែថាការងាររបស់ ឯងត្រូវទទួលរងគ្រោះថ្នាក់ច្រើនណាស់" ។

"អញ្ចឹងមែនហើយអាសម" សៅឆ្លើយឡើង" ឲ្យតែភ្លាត់ជាប់មកហើយនៅក្នុងគុកវាស្រួលម្យ៉ាងដែរ ដល់ពេលបាយស៊ីស្រាប់ ហើយមានគេយាមឲ្យទៀតផង... និយាយហើយសៅលូកហោប៉ៅដកក្រដាសប្រាក់ ១០០រៀលមួយដុំបង្អួតសម" មើលនេះនែអាសម ! អញចេញពីផ្ទះតែមួយសន្ទុះក៏បានប្រាក់មកជិត ២០០រៀលក្នុងពេលដែលថៅកែម្នាក់ចូលទិញសំបុត្រកុនហើយ ភ្លេចខ្លួនឯងគិតមើល ! មួយថ្ងៃ ២០០រៀលធ្វើការអីបាន" ។

សុំទោសចចុះសៅ "សមនិយាយឡើង" គ្នាធ្វើដូចឯងមិនបានទេ គ្នាជាមនុស្សល្ងង់ភ្លីភ្លើ ដូចឯងថាមែន គ្នាសុខចិត្តដាច់ពោះងាប់គ្នាមិនព្រមប្រព្រឹត្តទុច្ចរិតទេ ណ្ហើយ !គ្នាលាហើយសៅ... ។

សៅងក់ក្បាល ។

"ទៅដេកគិតមើលមួយយប់មើលអាសម្លាញ់ ! បើឯងព្រមរកស៊ីជាមួយអញ អញនឹងទៅរកទិញខោអាវល្អៗ ឲ្យឯងពីរបីប្រដាប់ ហើយនងឲ្យប្រាក់ឯងទុកចាយខ្លះៗពីតឡូវកុំឲ្យខ្មាស់គេសព្វបើអាប្រាក់ ១០០រៀល អញឲ្យគាត់មួយឆ្នាំមុនក៏បានថ្លៃផ្ទះឡើងដល់ទៅ ១០០០រៀល ក៏អញរកឲ្យគាត់បានដែរ..."សមលែងនិយាយស្តីថាអ្វីទៀតហើយក្រោកដើរចេញពីផ្ទះសៅទៅ ដោយឥតមានជ្រះថ្លា និងមុខរបររបស់សៅនោះសោះឡើយ... ។

សម និងនាងសយបានជួបមុខនឹងតាសាន នាយទុនមុខក្រាស់ម្តងទៀតក្នុងពេលល្ងាចស្អែកឡើង ។ សមកំពុងតែមានអារម្មណ៍មិនសូវស្រួល ក្រោយពេលដែលត្រឡប់មកពីរកការងារធ្វើវិញ ហើយរកមិនបានដូចថ្ងៃមុនៗ ទៀតដែរតែសមខំប្រឹងញញឹមទៅរកម្ចាស់ផ្ទះ ហើយ និយាយអង្វរករសុំពន្យារពេល ព្រមទាំងចង្អុលបង្ហាញហេតុផលនៃការខ្វះខាតឲ្យម្ចាស់ផ្ទះបាន ដឹងតែផលសមបានទទួលពីតាមសាននោះក៏សំដីគម្រោះគម្រើយកំបុតកំបុយ... ។

"សេចក្តីខ្វះខាតរបស់ឯង វាមិនមែនជារបស់អញផងឯណា តាសាននិយាយយ៉ាងម៉ឺងម៉ាត់អញជួយឯងមិនបានទេ អញត្រូវការតែប្រាក់ថ្លៃឈ្នួលផ្ទះអញប៉ុណ្ណោះមិនបាច់ឯងអធិប្បាយឲ្យ វែង

ឆ្ងាយទេ បើឯងគ្មានប្រាក់ឯងត្រូវតែចុះចេញពីផ្ទះអញទៅ បើតាមពិតអញត្រូវទារយកថ្លៃ ដែលឯងនៅលើស ៧-៨ ថ្ងៃនេះផង "តែអញមិនយកទេ គ្រាន់តែឲ្យឯងចុះចេញពីផ្ទះអញល្ងាច នេះប៉ុណ្ណោះ" ។

សមស្ទើរអត់ទ្រាំមិនបាន ខំសម្លឹងមើលមុខតាសានដោយកំហឹងតែក៏ខំអង្វរករម្តងទៀត ។

"លោកតាគួរតែអាណិតអាសូរអ្នកក្រដូចរូបខ្ញុំខ្លះកផងទានប្រោស តាំងពីដើមមកខ្ញុំបាន មិនដែលជំពាក់ថ្លៃឈ្នួលផ្ទះលោកតាម្តងណាសោះ ទើបតែពេលនេះខ្ញុំបាទកុនមែនទែនតែម្តង លោកតា..." ។

តាសានសើចទាំងខឹងសម្បារ ។

បើអញរវល់តែអាណិតអាសូរពួកឯង ប្រហែលជាអញរកបាយស៊ីមិនបានទេមលើទៅ ពួកឯងនេះបើអញមិនតឹងទារទេ មុខជាគ្មានអាណាបង់ថ្លៃឈ្នួលផ្ទះឲ្យអញទេអញលែងនិយាយនឹងឯងទៀតហើយ ឲ្យឬមិនឲ្យថាមក... ។

"សុំពន្យារពេលឲ្យខ្ញុំបាទបានកន្លះខែទៀតទៅចុះទានប្រោស"

តានាយទុនគ្រវីក្បាលហើយនិយាយខ្លាំងៗថា៖

អញប្រាប់ឯងហើយថាមិនបានទេ-ឥឡូវឯងមិនព្រមឲ្យអញមែនទេ?

"លោកតា ! " សមនិយាយដោយសម្លេងញ័រៗ "ខ្ញុំបាទមិនទាន់មាន ទានប្រោស ។

"បើអញ្ចឹងឯងត្រូវចុះចេញពីផ្ទះរបស់អញ ! ចុះចេញពេលល្ងាចនឹង" ។

ហួសនិស័យនឹងអត់ទ្រាំបាន សមលែងនិយាយនឹងតាសាន។ តាសានក៏ដើរត្រឡប់ទៅផ្ទះគាត់វិញ ។

សមគិតថា ពិតណាស់អ្នកក្រដូចសម គ្មានផ្លូវតតាំងនឹងអ្នកមានបានឡើយ ព្រោះប្រាក់ មានអំណាចជាងអ្វីទាំងអស់ សូម្បីតែសេចក្តីយុត្តិធម៌ កាលបើអំណាចប្រាក់ចូលទៅជ្រៀតជ្រែក បានហើយ ក៏អាប្រែប្រួលទៅជាអយុត្តិធម៌វិញបានដែរ... ។

ខណៈនោះសមដកដង្ហើមធំសម្លឹងមើលមុខប្រពន្ធ ហើយប្រាប់ប្រពន្ធឲ្យរៀបចំអីវ៉ាន់ ដើម្បីចុះចេញពីកូនខ្ទមតាសាន ។

ល្ងាចនោះ ដោយសារការទាល់ច្រក សមបាននាំប្រពន្ធទៅសំណាក់អាស្រ័យនៅនឹងសំយាបព្រះវិហារលោកសង្ឃយួន នៅវត្តទួលប្រស្រី ។ សមគ្មានទ្រព្យសម្បត្តិអ្វីក្រៅពីមុង ខ្នើយ កន្ទេល និងខោអាវពីបន្លាស់ម្នាក់នោះឡើយ ហើយជាពិសេស សម និងនាងសយមានប្រាក់នៅជាប់នឹងខ្លួនចំនួន ១០រៀលប៉ុណ្ណោះ ដែលជាប្រាក់ចុងក្រោយបំផុតសំរាប់បន្តជីវិតឲ្យរស់នៅក្នុងលោកតទៅទៀត ។ ឥឡូវនេះសម និងនាងសយបានក្លាយខ្លួនទៅជាមនុស្សខ្វាត់ខ្វាត់គ្មានផ្ទះនៅ ដែលមិនខុសគ្នាពីស្មូមយាចកប៉ុន្មានឡើយ ។

នៅក្នុងវត្តទួលប្រស្រីមានសភាពស្ងប់ស្ងាត់ជ្រងំ គួរឲ្យអន្លង់អន្លោចជាខ្លាំង...សម និងនាងសយអង្គុយឱបក្បាលជង្គង់មើលមុខគ្នាដោយការព្រួយចិត្ត...នៅត្រង់សំយាបព្រះវិហារជ្រុងខាងលិចមានឆ្កែពីរបីដេកសន្ធឹកខ្លួនដោយការខ្ជិលច្រអូស...ជួនកាលវាគ្រហឹមរ ជួនកាលវាព្រូស ហើយប្រខាំគ្នារម៉ោករម៉ាំង ។

៥ថ្ងៃបានកន្លងផុតទៅ !... ៥ថ្ងៃដែលបានកន្លងផុតទៅ សេចក្តីព្រួយសំរាប់រូបនាយសម និងនាងសយ... ។

ល្ងាចនោះ សមដេកលក់ស៊ុបហើយស្រមុកខុរៗ នៅលើកន្ទេលរហែកមួយ ។នៅក្បែរខ្លួនសមមានកន្ត្រកផ្តៅមួយសម្រាប់ដាក់អីវ៉ាន់បន្តិចបន្តួច ។

ម៉ោង៧ ហើយ ។ នាងសយកំពុងតែដើរកាត់ក្លោងទ្វារវត្តចូលតម្រង់មកព្រះវិហារយ៉ាងរួសរាន់ ។ដៃរបស់នាងកាន់កញ្ចប់បាយ និងម្ហូបដែលនាងបានទៅទិញមកពីផ្សារ ។ ទឹកមុខរបស់នាងស្រស់បស់គ្រាន់បើជាងសព្វថ្ងៃ ។

គ្រាន់តែឈានជើងចូលមកក្នុងសំយាបព្រះវិហារភ្លាម នាងសយក៏ស្រែកហៅប្តី ។ សមភ្ញាក់ហើយស្ទុះក្រោកឡើងសម្លឹងមើលមុខប្រពន្ធដោយអាការៈងឿងឆ្ងល់ ។

"យី ! ល្ងាចណាស់ហើយទេតើ" សមនិយាយឡើងទាំងមិនទាន់អស់ងងុយ ។

"អូនឯងទៅផ្សារពីកាលណាក៏បងមិនដឹង បងដេកគិតៗទៅក៏ស្រាប់តែលក់មិនដឹងខ្លួនតែម្តង" ។

នាងសយដាក់កញ្ចប់បាយ និងម្ហូបលើឥដ្ឋ ហើយក៏អង្គុយជិតប្តីព្រមទាំងញញឹមដាក់ប្តី ។

ពេលនោះ នាងសយនិយាយប្រាប់ប្តីអំពីការដែលនាងទៅផ្សារ បានជួបនឹងយាយចាស់ម្នាក់ដើររកស្រីបម្រើឲ្យចៅកែហុក សម្រាប់បោសសំអាចនឹងមើលថែទាំផ្ទះសម្បែរ ។ នាងបានបញ្ជាក់ថា នាងបានព្រមព្រៀងថាទៅជាមួយនឹងគេហើយ ព្រោះគេឲ្យប្រាក់ខែដល់ទៅ២០០រៀលក្នុងមួយខែ ហើយនាងប្រាប់ថា ស្អែកនេះនាងសន្យាជួបគ្នានឹងយាយចាស់នោះ ដើម្បីឲ្យគាត់ជូននាងទៅជួបនឹងចៅកែហុក ។

សមស្តាប់ប្រពន្ធនិយាយហើយដកដង្ហើមធំព្រមទានិយាយថា៖

សយអូន បងមិនចង់ឲ្យអូនបែកពីបង់សោះតែធ្វើម៉េច ពេលនេះទឹកវាចូលច្រមុះហើយ យើងត្រូវតែបែកគ្នាជាបណ្តោះអាសន្នសិន បើអូនបានទៅនៅស៊ីឈ្នួលគេមែនបងក៏គិតធ្វើដំណើរ ទៅស្រុកបាន ៩-១០ ថ្ងៃដែរ ព្រោះឥឡូវវាដូចជាស្ងប់ពួកឥស្សរៈគ្រាន់បើហើយ-បងនឹងទៅលក់ របស់របរឯស្រុក ក្រែងបានប្រាក់កាសខ្លះយកមករកស៊ីនឹងគេ... ។

នាងសយសម្លឹងមើលមុខប្តី ហើយសួរដោយការងឿងឆ្ងល់ ៖

"បង ១ ចុះបងបានប្រាក់ថ្លៃរទេះភ្លើងពីណា ?"

"មិនអីទេអូន ! " សមឆ្លើយឡើង " យើងនៅមាមុខមួយលក់ទៀតដែរហើយបើខ្វះខាត ប៉ុន្មានបងដើរកខ្ចីពួកម៉ាកបន្ថែមទៀត... អើ ស្អែកនេះ បងក៏ត្រូវជូនអូនទៅដែរ បើចៅកែនោះគេ មានចិត្តសប្បុរស បងក៏សុំជ្រកអាស្រ័យនៅជាមួយនឹងគេដែរគេប្រើបងឲ្យធ្វើអីក៏បានឲ្យតែបាន នៅជិតអូន... " ។

សម និងសយនិយាយឡើង " សុំបងកុំព្រួយបារម្ភអី បើទុកជាបងមិនបាននៅធ្វើការជា មួយនឹងខ្ញុំ ហើយបងនៅឯណាក៏ដោយ ខ្ញុំនឹងសុំចៅកែទៅជួបបងបើយ៉ាងហោចណាស់ក៏មួយ អាទិត្យម្តងដែរ..." ។

"ឱ ! កាលណាហ្ន ! យើងនឹងបានសុខសប្បាយដូចគេ.. " សមឧទានឡើងតិចៗ ។

ខណៈនោះ នាងសយក៏ចាត់ចែងស្រាយកញ្ចប់បាយនឹងម្ហូបចេញ ។ អ្នកទាំងពីរនាំគ្នាបរិភោគអាហារដោយអាការៈស្ងប់ស្ងៀម ពោរពេញទៅដោយសេចក្តីទុក្ខព្រួយ ។

យាយចាស់ពីម្សិលមិញ បានមកនាំនាងសយយកទៅប្រគល់ឲ្យថៅកែហុក នៅពេលព្រឹក ។ សមបានឆ្លៀតឱកាសនេះទៅតាមនាងសយជាប្រពន្ធដែរដើម្បីឲ្យបានស្គាល់ផ្ទះ ហើយនឹង និយាយសុំការងារគេធ្វើផង ។

ថៅកែហុក ជាបុរសមានវ័យកណ្តាល ជាអ្នកជំនួញដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភម្នាក់ ជាពោះម៉ាយដែលមានអាយុប្រហែលជា ៥០ឆ្នាំ តែសាច់ឈាមនៅខ្ចីល្អក់នៅឡើយ ព្រោះគាត់ជា អ្នកមាន ។ ផ្ទះរបស់ថៅកែហុកជាផ្ទះធំទូលាយ មានរថយន្ត ២-៣ ហើយមានអ្នកបម្រើប្រុសស្រី ជាង ១០នាក់ ។ បែបសភាពរបស់ថៅកែហុក បើគេមើលពីខាងក្រៅក៏ឃើញថា ជាមនុស្សចិត្តល្អ ។ ថៅកែហុកនេះជាកូនថៅចិន តែគ្មានឬកពារជាចិននៅជាប់នឹងខ្លួនឡើយ [+]។ គាត់ជាមនុស្ស ម្នាក់ដែលមានគេស្គាល់រាប់អាចច្រើន ព្រោះតែអំណាចប្រាក់របស់គាត់នុះឯង ។

ចាប់តាំងពីវិនាទីដំបូង ដែលបានឃើញមុខនាងសយថៅកែហុកក៏ពេញចិត្តចំពោះរូបនាងណាស់ តែគាត់មិនពេញចិត្តនឹងសមសោះក្នុងកាលដែលគាត់ដឹងថា សមជាប្តីរបស់នាង

"ខ្ញុំព្រមយកឯងជាស្រីបំរើរបស់ខ្ញុំចាប់តាំងពីឥឡូវនេះទៅ ថៅកែហុកនិយាយមួយៗ កិរិយាខាងក្រៅរបស់គាត់ពេញទៅដោយសេចក្តីអាណិតអាសូរ "ដំបូងខ្ញុំនឹងឲ្យប្រាក់ខែ២០០ រៀល សិនតែសម្រាប់ប្តីឯងនោះខ្ញុំស្តាយណាស់ដែលគ្មានការអីល្មមឲ្យធ្វើបាន តែណ្ហើយចុះឯង ឧស្សាមកលេងប្រពន្ធឯងរឿយៗផង ក្រែងលោក៏ខ្ញុំមានការងារអ្វីល្មមអោយឯងធ្វើបាន"។

សំដីដ៏ទន់ភ្លន់លើបេះដូងដ៏ខ្មៅ និងស្មោកគ្រោករបស់ថៅកែហុកនេះ បានធ្វើអោយសម គោរពោតក្រែងនាយទុនចិត្តចោរនេះយ៉ាងស្មោះអស់ពីពោះ រហូតដល់ទៅសង្ឃឹមថា ប្រពន្ធរបស់ខ្លួនមុខជាបានទទួលនូវសេចក្តីសុខសប្បាយនៅក្រោមដំបូលផ្ទះរបស់នាយទុននេះហើយ...។

"ខ្ញុំបាទគ្រាកអរណាស់! សមនិយាយព្រមទាំងលើកដៃសំពះថៅកែហុក។

ខ្ញុំបាទសុំផ្ញើរប្រពន្ធខ្ញុំបាទនឹងព្រះតេជគុណាផងទានប្រោស។

កុំព្រួយ! កុំព្រួយ!ខ្ញុំតែងតែមេត្តាត្រាប្រណីដល់អ្នកបម្រើរបស់ខ្ញុំគ្រប់ៗគ្នាដូចជាកូនថៅរបស់ខ្ញុំដែរ។

មុនពេដែល សម និងនាងសយបែកគ្នា នាងបានចេញមកជូនដំណើរប្តីដល់ទ្វាររបង។អ្នកទាំងពីរបានសម្លឹងមើលមុខគ្នាដោយសេចក្តីអាល័យ។

សយអូន! សុំអូនខំយកលចិត្តទុកដាក់បម្រើបម្រាស់លោកអោយមែនទែនណាអូន! សមផ្តាំប្រពន្ធមុនពេលបែកគ្នា។

លោកនេះដូចជាចិត្តល្អណាស់ ហើយមិនប្រកាន់ឯមករកខ្លួនផង។

ចុះបងទៅស្រុកអង្កាល់?ដល់បងត្រលប់មកវិញសុំបងមករកខ្ញុំភ្លាមណា៎។

´´បងចង់ទៅស្អែកហ្នឹងអូន ហើយបងទៅតែ៧ ៨ថ្ងៃទេ បងនឹងត្រឡប់មកវិញ លាសិនហើយណា៎អូន!....´´។

សម និងសយបែកគ្នាទាំងអាល័យ...សមដើរឃ្លាតចេញពីនាងសយទៅ ទាំងចិត្តដែលដក់ជាប់នៅលើរូបនាង...។

ॐॐॐॐॐ

## ភាគទី៤ ក្រោមដំបូលផ្ទះនាយទុន

គ្រាន់តែពេលមួយថ្ងៃ ដែលនាងបានចូលមកជ្រលនៅក្រោមដំបូលផ្ទះ របស់ថៅកែហុកនេះ នាងសយក៏នឹកតក់ស្លុតជាខ្លាំង.....។

ស្រីបំរើច្រើនអ្នកបានខ្សឹបខ្សៀវប្រាប់នាងថា ថៅកែហុកនេះជាមនុស្សខិលខូចនឹងស្រីញីណាស់ ព្រោះស្រីបំរើនូវក្នុងផ្ទះនេះ ច្រើនតែធ្លាក់ខ្លួនទៅជាចំនីនៃសេចក្តីសប្បាយថៅកែហុកស្ទើរតែទាំងអស់ ។

ក្នុងពេលដែលនាងសយកំពុងតែរៀបចំបោសសំអាតបន្ទប់តូចនៅខាងក្រោយជាបន្ទប់ដែលនាងត្រូវនូវនោះ ថៅកែហុកក៏បានចូលទៅជួបនឹងនាងទាំងពីនាក់តទល់ ។ គាត់ចេះតែរំពៃសម្លឹងមើលនាងដើយការយកចិត្តទុក្ខដាក់ ។ តែបើទុកជាថៅកែនេះញញឹមដាក់នាងយ៉ងណាក៏ដោយ នាងសយក៏នូវតែនឹកតក់ស្លុត់រន្ធត់ក្នុងចិត្តមិនតិចឡើយ ព្រោះនាងនឹកដល់ពាក្យសំដីដែលស្រីបំរើចាស់ៗនិយាយប្រាប់នាងកាលពីថ្ងៃ.....។

"សយ ! "ថៅកែហុកនិយាយឡើងទាំងទឹកមុខញញឹម´សយ ឯងដូចជាមានស្អីនៅក្នុងខ្លួន ធ្វើអោយខ្ញុំអាណិតអាសូរជាខ្លាំង " ។

ក្នុងយប់នេះ.....យប់ដែរនឹងត្រូវមកដល់មិនហួសពីរបីម៉ោងទៀតនោះ ថៅកែហុងមានគ្រោងការណ៍នឹងរំលោភលើរូបនាងសយ ដែលស្រីបំរើគួរអោយអាណិត ហើយមានសភាពមិនខុសគ្នា ពីពងមាន់នៅក្នុងក្រញាំដៃគាត់ឡើយ ។

ម៉ោង ២១ ហើយ ....ភ្លៀងកំពុងធ្លាក់ជោគជាំ....។

នាងសយកំពុងអង្គុយក្រៀមក្រំ ដោយការព្រួយបារម្ភនៅក្នុងបន្ទប់ដេករបស់នាងតែម្នាក់ឯង ...នាងកំពុងនឹកដល់ប្តីសម្លាញ់ និងកំសត់កម្មរបស់នាង ហើយនាងនឹកដល់សេចក្តីអភ័ព្វរបស់នាង ....។

ខណ:នោះនាងសយឮសូរគោះទ្វាររន្ទាប់ផ្ទួនៗគ្នាជាច្រើនដង ។ នាងព្រឺក្បាលខ្វាលនឹងខ្លាចហេតុការណ៍ដែលត្រូវកើតឡើង ដូចពាក្យសំដីស្រីបំរើចាស់ៗនិយាយប្រាប់នាងកាលពីថ្ងៃ.....។

"អ្នកណា ?" នាងស្រែកសួរដោយសំលេងតិចៗហើយញ័រៗ ។

"ខ្ញុំ !...." ។

នាងសយបុកពោះភឹបៗ ព្រោះស្គាល់ជាសំលេងរបស់ថៅកែហុក ។ នាងសន្សឹមៗក្រោកឡើងមួយសន្ទុះ ហើយក៏កាត់ចិត្តដើរទៅបើកទ្វារ ។ នាងគិតថាប្រសិនបើថៅកែហុកប្រព្រឹត្តិរំលោភលើរូបនាង នាងនឹងសំពះអង្វរករ គេដើម្បីយោងខ្លួនអោយរួចផុតពីគ្រោះថ្នាក់នោះ ។

លុះទ្វារបន្ទប់បើកឡើង នាងសយក៏បានជួបមុខនឹងថៅកែហុកក្នុងរយះដ៏ជិត ។ "កំពុងធ្វើអីសយ ?"ថៅកែហុកសួរនាងដោយទឹកមុខញញឹម ។

"ចាំស ! ឥតធ្វើអ្វីទេលោក....!"។

ថៅកែហុកដើរចូលមកជិតនាង នាងសយក៏ដើរថយក្រោយ ។បេះដូងរបស់នាងស្ទើរតែឈប់លែងធ្វើការក្នុងខណ:ដែលថៅកែហុកចេះតែដើរចូលមកជិតនាង ។ នាងសយមានទឹកមុខសស្លាំងដូចជាគ្មានឈាម ។ នាងនឹកថានឹងធ្វើយ៉ាងណាស្រួល ? បញ្ហានឹងស្មុគស្មាញបានកើតឡើងដល់នាងហើយ.....។

ភ្លៀងនូវតែធ្លាក់ចុះមកមិនដាក់គ្រាប់ ។ នាងសយថយទៅទើសនឹងជញ្ជាំងហើយឈរនូវស្ងៀម ។ នាងនឹកគួសវាសដល់បំណងរបស់ថៅកែហុក....។

"សយ!" ថៅកែហុកនិយាយហើយ រឹតតែដើរចូលមកជិតនាងទៀត ។

រាងកាយរបស់នាងសយញ័រចំប្រប់ ដែលមិនខុសគ្នាពីកូនឈ្លូសបិតនៅក្នុងទីចំពោះមុខទីរាជសីហ៍ ។

"លោក" នាងសយនិយាយដោយសំលេងញ័រៗ ព្រមទាំងលើកដៃសំពះ ។

"សុំលោកអាណិតខ្ញុំ....."។

ថៅកែហុកញញឹម ។ ដោយការពេញចិត្តនឹងរូបឆោមរបស់នាងសយជាខ្លាំងព្រោះសាច់ឈាមដ៏ទ្រលុកទ្រលន់របស់នាង បានធ្វើអោយថៅកែហុកងងឹតមុខក្នុងផ្លូវកាមអារម្មណ៍ ។សេចក្តីសុខរបស់ថៅកែហុក បិតនៅត្រង់ការរួមរស់នឹងស្រីដែលគាត់ពេញចិត្តទោះ ស្រីនោះជាស្រីបំរើក៏ដោយ ហើយគាត់ឥតរវល់នឹកនាថា ជាប្រពន្ធកូនបានឡើយ ។ ថៅកែហុកអង្អែលស្មានាងតិចៗ ៖

"កុំខ្លាចខ្ញុំធ្វើអីសយ ! មកអង្គុយនិយាយលេងសិន" ។

"លោក!" នាងសយនិយាយ" បើលោកគ្មានការអីក្នុងយប់នេះទេ សុំលោកមេត្តារង់ចាំប្រសាសន៍នៅថ្ងៃស្អែកទៅ "

ថៅកែហុកសើចតិចៗ ហើយចាប់ទាញដៃអោយអង្គុយលើគ្រែជិតគាត់ ៖

"កុំខ្លាចខ្ញុំធ្វើអ្វីសយ !ខ្ញុំគ្មានធ្វើអីសយទេ ខ្ញុំចូលមកនិយាយលេងនឹងសយឯងទេ តើ ព្រោះខ្ញុំពេញចិត្តនឹងឫកពារសុភាពរាបសាររបស់សយឯងណាស់ "។

"តែខ្ញុំជាស្រីបំរើ មិនសមកិត្តិយសរបស់លោកទេ"

មិនអីទេសយ !កុំនឹកអញ្ជឹងធ្វើអី ខ្ញុំមិនមែនជាយក្សឯណា មកអង្គុយមក អង្គុយនិយាយគ្នាលេង ខ្ញុំមិនមែនជាមនុស្សប្រកាន់ខ្លួនប្រាណទេ ។

ថៅកែអង្គុយលើគ្រែ ហើយចាប់ទាញដៃនាងសយអោយអង្គុយជិត ។

ធនបតី លូកហោប៉ៅអាវទាញយកក្រដាសប្រាក់ ១០០ រៀល ថ្មីថៃស ២ សន្លឹក ហើយញាត់ទៅក្នុងដៃនាងសយ ។

"ហ៎ាសយ ! យកប្រាក់ ២០០ រៀលនេះទុកចាយទៅ "ថៅកែហុកនិយាយចប់ ហើយក៏ស្រវ៉ាអោបនាងដោយការក្រហល់ក្រហាយ " សយ កុំខ្លាចអី ហើយកុំគិតអី ច្រើនពេកឯងនឹងត្រូវបានសេ

ចក្តីសុខយ៉ាងពេញចិត្ត បើឯងព្រមធ្វើប្រពន្ធខ្ញុំព្រោះឯងមានទឹកមុខដែលធ្វើអោយខ្ញុំអាណិតនឹស្រលាញ់ជាខ្លាំង....។

នាងសយយំខ្សឹបខ្សួល...នាងញាប់ញ័រសព្វសាច់ដោយការភ័យខ្លាចហើយនាងក៏ហុចប្រាក់អោយទោថៅកែហុកវិញ ។

"សុំលោកយកប្រាក់ទៅវិញចុះ សុំលោកយកទៅសំរេចជាមួយនឹងសេចក្តីត្រូវការរបស់លោកជាមួយនឹងស្រីដ៏ទៃទៀតចុះ ឯរូបខ្ញុំមិនមែននូវទំនេរទេ ខ្ញុំមានប្តីហើយ "។

ថៅកែហុកសំលឹងមុខនាងសយដោយសេចក្តីក្រេវក្រោធ ។

" សយ !"ថៅកែហុកនិយាយឡើង " សយឯងជាអ្នកក្រ សេចក្តីត្រូវការរបស់អ្នកក្រនោះមិនមែនប្រាក់ទេឬ ? ឯងបណ្តោយអោយគ្នាត្រឹមមួយភ្លែតប៉ុណ្ណោះ ដោយគ្មាននណារឃើញ និងដឹងលឺសោះផង ឯងក៏បាន ២០០ រៀលទៅហើយ "។

នាងសយមិនបានជានឹកនាថា អ្នកមានឋានៈខ្ពស់មានចិត្តសាមាត្យ គ្មានសីលធម៌ ហើយប្រាសចាកការអៀនខ្មាស់គិតតែប្រព្រឹត្តិបន្ទុបន្ថយនូវសេក្តីក្រហល់ក្រហាយ ដោយផ្លូវកាមារម្មណ៍របស់ខ្លួនតែប៉ុណ្ណោះសោះឡើយ ហើយគ្មានគិតថា ជាប្រពន្ធកូនរបស់អ្នកដទៃ ។

"លោក ! ខ្ញុំព្រមធ្វើជាប្រពន្ធលោកមិនបានទេ " នាងសយនិយាយទាំងទឹកភ្នែក ខ្ញុំចូលមកនូវក្នុងផ្ទះនេះ ក៏បម្រើបម្រាស់លោក ប្តូរយកប្រាក់លោក បើទុកជាខ្ញុំ ក្រយ៉ាងម៉េច ក៏ខ្ញុំនូវតែដឹងគុណទោស បុណ្យបាប អាក្រក់ខ្លះដែរ ខ្ញុំនូវតែស្មោះត្រង់នឹងប្តីរបស់ខ្ញុំជានិច្ច ។

ថៅកែហុកស្រវាអោបនាងទៀត ។ នាងខំបម្រះចេញ ហើយស្ទុះក្រោកឈរឡើង ។ នាងលែងគោរពកោតក្រែងថៅកែហុកទៀតហើយ...។

"លោក ! "នាងសយនិយាយតទៅទៀត " សុំលោកកុំយល់ថា អ្នកក្រសុទ្ធតែមានចិត្តដូចគ្នាទាំងអស់នោះអោយសោះ សុំលោកជ្រាបថា អំណាចប្រាក់របស់លោកគ្មានប្រយោជន៍អីដល់អ្នកក្រដូចខ្ញុំនេះទេ ខ្ញុំចូលមកស៊ីឈ្នួលលោកក៏ព្រោះខ្ញុំក្រ តែខ្ញុំពេញចិត្តនិងអំពើររបស់ខ្ញុំ ខ្ញុំសុខចិត្តស្លាប់ល្អជាជាងព្រមលះបង់ខ្លួនប្រាណអោយលោកមខ្ញុំនឹងចុះចេញពីផ្ទះឥឡូវហ្នឹង ពីដើមខ្ញុំមិនបានជានឹកនាថា អ្នកមានដូចលោក មានចិត្តអាក្រក់ដ៏ម្លឹងសោះ "។

ថៅកែហុក ស្ទុះក្រោកឡើងទៅឈរវាំងទ្វារ ។ ទឹកមុខរបស់គាត់ដែលញញឹម កាលពីម្សិលមិញនេះ ក៏ក្លាយទៅជាក្រញូវទៅវិញ ។

"សយ !"ថៅកែហុកនិយាយឡើងដោយមើងម៉ាត់ ។

"ឯងធ្លាក់ខ្លួនមកនៅក្នុងក្រញាំដៃដៃខ្ញុំហើយ ឯងគេចទៅណាមិនរួចទេ ខ្ញុំត្រូវការឯងមកអូនស្រី...ឯងចេញទៅណាមិនរួចទេ "។

ថៅកែហុងដើរចូលទៅជិតនាងសយទៀត ។ នាងខំស្រែកឡើងយ៉ាងខ្លាំងតែភ្លៀងដែរកំពុងធ្លាក់ជោគជាំខាងក្រៅ និងដៃដ៏របាំសរបស់ថៅកែហុកដែលខ្ទប់មាត់នាងជាប់នោះ ធ្វើអោយសំលេងរបស់នាងសយឮ ត្រឹមតែក្នុងបន្ទប់នោះប៉ុណ្ណោះ នាយទុនដែលមើលឃើញស្រីទុគតិគឺជាចំនីដ៏មានឱជារស ក៏ស្ទុះចូលទៅអោបនាងសយទៀតហើយអោបថើបយសេចក្តីដោយសេចក្តីអន្ទះអន្ទែងក្នុងផ្លូវកាមារម្មណ៍ ។ នាងសយខំបម្រះតស៊ូ អោយរួចពីសភាព ព្រៃផ្សៃរបស់ថៅកែហុកក៏ប៉ុន្តែភាពនាងជាស្រី ធ្វើដូចម្តេច នឹងមានកំម្លាំងរឹងមាំរើខ្លួនរួច...ទីបំផុតនាងក៏ស្បើយកំលាំងបន្តិចម្តងៗ ហើយក៏ធ្លាក់ខ្លួនទៅក្នុងរង្វង់ដៃត្រកងបីអោបរបស់ថៅកែហុក ។ ថៅកែហុក បីនាងយកទៅដាក់នៅលើគ្រែដោយកំលាំងដ៏ខ្លាំងក្លា...។

យប់នេះជាយប់ដែលនាងមានចិត្តស្លុត់យ៉ាងខ្លាំង....នាងធ្លាប់បានសច្ចាថានឹងមិនព្រមអោយមានឈ្មោះថា ជាស្រីប្តីពីរ....តែយប់នេះ នាងត្រូវលះបង់របស់គ្រប់...បែបយ៉ាងអោយដល់ធនបតីដែលតែងស្វែងរកសេចក្តីសុខសម្រាន្តពីពួកស្រីបំរើ នៅក្នុងផ្ទះរបស់គាត់....។

ព្រឹកឡើងនាងសយបានចុះចេញពីផ្ទះថៅកែហុកតាំងពីព្រលឹម ។ នាងស្ទើរតែប្រហារជីវិតរបស់នាងចោល ព្រោះតែសេចក្តីឈឺចាប់ក្នុងចិត្ត ។ នាងគិតថារបស់ដែលមានតម្លៃជាទីបំផុតក្នុងជីវិតរបស់នាង បានខូចខាតអស់ហើយៗជារឿងឆ្អេះឆ្អាបជាប់នឹងខ្លួននាងអស់មួយជីវិត...នាងយំទាល់តែហើមភ្នែក....នាងចុះចេញពីផ្ទះថៅកែហុកដោយគ្មានឥតបានលាអ្នកណាឡើយ។

នាងសយដើររកមិត្តភក្តិកម្មករត្រីចក្រយានម្នាក់ដែលស្និតស្នាលនឹងប្តីនាងហើយដែលធ្លាប់បានជួយគ្នាទៅវិញទៅមកដូចបងប្អូនបង្កើត ។នាយមី និងនាងម៉ុមប្តីប្រពន្ធទាំងពីរបានទទួលរាក់ទាក់រួសរាយរកនាងសយដូចពេលមុនៗ ។ នាងសយបានបរិយាយរឿងរាវដែលកើតឡើងនៅក្នុងផ្ទះថៅកែហុកកាលពីយប់មិញអោយនាងមី នឹងនាងម៉ុមបានសព្វគ្រប់ ហើយនាងក៏សុំនូវសំណាក់អាស្រ័យនឹងគេ ទម្រាំប្តីនាងត្រលប់មកពីបាត់ដំបងវិញ ។

ខណៈនោះ នាយម៉ីក៏បាប់ផ្ដើមនិយាយឡើងដោយការ យល់ចិត្តយល់ថ្លើមនាងសយថា ៖

"មិនអីទេសយ ! ផ្ទះគ្នាក៏ដូចជាផ្ទះឯងដែរ យប់មិញសមវាមកដេកនៅផ្ទះគ្នានេះ ហើយយូរណាស់ទម្រាំហ៊ានហាមោត់ខ្ចីប្រាក់គ្នា យកទៅធ្វើជាសាហ៊ុយទទួលម្សិលមិញនេះ គ្នាមានប្រាក់ ២០០ រៀលគ្នាក៏អោយសមខ្ចី១៥០រៀលទៅសមប្រាប់ថា វាទៅបាត់ដំបងតែ ៥ថ្ងៃទេ វានឹងត្រលប់មកវិញ មិនអីទេសយនៅជាមួយគ្នាសិនចុះទម្រាំសមវាត្រលប់មកវិញ " ។

នាងសយបានសំនាក់នូវផ្ទះនាងម៉ី និង នាងម៉ុមតាំងពីថ្ងៃនោះមក ។ នាងតែងជួយធ្វើកិច្ចការក្នុងផ្ទះនាងម៉ុមជានិច្ច មានការដាំស្ល និងមើលកូនជាដើមព្រោះនាងម៉ុមមានកូនពីរនាក់ ។

៥ថ្ងៃបានកន្លងផុតទៅតៀត ។ នៅពេលរសៀលថ្ងៃព្រហស្បត៍ រថភ្លើងបាត់ដំបង ភ្នំពេញបានដឹកនាំអ្នកដំណើរទាំងឡាយមានសមជាដើម មកដល់រាជធានី នៅវាលាម៉ោង ១៤ កន្លះ ។ សម បានត្រលប់មកភ្នំពេញវិញ ដោយការសំរេចផលយ៉ាងពេញចិត្ត គឺសមបានទៅទារប្រាក់ដែលគេជំពាក់ និងលក់អីវ៉ាន់បន្តិចបន្តួចបានប្រាក់ចំនួន ៦០០៛ ។

សមខំធ្វើដំណើរទៅរកប្រពន្ធឯផ្ទះថៅកែហុកយ៉ាងរួសរាន់ ដើម្បីប្រាប់នាងអោយដឹងថា ខ្លួនគេមានជោគវាសនាគ្រន់បើបន្តិចវិញហើយពហើយសមនឹងអោយនាង នៅស៊ីឈ្នួលថៅកែហុកតែ១ខែប៉ុណ្ណោះ ដល់ពេលដាច់ខែ នឹងអោយនាងលាឈប់ ដើម្បីត្រលប់មករួមរក្សជាមួយគ្នាតទៅទៀត ។

សមទៅដល់ផ្ទះថៅកែហុកនៅពេលម៉ោង ១៥ ។ ពេលនោះស្រីបំរើរបស់ថៅកែហុកម្នាក់បានប្រាប់សមថា ៖

សយមកនៅបានតែ ១យប់ប៉ុណ្ណោះ លុះព្រឹកឡើងក៏លួចរត់បាត់ទៅ ហើយឮលោកមានប្រសាសន៍ថា សយបានលួចយកឥវ៉ាន់លោកទៅច្រើនណាស់។

សមស្រឡាំងកាំងហាក់ដូចជាមិនចង់ជឿថា ប្រពន្ធរបស់ខ្លួនហ៊ានលួចឥវ៉ាន់ ថៅកែហុកសោះឡើយ តែលុះសភាពក្រលំបាក សមក៏គិតថា ជួនកាលវាមានដូច្នេះមែន ប្រសិនបើនាងសយចង់ជួយជ្រោមជ្រែងខ្លួនក្នុងរឿងប្រាក់កាក់នោះ ។ សមមិនបានសាកសួរអ្វីទៀតឡើយ ហើយក៏លាស្រីបំរើ ដោយដើរទៅវិញយ៉ាងរួសរាន់ ។

សមមានមិត្តភក្តិកម្មករដ៏ស្និទ្ធស្នាលនឹងគ្នា ត្រឹមតែប៉ុន្មាននាក់ប៉ុណ្ណោះ ។ សមជឿជាក់ថា មុខជាសំណាក់អាស្រ័យនៅជាមួយមិត្តភក្តិ ហើយសមក៏ប្រញាប់ញាល់ទៅតាមរកនាងភ្លាម ។ ផ្ទះទីមួយដែលសមត្រូវទៅរកនោះគឺ ផ្ទះនាងម៉ី និងនាងម៉ុម ។

សមបានដើរទៅដល់ផ្ទះនាងម៉ី ក្នុងខណៈដែរនាងម៉ីកំពុងតែរុញត្រីចក្រយានចេញពីផ្ទះ ប្រុងប្រៀបនឹងចេញទៅរកស៊ី ងូតញើសតាមទឹក....។

អ្នកទាំងពីរនាក់ប្រាស្រ័ទាក់ទងរកគ្នាដោយសេក្តីស្និទ្ធស្នាល ។

"បង ម៉ី អើយ ! " "សមនិយាយឡើង"ខ្ញុំចុះពីរទេះភ្លើងភ្លាម ខ្ញុំទៅរកប្រពន្ធខ្ញុំភ្លាមនៅផ្ទះថៅកែហុក តែមិនជួប មានស្រីបំរើម្នាក់បានប្រាប់ខ្ញុំថា ប្រពន្ធខ្ញុំទៅនៅបានតែផ្ទះគេតែមួយយប់ ក៏លួចអីវ៉ាន់គេរត់បាត់ ឥឡូវមិនដឹងជាវាទៅនៅឯណាទេបង "។

ម៉ីខាំធ្មេញណែន ។

"វាមានទៅណា " ម៉ីឆ្លើយឡើង សយវារត់មកនូវផ្ទះគ្នានឹងទេតើ ។

តពីនោះមក ម៉ីក៏បាននិយាយរឿងរ៉ាវរបស់នាងសយប្រាប់សមតាមពាក្យសំដីដែលនាងបាននិយាយប្រាប់ពីថ្ងៃមុនដោយសព្វគ្រប់ ។

សមឈរនៅធ្មឹង ហាក់ដូចជាត្រូវរន្ទះបាញ់ត្រូវត្រង់ដើមទ្រូង ។ ទឹកភ្នែករបស់សមស្រក់ចុះតក់ៗ ជាទឹកភ្នែករបស់មនុស្សអ្នកក្រដែលបានទទួលនូវសេក្តីឈឺចាប់ពីអ្នកមាន ....។

" អាហុក !.....សមនិយាយើងដោយទោសៈ ។

"អញ មិនបណ្តាយអោយរឿងនេះនៅស្ងៀមអញ្ជឹងមិនបានទេ កាលបើវាហ៊ានរំលោភលើប្រពន្ធអញអញ្ជឹង អញក៏ត្រូវហ៊ានសម្លាប់វាចោលដែរ....។

ម៉ីទះស្មាសមតិចៗ ដើយនិយាយកាត់ឡើងថា ៖

ណ្ហើយសម ! កុំទៅរករឿងនឹងគេព្រោះគេជាអ្នកមានឯងត្រូវគិតថានេះជាកម្មរបស់ឯង....

សមប្រញាប់ប្រញាល់ដំរចូលទៅក្នុងផ្ទះ ។ សមរន្ធត់ចិត្តជាខ្លាំងក្នុកាលដែលក្រឡេកមើទៅឃើញ នាងសយកំពុងតែដេកដណ្តប់ភួយ ។ សម ស្រែកហៅប្រពន្ធខ្លាំងៗ ល្មមធ្វើអោយនាងសយ

ភ្ញាក់ដឹងខ្លួន ។ គ្រាន់តែបើកភ្នែកឃើញប្តី នាងសយក៏ទ្រហោយំ ។ សមចូលទៅអង្គុយជិត ហើយងង្អែលថ្ងាស់ប្រពន្ធថ្នមៗ ព្រមទាំងនិយាយលួងលោមថា៖

កុំយំធ្វើអីអូន ! បងបានដឹងរឿងរាវ ដោយសារបងម៉ី រួចហើយ មិនអីទេអូន បងត្រូវតែសងសឹកនូវអំពើរអាក្រក់របស់វាចោល ....។

កុំបង ! កុំ!....កុំគិតអញ្ចឹង បើបងចង់សងសឹកជំនួសខ្ញុំ បងមុខជាត្រូវជាប់គុក ច្រវាក់មិនខានណ្ហើយបង ! កុំធ្វើអីគេ នេះជាកម្មរបស់យើង។

ទឹកចិត្តរបស់សមពោរពេញទៅដោយការអាឃាតព្យាបាទ បើទុកជានាងម៉ី និង នាងម៉ុម ព្រមទាំងនាងសយហាមឃាត់យ៉ាងណាក៏ដោយសមក៏នូវតែមិនព្រម លះបង់គំនិតព្យាបាទដែលចង់ប្រហារជីវិតថៅកែហុកនោះចោរឡើយ ។

ខណៈនោះនាងម៉ុមក៏និយាយឡើងថា ៖

មិនអីទេសយ បើវាពិបាកណាស់ ក៏នូវសំនាក់ផ្ទះខ្ញុំសិនចុះ ទម្រាំរកជួលផ្ទះបាន ។

សមញញឹមដោយទឹកភ្នែកដោយទឹកចិត្តដែរពោរពេញទៅដោយការមួរហ្មង ។

ឣឣឣឣឣ<<<<<

## ភាគទី៥ ជាប់គុកព្រោះចាញ់កលនាយទុន

ភ្លៀងកំពុងរលឹមស្រិចៗ...ផ្លេកបន្ទោលបញ្ចេញរស្មីភ្លឺឡើងភ្លែតៗ ហើយផ្គរលាន់ក៏គ្រហឹមឡើងមិនដាច់សូរ...

យប់នោះ ជាយប់ដែលសមកាត់ចិត្តយ៉ាងដាច់ខាតដើម្បី ប្រហារជីវិតថៅកែហុកនាយទុនដែលបានកំហែងចាប់ប្រពន្ធរបស់គេ ដោយការក្រហល់ក្រហាយក្នុងផ្លូវកាមារម្មណ៍ ហើយដែលធ្វើអោយនាងសយ ត្រូវទទួលនូវការឈឺចិត្តចាប់នឹងអាមាស់មុខអស់មួយជីវិត។

ពេលនោះ សមបានមកប្រាកដខ្លួននៅក្នុងបរិវេណរបងផ្ទះរបស់ថៅកែហុក ហើយ ខោអាវ និង រាងកាយរបស់សមទទឹកជោកដោយគ្រាប់ភ្លៀង។ សមឈរនៅក្នុងទីងងឹតក្រោមម្លប់ឈើធំ

មួយដើយខាងក្រោមផ្ទះ។ សមកាន់កាំបិតស្នៀតមួយនៅដៃ ហើយកាំបិតស្នៀតនេះឯង ដែលសមត្រូវធ្វើចុងរបស់វានៅត្រង់ពោះ ឬដើមទ្រូងរបស់ថៅកែហុកនាយទុនចិត្តពាលអន្យតិរ្ថិយដែលបានកំហែងគម្រាមចាប់ប្រពន្ធរបស់ខ្លួន...

ពន្លឺគោមអគ្គិសនីខាងលើផ្លូវថៅកែហុក នៅភ្លឺនូវឡើយ។ សមសម្ងំឈរនៅស្ងៀមជិតកន្លះម៉ោង។ ទីបំផុតសមក្រឡេកមើលទៅឃើញថៅកែហុកដើរត្រេះត្រុះនៅក្នុងបន្ទប់។

សមមានទឹកមុខគួរអោយខ្លាច...ភ្នែកក្រហមដូចរងើកភ្លើង...សមគិតស្មានថា បន្ទប់ដែលថៅកែហុកកំពុងដើរចុះឡើងនេះ ជាបន្ទប់សំរាប់ធ្វើការ សមដើរសន្សឹមៗ ចូលមករកផ្ទះដោយការប្រុងប្រយ័ត្នខ្លាចក្រែងមានអ្នកណាមួយឃើញមុនពេលដែលបានប្រហារជីវិតនាយទុនចិត្តមារនោះ។

ការស្មានរបស់សមចំជាត្រូវមែន។ បន្ទប់ដែលបានពោលខាងលើនេះ ជាបន្ទប់សំរាប់ធ្វើការរបស់នាយទុនចិត្តចោរមែន។ ថៅកែហុកស្លៀកពាក់ខោអាវតាមរបៀបនៅផ្ទះ ហើយបៀមខ្សៀមួយយ៉ាងធំ។ គាត់កំពុងតែប្រើគំនិតនៅក្នុងកិច្ចការជំនួញរបស់គាត់។ នៅលើតុសរសេររបស់គាត់ ពោរពេញទៅដោយឯកសារផ្សេងៗ។

ថៅកែដើរវិលវល់ចុះឡើងនៅក្នុងបន្ទប់នេះ។ គាប់ជួនជាក្នុងខណៈនោះគាត់អង្គុយចុះទៅលើកៅអីដែលតាំងនៅចំពីមុខតុសរសេរ។ ក្នុងពេលជាមួយគ្នានេះសមក៏ខំប្រឹងប្រតោងឡើងតាមបង្អួចពីខាងឆ្វេងថៅកែហុក ហើយក៏សន្សឹមៗកន្លងបង្អួចចូលមក។

សមឈរនៅស្ងៀមមួយស្របក់ ខំសម្លឹងសម្លក់មើលថៅកែហុកដោយភ្នែកក្រឡោត ហើយក៏និយាយឡើងដោយពាក្យសំដីដាច់ខាតថា៖

" លោកហុក! "

ថៅហុកភ្ញាក់ព្រើត ហើយក៏ងាកមើលទៅម្ចាស់នៃសំលេងនោះភ្លាម។ លុះឃើញថាជាសមថៅកែសមក៏ស្រឡាំងកាំង។ គាត់ដឹងភ្លាមថា ការដែលសមរុករានទន្ទ្រានទីចូលមកក្នុងផ្ទះរបស់គាត់ទាំងថ្មើរនេះ ហើយមានកាន់កាំបិតស្នៀតជាប់នៅដៃផងនោះ មិនមែនមកដោយការល្អទេ។ នាយ

ទុនមុខក្រាស់ភិតភ័យជាខ្លាំងដែលជាការធម្មតារបស់អ្នកមាន ហើយបានប្រព្រឹត្តនូវអំពើឧក្រិដ្ឋរាល់រូបត្រូវខ្លាចសេចក្តីស្លាប់។

ឥឡូវនេះ ស្ថានការណ៍ដ៏ចង្អៀតចង្អល់បានកើតឡើងដល់ថៅកែហុក ហើយគាត់ក្រោកឈរស្រឡាំងកាំងមួយសន្ទុះ ទើបខំប្រឹងញញឹមដាក់សម ដោយទឹកមុខដែលមានលេសន័យ។

" ឱសមឬ!..." ថៅកែហុកនិយាយតាមសម្រួល

" ឯងមកធ្វើអីទាំងថ្មើរនេះ..."

" បាទ ! ខ្ញុំហ្នឹងហើយលោកឈ្មោះអាសម ឱលោកនៅចាំខ្ញុំបាទបានដែរ? លោកធ្លាប់បានជួបខ្ញុំបាទតែម្តងប៉ុណ្ណោះ ក៏ចាំមុខខ្ញុំបាទបានដែរ ខ្ញុំបាទហ្នឹងហើយជាប្តីរបស់សយ..."

ថៅកែហុកមានទឹកមុខស្លេកស្លាំង។ គ្រាប់ញើសក៏ចេញឡើងភ្លាមនៅត្រង់ថ្ងាសរបស់គាត់។ ជីវិតរបស់គាត់ត្រូវបិតនៅក្នុងសេចក្តីប្រាថ្នារបស់សមហើយ។ ភ្នែតដ៏ធំក្រឡោត និងពណ៌ក្រហមដូចឈាមរបស់សម បានធ្វើអោយថៅកែហុកព្រឺខ្លួនជាខ្លាំងដូចជាថា មានអំណាចអ្វីមួយយ៉ាង ខ្លាំងក្លាមកគ្របសង្កត់នៅលើទឹកចិត្តរបស់គាត់។

" សម! " ថៅកែហុកព្យាយាមធ្វើចិត្តអោយរឹងពឹងហើយនិយាយ

" ឯងមានការអីសម? អង្គុយសិនទៅ ម៉េចក៏មិនចាំស្អែកសឹមមករកខ្ញុំមិនគួរមកផ្ទះទាំងភ្លៀងអញ្ចឹងសោះ "

សមសើចឡើងទាំងកំណាច

" លោក ! សមនិយាយព្រមទាំងសម្លឹងស្ទើរស៊ីសាច់ " កុំតក់ស្លុតអី ប្រសិនបើខ្ញុំជប្រាបលោកថា ខ្ញុំត្រូវការយកជីវិតលោកដើម្បីថ្នូរនឹងរបស់ដែលប្រពន្ធខ្ញុំបានខូចបង់ឲ្យទៅលោក ព្រោះតែអំពើព្រៃផ្សៃរបស់លោក លោក ! លោកជាអ្នកមាន លោកយល់ថាពួកស្រីអ្នកក្រជាគ្រឿងលេងសើចសប្បាយរីករាយរបស់លោក ឫ ជាផ្កាឈើដែលបិតនៅក្នុងដៃលោក ដោយមិនគិតថា ជាកូនប្រពន្ធរបស់អ្នកដទៃ-នាងសយជាប្រពន្ធខ្ញុំ-ជាដួងចិត្តរបស់ខ្ញុំ ដែលខ្ញុំស្រលាញ់ស្មើដោយជីវិត...ស្រលាញ់ដូចអ្នកដទៃគេស្រលាញ់ដូចអ្នកដទៃគេស្រលាញ់ប្រពន្ធគេអញ្ចឹងដែរ-ហេតុនេះហើយបានជាខ្ញុំខំ

តាមមករកជួបនឹងលោក ដើម្បីសុំជីវិតរបស់លោកដោយកាំបិតស្នៀតនេះ កុំស្រែកលោក សុំលោកនៅស្ងៀម...វាគ្មានប្រយោជន៍អីក្នុងការដែលលោកស្រែកអោយគេមកជួយនោះទេ ព្រោះបន្ទប់នេះលោកបានបិទជិត ហើយដាក់គន្លឹះពីខាងក្នុងផងទម្រាំនឹងមានអ្នកណាមកជួយ កាំបិតស្នៀតនេះវាមុខជាមុតធ្លុះទៅដល់បេះដូងរបស់លោកទៅហើយ។

និយាយចប់ហើយ សមក៏ដើរចូលទៅជិត។ ថៅកែហុកដើរថយក្រោយក្រាក។ សេចក្តីភិតភ័យបានកើតឡើងដល់គាត់យ៉ាងខ្លាំង ហើយសេចក្តីភិតភ័យនោះក៏បានបង្គាប់អោយគាត់លើកដៃស្តាំវាឡើង ព្រមទាំងនិយាយអង្វរករដោយសម្លេងញ័រៗថាៈ

ឈប់ ! ឈប់សិនសម ! ... ឯងកុំអាលធ្វើចិត្តខ្លាំងអញ្ចឹងពេក-មុននឹងសម្លាប់ខ្ញុំសុំទុកពេលអោយខ្ញុំនិយាយបានពីរបីម៉ាត់សិន។

សមឈរនៅចំពោះមុខថៅកែហុក ក្នុងរយៈដ៏ជិត។ កិរិយារបស់សមមានសភាពដូចយក្សរិកលចរិត។ ការញញឹមទាំងក្រេវក្រោធរបស់សម បានធ្វើអោយនាយទុនមុខក្រាស់ខ្លបខ្លាចជាខ្លាំង “។

" លោកនិយាយអីនឹងខ្ញុំ ក៏និយាយអោយឆាប់មក " សមបញ្ជាយ៉ាងដាច់ខាត " ខ្ញុំទុកពេលអោយលោក បានត្រឹមតែពីរបីនាទីប៉ុណ្ណោះ” បេះដូងរបស់ថៅកែហុកស្ទើរតែឈប់ធ្វើការព្រោះតែការភិតភ័យ

" សម ! ខ្ញុំបានជាខុសជ្រុលទៅហើយអូន ! " ថៅកែហុកអង្វរករ

ខ្ញុំមិនបដិសេធទេក្នុងការដែលខ្ញុំបានកំហែងចាប់ប្រពន្ធរបស់ឯងនោះ តែការដែលខ្ញុំបានជាធ្វើជ្រុលដូច្នោះ ព្រោះខ្ញុំស្រវឹងស្រាមិនដឹងខ្លួន ហើយឃើញអាក្រក់ថាជាល្អ...

" លោក ! សមនិយាយឡើងព្រមទាំងសើចដោយកំហឹង " លោកមិនមែនជាមនុស្សព្រៃផ្សៃ

ឯណា លោកជាអ្នកមាន ហើយបានទទួលនូវការសិក្សាអប់រំមកយ៉ាងល្អ ឯរូបខ្ញុំគ្រាន់តែជាកម្មករម៉េចក៏គង់ខ្ញុំនៅដឹងការខុសត្រូវថា ស្អីគួរប្រព្រឹត្ត ស្អីគួរវៀង ពាក្យដោះសាររបស់លោកគ្មានហេតុផលល្មមអោយខ្ញុំអត់ទោសអោយលោកបានទេ ខ្ញុំបានតាំងចិត្តដាច់ខាតហើយថា ខ្ញុំត្រូវតែសម្លាប់លោក ខ្ញុំមិនព្រមលះបង់នូវគំនិតនេះជាដាច់ខាត...

" ឈប់សម ! ឈប់សិន ! " នាយទុនអង្វរករហើយលើកដៃសំពះកម្មករ

បើមានផ្លូវណាមួយដែលខ្ញុំអាចសងកំហុសរបស់ខ្ញុំបាននោះ សុំសមអាណិតប្រាប់មកខ្ញុំចុះសម ! យ៉ាងម៉េចៗ ក៏ប្រពន្ធរបស់ឯងបានខូចខ្លួនប្រាណអោយខ្ញុំទៅហើយ បើទុកជាសមសម្លាប់ខ្ញុំក៏វាគ្មានប្រយោជន៍អីទេក្រៅពីសមឯងត្រូវជាប់គុកជាប់ច្រវាក់-សម ! ឯងមិននឹកអាណិតប្រពន្ធឯងទេឬបើឯងត្រូវជាប់គុកជាប់ច្រវាក់ទៅនោះ ? -សម ! ប្រសិនបើឯងត្រូវការប្រាក់កាសវិញមិនស្រួលជាងឬ ? ខ្ញុំពេញចិត្តអោយប្រាក់កាសដល់ឯងឥឡូវហ្នឹង ស្រេចតែឯងចង់បានប៉ុន្មាន ខ្ញុំក៏អោយប៉ុណ្ណោះភ្លាម... បើធ្វើអញ្ចឹងទៅវាមិនមានប្រយោជន៍ជាងសម្លាប់ខ្ញុំឬសម ?

" លោក ! ប្រពន្ធរបស់ខ្ញុំមិនមែនជាវត្ថុសម្រាប់ទិញដូរទេ " សមនិយាយកាត់ឡើងអំពើព្រៃផ្សៃរបស់លោកបានធ្វើអោយបេះដូងប្រពន្ធខ្ញុំមានដំបៅរហូតដល់ថ្ងៃស្លាប់។

ថៅកែហុកហាក់ដូចជាមានកំលាំងចិត្តគ្រាន់បើ ក្នុងកាលដែលគាត់សង្កេតឃើញសម មានពាក្យសំដីទន់ជាងមុនបន្តិច។

" អូនប្រុស ! " ថៅកែហុកនិយាយពន្យល់សារជាថ្មី បងបានជាខុសហើយអោយបងបានសងនូវអំពើអាក្រក់របស់បងនោះដោយប្រាក់ទៅចុះ សុំឯងកុំគិតថា បងមើលងាយឯង

អោយសោះ -ការពិត ឯងក៏ជាអ្នកក្រ ឯងគួរតែយកប្រាក់ជម្ងឺចិត្តពីបងទៅធ្វើជាដើមទុនរកស៊ីទៅឯងនិងប្រពន្ធឯង ក៏នឹងបានសេចក្តីសុខសប្បាយតរៀងទៅ -ប្រាប់បងមកចុះសម តើឯងត្រូវការប៉ុន្មាន ?

ទឹកភ្នែករបស់សមហូរចុះច្រោកច្រោកត្របក។ សមឈរនៅស្ងៀមមួយសន្ទុះ។ អំណាចទឹកប្រាក់បានធ្វើអោយសមរារែកហើយ។ សមគិតថា ក្នុងមួយជីវិតរបស់អ្នកក្រដូចរូបខ្លួននេះគ្មានពេលសង្ឃឹមថា នឹងបានរុងរឿងឡើយ ក្រៅពីរកព្រឹកស៊ីល្ងាចទៅតាមសភាពហូរហែរ។ សមគិតថា គួរតែទារជម្ងឺចិត្តពីថៅកែហុកមួយម៉ឺនរៀល ព្រោះប្រាក់ចំនួនប៉ុណ្ណោះ ល្មមជួយអោយខ្លួនគេ និងប្រពន្ធគេ រកសេចក្តីសុខបានហើយ។

អ្នកក្រមែងតែងតែត្រូវធ្លាក់ខ្លួនទៅជាខ្ញុំកំដររបស់អំណាចប្រាក់... ពិតណាស់ក្នុងលោកយើងនេះមនុស្សគ្រប់រូបដែលនឹងមានបាយបរិភោគ ឬមានជីវិតរស់នៅបានក៏ដោយសារតែទឹកប្រាក់នុះឯង...សមសម្លឹងមើលមុខថៅកែហុក ដោយក្រសែភ្នែកដែលប្រាប់នូវលក្ខណៈថា មានការអត់

អោន...

" លោក ! សមនិយាយដោយការឈើញចិត្តឈើញថ្លើម ព្រោះការអង្វរកររបស់ថៅកែហុក " បើខ្ញុំទាមទារជម្ងឺចិត្តពីលោក ជូនកាលលោកគិតថា តម្លៃខ្លួនប្រពន្ធខ្ញុំដែលជាអ្នកក្រនោះ វាថ្លៃជ្រុលពេកទេដឹង ?

ថៅកែហុកញញឹមដោយមានជ័យជំនះ

" ទេប្អូនប្រុស ! បងឥតមានគិតអញ្ចឹងទេ ! ថៅកែហុកឆ្លើយឡើង " ស្រេចតែឯងចុះឯងកាត់ថ្លៃប៉ុន្មានក៏បាន ដើម្បីអោយសមល្មមទៅតាមការដែលឯងស្រលាញ់ប្រពន្ធ

មើល ! និយាយមកមើល តើឯងត្រូវការប៉ុន្មាន?

" មួយម៉ឺនរៀល ! " សមឆ្លើយមកភ្លាម

ថៅកែហុកងក់ក្បាលទទួល

" បាទអូនប្រុស ! បាន ! បងនឹងយកប្រាក់អោយអូនឯងឥឡូវហ្នឹង "

" អរគុណនឹងលោកណាស់ហើយ " សមឆ្លើយឡើង

" តែសុំអោយបានក្នុងពេលឥឡូវនេះ កុំចាំបាច់ដើរទៅយកឯណា..."

" អូនប្រុសអើយ " ថៅកែហុកឆ្លើយកាត់ឡើង " បងគ្មានកិច្ចកលអីទេ បងអាណិតឯងណាស់ហើយបងពេញចិត្តនឹងចំនាយប្រាក់មួយម៉ឺនរៀលនេះអោយឯងភ្លាម "

ថៅកែហុកញញឹមដាក់សម ... គាត់ដើរទៅរកតុធ្វើការរបស់គាត់ហើយក៏ទាញថតតុខាងស្តាំចេញមក។ ក្នុងខណៈនោះ អាកប្បកិរិយារបស់នាយទុនចិត្តចោរក៏ផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ ថៅកែទាញយករ៉ឺវ៉លវែរ ៨ម.មដែលនៅក្នុងថតតុនោះមកកាន់នៅដៃដម្រង់មាត់គ្រែទៅរកសម ហើយក៏សើចឡើងយ៉ាងសប្បាយតាមបែបន័យបុគ្គលអ្នកមានជ័យជំនះ ។

" ទម្លាក់កាំបិតចោលភ្លាមអាសម ! ... " ថៅកែហុកស្រែកគម្រាម អាឯងនៅមិនទាន់ចង់ងាប់ទេមែនទេមិនអញ្ចឹងឬ ឭទេ ! អញប្រាប់ថាអោយអាឯងទម្លាក់កាំបិតចោល ។ កុំរឹងទទឹង អញបាញ់អា

ឯងសម្លាប់ចោលឥឡូវហ្នឹង នេះជាផ្ទះរបស់អញ អញមានអំណាចបាញ់អាឯងសម្លាប់ចោលដូចជាឆ្កែបានអាក្របី មនុស្សភ្លើដូចអាឯងនេះវាគ្មានប្រាជ្ញាគិតគូរការអីទេ-ដែលមានឬអាណាព្រមអោយប្រាក់អាឯងមួយម៉ឺនរៀលងាយៗអញ្ចឹង នែអាសម ! ធុនប្រពន្ធអាឯងនោះ សមតែអោយ១០រៀលតែប៉ុណ្ណោះ - ទម្លាក់កាំបិតចោលភ្លាមអាចំកួត !

កាំបិតស្នៀតបានរបូតធ្លាក់ចុះពីដៃរបស់សមហើយ... អំណាចកាំភ្លើងបានធ្វើអោយសមព្រមចុះចាញ់តែក្រសែភ្នែករបស់សម ដែលសម្លឹងមើលមុខថៅកែហុកនោះរឹងមិនព្រមព្រិច ជាក្រសែភ្នែកដែលប្រាប់អោយដឹងថា ចិត្តរបស់សមពោរពេញទៅដោយការអាឃាតព្យាបាទ ។

ថៅកែហុកដើរថយក្រោយទៅរកទ្វារ។ គាត់មួរគន្លឹះទ្វារបើកហើយស្រែកហៅអ្នកបម្រើ ។ ខណៈនោះស្រីបម្រើម្នាក់បានចូលមក។ គ្រាន់តែឃើញថៅកែហុកកំពុងតម្រង់កាំភ្លើងគម្រាមបុរសចម្លែកភ្លាម ស្រីបំរើនោះក៏ភិតភ័យជាខ្លាំង។ ធនបតីបានស្រែកប្រើស្រីនោះ អោយទៅហៅគូលីប្រុសៗ ដែលនៅខាងក្រោមបីបួននាក់អោយមកជួមនឹងគាត់យ៉ាងឆាប់ ដើម្បីចាប់សមចងដៃ។

" បាញ់អញសម្លាប់ចោលទៅអាហុក " សមនិយាយ

" ពេលនេះបានដៃអាឯងហើយ "

ថៅកែហុកសើចឡើងដោយមានជ័យជំនះ

" អាសម ! អញស្ដាយណាស់ " ថៅកែហុកនិយាយ

" គ្រាប់កាំភ្លើងរបស់អញវាថ្លៃជាងជីវិតរបស់ឯងទៅទៀត - អ្នកក្រដូចអាឯងនេះ វាគ្មានតម្លៃអីនៅក្នុងខ្លួនទេ - អញនឹងអោយអ្នកបំរើអញអូសក្បាលអាឯងយកទៅអោយប៉ូលីសវិញល្អជាង អាឯងដឹងឬទេថា អាឯងត្រូវជាប់គុកច្រើនឆ្នាំក្នុងឋានៈដែលអាឯងព្យាយាមសម្លាប់អញ? តែថា អញនឹងត្រាប្រណីអោយអាឯងខ្លះ ព្រោះអញក៏ធ្លាប់យកប្រពន្ធអាឯងម្ដងដែរ អញនឹងចោទអាឯងត្រឹមតែថា អាឯងលបចូលមកក្នុងផ្ទះអញក្នុងពេលយប់ បើយ៉ាងច្រើនណាស់អាឯងក៏ត្រូវជាប់គុកត្រឹមតែ៣ខែប៉ុណ្ណោះ ដើម្បីជាមេរៀនសម្រាប់ប្រដៅអោយអាឯងចេះគិតវែងឆ្ងាយតទៅថ្ងៃក្រោយថាខ្លួនអាឯងប៉ុណ្ណឹងគ្មានផ្លូវអីនឹងយកមកឈ្នះអញទេអាសមអើយ ! មិនគួរណាជាអាឯងខំកាត់មករកចូលទ្រូងអញ្ចឹងសោះ "

សមខាំធ្មេញណែន គិតដល់ភាពដែលខ្លួនត្រូវចូលទៅនៅក្នុងគុក...ការឈឺចាប់ក្នុងចិត្តបានកើតឡើងដល់សមយ៉ាងខ្លាំង ។ សមត្រូវធ្លាក់ខ្លួនទៅនៅក្នុងឥទ្ធិពលរបស់ថៅកែហុកហើយៗ សមសម្លឹងមើលទៅ ដូចជាគ្មានឃើញផ្លូវអ្វីនឹងគេចខ្លួនអោយរួចផុតពីអាជ្ញានេះបានឡើយ ។

អ្នកបំរើរបស់ថៅកែហុកពនាក់ បានដើរចូលមកក្នុងបន្ទប់យ៉ាងរូសរាន់ ។ ថៅកែហុកសប្បាយចិត្តជាខ្លាំង ។

" នែវ៉ី ! " ថៅកែហុកបាននិយាយឡើង " អានេះ វារុករានទន្ទ្រានទីចូលមកក្នុងផ្ទះយើងចាប់វាយកទៅអោយប៉ូលីសនៅ តែថាត្រូវបង្អន់វាបន្តិចសិន "

គ្រាន់តែផុតពាក្យរបស់ថៅកែហុកភ្លាម អ្នកបំរើទាំងពនាក់ ក៏ស្ទុះចូលមកចោមរោមចាប់សមដោយកំលាំងបាយតាមពាក្យបង្គាប់របស់ថៅហ្វាយនាយវា ។ ខណ:សមត្រូវតស៊ូការពារខ្លួនខ្លះៗ ។ សម្លេងតូតាងបានលាន់ឮឡើងពេញផ្ទះ ។ ធនបតីឈរញញឹមមើលការតស៊ូរវាងមនុស្សម្នាក់ និងមនុស្សបីនាក់ដោយការពេញចិត្ត ។ សមត្រូវគេធាក់ចំឆ្អឹងជំនីរដួលផ្ងារស្រទាងទៅលើឥដ្ឋ ។ ពេលនោះ ត្រូវគេចោមរោមទាត់ធាក់តាមចិត្តទាល់តែទ្រមនៅក្នុងបន្ទប់នោះ ។

" ល្មមហើយវ៉ី ! " ថៅកែស្រែកឃាត់ " នាំគ្នាសែងយកទៅអោយប៉ូលីសទៅ ហើយប្រាប់ប៉ូលីសថា ពួកឯងរាល់គ្នាបានឃើញអានេះវាលយចូលមកក្នុងផ្ទះ ពួកឯងក៏នាំគ្នាដេញចាំវា តែវាតដៃបានជាពួកឯងនាំគ្នាវាយវាវិញ - មើលគិតគូរនិយាយអោយត្រូវគ្នាទៅ "

គូលីរបស់ថៅកែហុកម្នាក់មានមាឌធំបង ដើរចូលមកជិតហើយក៏លើកជើងស្តាំឡើងធាក់សមមួយជើងទៀតធ្វើអោយរាងកាយសមផ្លាស់ពីផ្អៀងទៅជាដេកផ្កាប់មុខទៅវិញ។ ដោយសារភ្លើងអគ្គិសនីក្នុងបន្ទប់នោះ គេអាចមើលឃើញមុខមាត់របស់យ៉ាងច្បាស់ ។ ខាងក្រោមភ្នែកស្តាំមានសាច់ហើមប៉ោងឡើងយ៉ាងធំ មុខមាត់បែកចេញឈាមរហាម... អ្នកបំរើដៃឯករបស់ថៅកែហុក អោនទៅចាប់កន្ត្រាក់សក់ក្បាលសមអោយក្រោកឈរឡើង ។ ជើងទាំងពីររបស់សមទន់ល្វន់ល្វតស្ទើរតែគ្មានកំលាំងកំហែងល្មមនឹងទប់ដងខ្លួនអោយឈរនៅនឹងមួយកន្លែងជាប់ ។

កម្មករអភ័ព្វដកដង្ហើមស្ទើរតែមិនដល់គ្នា តែភ្នែកនៅតែបើកឡើងក្រឡេតសំលឹងមើលមុខថៅកែហុក ។

អ្នកបំរើជំនិតរបស់ថៅកែហុកម្នាក់ទៀតសើចឡើងទាំងឃ្នាន់ខ្នាញ់ យកដៃឆ្វេងកន្ត្រាក់អាវរបស់សម ហើយដាល់ថៃមដោយដៃស្តាំពេញទំហឹង ធ្វើអោយសមទ្រេតតះៗ ថយទៅក្រោយប៉ះ

នឹងជញ្ជាំង ។ ម្នាក់ទៀត ស្ទុះភ្លែតទៅធាក់ថែមមួយជើងទៀតអោយសមចុកពោះស្រុញខ្លួនដួលនៅចំពោះមុខថៅកែហុក ដែលកំពុងតែសើចដោយមានជ័យជំនះ សមត្រូវគេចាប់ចងបញ្ជូនខ្លួនយកទៅប្រគល់អោយប៉ូលីស ហើយតមកក៏ត្រូវប៉ូលីសនាំខ្លួនយកទៅផ្ញើទុកនៅគុកធំជាបណ្ដោះអាសន្ន ។

មិនយូរប៉ុន្មាន សមក៏ត្រូវគេបញ្ជូនខ្លួនយកទៅកាត់ទោសនៅសាលាដំបូង ហើយក៏ប្រាកដថាតុលាការបានកាត់ទោសដាក់គុកសមចំនួន ៣ ខែ ។

ឆ្ឆឆ

## ភាគទី ៦ មហាទុក្ខក្នុងគុកធំ

ថ្ងៃអាទិត្យ ជាថ្ងៃដែលរាជការអនុញ្ញាតអោយក្រុមគ្រួសារចូលទៅជួបនឹងអ្នកទោសបាន...

នាងសយបានកាន់នំមួយកញ្ចប់ចូលទៅសុំអនុញ្ញាតជួបនឹងប្ដីរបស់នាងជាមួយនឹងនាងមុំ ។ នាងយំខ្សឹបខ្សួលជាខ្លាំង នៅពេលដែលភ្នាក់ងារគុកបានបញ្ចេញសមអោយមកជួបនឹងនាង ព្រោះនាងនឹកអាណិតប្ដីនាង ដែលបានទទួលនូវគ្រោះអាក្រក់ដោយសារនាយទុនចិត្តចោរ...

" បង ! បងជាប់គុកជាប់ច្រវាក់ព្រោះរូបអូន " នាងសយនិយាយឡើងទាំងទឹកភ្នែក ខ្ញុំបានឃាត់បងហើយថា កុំចងគុំនំគុំគួនអីនឹងគេ ព្រោះគេជាអ្នកមាននេះទោះជាគេមិនចោទបងថា បងចងសម្លាប់គេ កុំអីបងជាប់គុកយ៉ាងតិចក៏១០ឆ្នាំដែរ ។

" ណ្ហើយអូន ! " សមនិយាយឡើងព្រមទាំងសម្លឹងមើលមុខប្រពន្ធដោយសេចក្ដីអាល័យ

" ឥឡូវវាហួសទៅហើយ ! មិនអីទេ បងទ្រាំតាមកម្មទៅចុះ ! ៣ខែមិនជាយូរប៉ុន្មានទេ " សមបែរមុខទៅរកមុំហើយនិយាយផ្ដាំផ្ញើ " បងមុំ ! សុំបងមើលប្រពន្ធខ្ញុំផង ខ្ញុំគ្មានអ្នកណាទុកចិត្តដូចរូបបងទេ... "

" មិនអីទេសម ! " មុំឆ្លើយឡើងទាំងអាណិតអាសូរ

" អោយសយវានៅជាមួយនឹងគ្នាចុះ ចាំគ្នាមើលការខុសត្រូវអោយ "

សមនឹកត្រេកអរចំពោះទឹកចិត្តដ៏សប្បុរសរបស់មីុយ៉ាងក្រៃលែង ។

" បងមីុ ! បងឯងមានគុណលើរូបខ្ញុំច្រើនណាស់ " សមឆ្លើយឡើងពេលខ្ញុំលំបាកយ៉ាងម៉េច បងឯងមិនចោលខ្ញុំដែរ ខ្ញុំនឹងមិនភ្លេចគុណបងឯងទេបង ។

ខណៈនោះនាងសយក៏ហុចកញ្ចប់នំអោយប្តី ។ មុនពេលដែលអ្នកទាំងបីនិយាយគ្នាថាអ្វីតទៅទៀត ភ្នាក់ងារអនុរក្សម្នាក់ដើរចូលមកជិតហើយស្រែកប្រាប់ថា

" ប៉ុណ្ណឹងហើយ ! និយាយគ្នាប៉ុណ្ណឹងបានហើយ "

សមក្រោកឈរឡើងហើយនិយាយលាប្រពន្ធ និង មីុថា ៖

" លាហើយអូន ! លាហើយបងមីុ ! "

សមដើរចូលទៅក្នុងទ្វារគុកវិញ ។ នាងសយស្រក់ទឹកភ្នែកច្រោកៗ ព្រោះនាងនឹកអាណិត និង អាឡោះអាល័យប្តី...មីុសម្លឹងមើលតាមសមទាល់តែផុតកន្ទុយភ្នែកហាក់ដូចជាភ្លេចខ្លួន...

" ទៅសយ ! ត្រឡប់ទៅផ្ទះវិញ ! " មីុនិយាយទៅកាន់នាងសយ " ណ្ហើយកុំយំសោកធ្វើអី ៣ខែវាមិនយូរប៉ុន្មានទេ "

ពួកអ្នកទោសបានចូលទៅក្នុងគុកវិញអស់ហើយ ។ មីុបាននាំនាងសយត្រឡប់ទៅផ្ទះវិញទាំងក្រៀមក្រំ...

ចាប់តាំងពីវិនាទីដំបូងដែលសមបានចូលទៅក្នុងគុក ហើយនៅក្នុងការឃុំគ្រងរបស់ភ្នាក់ងារអនុរក្សនៃពន្ធនាគារនោះ សមបានយល់ឃើញថានៅក្នុងគុកនេះមានសភាពមិនខុសពីនរកតាមដែលចាស់ៗ ធ្លាប់បាននិយាយនោះឡើយ ។

សមត្រូវគេនាំខ្លួនចូលទៅក្នុងល្វែងនៃបន្ទប់មួយផ្សេងពីបន្ទប់ដែលសមនៅពីម្សិលម៉្ងៃ ។ ក្នុងបន្ទប់ថ្មីនេះមានអ្នកទោសជាច្រើនប្រជៀតគ្នាអង្គុយ និងដេក ។ អាកាសអាប់អួរធុំក្លិនស្អុយឆ្អេះឆ្អាបលាមក និង ញើសនៃពួកអ្នកទោសដែលម្នាក់ៗ សុទ្ធតែមានមុខគួរអោយខ្លាច ជាអាជ្ញាករដែលធ្លាប់

ជាប់គុកមួយខ្លួនៗ រាប់ដងមិនឈ្នះ។ភ្នាក់អនុរក្សប្រានក្បាលសមបញ្ចូលទៅក្នុងបន្ទប់នោះហើយចាក់សោរជាប់ ។

សមពិនិត្យមើលឃើញពួកអ្នកទោសទាំងអស់នោះសម្លឹងមើលមុខខ្លួនរហប ហើយមានអ្នកទោសម្នាក់នោះស្លៀកពាក់ខោអាវស្រួលបួលដូចជាអ្នកគ្មានទោស មានបែបភាពដូចជាអ្នកមាន ។ អ្នកទោសនេះសម្លឹងមើលមុខសម ហើយក៏និយាយឡើងដោយការមិនពេញចិត្ត ។ " ងាប់ហើយវើយ ! បន្ទប់ចង្អៀតណែនប៉ុណ្ណឹងទៅហើយបន្ថែមអានេះម្នាក់មកធ្វើអីទៀត បានកន្លែងឯណាដេក ? "

អ្នកទោសទាំងអស់គ្នាបែរមកមើលអ្នកនិយាយដោយបែបគោរព ។ អ្នកនិយាយនេះឈ្មោះហួ ។ បុរសនេះត្រូវតុលាការកាត់ទោសជាប់គុក ៣ ខែដែរ ក្នុងបទបើកល្បែងស៊ីសង ។ អ្នកទោសទាំងអស់គ្នាហៅបុរសនេះថា ហ៊ាហ៊ួៗ ។ ការជាប់គុករបស់បុរសនេះ វាគ្រាន់តែធ្វើអោយបុរសនេះគ្មានឥស្សរភាព ក្នុងការដើរចេញទៅខាងក្រៅបរិវេណនៃគុកតែប៉ុណ្ណោះ ។ ហួរស់នៅយ៉ាងស្រួលក្នុងគុក គឺមានកន្លែងដេកស្រួល មានមុងមានភួយដណ្តប់ មានអាហារបរិភោគឆ្ងាញ់ៗ ។ ពួកអ្នកទោសក្នុងបន្ទប់នេះតែងផ្លាស់គ្នាបម្រើយកចិត្តយកថ្លើមហួជានិច្ច ។ ពួកភ្នាក់ងារអនុរក្ស ក៏កោតក្រែងចិត្តហួណាស់ដែរ ហើយអោយសិទ្ធិពិសេសដល់ហួស្ទើរតែគ្រប់យ៉ាង ។ ហួដេកតែនៅក្នុងបន្ទប់ដោយមិនបាច់ធ្វើការអ្វី ។ ការទាំងនេះក៏ដោយសារអំណាចទឹកប្រាក់របស់ហួនុះឯង...

អ្នកទោសម្នាក់ពោលឡើងជាបែបប្រចុបប្រចៃងថា ៖

« មិនអីទេហ៊ា អោយវាដេកខាងចុងជើងជិតធុងក៏បាន » វាសំដៅយកធុងលាមក និង មូត្រដែលគេដាក់នៅចុងជើង « បើវាហ៊ានដណ្តើមកន្លែងហ៊ា ទុកភារៈអោយខ្ញុំចាត់ការជូន »

សមដឹងថា ពួកអ្នកទោសនៅក្នុងបន្ទប់នេះទាំងអស់សុទ្ធតែធ្លាក់ខ្លួនទៅជាខ្ញុំកំដរនៃអំណាចទឹកប្រាក់របស់បុរសកូនចៅចិនឈ្មោះហួនេះជាពិតប្រាកដ ។ ពិតណាស់ជួនកាល វាអាចមានរឿងរ៉ាវធំដុំរវាងខ្លួនគេ និងពួកអ្នកទោសទាំងនោះ ។

សមមិនរវល់អើពើនឹងអ្នកណាទាំងអស់...សមដើរទៅអង្គុយលើកន្លែងមួយដែលនៅមិនឆ្ងាយប៉ុន្មានពីកន្លែងរបស់បុរសឈ្មោះហួនេះ

ខណ:ហួក៏ស្រែកឡើងភ្លាមថា ៖

« នែអានេះ ! ទៅខាងណោះទៅ កុំមកជិតអញ-នុះហ្ន៎ ! នៅខាងណោះមានកន្លែងទំនេរល្មមអាឯងដេកបាន »

សមញញឹមហើយឆ្លើយឡើងយ៉ាងសុភាព

« ដេកយ៉ាងម៉េចកើត បើនៅជិតធុងអាចម៍អញ្ចឹង »

អ្នកទោសរាងធំដំបងម្នាក់ឈ្មោះសួសជាកាប៉ូរ៉ាល់ ស្ទុះចូលមកយកដៃឆ្វេងចាប់អាវសមកន្ត្រាក់ ហើយនិយាយឡើង ដោយពាក្យសំដីហាក់ដូចជាធ្លាប់មានរឿងចងកម្មចងពៀរ នឹងគ្នាពីថ្ងៃម្សិលម៉ិញ

" អាឯងជាអ្នកលេងឬ ? "

" ទេ ! " សមឆ្លើយឡើងដោយការខំអត់សង្កត់ចិត្ត

" គ្នាមិនមែនជាអ្នកលេងទេ "

" បើអញ្ចឹងទៅ ! ទៅខាងណោះទៅ កុំមករុកគួនហ៊ា "

" យើងអាចនៅត្រង់ណាក្នុងបន្ទប់នេះ " សមនិយាយទាំងញញឹម

" ព្រោះយើងទាំងអស់គ្នានេះសុទ្ធតែជាអ្នកទោសដូចគ្នា "

" យីអាឯងនិយាយឡូយអញ្ចឹង មានតែអាឯងជាអ្នកលេងធំ...អាឯងនៅឯណាមិនស្គាល់អញ ?... "

កាលបើត្រូវគេមើលងាយសង្កត់សង្កិនដូច្នោះ សមខឹងឡើងមុខក្រហម ។ សមស្ទុះក្រោកឈរឡើងផ្អែកខ្នងនឹងជញ្ជាំងហើយលើកដៃចង្អុល មុខអ្នកទោសមាឌធំដំបងឈ្មោះសួសដែលចេញខ្លួនមកជំនួសហ្វូនោះ

" អាឯងក៏ជាអ្នកទោសដូចអញដែរ អាឯងគួរតែឃើញចិត្តឃើញថ្លើមអញខ្លះផងតែនេះអាឯងបែរជាបណ្តោយខ្លួនអោយធ្លាក់ទៅជាខ្ញុំរបស់អាអ្នកទោសម្នាក់នោះទៅវិញ ។ អាក្លើអើយ ! គិតដល់មិត្តភក្តិអ្នកទោសផងខ្លះទៅ មនុស្សដូចអញនេះមិនមែនជាអ្នកលេងទេ តែថា អញក៏ជាកូនប្រុស

ម្នាក់ដូចអាឯងដែរ បើអាឯងចង់ល្បងមើល ក៏សុំអោយអាឯងចូលមក អញបានប្រុងប្រៀបខ្លួនប្រាណចាំទទួលអាឯងរួចជាស្រេចហើយ អាក្លើ... ” នាយហ្វូខឹងទាល់តែញ័រអស់ទាំងខ្លួនប្រាណហើយស្រែកឡើងថា ៖

“ ពួកវ៉ីពួកយើង ! ទុកវាធ្វើអ្វី អានេះបែបឡូយសម្បើមណាស់ ពួយវាទៅ ! អញអោយរង្វាន់ឯងម្នាក់បារី ៥ ដើម ហើយបើមានរឿងរ៉ាវអីស្រេចនៅលើអញ ”

ពាក្យថា ម្នាក់បារី ៥ ដើមនេះ បានធ្វើអោយអ្នកទោសប្រហែល ១០ នាក់នាំគ្នាស្ទុះក្រោកឡើងដែលមើលទៅដូចជាថា សមជាសត្រូវស៊ីសាច់ហុតឈាមរបស់ពួកវា ។

អ្នកទោសម្នាក់ស្ទុះចូលមកដាល់តម្រង់ចំមុខសម តែសមគេចផុត ។ ដៃរបស់វាក៏ត្រូវជញ្ជាំងឮសូរបុាំង ហើយសមក៏ដាល់ស្របទៅវិញត្រូវចំចង្កា ធ្វើអោយវាដួលប្រូស ។ អ្នកទោស ៨-៩ នាក់ទៀតដែលក្នុងខណៈនោះមិនទាន់បានចូលប្រឡូកនៅឡើយ ក៏ចូលមកចោមរោមក្រញីសម ។ នាយហ្វូឈរច្រត់ចង្កេះមើលដោយការពេញចិត្ត ។

“ ពួយវ៉ី ! ពួកយើង ! ” នាយហ្វូស្រែកបង្គាប់ “ ពួយអោយអស់ដៃទៅ អានេះពូកែណាស់... ”

សម្លេងប៉ុងបាំងបានលាន់ឮឡើងពេញបន្ទប់ ។ សមខំមានះខាំធ្មេញតស៊ូដោយទឹកចិត្តរបស់កូនប្រុស ។ សមគិតថា ស៊ូស្លាប់ល្អជាងបណ្តោយអោយឆ្កែជារបស់នាយទុនកំហែងកំហាល់មើលងាយចោមរោមខាំខ្លួន ។ សមឈរទល់ខ្នងនឹងជញ្ជាំងដាល់ផងធាក់ផងធ្វើអោយ ពួកអ្នកទោសទាំងនោះដួលបាន ២-៣ នាក់ ។

តែខណៈនោះ ស្រាប់តែមានជើងរបស់អ្នកទោសណាម្នាក់ បានធាក់ចំចុងដង្ហើមរបស់សមពេញទំហឹង ធ្វើអោយសមដួលដេកទៅលើឥដ្ឋ ។

“ ថៃមវ៉ីថៃម ! ” នាយហ្វូស្រែកបញ្ជា

ជើងជាច្រើនបានធាក់ទន្ទ្រាំមកលើរាងកាយរបស់សម ។

ពេលនោះ ភ្នាក់ងារអនុរក្ស ២ នាក់បានរត់ចូលមកមើលឃើញហើយស្រែកឃាត់ថា ៖

“ ឈប់ ! ឈប់ ! ស្អីហ្នឹង ”

សម្លេងអនុរក្ស ក៏បានបញ្ឈប់នូវទារុណកម្មរបស់ពួកអ្នកទោសចិត្តទមិឡអន្យត្តិរីយទាំងនោះ ។ សមបានរើខ្លួនរួចពីការគ្រាំគ្រាខ្លួន ។ ភ្នាក់ងារអនុរក្សបានចាក់សោរទ្វារចូលរកមើលហេតុការណ៍ ។

" រឿងរ៉ាវអីហ៎ា ? " ភ្នាក់ងារអនុរក្សម្នាក់ដែលកាន់រំពាត់ក្តគោមួយប៉ុនមេជើងនៅដៃស្តាំសួរឡើង រឿងរ៉ាវយ៉ាងម៉េច ?

នាយហ្វូឆ្លើយឡើងភ្លាម

" អាស្អីគេនេះ គ្រាន់តែចូលមកភ្លាម ក៏ស្រាប់តែអាន់ជ្រីដើរទាត់ធាក់គេតាមចិត្ត-មើលចុះ ! វាធាក់ខ្ញុំមួយជើងដែរ បើលោកមិនជឿសួរអ្នកទាំងអស់គ្នានេះមើលចុះ "

" បាទលោក ! អញ្ចឹងមែន ! អានេះវាដើរទាត់ពួកខ្ញុំទាំងអស់គ្នា លេងម្នាក់មួយជើងតាមតែអំពើចិត្តវា " អ្នកទោសម្នាក់ឆ្លើយយោងនាយហ្វូ " ដល់វាមកទាត់ខ្ញុំ ខ្ញុំក៏ទ្រាំមិនបានដាក់វាមួយដៃចំកញ្ចប់មាត់វិញ ក៏ស្រាប់តែវាដាល់តបមកខ្ញុំយ៉ាងសម្បើមដៃតែម្តង ពួកខ្ញុំចូលមកឃាត់វា វាក៏ដាល់ទៀតលោកអញ្ជើញមើលចុះ មុខមាត់ខ្ញុំ និង ពួកខ្ញុំប៉ុន្មាននាក់ទៀតនេះសុទ្ធតែហើមថ្ពុរ

គ្រប់ៗគ្នា "

" អញ្ចឹងមែនលោក ! " អ្នកទោសឯទៀតនាំគ្នាបន្ថែមម្នាក់មួយម៉ាត់

" អាស្អីគេហ្នឹង បែបកោងសម្បើមដៃតែម្តងហើយទានប្រោស "

" នែអានេះ ! " ភ្នាក់ងារអនុរក្សដែលមានរំពាត់ក្តគោនៅដៃ យករំពាត់ក្តគោនោះគោះក្បាលសមហើយសួរ " ម៉េចក៏អាឯងធ្វើអញ្ចឹងហ៎ា ? "

" បាទលោក ! មិនមែនដូចពាក្យអ្នកអស់នេះប្តឹងមូលបង្កាច់នោះទេ " សមឆ្លើយឡើងតាមការពិត " តាមការពិត គឺពួកវាអស់នេះ ឃើញខ្ញុំបាទចូលមកថ្មីវាក៏នាំគ្នាធ្វើបាបខ្ញុំបាទដល់ឃើញខ្ញុំបាទមិនខ្លាច វាក៏ចោមរោមក្រញីខ្ញុំបាទតែម្តង "

" ទេវាដូចជាមិនទំនង " ភ្នាក់ងារអនុរក្សម្នាក់ទៀតនិយាយឡើង

" ចុះពីដើម ដែលពួកគេនៅយូរយារណាស់មកហើយ ម៉េចក៏មិនដែលឃើញមានរឿងរ៉ាវអី ? "

ក្នុងខណៈមួយរំពេចនោះ ភ្នាក់ងារអនុរក្សម្នាក់ទៀតក៏លើករំពាត់ក្ដគោឡើង ហើយវាត់ទៅលើខ្លួនសមពេញទំហឹង ដោយឥតមានមេត្តាត្រាប្រណីសោះឡើយ ។ រំពាត់ដ៏កំណាចនេះ បានស្រោចទៅលើរាងកាយរបស់សមស្ទើរតែដាច់ខ្យល់ស្លាប់ ។ មួយខ្លាប់ៗ វាឈឺរកប្រាប់មិនត្រូវ ។ អំណាចរំពាត់ក្ដគោ បានធ្វើអោយខ្នងសមបែកចេញឈាម ។ សមខំប្រឹងខាំធ្មេញអត់សង្កត់ដោយទឹកមុខគួរអោយអាណិត ។

មួយសន្ទុះក្រោយមក ទើបភ្នាក់ងារអនុរក្សដែលមាននាទីវាយនោះ ឈប់វាយ ហើយឈរសម្លឹងមើលសមដោយទឹកមុខគួរអោយខ្លាច ។ សមឆ្លៀតឱកាសនេះពោលឡើងថា ៖

" ខ្ញុំជឿហើយថា សេចក្ដីយុត្តិធម៌ក្នុងលោកនេះមិនមានសោះឡើយ ! លោកមិនបានជ្រាបនូវការពិត តែលោកកាត់ទោសបាទតាមពាក្យសាក្សីដែលគេនាំគ្នាទម្លាក់កំហុកមកលើរូបខ្ញុំបាទដោយអំណាចប្រាក់- កម្មករដូចខ្ញុំបាទមិនដឹងជាទៅអំពាវនាវស្រែកសុំនូវសេចក្ដីយុត្តិពីអ្នកណាទេក្រៅពីសុខចិត្តអោនក្បាលទទួលនូវគ្រោះកម្មតែប៉ុណ្ណោះ.... "

" អាឯងមិនចាំបាច់និយាយច្រើនទេ " ភ្នាក់ងារអនុរក្សគំហាក " អាឯងកុំភ្លេចថា សូម្បីតែនៅសាលា ក៏គេយកតាមចម្លើយរបស់សាក្សីជាសំខាន់ដែរ អាឯងគ្មានសាក្សីម្នាក់សោះ សាក្សីគេខាងណោះឆ្លើយត្រូវគ្នាទាំងអស "

ទឹកភ្នែករបស់សម ក៏ហូរធ្លាក់ចុះចាកគ្រាបកភ្នែកច្រោកៗ ។ ដំណក់នៃទឹកភ្នែកគ្រប់ៗ តំណក់នោះ កើតឡើងពីការខឹងតូចចិត្តចំពោះខ្លួន ដែលកើតមកមានជាតិកំណើតជាអ្នកក្រ ជា

កសិករ ហើយក្លាយខ្លួនទៅជាកម្មករ ដែលត្រូវគេប្រមាថមើលងាយសង្កត់សង្កិនជិះជាន់គ្រប់បែបគ្រប់យ៉ាង...។

**ភាគទី៧ គ្រោះថ្នាក់ចរាចរ**

បីខែបានកន្លងផុតទៅយ៉ាងយឺតយូរ... បីខែនៅក្នុងគុកធំនេះ សមបានទទួលនូវសេចក្ដីទុក្ខលំបាកស្ទើរតែពណ៌នាមិនបាន...

ទីបំផុតនៃថ្ងៃឥស្សរភាព ក៏បានត្រឡប់មកជារបស់សម កម្មករអភ័ព្វដែលគួរអោយអាណិតវិញ ។ សមបានរួចចាកទុក្ខទោសហើយ ។ សាលាដំបងបានចេញដីកាបង្គាប់អោយដោះលែងសមនៅក្នុងពេលព្រឹកនៃថ្ងៃអង្គារ ។

ពីយប់មិញនេះ សមដេកមិនលក់សោះ...សមនឹកត្រេកអរក្នុងការដែលត្រូវបានចេញទៅជួបនឹងពន្លឺខាងក្រៅគុក-នឹកត្រេកអរក្នុងការដែលត្រូវបានចេញទៅជួបនឹងប្រពន្ធកំសត់...

នៅពេលម៉ោង ៨ព្រឹក លោកភូឈ្លយគុកបានហៅសមអោយចូលទៅជួបនៅបន្ទប់ធ្វើការរបស់លោក ហើយលោកអោយឱវាទថា ៖

" សម ! ឯងដល់ពេលត្រូវរួចខ្លួនហើយ ឯងត្រូវតាំងចិត្តថ្លើមអោយល្អណ៎ា កុំត្រឡប់មកអោយខ្ញុំឃើញមុខទៀត ខ្ញុំសុំអោយពរស័ព្ទសាធុការឯង សុំអោយឯងបានប្រកបដោយជោគជ័យសិរីមង្គលគ្រប់ប្រការ-ទៅចុះសម-ទៅចុះសម ! កូនប្រពន្ធឯងដែលនៅរង់ចាំឯងឯផ្ទះកំពុងមើលផ្លូវចាំទទួលឯងដោយការរីករាយ "

សមលើកដៃសំពះលាលោកភូឈ្លយ ហើយក៏ដើរចេញពីបន្ទប់នោះទៅព្រមដោយលិខិតសំគាល់ខ្លួនបណ្ដោះអាសន្ន។ សមមានទឹកចិត្តរីករាយជាខ្លាំង។ ក្នុងខណ:ដែលឈានជើងចេញផុតពីទ្វារគុកធំមក សមក៏ដឹងខ្លួនថា ខ្លួនបានទទួលនូវឥស្សរភាពវិញហើយ។

សម្លេងដ៏ស្រួយឆ្នារបស់ស្រីម្នាក់ បានលាន់ឮឡើង

" បង ! បង ! "

សមភ្ញាក់ព្រើតហើយងាកទៅខាងស្ដាំភ្លាម។ សេចក្ដីត្រេកអរយ៉ាងលើសលប់បានកើតឡើងដល់សម នៅពេលដែលសមក្រឡេកមើលទៅឃើញនាងសយប្រពន្ធកំសត់រត់ចូលមក ដោយសេច

ក្តីរីករាយ។ អ្នកទាំងពីរសម្លឹងមើលមុខគ្នាទាំងទឹកភ្នែក ព្រោះសេចក្តីត្រេកអរដែលលាយទៅដោយសេចក្តីទុក្ខសោក។

" បង ! " នាងសយនិយាយឡើង " ខ្ញុំមកចាំទទួលបង មកជាមួយបងមុី នុះហ្ន៎ ! បងមុីចតស៊ីក្លូនៅឯណោះ "

" សមចោលភ្នែកក្រឡេកមើលទៅ ឃើញមុីឈរនៅជិតត្រីចក្រយាន កំពុងលើកដៃបក់ជាសញ្ញាស្រែកហៅដោយទឹកមុខញញឹម សំដែងនូវសេចក្តីអបអរសាទរក្នុងដែលសមបានទទួលនូវឥស្សរភាពនេះ។ សមងាកមុខមករកប្រពន្ធវិញ ហើយនិយាយថា ៖ " សយអូន ! កម្មពៀរបស់បងបានអស់ត្រឹមប៉ុណ្ណោះហើយ - ទៅអូន ! ទៅអោយផុតពីទីនេះអោយឆាប់ បងមិនចង់ឃើញទីនេះទៀតទេ "

និយាយចប់ សមក៏ទាញដៃប្រពន្ធដើរសំដៅទៅរកមុី។ មិត្តភក្តិកម្មករទាំងពីរក៏ស្ទុះទៅចាប់ដៃគ្នាហើយញញឹមដាក់គ្នា។

" សម ! " មុីចាប់ផ្តើមនិយាយឡើង " គ្នាមានសេចក្តីត្រេកអរណាស់ក្នុងការដែលឯងបានរួចចាកទោសនេះ ឯងត្រូវតាំជីវិតសាជាថ្មីតាំងពីឥឡូវនេះទៅឯងមិនបាច់ព្រួយទេ គ្នាបានទៅសួររកជួលស៊ីក្លូទុកអោយឯងរួចហើយ ម្ចាស់ស៊ីក្លូនោះគេចិត្តល្អណាស់ "

ភ្នែករបស់សមរលីងរលោងដោយទឹកភ្នែក

" បងមុី ! " សមនិយាយឡើង " បងឯងមានគុណលើរូបខ្ញុំ និង ប្រពន្ធខ្ញុំច្រើនណាស់ គុណច្រើនទាល់តែខ្ញុំមិនអាចនឹងបំភ្លេចចោលបានក្នុងមួយជាតិនេះ "

" រឿងគុណនោះ កំបាច់និយាយធ្វើអី " មុីឆ្លើយឡើង " គ្នាធ្លាប់បានប្រាប់ឯងហើយថា យើងជាមិត្តភក្តិនឹងគ្នា កាលបើម្នាក់មានទុក្ខ យើងត្រូវតែជួយគ្នាតាមកំលាំងដែលយើងអាចជួយទៅបាន - ទៅ ! ឡើងជិះស៊ីក្លូទៅ គ្នាធាក់ស៊ីក្លូជូនឯងទៅផ្ទះ "

" ទេបង ! " សមឆ្លើយឡើង " បងឯងជិះជាមួយនឹងសយចុះ ទុកអោយខ្ញុំធាក់វិញ ខ្ញុំខានធាក់ស៊ីក្លូបីខែមកហើយ ទុកអោយខ្ញុំម្តង "

ម៉ីគ្រវីក្បាលហើយឃាត់ភ្លាម

៉ កុំ ! កុំអីសម ! ឯងកំពុងតែត្រេកអរនឹងឥស្សរភាពរបស់ឯង ស្រួលមិនស្រួលតិចទៅបុកគេនាំអោយមានរឿងរ៉ាវទៀត - ទៅ ! ទុកអោយគ្នាធាក់វិញស្រួលជាង ៉

សមញញឹមដាក់ម៉ី ហើយនាំប្រពន្ធឡើងជិះត្រីចក្រយាន។ ម៉ីបានធាក់ត្រីចក្រយានជូនសម និង នាងសយធ្វើដំណើរត្រឡប់ទៅផ្ទះដែលឋិតនៅជិតវត្តមហាមន្ត្រី។

ព្រឹកស្អែកឡើង ម៉ីបាននាំសមទៅជួបនឹងម្ចាស់ត្រីចក្រយាន។ សេដ្ឋីនីមេម៉ាយនេះមានអាយុប្រហែលជា ៥០ ឆ្នាំ មានត្រីចក្រយានប្រហែល ៣០។ ក្នុងខណៈដែលម៉ីនាំសមទៅជួបនោះ យាយកានក៏បានសំដែងនូវសេចក្តីស្តាយថា ត្រីចក្រយានរបស់គាត់មានគេជួលអស់ហើយ។ សមស្ទើរតែអស់សង្ឃឹម តែលុះអង្គុយនិយាយមួយសន្ទុះទៅយាយកានក៏បានសាកសួរដល់រឿងផ្ទាល់ខ្លួនរបស់សម។ សមបានបរិយាយដល់គ្រោះថ្នាក់របស់ខ្លួន អោយយាយកានស្តាប់ដោយសព្វគ្រប់ ហើយយាយកានក៏មានចិត្តអាណិតអាសូរសមជាខ្លាំង។

៉ ខ្ញុំអាណិងឯង និង ប្រពន្ធឯងណាស់ ៉ យាយកាននិយាយដោយសុទ្ធចិត្ត

៉ គ្រោះថ្នាក់របស់ឯងនេះ កើតឡើងពីអ្នកមានតែថា ឯងកុំគិតថា អ្នកមានសុទ្ធតែមានចិត្តអាក្រក់ដូចគ្នាទាំងអស់នោះមិនមែនទេ មានអ្នកខ្លះ ដែលគេឃើញចិត្ត ឃើញថ្លើមអ្នកក្រខ្លះដែល ខ្ញុំមិនមែននិយាយលើកខ្លួនទេ ខ្លួនខ្ញុំនេះបើទុកជាបានយ៉ាងណា ខ្ញុំក៏នៅតែអាណិតអាសូរអ្នកក្រជានិច្ច ការនេះម៉ីក៏ដឹងស្រាប់ហើយ ខ្ញុំយកថ្លៃស៊ីក្លូថោកណាស់ ខ្ញុំយកតែ ២៥ រៀលប៉ុណ្ណោះក្នុងមួយថ្ងៃមួយយប់ ហើយជួនណាបើរកប្រាក់យកមកបង់ថ្លៃមិនបាន ខ្ញុំក៏អោយជំពាក់ខ្លះទៀត ហើយម្យ៉ាងទៀត ខ្ញុំមិនដែលយកប្រាក់កក់ទេ ៉

សមលើកដៃសំពះយាយកានដោយសេចក្តីគោរព ចំពោះការអាណិតអាសូររបស់គាត់ដល់ពួកកម្មករត្រីចក្រយាន។

៉ លោកយាយ ! ៉ សមនិយាយឡើង ៉ ខ្ញុំសុំបួងសួងអោយលោកយាយបានប្រកបដោយសេចក្តីសុខ-ចំរើនតរៀងទៅ ហើយបើអ្នកមានៗគេចេះអាណិងអាសូរដល់អ្នកក្រដូចលោកយាយអញ្ចឹងពួកអ្នកក្រមុខជានឹងបានធូរស្រាលគ្រាន់បើជាមិនខាន ៉

ទីបំផុតយាយកានក៏បាននិយាយថា " ណ្ហើយចុះ ! ខ្ញុំនឹងជួយរកស៊ីក្លូអោយឯងធាក់-ពីរបីថ្ងៃទៀតចាំមករកខ្ញុំ ខ្ញុំហ៊ានធានាថា ឯងមុខជាបានធូរស្រាលគ្រាន់បើជាមិនខាន "

មុីបាននាំសមត្រឡប់ទៅផ្ទះវិញដោយសេចក្តីរីករាយក្នុងចិត្តឥតឧបមា។ សមគិតថា ខ្លួនឯងនឹងបានត្រីចក្រយានធាក់ជាមិនខាន ដោយសារការជួយជ្រោមជ្រែងរបស់សេដ្ឋីនីដែលមានសេចក្តីអាណិតអាសូរដល់អ្នកក្រីក្រនេះ។

នៅពេលព្រលប់នៃថ្ងៃសុក្រ...ភ្លៀងកំពុងតែរលឹមស្រិចៗ។ សមកំពុងធាក់ត្រីចក្រយានទៅតាមវិថីដេសបូស ដើម្បីត្រលប់ទៅផ្ទះវិញ ក្រោយពេលដែលបានដឹកអ្នកជិះម្នាក់យកទៅដាក់នៅពេាងភាពយន្តអេដែន។

រថយន្តប៉ឺហ្សូពណ៌ខ្មៅមួយ បើកមកពីក្រោយសមយ៉ាងលឿន។ អ្នកបើកបរជាស្រី ហើយមានបុរសម្នាក់អង្គុយជិតនាង។ នាងទើបតែនឹងរៀនបើកបរថ្មីៗ ដោយមានគូសង្សារនាងជាអ្នកបង្រៀន។

ពេលនោះរថយន្តព្លីមុតមួយក៏បានបើកបរយ៉ាងលឿនមកពីខាងមុខសមដែរ។ ស្រីដែលកំពុងបើកបររថយន្តប៉ឺហ្សូនោះគិតថា ប្រជែងត្រីចក្រយានរបស់សមហើយសឹមជៀសគ្នានឹងរថយន្តព្លីមុតដែលមកពីខាងមុខនោះ តែរថយន្តព្លីមុតបានមកដល់ទន្ទឹមនឹងត្រីចក្រយានរបស់សមមុន។ ដូច្នេះរថយន្តប៉ឺហ្សូដែលមានកញ្ញាបើកបរមិនទាន់ស្ទាត់ជំនាញខ្លាចក្រែងបុកគ្នានឹងរថយន្តព្លីមុតក៏ទាញចង្កូតមកខាងស្តាំតែថា រថយន្តវាជ្រុលទៅហើយៗបាំងភក់ខាងក្រោយទៅនឹងបាំងភក់ត្រីចក្រយានខាងឆ្វេងរបស់សមយ៉ាងពេញទំហឹង ដែលមានសភាពមិនខុសគ្នាពីដុំថ្មទង្គិចនឹងពងមាន់។

" គ្រាំង ! "

ត្រីចក្រយានក្រឡាប់...សមខ្ទាតចេញពីកែបត្រីចក្រយាន ទៅដួលផ្កាប់មុខនៅលើថ្នល់។ កញ្ញាជាអ្នកបើកបររថយន្ត មានសេចក្តីភិតភ័យជាខ្លាំង។ នាងបន្ថយល្បឿនដោយការទប់ហ្វ្រាំង តែគូរសង្សាររបស់នាងក៏និយាយឡើងប្រញាប់ថា ៖

" ទៅ ! លឿនឡើង ! កុំឈប់ "

រថយន្តប៊ីហ្សូពណ៌ខ្មៅ បានស្ទុះទៅមុខយ៉ាងលឿនដូចកូនសេះ ហើយបត់ទៅខាងឆ្វេង ដោយឥតមាននឹករវីរវល់នឹងការស្លាប់របស់កម្មករត្រីចក្រយាន ដែលគួរអោយអាណិតនេះសោះឡើយ ហើយក៏គ្មានអ្នកណាចាំលេខរថយន្តនេះបានផង។

សមដេកស្តូកស្តឹង សន្លប់បាត់ស្មារតីនៅកណ្តាលថ្នល់ក្រោមតំណក់ទឹកភ្លៀងដោយមានក្បាល និងដៃជើងបែកចេញឈាម។ ប្រជាជនបាននាំគ្នារត់មកមើលសមហើយនិយាយអ៊ូអែគ្មានបានការអ្វី។

ក្នុងខណៈមួយដ៏ស្ងុះស្ងាប់ ជាទីជំរករបស់គ្រួសារម៉ី មានពន្លឺចង្កៀងប្រេងភ្លឺព្រឹមៗ។ ម៉ី និងប្រពន្ធព្រមទាំងនាងសយកំពុងតែនិយាយគ្នាពីសម ដែលធាក់ត្រីចក្រយានចេញទៅរកប្រាក់តាំងពីថ្ងៃរសៀលរហូតមកដល់ពេលថ្មើនេះនៅមិនទាន់ត្រឡប់មកផ្ទះវិញ។ អ្នកទាំងបីនាក់ចិត្តជាខ្លាំងក្រែងលោសមមានគ្រោះថ្នាក់ដោយត្រូវរថយន្តបុក ឬប៉ូលីសចាប់ជាដើម។

ម៉ោង ២៤ហើយ...កូនក្មេងដេកលក់អស់ហើយ។ ពួកអ្នកផ្ទះជិតខាងក៏ដេកស្ងៀមស្ងាត់គ្មានឮសូរសម្លេងអ្វី។ ភ្លៀងរលឹមស្រិចៗ អាកាសត្រជាក់...ទ្វារខ្ទមរបស់ម៉ីនៅបើកចំហនៅឡើយ។ អ្នកទាំងអស់គ្នា ចេះតែសម្លឹងរំពៃមើលទៅខាងក្រៅរឿយៗ។ ជាពិសេសនាងសមរំពៃមើលញឹកជាងគេ ព្រោះនាងព្រួយបារម្ភជាងគេ ហើយរួរៗនាងដើរចេញទៅមើលត្រង់មាត់ទ្វារម្តង។

តាមធម្មតា សមមិនដែលត្រឡប់មកផ្ទះវិញហួសពីម៉ោង ២២ ទេ ព្រោះសមមិនដែលទៅលេងឯណា ឬទៅរកអ្នកណាសោះឡើយ។ កុន ឬល្ខោនសមមិនដែលមើលដែរ។ កាលបើដូច្នេះ វាជាការធម្មតា ដែលអ្នកផ្ទះត្រូវតែព្រួយបារម្ភ។

" ទេ ! សមមិនដែលទៅណាមកណាទេ " ម៉ីនិយាយឡើង

" ថ្មើរនេះ វាគួរតែត្រឡប់មកផ្ទះវិញហើយ ព្រោះពេលពាក់កណ្តាលអាធ្រាតទៅហើយ "

នាងសយមានទឹកមុខប្រកបដោយការភ័យព្រួយ។ នាងដកដង្ហើមវែងៗហើយពោលឡើងថា៖

" ខ្ញុំក្រែងតែបងសមមានគ្រោះថ្នាក់ទេបង "

នាងម៉ុមបានបន្ថែមឡើងថា ៖

" ខ្ញុំក៏អញ្ជឹងដែរសយ "

" ទេ ! កុំអាលគិតអញ្ជឹងសយ " ម៉ីនិយាយកាត់ឡើង " ជួនកាលមានអ្នកជិះគេជួលទៅឆ្ងាយៗ ឬក៏គេជួលជិះជាម៉ោងក៏មិនដឹង

នាងសយដកដង្ហើមវែងៗ ហើយនិយាយតទៅទៀតថា ៖

" វាចេះតែមានស្អីធ្វើអោយខ្ញុំគិតអញ្ជឹងណាបងម៉ីស្រុកឥឡូវទុកចិត្តមិនបានទេ "

" ទេសយ ! " ម៉ីឆ្លើយឡើង " សមធាក់ស៊ីក្លូគ្រាន់បើដែរ មិនមែនអោយឡានបុកផ្តេសផ្តាសទេ ឯងកុំអាលអន្ទះសារពេក ទ្រាំចាំមើលបន្តិចទៀតសិនមើល បើមិនឃើញវាមកចាំខ្ញុំធាក់ស៊ីក្លូចេញទៅតាមរកវា "

បានឮដូច្នេះ នាងសយមានទឹកមុខស្រស់គ្រាន់បើបន្តិច តែទឹកចិត្តរបស់នាងនៅតែព្រួយបារម្ភចំពោះប្តី ដែលមិនធ្លាប់ត្រឡប់មកផ្ទះវិញយឺតយ៉ាវយ៉ាងនេះ។

ម៉ោង ១នៃថ្ងៃថ្មីហើយ...សមនៅតែមិនទាន់ត្រឡប់មកផ្ទះវិញ។ អ្នកទាំងអស់គ្នាកំពុងតែអង្គុយជំនុំគ្នាដោយការភ័យព្រួយបារម្ភ។

" បងម៉ី ! " នាងសយនិយាយដោយការភ័យព្រួយ " សុំបងអាណិតចេញទៅតាមរកបន្តិចមើល ខ្ញុំព្រួយណាស់បង "

មុនពេលដែលម៉ីឆ្លើយថាអ្វី នាងម៉ុមជាប្រពន្ធក៏បាននិយាយបន្ថែមឡើងទៀតថា " គួរណាស់តែទៅតាមរកមើលមើល៍បង វាដូចជាប្លែកណាស់ ថ្មើរនឹងហើយម៉េចនៅតែមិនមកអញ្ជឹង - ទៅបង ! នាំសយជិះស៊ីក្លូទៅ "

ម៉ីសម្លឹងមុខប្រពន្ធហើយនិយាយឡើងថា ៖

" យើងគិតទៅរកវានៅឯណាហ្ន៎? "

" គួរតែទៅរកនៅមន្ទីរពេទ្យមុនគេបង ! " នាងម៉ុមបញ្ចេញយោបល់ឡើង

" បើសមមានគ្រោះថ្នាក់ ប៉ូលីស ឬអ្នកដែលបានប្រទះឃើញនូវហេតុការណ៍នោះមុខជានាំទៅមន្ទីរពេទ្យ បើរកឯមន្ទីរពេទ្យអត់ឃើញ ត្រូវទៅរកតាមប៉ុស្តិ៍ប៉ូលីស ក្រែងលោសមធាក់បុកគេ ឬក៏មានរឿងរ៉ាវឈ្លោះទាស់ទែងនឹងអ្នកណា ហើយប៉ូលីសចាប់យកទៅឃុំឃាំង "

ម៉ីងក់ក្បាលហើយនិយាយថា ៖

" ទៅ ! បើអញ្ចឹងទៅក៏ទៅ ! "

" ទៅបង ! " នាងសយពោលឡើងដោយការយល់ព្រម

ក្នុងពេលម៉ោងជាមួយគ្នានោះម៉ីបាននាំនាងសយទៅដល់មន្ទីរពេទ្យព្រះកេតុមាលា

ម៉ីចតត្រីចក្រយានទុកនៅខាងមុខក្លោងទ្វារ ហើយនាងដើរចូលទៅក្នុងមន្ទីរពេទ្យ។

ឆ្មាំទ្វារនៃមន្ទីរពេទ្យព្រះកេតុមាលាកំពុងតែអង្គុយនៅត្រង់តុមួយ។ ម៉ីលើកដៃសំពះឆ្មាំទ្វារ ហើយសួរថា ៖

" សុំទោសលោក ! លោកមានឃើញអ្នកស៊ីក្លូណាមានគ្រោះថ្នាក់ ហើយចូលមកពេទ្យ ឬទេ ទានប្រោស ? "

ឆ្មាំទ្វារអង្គុយមួយសន្ទុះ ហើយក៏ឆ្លើយថា ៖

" បាទមាន ! ពីម៉ោង ៧ កន្លះ មានប៉ូលីសខាងពេទ្យចិន បាននាំយកអ្នកស៊ីក្លូម្នាក់ដែលត្រូវឡានបុក ហើយមានរបួសជាទម្ងន់មកទីនេះ "

នាងសយធ្លាក់ថ្លើមក្តុក ហើយសួរឆ្មាំទ្វារយ៉ាងរួសរាន់តទៅទៀតថា

" សុំទោសលោក ! អ្នកនោះឈ្មោះអី ?"

" បាទមិនដឹងឈ្មោះអីទេ " ឆ្មាំទ្វារញញឹមហើយឆ្លើយឡើង

" ខ្ញុំមាននាទីគ្រាន់តែចាំយាមទ្វារប៉ុណ្ណោះ - អ៎ ! សុំចាំមួយភ្លែត ចាំខ្ញុំទៅសួរលានុប្បដ្ឋាកមើល "

អ្នកយាមទ្វារដើលចូលទៅក្នុងមួយសន្ទុះ ក៏ត្រឡប់មកវិញយ៉ាងរហ័សរហួនហើយប្រាប់នាងសយតាមការដែលខ្លួនបានដឹង

" អ្នករងគ្រោះនោះឈ្មោះសមអ្នក ! ត្រូវ ឬទេ ? ត្រូវជាស្អីនឹងអ្នក ? "

" ចាំសហ្នឹងហើយ ! ត្រូវជាប្ដីរបស់ខ្ញុំ "

នាងសមរំភើបចិត្តជាខ្លាំង ក្នុងកាលដែលដឹងថា ប្ដីរបស់នាងមានគ្រោះថ្នាក់។ ខណៈនោះ ទឹកភ្នែករបស់នាងក៏បានហូរធ្លាក់ចុះមកភ្លាម។ មីសួរឆ្មាំទ្វារយ៉ាងរួសរាន់ទៀតថា

" ខ្ញុំសុំចូលទៅមើលបានទេលោក ? ! លោកបានជ្រាបឬទេថា អ្នកជម្ងឺនោះវាយ៉ាងម៉េចទៅហើយ ? "

" បាទមិនដឹងជាយ៉ាងម៉េចដែរ " ឆ្មាំទ្វារឆ្លើយទាំងសេចក្ដីអាណិតអាសូរ

" តែឮគេថាធ្ងន់ណាស់ អញ្ជើញទៅរកសាលនោះទៅ ទៅជួបនឹងគ្រូពេទ្យសិន ហើយសុំលោកមើល ក្រែងលោកអនុញ្ញាតអោយចូលទៅមើលបាន "

មីបាននាំនាងសយដើរតម្រង់ទៅសាលដែលឆ្មាំបានចង្អុលបង្ហាញ។ ក្នុងខណៈជាមួយគ្នានេះ គ្រូពេទ្យប្រចាំវេននៃមន្ទីរពេទ្យព្រះកេតុមាលា កំពុងឈរនៅត្រង់មាត់ទ្វារដោយមានគិលានុប្បដ្ឋានម្នាក់ឈរនៅជិត។ មី និង នាងសយលើកដៃសំពះសំដែងសេចក្ដីគោរពចំពោះគ្រូពេទ្យ។

" ព្រះតេជគុណ ! " មីសួរគ្រូពេទ្យ " ខ្ញុំបាទសុំចូលមើលសមបន្តិចបានឬទេទានប្រោស ! "

គ្រូពេទ្យងើបមុខឡើងដោយការគិតមួយសន្ទុះ ហើយក៏សួរមកមីវិញថា

" សមណា? អ្នកធាក់ស៊ីក្លូហ្នឹងឬ ? "

" ចាំសហ្នឹងហើយ ! " នាងសយឆ្លើយឡើង " អ្នកយាមគេប្រាប់ថា ឡានបុកមានរបួសជាទម្ងន់ "

គ្រូពេទ្យដកដង្ហើមវែង ហើយនិយាយតិចៗថា

" អ្នកជម្ងឺកំពុងឋិតនៅក្នុងសេចក្តីអន្តរាយ ព្រោះត្រូវរបួសធ្ងន់ណាស់ ខ្ញុំអនុញ្ញាតអោយចូលទៅមើលបាន ៥ នាទី តែសុំកុំរុកគួនអ្នកជម្ងឺ - នុះហ្ន៎ ! នៅក្នុងបន្ទប់នុះ "

និយាយចប់ គ្រូពេទ្យក៏នាំម៉ី និង នាងសយចូលទៅក្នុងសាល។ នាងសយមានទឹកភ្នែកធ្លាក់ចុះមកជោកថ្ពាល់ដោយសារការអាណិតអាសូរប្តី។ នាងគិតថា សមជាមនុស្សមានគ្រោះអាក្រក់ជាទីបំផុត ព្រោះទើបតែរួចពីគុកមក មិនទាន់បានប៉ុន្មានថ្ងៃក៏ត្រូវរថយន្តបុកទៀត ។ ពាក្យសំដីរបស់គ្រូពេទ្យដែលបាននិយាយប្រាប់នាងថា សមកំពុងឋិតនៅក្នុងសេចក្តីអន្តរាយនេះ នាងប្រែសេចក្តីថាជូនកាលជីវិតរបស់សមអាចផុតរលត់ក្នុងយប់នេះក៏មិនដឹង ព្រោះទ្រាំទ្រនឹងការឈឺចាប់មិនបាន។

ទ្វារនៃបន្ទប់ក្នុងសាលនេះត្រូវបើកដំហ ហើយពន្លឺអគ្គិសនីក៏បានបញ្ចេញរស្មីភ្លឺច្រាល

ឡើង។ គ្រូពេទ្យបាននាំម៉ី និង នាងសយចូលទៅក្នុងបន្ទប់នេះ។ ម៉ី និងនាងសយឈរស្រឡាំងកាំងសម្លឹងមើលទៅលើគ្រែខាងឆ្វេង។ សមត្រូវគេទុកអោយដេកនៅលើគ្រែមួយតែ

ឯង។ នៅតាមរាងកាយរបស់សមមានស្នាមរបួសជាច្រើនកន្លែង ដែលគ្រូពេទ្យបានលាបថ្នាំយ៉ាងរៀបរយ ។ ក្បាលរុំដោយក្រណាត់យ៉ាងធំជុំវិញ ហើយមានឈាមនៅត្រង់ក ដែលមើលទៅឃើញក្រហមច្រាល ឯដៃសងខាងមានស្នាមរលាត់ តែត្រង់កែងដៃបែកឈាម។ សមកំពុងតែដេកលក់ដកដង្ហើមផ្អឹកៗ ទឹកមុខសស្លាំង ហើយហារមាត់បន្តិច។

" បង ! បង ! " នាងសយស្រែកឡើងខ្ទរបន្ទប់ ហើយស្ទុះចូលទៅរកសមតែត្រូវគិលានុប្បដ្ឋាកស្ទុះចូលទៅរាំងពីរមុខជាប់។

" កុំ ! កុំ ! " គិលានុប្បដ្ឋាកហាម " កុំទៅប៉ះពាល់អោយសោះ អ្នកជម្ងឺកំពុងតែឈឺធ្ងន់ ទុកអោយដេកលក់អោយមានកំលាំងបន្តិច "

នាងសយឈយំយ៉ាងខ្លាំងស ហើយបេះដូងរបស់នាងស្ទើរតែឈប់ធ្វើការ...សេចក្តីស្រលាញ់ដែលលាយទៅដោយសេចក្តីអាណិត បានកើតឡើងដល់នាងយ៉ាងលើសលប់...

" ព្រះតេជគុណ ! " មុំលើកដៃសំពះគ្រូពេទ្យហើយសួរ " អ្នកបើកឡាននោះនៅឯណាទាន ប្រោស ? "

គ្រូពេទ្យស្ងាបដោយការងងុយ ហើយនិយាយតិចៗ ហាក់ដូចជាមិនចង់ឆ្លើយនឹងសំនួររបស់មុំ

" មិនដឹងឯងនៅណាទេ ប៉ូលីសដែលនាំអ្នកជម្ងឺមកនេះបាននិយាយថា អ្នកបើកឡាននោះ បានបើកឡានគេចបាត់ទៅ គ្មានអ្នកណាចាំលេខឡានបានទេ ! " គ្រូពេទ្យងាកមុខទៅខាងនាង សយ ហើយនិយាយលួងលោមដោយអធ្យាស្រ័យដ៏ល្អ " តែឈ្ពើយចុះ កុំព្រួយធ្វើអ្វី ចាំខ្ញុំជួយមើល អោយទាល់តែអស់សមត្ថភាព កុំគិតពេកនេះជាគ្រោះថ្នាក់របស់មនុស្ស ឈ្ពើយសូមអញ្ជើញត្រឡប់ ទៅផ្ទះវិញចុះ អ្នកជម្ងឺត្រូវការសម្រាកអោយបានច្រើន ព្រោះវាមានមុខរបួសច្រើន ហើយចេញ ឈាមច្រើនណាស់ "

នាងសយសម្លឹងមើលមុខប្តី ស្ទើរតែមិនចង់ព្រិចភ្នែក។ ទឹកភ្នែករបស់នាងចេះតែហូរធ្លាក់ចុះ មកថែមទៀត។

" ទៅសយ ! " មុំអោនខ្សឹប " ទៅ ! យើងទៅផ្ទះវិញកុំនិយាយខ្លាំងក្រែងសមភ្ញាក់ " មុំ និង សយ បានសំពះលាគ្រូពេទ្យ ត្រឡប់ទៅផ្ទះវិញទាំងទុក្ខព្រួយ។ មុនពេលចេញផុតពីមាត់ទ្វារនៃ បន្ទប់ នាងសយបានក្រឡេកមើលទៅសមម្តងទៀត ដោយសេចក្តីក្រៀមក្រំ និង អាល័យ។

ខែថ្មីបានកន្លងផុតបាត់ទៅហើយ...សមដេកឈឺនៅក្នុងមន្ទីរពេទ្យអស់រយះពេលជាងមួយខែ។ ក្រោយពីសប្តាហ៍ជាដំបូងមក ជម្ងឺរបស់ក៏កាន់តែធូរស្បើយជាលំដាប់។ ដោយសារសមត្ថភាពរបស់ វេជ្ជបណ្ឌិតនៃមន្ទីរពេទ្យព្រះកេតុមាលា សមក៏បានរួចជីវិតមកទាំងប្រផុតប្រដោយ ។

ក្នុងទីបំផុត សមក៏បានជាសះស្បើយឡើងវិញ ហើយលោកវេជ្ជបណ្ឌិត ក៏បានអនុញ្ញាតអោ យសមចេញពីមន្ទីរពេទ្យព្រះកេតែមាលា សមក៏បានរស់មានជីវិត។

រថយន្តដែលបើកបុកត្រីចក្រយាន និងរូបសមនៅតែរកមុខមិនទាន់ឃើញនៅឡើយ។ ការ

នេះប្រែសេចក្តីថា សមឈឺខ្លួនឥតអំពើ។ មិនតែប៉ុណ្ណោះត្រីចក្រយាន ដែលជាគ្រឿងឧបករណ៍ដ៏ សំខាន់សំរាប់រកស៊ីនោះ ក៏បាក់បែកខ្ទេចខ្ទីអស់ទៀត។

សមតាំងចិត្តថា លែងរកស៊ីធាក់ត្រីចក្រយានទៀតហើយ...សមគិតរកការដទៃធ្វើវិញ ព្រោះរបររកស៊ីនេះ បានប្រាក់មិនគ្រប់គ្រាន់ក្នុងការចាយវាយចិញ្ចឹមរាល់ថ្ងៃ តែនឿយហត់ណាស់ដោយត្រូវងូតញើសតាងទឹក...រាងកាយ និង សុខភាពឆាប់ទ្រុឌទ្រោម មិនតែប៉ុណ្ណោះរបរនេះពោរពេញទៅដោយគ្រោះថ្នាក់អន្តរាយទៀតផង ព្រោះរថយន្តនៅក្នុងទីក្រុង បើកបរលឿនហាក់ដូចជាប្រណាំងប្រជែង ហើយមើលទៅដូចជាមិនសូវឃើញមានរថយន្តណាបើកបរអោយមានល្បឿនក្នុង ១ម៉ោង៣០គ.ម នោះឡើយ។

អ្នកធ្វើចរាចរច្រើនណាស់ ដែលត្រូវរងគ្រោះដោយសារតែរថយន្ត បណ្តាលអោយមានគ្រោះផ្សេងៗ រហូតដល់ស្លាប់បាត់បង់ជីវិតក៏មានច្រើនណាស់ដែរ។

ឈឈឈឈ

**ភាគទី៨ នាយទុនបរទេស**

មើលទៅសមដូចជាថា សមនៅមានជោគវាសនាគ្រាន់បើនៅឡើយដែរ។ សមខំស្វះស្វែងរកការងារធ្វើមិនប៉ុន្មានថ្ងៃ ក៏បានចូលធ្វើការជាកម្មករក្នុងរោងឧស្សាហកម្មធ្វើសាប៊ូ ដែលម្ចាស់នៃរោងឧស្សាហកម្មនេះជាជនជាតិចិន។រោងឧស្សាហកម្ម ដែលសមចូលទៅធ្វើនេះមានកម្មករជាង ២០នាក់។

សមបានផ្លាស់ជីវិតថ្មីហើយ...ផ្លាស់ពីកម្មករត្រីចក្រយានទៅជាកម្មកររោងឧស្សាហកម្មធ្វើសាប៊ូ ដែលបានថ្លៃឈ្នួលក្នុងមួយថ្ងៃត្រឹមតែ ២៥រៀល តែត្រូវធ្វើការ១០ម៉ោងក្នុងមួយថ្ងៃ។

ថ្ងៃខែចេះតែកន្លងផុតទៅជានិច្ច...ការប្រឹងព្យាយាមនិងការប្រព្រឹត្តរៀបរយរបស់សម បានធ្វើអោយសមបានឡើងថ្លៃឈ្នួលដល់ទៅ ៣០រៀលក្នុងមួយថ្ងៃ។

ក្រោយពេលដែលសមចូលធ្វើការបានពីរខែ អ្នកចាត់ការដែលជាកូនកំលោះរបស់ថៅកែ ក៏ទុកចិត្តទុកថ្លើម ហើយពួកកម្មករទាំងអស់ដែលនៅធ្វើការជាមួយគ្នា ក៏ស្រលាញ់ពេញចិត្ត និងអធ្យាស្រ័យដ៏ល្អរបស់សមដែរ។

ជោគជតាល្អ និងជោគជតាអាក្រក់ វាអាចកើតឡើងភ្លាមៗ ដល់មនុស្សយើង...ថ្ងៃមួយអ្នកចាត់ការរោងឧស្សាហកម្មធ្វើសាប៊ូបានហៅសមអោយចូលទៅជួបនឹងលោកតែពីរនាក់ហើយលោកនិយាយថា

" កាប៉ូរ៉ាលកន បានលាឈប់ពីមុខតំណែងហើយ ឥឡូវខ្ញុំតាំងសមឯងអោយធ្វើជាកាប៉ូរ៉ាល ហើយខ្ញុំតំឡើងប្រាក់ខែអោយមួយថ្ងៃ ៥រៀលទៀត គឺសមឯងត្រូវបានមួយថ្ងៃ ៣៥រៀល ហើយខ្ញុំសង្ឃឹមថា សមឯងមុខជាមើលការខុសត្រូវពួកគូលីអោយធ្វើការបានដោយមានរបៀបរៀបរយជាមិនខាន "

សមនឹកត្រេកអរជាទីបំផុត

" លោក ! " សមនិយាយឡើង ខ្ញុំនឹងខំធ្វើការជូនលោកអោយពេញកម្លាំង

" ល្អហើយសម ! " អ្នកចាត់ការនិយាយដោយទឹកមុខញញឹម ហើយលើកដៃចង្អុលត្រង់ទៅបន្ទប់តូចមួយ ដែលបិតនៅក្នុងបរិវេណនៃរោងឧស្សាហកម្មធ្វើសាប៊ូ។

" សមឯងត្រូវមកនៅបន្ទប់ដែលកនធ្លាប់នៅ ព្រោះបន្ទប់នោះ ជាបន្ទប់សំរាប់អោយកាប៉ូរ៉ាលនៅ សមឯងមកនៅថ្ងៃណាក៏បាន "

សមត្រូវបែកចេញនាយម៉ី និង នាងម៉ុម ព្រោះត្រូវទៅនៅក្នុងរោងឧស្សាហកម្មធ្វើសាប៊ូ។ សមបាននាំប្រពន្ធកំសត់កំរទៅនៅកន្លែងធ្វើការ ហើយក្រោយពីនោះមកសមក៏បានប្រតិបត្តិនាទីរបស់ខ្លួនយ៉ាងត្រឹមត្រូវ ដោយមិនគិតដល់ការនឿយហត់ ព្រោះសង្ឃឹមថានឹងធ្វើខ្លួនប្រាណចំពោះការងារនេះដើម្បីសេចក្ដីរុងរឿងតទៅអនាគត។

រដូវភ្លៀងបានកន្លងផុតទៅហើយ។ អាកាសបានប្រែទៅជារងាយ៉ាងខ្លាំង សមធ្វើការបានគ្រប់៨ខែហើយ។

ពេលរសៀលនៃថ្ងៃនោះ ថៅកែ សេង លី ម្ចាស់រោងឧស្សាហកម្មធ្វើសាប៊ូនេះបានមកត្រួតត្រាមើលកិច្ចការ និងសេចក្តីរៀបរយ នៅក្នុងបរិវេណនៃរោងឧស្សាហកម្មរបស់គាត់ ដោយគាត់បាននាំមនុស្សប្រុសកំលោះម្នាក់មកជាមួយផង។ នៅពេលមកដល់ភ្លាមថៅកែបានឃើញពួកកម្មករខំធ្វើការគ្រប់ៗគ្នា ហើយមានរបៀបរៀបរយល្អ។

ថៅកែ សេង លី បានប្រាប់ពួកកម្មករទាំងអស់គ្នាថា សេង អាន អ្នកចាត់ការចាស់ដែលត្រូវជាកូនរបស់គាត់នោះ ត្រូវធ្វើដំណើរទៅមើលកិច្ចការជំនួញនៅហុងកុង ឥឡូវគាត់បានតាំង សេង ហុងក្មួយរបស់គាត់ធ្វើជាអ្នកចាត់ការជំនួស សេង អាន។

ថៅកែបានពិនិត្យមើលកិច្ចការផ្សេងៗ មួយសន្ទុះក៏ឡើងជិះរថយន្តត្រឡប់ទៅផ្ទះវិញ។ ល្ងាចនៃថ្ងៃនោះ មុនពេលឈប់ធ្វើការបន្តិច សេង ហុង អ្នកចាត់ការធ្វើដែលពេញទៅដោយការប្រកាន់ឫកពា ប្រើសំដីទ្រគោះបោះបោកដាក់កម្មករ សំដែងនូវអំណាចដ៏ធំក្នុងឋានៈជាថៅហ្វាយនាយ បានហៅសមអោយចូលទៅក្នុងបន្ទប់ធ្វើការហើយប្រាប់កិច្ចការផ្សេងៗ ដែលត្រូវកែប្រែក្នុងរឿងធ្វើការងារ។

សមមិនចូលចិត្តនឹងអ្នកចាត់ការថ្មីនេះសោះព្រោះសេងហុង មានបុគ្គលិកលក្ខណៈខុសគ្នាស្រឡះពី សេង អាន។

" អាសម ! " សេង ហុង និយាយដោយទឹកមុខស្មើៗ។

" ចាប់តាំងពីថ្ងៃស្អែកនេះទៅ អញត្រូវបន្ថយចំនួនគូលីខ្មែរចេញ ១០នាក់ ឯងជ្រើសរើសមើល ! អាណាគួរអោយវាទៅ អាណាគួរអោយវានៅ ហើយឯងត្រូវប្រាប់វាថា ស្អែកនេះមិនបាច់មកធ្វើការទេ បន្តិចទៀតអញអោយគេបើកប្រាក់អោយវា គ្រប់ចំនួនថ្លៃដែលវាធ្វើការ អញនឹងរកគូលីចិន យួនមកជំនួសវិញ ព្រោះគូលីខ្មែរធ្វើការយឺតហើយខ្ជិលណាស់ ឯអាសមឯង អញទុកអោយនៅធ្វើជាកាប៉ូរ៉ាល ដដែល "

សមដូចជាស្រឡាំងកាំង។ ពាក្យបង្គាប់របស់ថៅហ្វាយថ្មីនេះមិនខុសគ្នាពីពាក្យពិភាក្សាកាត់ទោសប្រហារជីវិតរបស់ថៅក្រមប៉ុន្មានឡើយ ព្រោះសមធ្លាប់ដឹងដល់ការរស់នៅរបស់កម្មករ។សមគិតថា ពួកកម្មករនៅក្នុងរោងឧស្សាហកម្មធ្វើសាប៊ូនេះសុទ្ធតែជាអ្នកក្រីក្ររកព្រឹកស៊ីល្ងាច ត្រូវ

ការងារជូតញើសតាងទឹក ដើម្បីបានប្រាក់បន្តិចបន្តួចយកទៅចិញ្ចឹមជីវិត ដែលមានជីវិតប្រពន្ធរួម នៅក្នុងនោះផង បើត្រូវគេបញ្ឈប់លែងអោយធ្វើការដោយមិនដឹងខ្លួនដូច្នេះ ក៏ជាការពិតណាស់ ដែលពួកកម្មករទាំងនោះនឹងត្រូវបានទទួលនូវសេចក្ដីទុក្ខលំបាកជាខ្លាំង។

" សុំទោសលោក ! " សមនិយាយអង្វករ សេង ហុង

" ពួកគូលីទាំងអស់ សុទ្ធតែខំប្រឹងប្រែងណាស់លោក កុំបញ្ឈប់គ្នាអីអាណិតគ្នា " សេង ហុង សម្លឹងមើលមុខសមដោយការមិនពេញចិត្តហើយក៏និយាយឡើងថា ៖

" ទេមិនបានទេអាសម ! ពួកគូលីខ្មែរខ្ជិលណាស់ ធ្វើការមិនបានចំរើនទេ អញត្រូវបញ្ឈប់ ហើយយកពួកចិន យួនមកធ្វើវិញគ្រាន់បើជាង "

សមបានកាត់ចិត្តគ្លាមថា ត្រូវតែតវ៉ាដើម្បីបងប្អូនកម្មករ។ ខណៈនោះ សមក៏ជំទាស់ឡើងថា ៖

" លោក ! សុំលោកអាណិតគ្នាផងចុះ ពួកគូលីទាំងអស់ សុទ្ធផ្ញើជីវិតលើការងារនោះ ហើយ សុទ្ធតែធ្លាប់ធ្វើការនៅកន្លែងនេះយូរណាស់មកហើយ ។"

" អាសម ! " សេង ហុង និយាយឡើងទាំងខឹង " ឯងដឹង ឬទេថា ការងាររបស់យើងគួរតែបាន ចំរើនជាងនេះឆ្ងាយណាស់ បើបានគូលីចិន យួន ទាំងអស់ឬពាក់កណ្ដាលមកធ្វើការនោះ ការងារ របស់យើងមិនមែនជាអញ្ចឹងទេ ខ្មែរខ្ពងវែងណាស់ ! តាមចិត្តអញ អញចង់យកគូលីចិន យួន ទាំង អស់ផង តែធ្វើអញ្ចឹងទៅដូចជាជ្រុលពេក "

ទឹកមុខរបស់សមឡើងក្រហម...សមសម្លឹងមើលមុខថៅហ្វាយថ្មីដោយសេចក្ដីឃ្នាន់ខ្នាញ់។

" លោក ! " សមនិយាយឡើង " លោកគួរអាណិតដល់ គូលីខ្មែរទាំងអស់នេះខ្លះផង ពួកគូលី ខ្មែរទាំងអស់នេះ ខ្ញុំហ៊ានធានាអះអាងថា គ្មានអ្នកណាខ្ជិលច្រអូសទេ ពួកគូលីខ្មែរទាំងអស់នេះធ្វើ ការលើសពីតំលៃប្រាក់ខែផង "

" អាសម ! " សេង ហុង ស្រែកគំរាមហើយលើកដៃចង្អុលមុខ " អាឯងគ្មាននាទីអីដែលត្រូវ សំដែងហេតុផលអោយអញស្ដាប់ទេ ទៅ ! ចេញទៅ ! ចេញពីបន្ទប់អញអោយឆាប់ ទៅប្រាប់ពួក គូលីឯងអោយដឹងថា អញបញ្ឈប់ពួកគូលីខ្មែរពាក់កណ្ដាលចាប់ពីថ្ងៃស្អែកនេះទៅ ឯថ្លៃឈ្នួលក្នុង

អាទិត្យនេះ អញនឹងបើកអោយវានៅពេលឈប់ធ្វើការ អាឯងកុំជំទាស់នឹងអញ តិចអញបញ្ឈប់ទាំងអាឯងផងប្រយ័ត្ន ˝

សមក្រោកឈរឡើង ហើយនិយាយដោយលែងមានការគោរពកោតក្រែង

˵ បើទុកជាលោកមិនបញ្ឈប់ក៏ខ្ញុំឈប់ដែរ ឯពួកគូលីនោះបើលោកមិនអាណិតទេក៏ស្រេចនឹងលោកទៅចុះ ˝

˵ ទៅអាសមចេញទៅ ! ˝ សេង ហុង ស្រែកយ៉ាងខ្លាំង

˵ឯង ចង់នាំពួកគូលីអោយបះបោរផងអាសម? ˝

សមញ៉េរធ្មេញក្រឹតដោយទោសៈតែខំអត់សង្កត់ចិត្តហើយដើរចេញពីបន្ទប់នេះទៅ

ការជ្រួលជ្រើមបានកើតឡើងក្នុងរោងចក្រឧស្សាហកម្មធ្វើសាប៊ូភ្លាម ក្នុងពេលដែលសមបានទៅប្រាប់នូវបំណងរបស់ សេង ហុង អោយកម្មករខ្មែរទាំងអស់ដឹង។ កម្មករចិត្តឆៅខ្លះបានស្រែកជេរ សេង ហុង ហើយប្រុងនឹងបង្កនូវវិនាសកម្មផ្សេងៗ តែសមបានខំហាមប្រាមដល់មិត្តកម្មករទាំងអស់នោះអោយបិតនៅក្នុងសេចក្ដីស្ងប់ស្ងៀម ហើយសមបានសន្យាថា និងធានាលុបលាងនូវអំពើអយុត្តិធមិរបស់នាយទុនបរទេសនេះអោយទាល់តែបាន។

ម៉ោង១៧កន្លះ...សំដែងរកគាំងបានលាន់លឺឡើងក្នុងរោងចក្រឧស្សាហកម្មធ្វើសាប៊ូជាសញ្ញាប្រាប់កម្មករអោយដឹងថា ដល់ពេលឈប់ធ្វើការហើយ។ ពួកកម្មករទាំងអស់បានទៅប្រជុំគ្នានៅត្រង់ទីធ្លាខាងមុខរោងចក្រឧស្សាហកម្ម។

ពួកកម្មករខ្មែរទាំងអស់នោះនឹកខឹងសម្បារជាខ្លាំង ចំពោះការបញ្ឈប់កម្មករខ្មែរពាក់កណ្ដាលនេះ។ កម្មករខ្លះស្ទើរតែប្រើកំលាំងបាយទៅហើយ តែសមបានហាមឃាត ˵ កុំពួកយើងកុំ ! យើងមិនត្រូវប្រើកំលាំងបាយទេ ˝

សមដាស់តឿន ˵ ពួកយើងជាកម្មកររកព្រឹកស៊ីល្ងាចតាមធម្មតា ពួកយើងតែងត្រូវគេមើលងាយជិះជាន់សង្កត់សង្កិនតែពួកយើងត្រូវតែរក្សាទុកមាយាទដ៏ល្អ ហើយត្រូវបិតនូវក្នុងសេចក្ដីស្ងាត់ស្ងៀម ˝

" ទេបងសម ! " ម្នាក់និយាយឡើង "វាដូចជាហួសពេកបង "

" ណ្ហើយគ្នាយើងអើយ ! កើតមកជាអ្នកក្រ វាតែងតែអញ្ចឹងឯង " សមឆ្លើយឡើង " សេចក្តីយុត្តិធម៌មិនឋិតនៅលើសេចក្តីពេញចិត្តពេញថ្លើមរបស់ថៅហ្វាយនាយ ឬថៅកែណ្ហើយកុំអី ! ស្រួលមិនស្រួលយើងជាប់គុកឥតអំពើ ព្រោះគេមានប្រាក់ យើងត្រូវតែចាញ់គេដរាប " ខណៈនោះ សមបានត្រឡប់ទៅក្នុងបន្ទប់អ្នកចាត់ការទៀតដើម្បីសុំបើកប្រាក់។

សេង ហុង ជក់បារីឈរនៅជិតបង្អួចដោយទឹកមុខដែលសំដែងនូវការមិនសប្បាយចិត្ត។ សំលែងស្រែកជេររបស់កម្មករ បានធ្វើអោយ សេង ហុង ក្រេវក្រោធខ្លាំង។

គ្រាន់តែឃើញសមចូលមកដល់បន្ទប់ភ្លាម សេង ហុង ក៏ស្រែកឡើងថា ៖

" អាសម ! អាឯងនាំគួលីបះបោរ តិចអញប្តឹងដល់គុកឥឡូវ "

" មិនមែនអញ្ចឹងទេលោក " សមឆ្លើយឡើងខ្ញុំជាអ្នកសម្រុះសម្រួលទេតើ

" អាឯងនេះក្បាលខូច ! " សេង ហុង និយាយឡើងទាំងកំហឹង

" អញដេញទាំងក្បាលអាឯងចោលទៀត អាសមអញលែងត្រូវការជួលអាឯងទៀតហើយ អាឯងត្រូវចេញពីទីកន្លែងនេះនៅពេលព្រឹកស្អែក"

សេង ហុង បានរាប់ប្រាក់មកអោយសមទាំងខឹងសម្បារ។ សមដើរចេញពីបន្ទប់ធ្វើការរបស់អ្នកចាត់ការមកវិញហើយក៏យកប្រាក់ទៅបើកអោយពួកកម្មករ។ ពួកកម្មករទាំងអស់ នាំសាកសួរសមដែលសមស្ទើរតែឆ្លើយមិនរួច ព្រោះការពិបាកចិត្ត។

សមបានពណ៌នារឿងរ៉ាវទាំងអស់អោយកម្មករស្តាប់ដោយទុក្ខព្រួយ។

ពួកកម្មករទាំងនោះ ក៏បានសំដែងនូវការតូចចិត្តតូចថ្លើមនិងការភ័យព្រួយបារម្ភចំពោះអនាគតនៃជីវិត ព្រោះត្រូវនាយទុនបរទេសបញ្ឈប់លែងអោយធ្វើការដោយមិនដឹងខ្លួន អ្នកទាំងអស់គ្នាខឹងនឹង សេង ហុង ជាខ្លាំងតែមិនដឹងជាធ្វើអ្វីគេបាន

សមបានបែកចេញពីពួកកម្មករខ្មែរទាំងនោះ ហើយដើរតម្រង់ទៅផ្ទះដែលតាំងនៅជ្រុងខាង

ជើង ដោយទឹកមុខដ៏ស្រងូតស្រងាត់។ សមបានបដិបត្តិនាទីរបស់ខ្លួនសមនឹងតំណែងកាប៊ូរ៉ាលដ៏ល្អ បើទុកជាសមត្រូវនាយមុនបណ្តាញចេញលែងអោយធ្វើការក៏ដោយតែពួកកម្មករទាំងអស់មិនអាចបំភ្លេចនូវសេចក្តីល្អរបស់សមបានឡើយ។ ទីបំផុតសមត្រូវនាំនាងសយប្រពន្ធកំសត់ចេញពីរោងចក្រឧស្សាហកម្មធ្វើសាប៊ូ នៅបណ្តោះអាសន្នជាមួយនាយម៉ី និង នាងម៉ុមម្តងទៀត។

" បងម៉ី ! " សមនិយាយឡើងក្រោយពេលដែលបាននិយាយដល់រឿងរ៉ាវទាំងអស់ដែលបានកើតឡើងនៅក្នុងរោងចក្រឧស្សាហកម្មធ្វើសាប៊ូសព្វគ្រប់ហើយ " ខ្ញុំគ្មានបំណងចង់បៀតបៀនបងម៉ីឯងសោះ តែខ្ញុំគ្មានកន្លែងនៅ ខ្ញុំមកសុំបងម៉ីឯងសំណាក់អាស្រ័យនៅជាបណ្តោះអាសន្នសិន ទម្រាំរកផ្ទះបាន... "

" នៅចុះសម ! " ម៉ីឆ្លើយឡើងដោយសុទ្ធចិត្ត " នៅចុះមិនអីទេបើឯងរកការងារធ្វើមិនទាន់បានទេ ចែកស៊ីក្លូគ្នាផាក់ក៏បាន គឺសមឯងផាក់យប់គ្នាផាក់ថ្ងៃ ហើយចេញថ្លៃឈ្នួលគ្នាពាក់កណ្តាល " សមបានសំណាក់នៅជាមួយនាយម៉ីនិងនាងម៉ុមម្តងទៀត។ សមតែងគិតថា មានតែមិត្តភក្តិកម្មករទេ ដែលអាចយល់ចិត្តថ្លើមរបស់កម្មករដូចគ្នា។

ꩰꩰ ꩰꩰ

## ភាគទី ៩ អ្នកនយោបាយបោកប្រាស់

ថ្ងៃ ខែចេះតែកន្លងផុតទៅជានិច្ច...សមខំស្វះស្វែងរត់រកការងារធ្វើទៅទៀត។ ដោយសារសេចក្តីព្យាយាមក៏បានសម្រេចនូវជោជ័យដ៏គួរពេញចិត្ត។ សមបានចូលទៅធ្វើការនៅក្នុងរោងចក្រមួយទៀត ក្នុងតំណែងជាកម្មករ។ ជីវិតរបស់សមតែងប្រែប្រួលទៅតាមយថាកម្ម។ ដោ យ សារសេចក្តីប្រឹងប្រែង សមបានឡើងតំណែងជាកាប៉ូរ៉ាល ២ ទៅ ៣ ខែទៀត។ សមបានធ្វើខ្លួនអោយជាទីស្រលាញ់រាប់អានរបស់មិត្តភក្តិកម្មករនៅទៅនោះ ហើយខំជួយជ្រោមជ្រែងពួកកម្មករអោយបានទទួលនូវសេចក្តីយុត្តិធម៌ពីថៅកែ។ ដូច្នេះថៅកែដែលធ្លាប់ស្រឡាញ់សមមកពីមុន ឥឡូវក៏ប្រែទៅជាស្អប់ខ្ពើមសមទៅវិញ។

ទីបំផុត សមក៏ត្រូវគេបណ្តេញចេញលែងអោយធ្វើការនៅកន្លែងនោះ ដោយគ្មានកំហុសអ្វីទៀត...

សមបានចូលនៅធ្វើការជាកម្មករលីសែងនៅកំពង់ផែ ហើយបានឡើងឋានៈជាកាប៉ូរ៉ាល់ម្តងទៀត។ សមបានសាងខ្លួនអោយជាទីស្រឡាញ់រាប់អានរបស់ពួកកម្មករ។ ហេតុនោះ សមទើបក្លាយខ្លួនទៅជាទីសំអប់របស់នាយទុន ព្រោះសមតែងជជែកតវ៉ាជំនួសពួកកម្មករដែលធ្លាប់ធ្វើការជាមួយសម បាននឹកដល់គុណបំណាច់របស់សមដោយគ្មានថ្ងៃនឹងបំភ្លេចបាន។

ពេលនេះសមត្រូវទំនេរការងារនៅផ្ទះជិតមួយខែ...សមត្រូវងាកមកធាក់ត្រីចក្រយានវិញ តែសមធាក់នៅពេលថ្ងៃ ដែលបានប្រាក់ល្មមនឹងចិញ្ចឹមជីវិតតែមួយថ្ងៃៗប៉ុណ្ណោះ ឯពេលយប់មុីជាអ្នកធាក់។អ្នកទាំងពីររស់នៅជាមួយគ្នាដោយសេចក្តីសុខសប្បាយ ដែលមានសភាព, មានជីវភាពដូចពួកវណ្ណៈទាំងឡាយគឺមានការរស់នៅធម្មតាសាមញ្ញ ស៊ីងាយដេកងាយ ដូចពួកអ្នកក្រទូទៅ។

សមមានគំនិតចង់លើកតំកើងជីវភាពរបស់ពួកកម្មករ សមចាប់ផ្តើមសាងខ្លួនអោយជាទីស្រឡាញ់រាប់អានរបស់ពួកកម្មករត្រីចក្រយានទៀត។ សមស្អប់ខ្ពើមពួកនាយទុនចិត្តមារដែលតែងស៊ីសាច់ហុតឈាមពួកកម្មករ កសិករខ្មែរ តែងគោរពបូជានាយទុនដែលមានចិត្តសប្បុរស

។ សមបានក្លាយខ្លួនទៅជាបុរសម្នាក់ ដែលមានគេស្គាល់ច្រើននៅក្នុងសង្គមកម្មករ។

សមបានចាប់ផ្តើមចាត់តាំងបង្កើតជាសមាគមកម្មករឡើងស្ងាត់ដោយមិនបានសុំអនុញ្ញាតច្បាប់ពីរាជការត្រឹមត្រូវឡើយ ព្រោះតែសេចក្តីល្ងង់ខ្លៅរបស់កម្មករនុ៎ះឯង។ ពួកកម្មករជាច្រើន បាននាំគ្នារួបរួមជាសមាជិកសមាគម តែថាសមាគមនេះ ជាសមាគមដែលសង្គមជាន់ខ្ពស់មើលងាយមើលថោកនិងរង្កៀសព្រោះជាសមាគមរបស់កម្មករនេះ តែជាប្រធានគ្មានកិត្តិយសដូចសមាគមដទៃព្រោះប្រធាន និងសមាជិកគ្មានទ្រព្យសម្បត្តិអ្វីក្រៅពីកំលាំងកាយប៉ុណ្ណោះ ហើយបុគ្គលក្រៅពីនេះ គ្មានអ្នកណាមករវីរវល់សោះឡើយ។

" តែលុះសមាគមនេះរីកចំរើនឡើងដោយមានចំនួនសមាជិកច្រើនគ្រាន់បើបន្តិចក៏ស្រាប់តែមានអ្នកនយោបាយបោកប្រាស ២ ទៅ ៣ នាក់ដែលមើលឃើញអនាគត បានចូលមកជ្រៀតជ្រែកសមាគមកម្មករនេះ ដែលជួយជាគំនិត និងប្រាក់កាសខ្លះៗសដែលរាប់ថាជា នុយដ៏សំខាន់សំរាប់ទាក់ទាញទឹកចិត្តរបស់ពួកកម្មករដែលមិនបានដឹងដល់ការពិត។ ពួកអ្នកនយោបាយទាំងនេះមានបំណងចង់ធ្វើអោយកម្មករជាសមាជិកនៃសមាគមនិយម រាប់អានខ្លួនគេ ហើយគេក៏ក្តាប់សមាគមនេះបិតនៅក្រោមឥទ្ធិពលរបស់គេ ដើម្បីជាប្រយោជន៍ដល់ការបោះឆ្នោតជ្រើសតាំងតំណែងរាស្ត្រ

ក្នុងពេលខាងមុខឆាប់ៗនេះដែលពួកគេទាំងនោះក៏សុទ្ធតែត្រូវឈរឈ្មោះជាបេក្ខជនដែរ...អ្នកនយោបាយទាំងនោះដឹងច្បាស់ថាកម្មករខ្មែរទាំងអស់សុទ្ធតែមានដើមកំណើតជាកសិករ។ កម្មករទាំងនេះតែងមកធ្វើការនៅទីក្រុងនៅពេលទំនេរពីការភ្ជួររាស់នៅស្រុកវិញដើម្បីប្រកបកិច្ចការស្រែចំការ។ ដូច្នេះពួកអ្នកនយោបាយទាំងនោះបានមកទាក់ទងនឹងពួកកម្មករទុកអោយហើយដើម្បីជាការស្រួលដល់ពេលបោះឆ្នោត ដែលគេត្រូវពឹងពាក់ពួកកម្មករទាំងនោះអោយធ្វើជាដៃជើងរបស់ពួកគេ...

" សម ! ប្អូនឯងអាណិតជួយខ្ញុំអោយមែនទែនណា៎ "

អ្នកនយោបាយម្នាក់និយាយនឹងសម ដូចបែបសុភាពដូចកុកចាំសីល " ខ្ញុំស្ម័គ្រចិត្តធ្វើជាបេក្ខជនតំណាងរាស្ត្រមែនទែនហើយ បើសមជួយខ្ញុំ ខ្ញុំសង្ឃឹមថា មុខជាបានជាប់ពិតប្រាកដ បើខ្ញុំបានធ្វើតំណាងរាស្ត្រមែននោះ សូមកុំភ័យអោយសោះ ខ្ញុំនឹងជួយពួកកម្មករអោយពេញសមត្ថភាព ខ្ញុំនឹងតវ៉ាអោយរដ្ឋាភិបាលជួយលើកស្ទួយឋានៈជីវភាពរបស់កម្មករអោយបានស្រួលដូចជាតវ៉ាអោយម្ចាស់ត្រីចក្រយានយកថ្លៃឈ្នួលថោក ឬជួយតវ៉ារដ្ឋាភិបាលអោយជួយជ្រោមជ្រែងពួកកម្មករអោយមានផ្ទះនៅ មានភ្លើង ទឹកម៉ាស៊ីនប្រើប្រាស់ជាដើម... "

ទីបំផុតអ្នកនយោបាយទាំងអស់នោះ ក៏បានទទួលនូវការជួយជ្រោមជ្រែងពីសម និង

ពួកកម្មករក្នុងការបោះឆ្នោតជាសកលដោយពេញទំហឹង ហើយក៏បានជាប់ឆ្នោតជាសមាជិករសភាដូចបំណងមែន។ តែក្រោយពីពេលនោះមកតំណាងរាស្ត្រទាំងនោះលែងមកជាសមាគមដើម្បីមើលការខុសត្រូវសុខទុក្ខរបស់កម្មករទៀតហើយ។ ការរុងរឿងរបស់ពួកនយោបាយទាំងនោះ បានកើតឡើងពីការជ្រោមជ្រែងរបស់ពួកកម្មករពិតៗ តែឥឡូវនេះគេភ្លេចពាក្យសន្យាអស់ហើយ កាលបើពួកកម្មករបានជួបមុខនៅពេលក្រោយៗមក ពួកអ្នកនយោបាយទាំងនោះ ក៏ធ្វើហាក់ដូចជាមិនស្គាល់។ សមដឹងខ្លួនច្បាស់ហើយថាពួកកម្មករជាអ្នកល្ងង់ខ្លៅត្រូវពួកអ្នកនយោបាយរូបខ្លះបោកបញ្ឆោតអោយជឿតាមបានយ៉ាងងាយស្រួល។ សមបានប្តេជ្ញាថា តទៅថ្ងៃមុខលែងបណ្តោយអោយពួកអ្នកនយោបាយបោកប្រាសបានទៀតហើយៗ សមនឹកមមៃថា " ឱហ្ន៎អ្នកនយោបាយ ! វាក្លាយទៅជាអ្នកនយោបោកទៅវិញទេតើហ្ន៎ ! ... "

នៅតាមវិថីនានាក្នុងរាជធានី ដែលពោរពេញទៅដោយយានជំនិះផ្សេងៗនិងល្អងធូលី សមធាក់ត្រីចក្រយានខ្លះៗ ក្រោមកំដៅព្រះអាទិត្យយ៉ាងក្ដៅ ដើម្បីស្វែងរកអ្នកជិះ។ មុខរបររបស់សមជាមុខរបរដែលត្រូវជូតញើសតាំងទឹក តែជាមុខរបរដែលសុចរិច តែជាទីរង្កៀសរបស់វណ្ណៈជាន់ខ្ពស់ដោយភាគច្រើន។

សេចក្ដីសុខ ឬដោគវាសនាល្អរបស់ពួកកម្មករ បើទុកណាវាកើតមានឡើង ក៏វាកើតមានឡើតតែមួយពេលមួយខណៈប៉ុណ្ណោះ ដែលមិនខុសគ្នាពីការយល់សប្តិល្អដែល តែលុះភ្ញាក់ដឹងខ្លួនឡើងសប្តិនោះក៏អណ្ដែតត្រសែតចេញបាត់ទៅ ដោយទុកនៅតែសេចក្ដីសោកស្ដាយ និងស្លុតរន្ធត់ចិត្តអោយអ្នកម្ចាស់តែប៉ុណ្ណោះ។

សមាគមកម្មករ ដែលមានសមជាប្រធានតែគ្មានកិត្តិយសនោះតាំងបាននៅត្រឹមតែកន្លះឆ្នាំប៉ុណ្ណោះ ព្រោះសមាគមនេះមិនបានទទួលនូវការឧបត្ថមពីអ្នកណាទេក្រៅពីពួកកម្មករសោះឡើយ ហើយទីបំផុតក៏ត្រូវរលំរលាយរលត់រូបដែលេជាធ្វើអោយពួកនាយទុនសើចចំអកអោយ។

ត្រីចក្រយានក៏នៅតែត្រីចក្រយានដដែល...ឯកម្មកររកព្រឹកស៊ីល្ងាចដែលត្រូវទីពឹងលើកំលាំងខ្លួនឯងនោះ ក៏នៅជាកម្មករដដែល...

សម្លេងកណ្ដឹង " ម៉ឹង ! ម៉ឹង ! " បានលាន់ឮឡើងទៅនៅគ្រប់វិថីនានាក្នុងព្រះរាជធានី។ អ្នកអង្គុយនៅលើកែមនៃត្រីចក្រយាននោះ គឺពួកកម្មករដែលរកព្រឹកស៊ីល្ងាចនឿយហត់ងូតញើសតាងទឹកដោយសម្មាអាជីវៈ តែច្រើនបានទទួលនូវការមើលងាយមើលថោកពីអ្នកមាន អ្នកធំភាគខ្លះ។

នៅក្នុងភោជនីយដ្ឋាននានា ប្រសិនបើមានកម្មករត្រីចក្រយានណាមួយចូលទៅអង្គុយបរិភោគម្ហូបអាហារផ្សេងៗ ក៏មុខជាត្រូវគេសម្លឹងសម្លក់ដោយកន្ទុយភ្នែកដែលសម្ដែងការមើលងាយរហូតដល់មានអ្នកខ្លះប្រញាប់ប្រញាល់ក្រោកដើរចេញ ព្រោះតែសេចក្ដីរង្កៀសនុះឯង។ សភាពដ៏ល្វីងជូរចត់ដែលគួរអោយតូចចិត្តតូចថ្លើមនេះ កម្មករភាគច្រើនៗបានជួបប្រទះស្ទើររាល់ថ្ងៃ។

មិនតែប៉ុណ្ណោះពួកចិន យួន នៅហ៊ានអោយទឹកតែទៀតផង ។ សមនិងមិត្តភក្តិត្រូវបែកខ្ញែកគ្នាទៅរកកន្លែងថ្មីនៅតែរៀងៗខ្លួន ហើយក៏អស់សមត្ថភាពក្នុងរូបមិត្តភក្តិកម្មករ អោយបិតនៅជាដុំកំពូនបានដូចពីពេលមុនៗទៀតហើយ...

សមបាននាំនាងសយប្រពន្ធកំសត់កម្រទៅរកជួលកូនខ្ទមនៅឆ្ងាយពីទីក្រុងដែលពួកនាយទុនបានទៅចាប់ដីថ្មីទុកលក់ ហើយសង់កូនខ្ទមធ្វើជាគ្រឿងចំណាំនៅលើដីរបស់គេនោះ ដែលយើងមើលទៅឃើញថា ប្រសិនបើមនុស្សមានឋានៈខ្ពស់ជាងសមបន្តិច អ្នកម្ចាស់កូនខ្ទមនោះជួលអោយទៅនៅចាំដីក៏មិនទៅនៅផង។ សមនៅតែរកស៊ីធាក់ត្រីចក្រយានដដែល ដែលមុខរបរនោះអាចជួយអោយសមមានជីវិតរស់នៅបានមួយថ្ងៃប៉ុណ្ណោះ តែក៏មិនអាចនឹងសន្សំប្រាក់កាសទុកបានឡើយព្រោះមានថ្ងៃខ្លះ សមរកប្រាក់ស្ទើរតែមិនបានសោះក៏មាន។ ការទាល់ច្រកនោះ‶ ឯងដែលធ្វើអោយកម្មករខ្លះនឹងអត់ទ្រាំនៅបាន ហើយខ្លះបែរជាយល់ឃើញនូវការអាក្រក់ថាជាល្អ ហើយកាត់ចិត្តលែងរកស៊ីដោយសម្មាអាជីវ:បែរជាទៅប្រកបការរកស៊ីក្នុងផ្លូវទុច្ចរិតទៅវិញ...

ꩡꩡꩡꩡ

## ភាគទី១០ អ្នកលេខស្រុកក្រុង

ខែមិនាបានកន្លងផុតទៅ។វិថីនៃជីវិតរបស់សមនៅតែមានសភាពងងឹងងល់ដដែល។ឋានៈរបស់សមមិនបានចម្រើនសោះឡើយ។ពីពេលមុនមកយ៉ាងណាឥឡូវនេះសមនៅតែមានសភាពយ៉ាងនោះដដែល តែរាងកាយ និងសុខភាព របស់សមចេះតែទ្រុឌទ្រោមជានិច្ច ព្រោះរាងកាយមិនបាន ទទួល នូវអាហារ ដែលមានគុណប្រយោជន៍ដ៏គ្រប់គ្រាន់។

សព្វថ្ងៃសមមិនអាចនឹងធាក់ត្រីចក្រយានបានពេញៗមួយថ្ងៃដូចពេលមុនៗទៀតឡើយ ព្រោះសមចេះតែចុកដៃ ជើងអស់កម្លាំងល្វិតល្វៃហើយឈឺជារឿយ ៗ។ ការរកសស៊ីចិញ្ចឹមជីវិតរបស់សម ក៏ចេះតែលំបាកឡើងៗ តែក៏រាប់ថានៅ មានវាសនាល្អគ្រាន់បើដែរ ព្រោះសមអាចជួលត្រីចក្រយានយកមកធាក់បាន។ឥឡូវភារ:ដ៏ធ្ងន់ធ្ងរបានកើតឡើងដល់សមហើយ...ទារកក្នុងគិភរបស់នាង សយដែលជាដំណក់ឈាមរបស់សម ក៏ដល់ពេលគ្រប់ខែហើយ។ សមគ្មាន ប្រាក់គ្រប់គ្រាន់សម្រាប់ទិញគ្រឿងប្រើប្រាស់ និងទិញថ្នាំសង្កូវអ្វីឡើយ។ ដូច្នេះ សមត្រូវខាំធ្មេញធាក់ត្រីចក្រយានទៅរកប្រាក់២-៣ម៉ោងក្នុងមួយថ្ងៃក្រែង លោបានខ្លះៗ យកមកទុកកាពារក្នុងគ្រាមានអាសន្ន។ថ្ងៃនេះតាំងពីព្រលឹមទល់ព្រលប់ សមមិនបានធាក់ត្រីចក្រយានចេញពីផ្ទះ ឡើយ ព្រោះសមចេះតែក្តៅខ្លួនប្រាណហើយស្រៀវស្រាញ់ដូចជាចង់គ្រុន‶បង″ នាងសយនិយាយ″បើមិនស្រួលខ្លួនសុំបងសំរាកខ្លះទៅក្រែងលោវារឹតតែឈឺខ្លាំង

ឡើងទៀត″

"យើងមានប្រាក់នៅសល់ខ្លះទេអូន?" សមសួរប្រពន្ធ

"ចាស!មាននៅសល់៨០រៀលដែរបង"

"៨០រៀល!" សមដកដង្ហើមធំ"តែអង្ករ និងអុសយើងអស់ហើយមែនទេអូន"

" មិនអីទេបង!"នាងសយលួងលោមប្ដី" អង្ករយើងមាននៅសល់ខ្លះដែរ អុសនោះ យើងអាចរើសនេះរើសនោះដុតបណ្ដោះអាសន្នបាន សុំបងសំរាកមួយថ្ងៃនេះទៅ ចាំស្អែកសឹមចេញទៅរកលុយ ឯថ្លៃឈ្នួលស៊ីក្លូនោះយើងអាចសុំលោកយាយជំពាក់២-៣ថ្ងៃក៏បាន"

"ហ៊ឹះ!"សមនិយាយទាំងតឹងចិត្ត" មិនដឹងជាពេលណាទេ ទើបយើងបានធូរ គ្រាន់បើទេអូន"

"កុំគិតអីច្រើនពេកបង! បើយើងខំរកស៊ីដោយសុចរិតបែបនេះគង់មានថ្ងៃ ណាមួយព្រះជាម្ចាស់ជួយយើងជាមិនខាន"

"ទម្រាំព្រះប្រោស យើងក្លាយខ្លួនជាប្រេតហើយ អូន! ប្រដាប់សម្រាប់ប្រើប្រាស់កូនយើងក៏មិនទាន់បានទិញទុកសោះ ហើយបើអូនសម្រាលកូនថ្ងៃនេះ ឬថ្ងៃស្អែកមិនដឹងទៅសម្រាលឯណាទេ លុយកាក់យើងក៏គ្មាន..."

នាងសយសម្លឹងមុខប្ដីដោយការយើញចិត្តយើញថ្លើមហើយនិយាយឡើង ថា៖

"ទៅសម្រាលឯពេទ្យបង! ខ្ញុំទៅដេកកន្លែងសម្រាប់មនុស្សអនាថា បើខ្ញុំឈឺពោះពេលណាបងជូនខ្ញុំទៅពេទ្យទៅ ក៏វាហើយគ្នាទៅហើយៗ ទម្រាំខ្ញុំចេញពីពេទ្យមកវិញបងមុខជារកប្រាក់ទិញអីវ៉ាន់សម្រាប់កូនយើងបានខ្លះមិនខាន- ល្ហើយគេងសម្រាកទៅបង ខ្ញុំទៅរកដាំបាយហើយ" និយាយចប់នាងសយក៏ រំកិលខ្លួនទៅរកចង្ក្រាន ដែលតាំងនៅជាមួយនឹងបន្ទប់ដេកនោះដែរ។

សមប្រះខ្លួនសន្សឹមៗដោកទៅលើកន្ទេលចាស់មួយហើយយកដៃមកកើយ ជំនួសខ្នើយ... សមនឹកដល់សេចក្ដីលំបាកវេទនាក្នុងមុខរបរចិញ្ចឹមជីវិត ដោយ សមនៅមិនដែលឃើញ មានកម្មករត្រីចក្រយានណាមួយដែលមានឋានៈដូចរូបសមនេះ បើឈប់លែងធាក់ត្រីចក្រយាននឹងទៅរកការងារអ្វីអោយបានគ្រាន់បើជាងនេះឡើយ។

ពេលយប់បន្តិចហើយ...ព្រះច័ន្ទខាងខ្នើតបានភ្លឺត្រចះត្រចង់...

ក្រោយពេលងូតទឹកនិងបរិភោគរួចហើយ សមដូចជាស្រឡះមុខមាត់គ្រាន់បើបន្តិច ហើយមានកំលាំងល្មមចេញទៅរកធាក់ត្រីចក្រយានរកប្រាក់បាន។

សមនិយាយប្រាប់ប្រពន្ធថា ខ្លួនគេនឹងចេញទៅរកប្រាក់មួយសន្ទុះ។នាង សយមិនព្រមអោយទៅ តែលុះសមសន្យាថានឹងត្រឡប់មកផ្ទះវិញក្នុងរវាង២-៣ម៉ោងយ៉ាង នាងក៏ញព្រមអោយប្ដីចេញទៅ។

ចេញផុតពីខ្ទមដូចសម្បុកកណ្ដុរទៅ សមបានធាក់ត្រីចក្រយានឃីតៗតាមវិថីនានា។ លុះទៅដល់ស្ពានកូនកាត់ សមក៏បានជួបនឹងអ្នកជិះពីរនាក់សុទ្ធតែ ប្រុសៗមានវ័យកណ្ដាល ដែលទើបនឹងដើរចេញពីផ្ទះចិន។

អ្នកជិះបក់ដៃហៅចក្រយានអោយឈប់ ហើយក៏ឡើងជិះដោយប្រើដៃជា សញ្ញាបញ្ជាអោយសមធាក់ត្រីចក្រយានតាមបំណងរបស់គេ។ លុះត្រីចក្រយានចេញផុតពីកន្លែងនោះបន្ដិច ម្នាក់ក៏និយាយឡើងថា"យើងជិះលេងអោយសប្បាយចិត្តបន្ដិច"។

សមបានឮគេនិយាយដូច្នោះ ក៏នឹកត្រេកអរតែក្នុងចិត្តដោយគិតថា បើយ៉ាងតិចណាស់ក៏បាន ២០រៀលដែរ ព្រោះអ្នកទាំងពីរនាក់នេះជិះត្រីចក្រយាន លេងលំហែប្រាណ។

ត្រីចក្រយានបានបត់ចុះបត់ឡើងតាមវិថីនានា និងត្រូវឈប់ចាំនៅតាមទីកន្លែងផ្សេងៗទៀត។ ទីបំផុតសមក៏ធាក់ត្រីចក្រយានជូនអ្នកជិះទៅដល់វត្តភ្នំ តាមការបង្គាប់បញ្ជារបស់គេ។ សម្លេងអ្នកជិះបានខ្សឹបគ្នាខ្សាវៗ តែសមមិនបានជាយកចិត្តទុកដាក់នឹងសម្លេងនោះឡើយ។ មួយសន្ទុះក្រោយមកត្រីចក្រយានក៏បានទៅដល់ខាងលិចវត្តភ្នំចំហើយសមបានទទួលនូវពាក្យបញ្ជាអោយ បញ្ឈប់ត្រី ចក្រ យាន។

សមបានបញ្ឈប់ត្រីចក្រយានតាមពាក្យបង្គាប់របស់អ្នកជិះដោយសេចក្ដី នឿយហត់។ ក្នុងខណៈភ្លាមៗនោះ អ្នកជិះម្នាក់ក៏ស្ទុះចុះពីត្រីចក្រយាន ហើយដកកកាំបិតស្នៀត ឯអ្នកជិះម្នាក់ទៀតក៏ចុះពីត្រីចក្រយានដែរ។

"កុំស្រែក!មានប្រាក់ឬទេ?អោយឆាប់មក!"

សង្ឃឹមអ្វី!កម្លាំងកាយក៏គ្មាន ប៉ូលីសក៏គ្មាន!...សមមានសង្ឃឹមតែម្យ៉ាងគឺ ត្រូវលើកដៃសំពះគេព្រមទាំងនិយាយអង្វរករគេថា៖

"ខ្ញុំបាទគ្មានលុយទេលោក!ខ្ញុំបាទទើបនឹងចេញពីផ្ទះមក ក៏មកជួបនឹង លោកតែម្ដង"

"កុំរឹងទទឹងអោយៗឆាប់មក! ម្នាក់កំហែងឡើង"

"ខ្ញុំបាទគ្មានសោះលោក បើលោកមិនជឿសុំលោកឆែកឆេរមើលចុះ"

ពួកគេទាំងពីរនាក់ ក៏ឆែកឆេរមើលតាមហោប៉ៅអាវខោ និងត្រីចក្រយាន របស់សម។ លុះមិនឃើញមានប្រាក់កាសអ្វី សូម្បីមួយសេនសោះនោះម្នាក់ក៏ធាក់សមមួយជើងព្រមទាំងជេរថា៖

"អាឆ្កួត! អញនឹកស្មានថាមានខ្លះ" ហើយចោរទាំងពីរនាក់ក៏នាំគ្នាគេចខ្លួនបាត់ទៅ។

ម៉ោង២៣ហើយ...សមកម្មករត្រីចក្រយានអភ័ព្វដែលគួរឲ្យអាណិតអាសូរនេះក៏បានធាក់ត្រីចក្រយានត្រឡប់ទៅផ្ទះវិញដោយការអស់សង្ឃឹម។សមបានបញ្ឈប់ត្រីចក្រយាននៅមុខខ្ទម។ ទ្វារខ្ទមនៅចំហនៅឡើយ។

សមមើលទៅឃើញប្រពន្ធដេកនៅលើដំណេក។ពន្លឺចង្កៀងប្រេងកាតភ្លឺឡើងព្រឹមៗ សមស្រែកហៅប្រពន្ធពីចំងាយ។ នាងសយស្ទុះក្រោកឡើងទទួល។

"សយ!ថ្ងៃនេះបងស៊យណាស់អូន"សមនិយាយប្រាប់ប្រពន្ធក្នុងខណៈដែល ចូលទៅជិត"បងត្រូវពួកអ្នកលេងវាប្លន់យកប្រាក់ តែគ្រោះជាបងគ្មានទាន់បានប្រាក់មួយសេនជាប់នៅសោះ" ហើយសមក៏បានអធិប្បាយនូវហេតុការណ៍ដែលបានកើតឡើងអោយប្រពន្ធស្តាប់។

"បង!"នាងសយនិយាយទាំងទឹកភ្នែកដោយការអាណិតប្តី "ជួនកាលខ្ញុំអាចនឹងសម្រាលកូនក្នុងយប់នេះក៏មិនដឹង"

សមបើកភ្នែកធំៗ ហើយសួរឡើងថា៖"ម៉េចក៏អូនដឹង?"

"ព្រោះខ្ញុំចេះតែឈឺពោះ ឈឺផ្ចួនៗគ្នាមកពីរបីដងហើយៗមិនមែនឈឺពោះដូចធម្មតាទេបង" សមយកដៃអង្អែលស្មាប្រពន្ធថ្នមៗ ហើយនិយាយទាំងទុក្ខ ព្រួយថា៖

"អូន!បងគ្មានបប្រាក់ល្មមអោយអូនទៅសម្រាលកូននៅពេទ្យឈ្នួលទេមើលទៅអូនត្រូវទៅសម្រាលកូននៅពេទ្យរាជការត្រង់កន្លែងអនាថាហើយមើល ទៅ..."

"មិនអីទេបង! ត្រង់ណាក៏បានអោយតែបានសម្រាលស្រួល"

ប្តីប្រពន្ធទាំងពីរនាក់អង្គុយនិយាយគ្នាក្រោមដំបូលខ្ទមដ៏ស្ងាត់ដែលមានាពន្លឺចង្កៀងប្រេងកាតភ្លឺព្រឹមៗ ដោយសេចក្តីទុក្ខព្រួយជាខ្លាំង។ ជីវិតនៃអ្នកទាំងពីរហាក់ដូចជាកំពុងហៃលនៅក្នុងមហាសាគរ ដែលគ្មានកោះត្រើយ ហើយដែលពោរពេញទៅដោយព្យុះសង្ឃរា។

៚៚៚៚

## ភាគទី១១ ប្រពន្ធស្លាប់គ្មានទីពឹង

ពេលរំលងអាធ្រាត...ប្រហែលជាម៉ោង២កន្លះហើយ...

នាងសយឈឺពោះខ្លាំងឡើងៗ ទាល់តែនាងទ្រាំទ្រមិនបាន។នាងនឹកថាវា ដល់ពេលដែលនាងត្រូវសម្រាលកូនជាប្រាកដ។នាងខំយកដៃអង្រួនដាស់ប្ដី ថ្នមៗឲ្យក្រោកឡើង។

"អូយបង!ខ្ញុំឈឺពោះណាស់" នាងសយប្រាប់ប្ដី

"បើយ៉ាងនេះមើលទៅប្រហែលជាដាច់ខ្យល់ស្លាប់មិនខានទេ ខ្ញុំទើបតែដឹងពេលនេះថាម្ដាយខ្ញុំគាត់ឈឺចាប់ដូចរូបខ្ញុំអញ្ចឹងដែរ-អូយ!ម៉េចក៏ឈឺម្ល៉េះបង!"

សមភ្ញាក់ពីដេកស្រមេងស្រមើងឡើងហើយខំត្រកងអោបប្រពន្ធថ្នមៗ

"ខំអត់បន្ដិចទៅអូន!" សមលួងលោមប្រពន្ធ "ចាំបងទៅហៅសានឲ្យធាក់ស៊ីក្លូជូនយើងទៅពេទ្យ"

នាងសយគ្រវីក្បាល

"ទេបង!មើលទៅដូចជាទៅពេទ្យមិនបានទេ ខ្ញុំឈឺខ្លាំងណាស់ ទម្រាំជិះស៊ីក្លូដល់ពេទ្យ មើលទៅប្រហែលជាដាច់ខ្យល់ស្លាប់ហើយ!"

"បើអញ្ចឹងយើងគិតធ្វើម៉េច?"

"សុំបងទៅអញ្ជើញគ្រូពេទ្យ នរាឲ្យលោកជួយស្រោចស្រង់ជីវិតខ្ញុំផង"

"បើអញ្ចឹងអូនទ្រាំបន្ដិចសិនណា បងនឹងទៅអញ្ជើញលោក"

ហើយសមក៏ប្រញាប់ប្រញាល់ធាក់ត្រីចក្រយានចេញពីកូនខ្ទមទៅ។ លុះ បានទៅផ្ទះថ្មធំៗដែលនៅជាប់នឹងវិថីធំ សមបានបង្អង់ត្រីចក្រយានយន្ដរកមើល អក្សរ។

សមបញ្ឈប់ត្រីចក្រយាននៅត្រង់មាត់ទ្វាររបងនៃផ្ទះថ្មមួយ។ គ្រូពេទ្យនរា ជាគ្រូពេទ្យម្នាក់ដែលមានឈ្មោះបោះសម្លេងក្នុងការព្យាបាលរោគ។

សមយកដៃចុចកណ្ដឹងអគ្គីសនី។ សមឈររង់ចាំដោយការរសាប់រសល់ មួយសន្ទុះក៏មានមនុស្សដើរចេញមកមកបើកទ្វារហើយស្រែកសួរថា៖

"អ្នកណាហ្នឹង?" សមឆ្លើយឡើងភ្លាម"ខ្ញុំបាទមកសុំអញ្ជើញលោកគ្រូពេទ្យ ទៅមើលប្រពន្ធខ្ញុំបាទសម្រាលកូន"

ទ្វារបានរបើកចេញពីគន្លឹះយ៉ាងយឺតៗ។ អ្នកដែលមកបើកទ្វារនោះជាអ្នកបំរើរបស់លោកគ្រូពេទ្យនរា។បុរសនោះខំសម្លឹងមើលមុខសមស្ទើរមិនដាក់ភ្នែក។ ពន្លឺអគ្គីសនី៣៥ទៀន ដែលនៅខាងលើខ្លោងទ្វារបានធ្វើអោយអ្នកបម្រើលោកគ្រូពេទ្យស្គាល់មុខថាជាសម កម្មករត្រីចក្រយានដែលជួលខ្ទមគេនៅជ្រៅទៅក្នុងច្រកខាងក្រោម។អ្នកបម្រើនេះសម្លឹងមើលមុខសមដោយការយល់ចិត្តយល់ថ្លើម និងអាណិតអាសូរ "មើលទៅដូចជាគ្មានសង្ឃឹមទេបង!" អ្នកបម្រើនោះនិយាយនឹងសម "បើខ្ញុំចូលទៅដាស់លោក មុខជាខឹងនឹងខ្ញុំជាមិនខានមើលទៅដូចជាគ្មានសង្ឃឹមថាលោកនឹងអញ្ជើញទៅមើលទេហើយយប់អញ្ចឹងផងដូចជាមិនងាយទេក្រែងតែអ្នកជម្ងឺនោះជាអ្នកធំ-អ្នកមានខ្ញុំក៏មិនហ៊ានថាដែរក្រែងលោលោក អញ្ជើញទៅ"

សមដកដង្ហើមវែងៗលើកដៃសំពះអ្នកបម្រើលោកគ្រូពេទ្យនរាដោយសេចក្តីគោរពហើយ ក៏និយាយអង្វរករដោយពាក្យគួរអោយអាណិតអាសូរ។

"សូមមេត្តាប្រថុយចូលទៅដាស់លោកសាកមើលក្រែងលោលោកព្រម អញ្ជើញទៅសុំអាណិតតែខ្ញុំទៅចុះ"

អ្នកបម្រើលោកគ្រូដូចជានឹកចង្អៀតចង្អល់ចិត្តជាខ្លាំង

"ខ្ញុំអាណិតបងឯងណាស់តែថា...លោកមុខជាជេរប្រទេចខ្ញុំជាមិនខាន"

អ្នកបម្រើគ្រូពេទ្យស្ងៀមមួយស្របក់ទើបនិយាយតទៅទៀត "ណ្ហើយចុះ បង យើងសុទ្ធតែជាអ្នកក្រដូចគ្នាខ្ញុំប្រថុយចូលទៅដាស់លោកសាកមើលទៅចុះ-មកបង!ចូលមកខាងក្នុងមក បងត្រូវនិយាយអង្វរករលោកអោយមែនទែនណាក្រែងលោលោកអាណិតលោកទៅមើលអោយ..."

សមដើរតាមអ្នកបម្រើលោកគ្រូពេទ្យនរាចូលទៅក្នុងបរិវេណនៃផ្ទះ ហើយឈររង់ចាំនៅត្រង់មាត់ជណ្តើរ។

អ្នកបម្រើលោកគ្រូពេទ្យឡើងទៅលើផ្ទះ។ មួយសន្ទុះភ្លើងអគ្គិសនីក៏មាន ពន្លឺភ្លឺចិញ្ចាចឡើងនៅត្រង់យ៉មុខផ្ទះ។សភាពបុរសរូបរាងធាត់ធំបិតនៅក្នុង មជ្ឈឹមវ៉ៃយស្លៀកពាក់ខោអាវនៅផ្ទះ បានដើរចេញមកពីបន្ទប់កណ្តាល។ បុរសនេះគឺគ្រូពេទ្យនរា គ្រូពេទ្យដែលមានឈ្មោះល្បីល្បាញម្នាក់នៅក្នុងព្រះរាជធានី។ពេលនោះអ្នកមប្រើគ្រាន់តែដាស់លោកគ្រូពេទ្យឡើងហើយជំរាបលោកថាមានមនុស្សអញ្ជើញលោក អោយទៅមើលប្រពន្ធសម្រាលកូន។ គ្រូពេទ្យយល់ខុសនឹកស្មានថាជា

អ្នកជិតខាងក៏ប្រញាប់ប្រញាល់ចេញពីបន្ទប់ដេកដើរចុះមករកដើម្បីនឹងសាកសួរមើលអាការៈរោគជាមុនសិន។

តែលុះក្រលេកមើលទៅឃើញសមទឹកមុខរបស់គ្រូពេទ្យនរាក៏ប្រែទៅជាក្រញ៉ូវដែលជាការសំដែងនូវអាការៈមិនពេញចិត្តភ្លាម។ សមដើរទៅលុតជង្គង់លើកដៃសំពះលោកគ្រូពេទ្យនរានៅក្បែរកាំជណ្តើរ។

"សុំព្រះតេជគុណាមេត្តាអាណិអាសូរសត្វទីទ័លក្រម្តងទៅចុះទានប្រោសប្រពន្ធខ្ញុំបាទកំពុងឈឺពោះសម្រាលកូន ខ្ញុំបាទមកសុំអញ្ជើញព្រះតេជគុណាទៅមើលទានប្រោស"។

លោកគ្រូពេទ្យនរាជញ្ជក់មាត់ហើយជ្រួញចិញ្ចើមមិនព្រមនិយាយអ្វីនឹងសមក្រៅពី គ្រាន់តែសម្លឹងមើលដោយក្រសែភ្នែកដែលសំដែងនូវការរង្កៀសហើយ បែរមកទេសនាដាក់អ្នកបម្រើរបស់លោក "អាសួស! អាឯងអីក៏ចេះម្ល៉េះហ៊ានទៅដាស់អញទាំងស្មើនេះដែលអញកំពុងតែដេកលក់ស្រួលៗ អញស្មានតែពេទ្យ ធំគេមកតាមអញទេតើ បើដឹងថាអញ្ចឹងអញមិនចុះមកទេ យី អាសួស! អាឯងនេះចំជាភ្លើមែន"។

សមអោនក្បាលចុះលើកដៃសំពះលោកគ្រូពេទ្យនរាម្តងទៀតហើយក៏អង្វរករដោយសំឡេងញ័រៗម្តងទៀត។

"បើព្រះតេជគុណាមិនមេត្តាជួយសង្គ្រោះផងទេនោះ មើលទៅប្រពន្ធរបស់ខ្ញុំបាទពិតជាមានអន្តរាយដល់អាយុជីវិតពីការសំរាលកូននេះជាមិនខានឡើយទានប្រោស "ទេ!" លោកគ្រូពេទ្យនរាឆ្លើយឡើងទាំងមួម៉ៅ "ខ្ញុំគ្មាននាទីអីត្រូវទទួលការខុសត្រូវក្នុងការស្លាប់រស់របស់ប្រពន្ធឯងទេ សុំអញ្ជើញទៅវិញចុះ"។

"សូមព្រះតេជគុណាជួយយកតែបុណ្យទៅចុះទានប្រោស"

"កុំយកបុណ្យបាបមកនិយាយនឹងខ្ញុំខ្ញុំមិនត្រូវការបុណ្យអញ្ចឹងទេសុំយកទៅពេទ្យធំទៅ បើយកខ្ញុំទៅមើលទាល់តែគិតលុយអោយខ្ញុំ បើតិចណាស់ក៏មួយពាន់រៀលដែរ ខ្ញុំខំរៀនសូត្រមកអស់ប្រាក់មិនតិចទេ អ្នកឯងមានដែលជួយប្រាក់អោយខ្ញុំរៀនសូត្រឯណា?ចេះតែខ្ញុំអាណិតៗទៅមើលទទេយ៉ាងម៉េចបានទៅ! ទៅវិញចុះ ហើយដឹកទៅពេទ្យធំទៅ..."

និយាយចប់ហើយ លោកគ្រូពេទ្យនរាក៏ឡើងទៅលើផ្ទះវិញ។ សមខាំធ្មេញក្រឹតចង់តែស្រែកប្រកាសថាអ្នកក្រមិនខុសអ្វីពីសត្វតិរច្ឆាន ប៉ុន្តែសមនឹកដល់ប្រពន្ធដែលកំពុងដេកឈឺ បើនឹងស្រែកទៅក្រែងមានរឿងរ៉ាវ។ សមដើរចេញយ៉ាងរួសរាន់ពីអាណាខេត្រនៃផ្ទះរបស់គ្រូពេទ្យនរា។

សមធាក់ត្រីចក្រយានត្រឡប់ទៅខ្ទមវិញ ដោយសេចក្តីអស់សង្ឃឹម។តែ មុនដល់ខ្ទមនោះបន្តិចសមបានឮថ្ងូររបស់នាងសយដោយសេចក្តីឈឺចាប់ក្នុងការឈឺពោះសំរាលកូន ព្រោះវាចេះតែឈឺទ្វេរឡើងៗជាលំដាប់។

សមបានបានបញ្ឈប់ត្រីចក្រយាននៅពីមុខកូនខ្ទម។ ដោយសារពន្លឺភ្លើងចង្កៀង ដែលព្យួរនៅជញ្ជាំងសមបានក្រឡេកមើលទៅឃើញសានដែលជាកម្មករនៅផ្ទះជិតខាងកំពុងអង្គុយមើលនាងសយដោយទឹកមុខក្រៀមក្រំ។

សមនឹកអាណិតប្រពន្ធខ្លោចចិត្ត ហើយក៏ស្ទុះទៅអង្គុយជិតនាង។ លុះនាងសយបើកភ្នែកមើលទៅឃើញប្តីនាង ដូចជាមានកំលាំងគ្រាន់បើឡើងបន្តិច។

"អូយ!" នាងស្រែកឡើងដោយការឈឺចាប់

"ម៉េចទៅគ្រូពេទ្យអញ្ជើញមកទេបង?"

សមយកដៃអង្អែលរួចអង្អែលថ្នមៗ

"អូនអើយ! បងដូចជាទ័លប្រាជ្ញហើយ..." សមនិយាយប្រាប់ប្រពន្ធ "គ្រូ ពេទ្យគេមិនព្រមមកទេ គេថាបើអោយគេមួយពាន់ទើបគេមក ហ៊ឹះ! គ្រូពេទ្យអីបូជាប្រាក់ដូចព្រះអញ្ចឹង" និយាយចប់សមបែរមកខាងសាន" សាន!ឯងអាណិតគ្នា កុំអាលត្រលប់ទៅផ្ទះណាគ្នាគ្មានអ្នកណាក្រៅពីឯងទេអាណិតនៅជួយគ្នាផង!

"មិនអីទេសម" សានងក់ក្បាលទទួលហើយឆ្លើយឡើង" គ្នានឹងនៅជួយមើលឯងទាល់តែប្រពន្ធឯងបានសំរាលកូនរួចមិនអីទេយើងជួយគ្នាម្នាក់មួយដៃមួយជើងទៅ"។ទឹកភ្នែកបានស្រក់ចុះចាកត្របកភ្នែកទាំងគូរបស់សមហើយ ទឹកភ្នែកគ្រប់ៗដំណក់នោះវាស្រក់ចុះ ព្រោះការអាណិតនិងតូចចិត្ត។ក្នុងខណៈ នោះយាយចាស់ម្នាក់មានរូបរាងស្គម ខ្នងកោង ដែលជាអ្នកជិតខាងសមដែរក៏បានដើរចូលមកដល់មាត់ទ្វារខ្ទម។ យាយចាស់ជរានេះឈ្មោះប៉ោង។ គាត់នៅអាស្រ័យនៅជាមួយក្មួយប្រុសគាត់ម្នាក់ ដែលធ្វើការជាកម្មករលីសែងនៅកំពង់ផែ។សមនិងសានបែរមុខមកមើលយាយប៉ោង។

"ឱ យាយ ឬ ! " សមស្រែកអញ្ជើញ " អញ្ជើញចូលមកលោកយាយ "

យាយប៉ោងដើរចូលទៅក្នុងផ្ទះ ហើយអង្គុយជិតនាងសយ ដែលកំពុង ដេកថ្ងូរ។

" ម៉េចទៅហើយចៅ ? " យាយប៉ោងសួរ " ម៉េចក៏មិនដឹកយកទៅពេទ្យ "

" សយថាជិះស៊ីក្លូមិនបាន " សមបានឆ្លើយឡើង " ព្រោះឈឺពោះខ្លាំងណាស់ពេទ្យក៏នៅឆ្ងាយក្រែងទៅមិនទាន់"

"អើហ្ន៎! " យាយប៉ោងនិយាយឡើង " បើអញ្ចឹងធ្វើយ៉ាងម៉េចទៅយាយក៏មិនសូវប៉ិនប្រសប់ ក្នុងរឿងនេះដែរ តែក៏ល្មមជួយឯងបានខ្លះៗដែរ ក្រែងឯង ទៅអញ្ជើញគ្រូពេទ្យមកមើលមិនមែន ឬ"

"បាទយាយ!" សមឆ្លើយឡើងទាំងតូចចិត្ត "តែគេមិនព្រមមកមើលទេ គេថាយ៉ាងតិចណាស់ក៏គេយកមួយពាន់រៀលដែរ"

"ហ៊ឹះ" យាយប៉ោងនិយាយឡើង "យើងរកព្រឹកស៊ីល្ងាចអញ្ចឹងទៅរកប្រាក់មួយពាន់ឯណាមកឲ្យគេបានសម! មើលទៅសយប្រហែលជាសំរាលកូនឥឡូវហ្នឹងហើយ ឯងត្រូវបង្កាត់ភ្លើងដាំទឹកទុកអោយហើយទៅយាយនឹងជួយឯង ចំពោះការដែលយាយអាចជួយបានធ្វើម៉េចសម! កើតមកជាអ្នកក្រវាត្រូវតែពិបាកអញ្ចឹង"

សមខាំធ្មេញណែន...ហើយសម្លឹងមុខប្រពន្ធជាទីស្រឡាញ់ដោយសេចក្តី អាណិតអាសូរ។

យាយ! សមបែរមកនិយាយមកនិយាយនឹងយាយប៉ោង "គ្រូពេទ្យត្រូវបំពេញខ្លួនដើម្បីជាប្រយោជន៍ដល់បងប្អូនមនុស្សដោយមិនរើសមុខថាជាអ្នកមាន អ្នកក្រ ឬជាតិណាសាសន៍ណាឡើយតែឥឡូវខ្ញុំដឹងហើយថាមានគ្រូពេទ្យខ្លះបូជាប្រាក់ដូចព្រះហើយ មានគ្រូពេទ្យតិចណាស់ដែលជាគ្រូពេទ្យបំពេញខ្លួនដើម្បីជាប្រយោជន៍ដល់បងប្អូនមនុស្សទាំងឡាយ"

"ណ្ហើយសម!កុំនិយាយអីច្រើន" សាននិយាយកាត់ឡើង"យើងគិតតែរឿង យើងឯណេះទៅ-ចាំគ្នាទៅបង្កាត់ភ្លើងដាំទឹកអោយបើមានកាអីល្មមប្រើគ្នាក៏សុំប្រើមកចុះ-យើងជាពួកកម្មករដូចគ្នា យើងត្រូវតែជួយគ្នាទៅមក បើគ្មានប្រាក់កាសជួយយើងត្រូវយកកំលាំងជួយ"

"អរគុណនឹងឯងណាស់ហើយសានដែលឯងអាណិតគ្នាយ៉ាងនេះ"

សានមិនឆ្លើយថាអ្វីហើយដើរចូលទៅរកចង្ក្រាន។

សភាពស្ងប់ស្ងាត់បានកើតឡើង មួយសន្ទុះនាងសយអង្គុយខ្លះដេកខ្លះ ដោយមានទឹកមុខសស្លាំងហើយបែកញើសជោគថ្ងាស។ យាយប៉ោងក៏ចាប់ផ្តើមរៀបចំចាត់ចែងធ្វើការតាមរបៀបផ្សងបុរាណ។

អាការៈឈឺពោះរបស់នាងសយ បានបាត់ទៅមួយពេលមួយគ្រាហើយក៏ចាប់ផ្តើមឈឺឡើងទៀត។ គ្រានេះនាងសយឈឺខ្លាំងជាងមុន នាងត្រូវរឹតអង្អែលពោះខ្លួនឯងហើយស្រែកថ្ងូរខ្លាំងឡើងៗដែលគួរអោយអាណិតអាសូរជាខ្លាំង។

សមឆ្លេឆ្លាចុះឡើងដោយសេចក្តីភិតភ័យ។ទីបំផុតសមក៏រំកិលខ្លួនមក អង្គុយជិតប្រពន្ធហើយក៏ត្រកងបីឡើងព្រមទាំងនិយាយលួងលោមថា៖

"សយអូន! សុំអូនអត់ទ្រាំបន្តិចទៅបន្តិចទៀតបាត់ឈឺហើយអូន!"

នាងសយអោបប្តីជាប់ហើយបម្រះននៀល ដោយការឈឺចាប់។យាយប៉ោងពិនិត្យមើលផ្ទៃពោះរួចហើយាក៏ដកដង្ហើមធំ។ គាត់ងើបមុខឡើងសំលឹងមើលមុខសមហើយនិយាយថា៖

" កូនចេញមកទទឹងខ្លួនសម! ឱ ឯណាសានទៅណាហើយ?"

សានស្រែកឆ្លើយពីចង្ក្រានហើយក៏ដើរមករកយាយប៉ោង។យាយប៉ោងខំនិយាយទាំងត្រហេប ត្រហបទៅកាន់សានថា៖

"ជួយធាក់ស៊ីក្លូទៅកាន់ពេទ្យចិនបន្តិចយាយទៅរកពឹងយាយប៉ោះដែលកាត់ធ្វើឆ្មបអោយមកជួយយាយធ្វើមិនបានទេឥឡូវកូនចេញមកទទឹងខ្លួនមានតែយាយប៉ោះទេ ទើបជួយរួចទៅឆាប់ឡើងនឹងអាលត្រឡប់មកវិញ បណ្តោយអោយនៅឈឺអញ្ចឹងមិនស្រួលទេ"

សមលើកដៃសំពះយាយប៉ោងហើយនិយាយដោយសំឡេងញ័រៗ។

"អរគុណលោកយាយណាស់ហើយសូមលោកយាយអាណិតយកតែបុណ្យទៅចុះ ខ្ញុំមិនដឹងទៅពឹងពាក់អ្នកណាក្រៅពីយាយទេ"

យាយប៉ោងស្ទុះក្រោកឡើង ដោយរួសរាន់ ហើយដើរនាំមុខសានចេញពី ខ្ទមរបស់សមទៅ។ ត្រីចក្រយានបានបោលចេញពីច្រកតូចសំដៅទៅផ្លូវធំ។ នាងសយមានអាការៈឈឺចាប់ជាខ្លាំង។ សមគ្មានអ្វីជួយប្រពន្ធក្រៅពីគ្រាន់តែអង្គុយអោបឡើយដោយទឹកភ្នែករបស់សមក៏ហូរចេញមកសស្រាក់ព្រោះសេចក្តីអាណិតអាសូរចំពោះប្រពន្ធ។ "សយអូន" សមនិយាយឡើងទាំងទឹកភ្នែក "នេះព្រោះអូនជាប្រពន្ធបងកុំអីអូនមិនពិបាកអញ្ចឹងទេខំអត់ធ្មត់បន្តិទៅអូន!បន្តិចទៀតមយាយប៉ោងគាត់ត្រឡប់មកវិញហើយ"។

នាងសយចាប់ដៃប្តីច្របាច់ណែន ហើយស្រែកថ្ងូរ "អ៊ុំយបង!ខ្ញុំដាច់ខ្យល់ ស្លាប់ឥឡូវហ្នឹងហើយ ឱទេវតាលោកអើយ! សុំលោកជួយសង្គ្រោះជីវិត កូនខ្ញុំផង"

៣០នាទីបានកន្លងផុតទៅ...សានបានខំប្រឹងធាក់ត្រីចក្រយានយ៉ាងលឿនតាមវិថីនាកណ្តាលសភាពងងឹតនិងស្ងប់ស្ងាត់។ យាយប៉ោងអង្គុយលើត្រីចក្រយានជាមួយនឹងយាយចាស់ម្នាក់ទៀតដែលជាឆ្មបតាមរបៀបបែបបុរាណ តែបែបភាពរបស់យាយប៉ោងពេញទៅដោយក្តីអន្ទះសា។

ក្នុងពេលដែលយាយប៉ោងបានទៅដល់ផ្ទះយាយប៉ោះនោះយាយប៉ោងក៏គោះទ្វារហៅដោយសេចក្តីស្និទ្ធស្នាល។

យាយប៉ោះ ប្រញាប់ប្រញាល់រៀបចំខ្លួននឹងកន្ត្រកម្ជុលស្លា ហើយក៏ឡើងជិះត្រី ចក្រយានចេញពីផ្ទះមកជាមួយនឹងយាយប៉ោងភ្លាមដែលគាត់ពេញចិត្តជួយសង្គ្រោះដោយមិនត្រូវការយកមាសប្រាក់អ្វី ឡើយ។

ត្រីចក្រយានបានបត់ចូលទៅតាមច្រកផ្លូវតំរង់ទៅរកខ្ទមរបស់សម ហើយសាននៅតែខំប្រឹងធាក់យ៉ាងលឿនគ្មានបង្អង់ជើងឡើយព្រោះព្រួយបារម្ភនឹងជំងឺនាងសយលុះទៅដល់មុខខ្ទមសានក៏ចាប់ហ្វ្រាំងបញ្ឈប់ត្រីចក្រយានភ្លាម។

សានលោតចុះពីលើកែប ហើយស្ទុះចូលទៅក្នុងខ្ទមភ្លាមក្នុងខណៈនោះ សានមិត្តកម្មកររបស់សមក៏ស្រាប់តែស្រឡាំងកាំងព្រោះបានឃើញនូវភាព ដែលធ្វើអោយស្លុតរន្ធត់ចិត្តជាខ្លាំង។

នាងសយដេកត្រង់ខ្លួនស្តូកនៅលើរនាបខ្ទមហើយមានភួយចាស់មួយគ្របជិតតាំងពីក្បាលដល់ចុងជើង។ ចំណែកខាងសមកំពុងទ្រោបមុខនៅលើរូបដែលគ្របភួយនោះហើយយំខ្សឹកខ្សួល សានដឹងច្បាស់ថានាងសយប្រពន្ធរបស់សមបានលាចាកលោកនេះទៅហើយ ដោយគ្មានថ្ងៃនឹងវិលត្រឡប់មក វិញឡើយ។

ខណៈនោះយាយប៉ោង ដែលនាំយាយប៉ោះចូលទៅក្នុងខ្ទមតាមក្រោយសាននោះ ក៏ស្រែកឡើងយ៉ាងខ្លាំងក្នុងការដែលបានឃើញនូវរូបរាងកាយប្រាសចាកវិញ្ញាណរូបសពនាងសយដែលដេកស្តូកស្តឹង ហើយមានភួយចាស់មួយគ្របពីលើនោះ។

"ឱពុទ្ធោ! អនិច្ចាទុក្ខំអើយ!" យាយប៉ោងពោលឡើងដោយទឹកមុខស្ញប់ស្ញូត ហើយក៏ងាកមុខទៅរកយាយប៉ោះ ដែលជាសម្លាញ់របស់គាត់ព្រមទាំងនិយាយ ថា៖

" យើងមកយឺតពេកហើយប៉ោះ ឥឡូវគ្នាដាច់ខ្យល់ស្លាប់ទៅហើយ!"

យាយប៉ោះ ឈរស្រទ្បាំងកាំងមួយសន្ទុះ ទើបនិយាយតិចៗ ដោយសម្លេងញ័រៗថាៈ " ឱពុទ្ធោអើយ! សុំអោយវិញ្ញាណរបស់ឯងបានទៅកើតក្នុងទីសុខចុះ យាយតាំងចិត្តថាមកជួយសង្គ្រោះជីវិតឯងតែមិនទាន់បានជួយអី ឯងក៏ផុតដង្ហើមស្លាប់ទៅហើយ ព្រោះឯងសំរាលកូនមិនរួចបើយាយបានមកដល់មុននេះកន្លះម៉ោង ឯងប្រហែលជាមិនស្លាប់ទេ- តាមពិតគួរតែប៉ោងឯងទៅរកខ្ញុំតាំងពីពេល ចាប់ឈឺពោះនោះមកណ៎ាប៉ោង"

យាយប៉ោងបាននាំយាយប៉ោះចូលទៅអង្គុយជិតសព...សមងើបមុខឡើង សម្លឹងមើលយាយចាស់ទាំងពីនាក់។ សមមានរង្វង់មុខប្រឡាក់ជោគជាំដោយទឹកភ្នែកមានសក់កន្រ្ទើងកន្រ្ទាយមានរង្វង់ភ្នែកឡើងក្រហមដោយសេចក្តីតូចចិត្ត និងសោកសៅ ដែលមើលទៅដូចជា ថាខណៈនេះសមគ្មានសតិសម្បជញ្ញនៅក្នុងប្រាណឡើយ។

" ជំរាបសួរលោកយាយ!" សមនិយាយទាំងទឹកភ្នែកហើយលើកដៃសំពះ

"សយបានស្លាប់ចោលខ្ញុំទៅហើយ!" នាងស្លាប់នៅក្នុងរង្វង់ដៃត្រកងបីឱបរបស់ខ្ញុំ-ខ្ញុំមិនដែលតក់ស្លុតរន្ធត់អីដូចជាការតក់ស្លុតរន្ធត់ចំពោះខ្មោចប្រពន្ធរបស់ខ្ញុំទេ-ខ្ញុំអរគុណានឹងលោកយាយណាស់ ដែលលោកយាយមេត្តាមកជួយខ្ញុំបើទុកជាមកមិនទាន់ក៏គង់តែមានឈ្មោះថា"លោកយាយចេះជួយឈឺឆ្អាលសង្គ្រោះបងប្អូនមនុស្សដូចគ្នាដែរ " យាយប៉ោះនៅស្ងៀមមិននិយាយថាអ្វី។ គាត់អង្គុយសម្លឹងមើលសពដោយទឹកមុខក្រៀមក្រំ។សានខិតចូលទៅអង្គុយជិតសម ហើយយកដៃអង្អែលខ្នងសមថ្នមៗព្រមទាំងនិយាយលួងលោមថាៈ

"សម!ធ្វើយ៉ាងម៉េចសេចក្តីស្លាប់ជាការធម្មតារបស់មនុស្សលោក! នេះជាកម្មរបស់ប្រពន្ធសមឯងទេសមឯងកុំទុក្ខសោកអីខ្លាំងពេកត្រូវគិតថាគ្មានអ្នកណាអាចគេចផុតពីសេចក្តីស្លាប់បានទេណ៎ាសម..."

"សាន! គ្នាថាមិនមែនកម្មទេ" សមឆ្លើយឡើងទាំងទឹកភ្នែក " ប្រពន្ធរបស់គ្នាស្លាប់នេះក៏ព្រោះគ្មានគ្រូពេទ្យឬឆ្មបមកជួយមើលប្រសិនបើមានគ្រូពេទ្យឬឆ្មបមកជួយមើលនោះម្ល៉េះសមគ្នាបានកូនម្នាក់ ដែលអាចធ្វើអោយគ្នាបានសប្បាយ រីករាយទៅហើយសាន..."

"តែទុកជាយ៉ាងណាប្រពន្ធរបស់សមឯងក៏បានជាស្លាប់ហួសទៅហើយ"សាននិយាយលួងលោម" យើងកុំគិតពីរឿងគ្រូពេទ្យឬឆ្មបធ្វើអីទៀតបើទុកជាយ៉ាងម៉េចក៏មិនរស់វិញដែរ-ណ្ហើយសម! យើងគិតពីរឿងចាត់ការបូជាសពទៅចុះ សម..."

"ហ្នឹងហើយសម" យាយប៉ោងនិយាយកាត់ឡើង"ល្ងើយកុំគិតអីច្រើនពេក យើងគិតគូរពីរឿងបូជាសពនាងសយទៅចុះ បើឯងមានការអីដែលល្មមប្រើ យាយក៏សុំប្រាប់យាយមកចុះ យាយនឹងជួយឯងទាល់តែផុតចុងផុតដើម..."

"សមប្រពន្ធ!..." សមពោលឡើងទាំងរអាក់រអួល "ឱ លោកយាយអោយខ្ញុំធ្វើយ៉ាងម៉េចលោកយាយបើខ្ញុំគ្មានប្រាក់កាសអញ្ចឹង-ខ្ញុំអស់សង្ឃឹមហើយលោកយាយខ្ញុំជាមនុស្សអភ័ព្វខ្លាំងណាស់លោក យាយមុខជានឹកវេទនាជួសខ្ញុំមិនខាន បើខ្ញុំជំរាបលោកយាយថាខ្ញុំមានប្រាក់នៅសល់ត្រឹមតែសាមសិបរៀលប៉ុណ្ណោះខ្ញុំគ្មានប្រាជ្ញានឹងចាត់ការបូជាសពប្រពន្ធរបស់ខ្ញុំទេលោកយាយ..."

យាយប៉ោះដកដង្ហើមធំ ហើយវែងៗ។គាត់លូកដៃទៅក្នុងហោប៉ៅអាវហើយខិតចូលទៅជិតសម ព្រមទាំងហុចក្រដាសប្រាក់ដប់រៀលពីរសន្លឹកទៅអោយសម រួចនិយាយថា សម! យាយសុំចូលកុសលនឹងឯងម្ភៃរៀលចៅ យាយ ក៏ក្រណាស់ដែររកស៊ីល្ងាចតែក៏ពេញចិត្តជួយអ្នកក្រដូចគ្នាល្ងើយ! យាយសុំលា ឯងទៅផ្ទះវិញហើយសម សេចក្តីត្រេកអរឥតឧបមាបានជ្រួតជ្រាបចូលទៅក្នុង បេះដូងរបស់សម ។សមគិតថា យាយប៉ោះជាអ្នកក្រជាឆ្មបបុរាណ តែគាត់ពេញ ចិត្តក្នុងការជួយសង្គ្រោះគ្នាដោយមនុស្សធម៌ លុះជួយសង្គ្រោះឃិតយោងអ្វីមិនបាន គាត់ក៏សុខចិត្តលះបង់ប្រាក់កាសជួយក្នុងការកុសលបូជាសពម្ភៃរៀលទៀត ហើយប្រាក់កាសម្ភៃរៀលរបស់គាត់នោះរាប់ថាជាប្រាក់មានចំនួនច្រើនណាស់ ។ សមលើកដៃសំពះយាយប៉ោះហើយ ក៏ទទួលយកប្រាក់ម្ភៃរៀលនោះដោយសេចក្តីគោរព។

"លោកយាយ! ខ្ញុំអរគុណនឹងលោកយាយណាស់ហើយលោកយាយ" សមនិយាយទាំងខ្សឹកខ្សួល ហើយងាកទៅនិយាយជាមួយសាន "សាន! សានឯងឃើញទេដូចជាប្លែកឆ្ងាយណាស់រវាងយាយប៉ោះនិងគ្រូពេទ្យនរា... សានអើយ! មានតែអ្នកក្រទេ ដែលចេះយល់ចិត្តយល់ថ្លើមគ្នា- សុំសានឯងជួយដឹកយាយត្រឡប់ទៅផ្ទះគាត់វិញផងណា៎សាន"

"អឺមិនអីទេសម!" សានងក់ក្បាលទទួលហើយនិយាយឡើង" មិនអីទេចាំ គ្នាដឹកគាត់ទៅសមឯងមានការអីល្មមបានការអីអាចប្រើគ្នាបាន ក៏សុំប្រើមកចុះ កុំក្រែងចិត្តអីគ្នានឹងជួយឯងអោយពេញកំលាំង ទោះជាលំបាកលំបិនយ៉ាងម៉េចគ្នាត្រូវតែជួយបូជាសពប្រពន្ធឯងអោយវារួចជ្រះស្រឡះទៅយើងចេះតែជួយគ្នា តាមសភាពមានក្រអញ្ចឹងទៅណា៎សម..." សមញញឹមទាំងទឹកភ្នែកដោយសេចក្តីត្រេកអរចំពោះពាក្យសំដីរបស់សាន។សមសម្លឹងមើលតាមសានដែលកំពុងតែនាំយកយាយប៉ោះដើរចេញពីខ្ទមទៅ។

យាយប៉ោងបានចាត់ចែងរកទៀនធូបយកមកអុចនៅលើក្បាលដំណេកសពតាមទំនៀម ហើយក៏រៀបចំអីវ៉ាន់ក្នុងខ្ទមនោះអោយមានរបៀបរៀបរយ។ ចំណែកខាងសមវិញគ្មានកំលាំងចិត្ត នឹងជួយធ្វើអ្វីបានឡើយបានតែអង្គុយអោបក្បាលជង្គង់យំខ្សឹកខ្សួលអាឡោះអាល័យ និងអាណិត អាសូរខ្មោចប្រពន្ធ ប៉ុណ្ណោះ។

សមកម្មករអភ័ព្វគួរអោយអាណិត បានត្រូវប្រពន្ធស្លាប់ចោលទៅហើយ ដោយការសំរាលល កូនមិនរួច ព្រោះមិនបានទទួល និងការជួយជ្រោមជ្រែងពីគ្រូពេទ្យឬឆ្មបណាមួយ...មិនតែប៉ុណ្ណោះ ឥឡូវនេះត្រីចក្រយាន ដែលជាគ្រឿង ឧបករណ៍ដ៏សំខាន់សំរាប់ប្រកបការចិញ្ចឹមជីវិតរបស់សម នោះត្រូវបានម្ចាស់គេ ដកហូតយកទៅវិញហើយ ព្រោះសមគ្មានប្រាក់បង់ថ្លៃឈ្នួលអោយគេ ជីវិត របស់សមកំពុងតែបិតក្នុងវិបត្តិយ៉ាងធ្ងន់ធ្ងរ...ពេលលលនេះសមអស់ខ្លួនប្រាណហើយហើយរហូត ដល់ទៅប្រពន្ធទៀតផង...សមបានចាត់ការបូជាសពនាងសយយ៉ាងស្ងាត់ៗដោយសារពួកមិត្តភក្តិ កម្មករដែលបានបរិច្ចាគប្រាក់បន្តិចម្នាក់ៗជួយជ្រោមជ្រែងក្នុងការនេះ......

ឲ្យឲ្យឲ្យឲ្យឲ្យឲ្យ

## ភាគទី១២ ការរមិលគុណនៃអ្នកនយោបាយ

ការវិលវល់ផ្លាស់ប្តូរ ឬប្រែប្រួលនៃជីវិតរបស់មនុស្សតែងប្រព្រឹត្តទៅជាធម្មតា ហើយជីវិត របស់សមក៏មានភាគរួមនៅក្នុងការនេះដែរ...

ឥឡូវនេះសមជាកម្មករទំនេរទៀតហើយ។ រាល់ៗថ្ងៃសមខំស្វះស្វែងរកការ ងារធ្វើ។ជា ពិសេសសមខំស៊ើបសួររកជួលត្រីចក្រយានមកធាក់ទៀត តែថាម្ចាស់ ត្រីចក្រយានគ្រប់កន្លែងសុទ្ធ សឹងតែទារប្រាក់កក់មុនយ៉ាងតិចមួយរយហាសិបរៀល។

សមនឹកក្រែងចិត្តម៉ី និងម៉ុមជាខ្លាំង ព្រោះកាលបូជាសពនាងសយ ម៉ី និង នាងម៉ុមបាន លះបង់ប្រាក់កាសជាច្រើនជួយជាកុសលក្នុងពិធីនោះមិនតែប៉ុណ្ណោះមានពេលច្រើនដល់ណាស់ មកហើយម៉ី និងនាងម៉ុមបានជួយសង្គ្រោះក្នុងកាលដែលសមធ្លាក់ខ្លួនលំបាកវេទនា។ តែជាការ ចាំបាច់ ដែលសមសំឡឹងមើលទៅដូចជាគ្មានឃើញអ្នកណាអាចជួយជ្រោមជ្រែងខ្លួនបានសោះ ក្រៅពីប្តីប្រពន្ធទាំងពីរនាក់នេះសោះឡើយ។ តែថ្ងៃនោះលុះសមបានដើរទាំងក្រៀមក្រំ ទៅដល់ផ្ទះ នៃមិត្តភក្តិនោះសម បានឃើញម៉ីកំពុងដេកឈឺនៅនឹងដំណេកដោយមានរាងកាយស្លាំងស្គមមាន

សុខភាពទ្រុឌទ្រោមក្បាលជង្គង់ទាំងពីរឡើងហើមខុសធម្មតាព្រោះការត្រាកត្រាំដោយសារការធាក់ត្រីចក្រយានខ្លាំងពេកនុះ ឯង។

" សម! " ម៉ីនិយាយឡើងតិចៗ "គ្នាឈឺជិតកន្លះខែមកហើយស៊ីក្លូគ្នាម្ចាស់គេក៏អូសយកទៅវិញហើយ-សព្វថ្ងៃគ្នាកំពុងតែពិបាកណាស់ប្រពន្ធគ្នាត្រូវទូលនំលក់ ចុះសមឯងយ៉ាងម៉េចទៅឯងរកស៊ីក្លូធាក់បានហើយឬ?

សមឃើញ ម៉ីកំពុងដេកឈឺដូច្នោះ ក៏រលាយនូវគោលបំណង តាំងចិត្តថាមកពឹងពាក់

"ឪ បងម៉ី !ខ្ញុំ ឥតដឹងថាបងឯងឈឺសោះ ឯស៊ីក្លូនោះខ្ញុំរកមិនទាន់បានទេខ្ញុំកំពុងតែរត់រកសព្វថ្ងៃហ្នឹងបង ! ចុះពួកយើងមានអ្នកណាដែលល្មមចែកស៊ីក្លូគ្នាធាក់បានទេបង ?គេចែកអោយធាក់ពេលថ្ងៃក៏បានពេលយប់ក៏បាន "

"ទេសម ! គ្នាសំលឹងមើលទៅ ដូចជាមិនឃើញមានទេ " ម៉ីខំប្រឹងត្រដរក្រោកអង្គុយ ហើយនិយាយមួយៗ "សព្វថ្ងៃពួកស៊ីក្លូយើងរកប្រាក់មិនសូវបានសោះម្ល៉ោះហើយគេខំប្រឹងធាក់ទាំងយប់ទាំងថ្ងៃតែរៀងៗខ្លួន " សម បានសាកសួរអាការៈរោគរបស់ម៉ី ហើយក៏បែរទៅនិយាយដល់រឿងរកស៊ីទៀត ។

"បងម៉ី នឹងធ្វើការងារអី ដទៃទៀត ក៏ធ្វើមិនកើតបានដែរ ព្រោះខ្ញុំគ្មានចេះអីសោះបើរកស៊ីក្លូធាក់មិនបានទេមើលទៅប្រហែលជាដាច់ពោះស្លាប់ហើយ "

"បើអញ្ចឹង សមឯងមកនៅជាមួយនឹងគ្នាសិនមកក៏បានដែរសម " ម៉ីសំឡឹងមើលមុខសមហើយនិយាយដោយយល់ចិត្តយល់ថ្លើម " គ្នាក៏គ្មានរង្កៀសអីនិងសមឯងទេ " "ទេ មិនអីទេបង " សមឆ្លើយឡើងដោយខំប្រឹងញញឹមទាំងក្រៀមក្រំ " ខ្ញុំអគុណបងឯងច្រើនណាស់ ហើយក៏គ្មានអ្នកណាល្អដូចបងឯងទេខ្ញុំអគុណបងឯងច្រើនហើយ តែណ្ហើយចុះទុកអោយខ្ញុំផ្សងទៅតាមព្រេងវាសនាទៅចុះ បើខ្ញុំអត់ស្លាប់អោយវាស្លាប់ទៅចុះបើខ្ញុំរស់តែមករុកគួនបងទាំងកំពុងតែឈឺអញ្ចឹងបងក៏រឹតតែពិបាកណាស់ទៅទៀត "

"ទេកុំគិតអញ្ចឹងសម ! "ម៉ីគ្រវីក្បាលហើយនិយាយទាំងនឿយហត់ " ពួកយើងអ្នកក្រត្រូវតែពិបាកអញ្ចឹងតែយើងត្រូវតែជួយគ្នាក្នុងការដែលយើងអាចជួយបាន "និយាយដល់ត្រឹមនេះ ម៉ីដកដង្ហើមធំតែឪមែនហើយ ! សមឯងទៅរកលោកយ៉េងសាកមើលក្រែងលោកវាមានផ្លូវ សព្វថ្ងៃនេះលោកមានណាស់ មានស៊ីក្លូសាមសែសិបលោកមុខជាមិនភ្លេចឯងទេមើលទៅ ព្រោះកាលលោកបោះឆ្នោតធ្វើតំណាងរាស្រ្តសមឯងបានជួយជ្រោមជ្រែងស្វែងរកសំលេងពីពួកកម្មករយើង ជួយ

លោកបានច្រើននាក់ ដែលស្ទើរតែនិយាយបានថា លោកយ៉េងបានធ្វើតំណាងរាស្ត្រព្រោះតែឯងជួយលោកណាសម "

" លោកនឹងនៅចាំមុខខ្ញុំបានឬបងម៉ី ? " សមឆ្លើយឡើង " ខ្ញុំឮគេនិយាយថាឥឡូវនេះលោកយ៉េងមិនសូវអោយអ្នកណាជួបផ្តេសផ្តាសទេបង" "តែសំរាប់សមឯងប្រហែលជាលោកមិនភ្លេចគុណឯងទេមើលទៅ "ម៉ីនិយាយបញ្ជាក់ " ទៅរកលោកសាកមើលសម ទៅសុំជួលស៊ីក្លូលោកយកធាក់ស៊ីក្លូរបស់លោកសុទ្ធតែថ្មីៗទាំងអស់ លោកមុខជាមិនយកប្រាក់កក់ពីឯងទេព្រោះមនុស្សយើងដឹងគុណដល់គ្នាខ្លះៗ មែនទេសម ? គ្នានៅចាំមិនទាន់ភ្លេចទេ ចំពោះពាក្យសំដីដែលលោកយ៉េងបានសន្យា និងសមឯងថាលោកនឹងធ្វើជាតំណាងរាស្ត្ររបស់អ្នកក្រដោយសុំអោយឯងជួយលោកអោយពេញទំហឹង លោកនឹងជួយលើកស្ទួយជីវភាពរបស់អ្នកក្រ ហើយលោកនឹងជួយនិងមិនភ្លេចគុណឯងរហូតដល់ថ្ងៃស្លាប់ " សមអង្គុយមួយសន្ទុះហើយក៏ឆ្លើយឡើងថា៖

"បើអញ្ចឹង ខ្ញុំប្រថុយទៅរក លោកសាកមើលក្រែងលោ មានសំណាងលោកអាណិតជួលស៊ីក្លូអោយ "

សមអង្គុយនិយាយជាមួយនិងម៉ីប្រហែលកន្លះម៉ោងក៏លាត្រឡប់ទៅវិញហើយប្រាប់ម៉ីថា បើរកជួលត្រីចក្រយានបាននិងត្រឡប់មកប្រាប់វិញ ។

រសៀលនៃថ្ងៃនោះ សមក៏បានទៅដល់ផ្ទះតំណាងអ្នកក្រ គឺលោកយ៉េង ដែលកំពុងតែមានតំណែង ដ៏ខ្ពង់ខ្ពស់ និងមានឥទ្ធិពលក្នុងកិច្ចការរដ្ឋ ។ ផ្ទះនោះជាផ្ទះថ្មដ៏ធំទាន់សម័យមានអាណាខែត្រធំទូលំទូលាយ ហើយនៅជើងផ្ទះនេះ មានរោងត្រីចក្រយានដ៏ធំល្វឹងល្វើយ ។ឋានៈរបស់លោកយ៉េងបានផ្លាស់ប្តូរប្រែប្រួលពីបាតដៃទៅខ្នងដៃគ្រាន់តែពេលជាងមួយឆ្នាំប៉ុណ្ណោះ ។ មុនពេលធ្វើតំណាងរាស្ត្រលោកយ៉េងមានតែផ្ទះស្លឹកតូចស្ទៀកពាក់ខោអាវចាស់ៗ ទៅណាមកណាជិះតែទោចក្រយានចាស់តែជោគវាសនាបានជំរុញ លោកយ៉េង អោយមានឋានៈមានបានយ៉ាងស្តុកស្តម្ភដោយឆាប់រហ័សមានប្រាក់កាសទិញដីភូមិ ទិញត្រីចក្រយាន សាបសែសិបទុកសំរាប់ជួល ហើយនឹងបានដឹងថាលោកទិញរថយន្តយីហោអាមេរិចស្អាតៗពីរ ដែលការនេះគ្មានអ្នកណាអាចនឹងបានដឹងថាលោកបានហូរហៀរមកពីណាឡើយ ។

លុះបានដើរចូលទៅក្នុងរបង ហើយឈប់ឈរនៅខាងមុខផ្ទះ សមចោលភ្នែកក្រឡេកទៅឃើញស្រីក្មេងពីរ បីអ្នកកំពុងប្រលែងគ្នានៅលើផ្ទះ ហើយនៅខាងមុខរោងដាក់ត្រីចក្រយានមានជាងពីរនាក់កំពុងជួសជុល ត្រីចក្រយានរវាសរវាម ។

សម ឈរសំឡឹងមើលប្រហែលជាអស់ពេលជិតដប់នាទី ទើបឃើញបុរសចំនាស់បន្តិចចុះមកពីលើផ្ទះ ។ សមដើរទៅជិតលើកដៃសំពះហើយសួរថា ‶អត់ទោសលោក ! លោកតំណាងនៅឬទេ ?

‶នៅ ! អ្នកបំរើលោក យ៉េងឆ្លើយឡើងដោយពាក្យសំដីកំបុតកំបុយ ហើយក៏សួរមកសមវិញភ្លាមថា ‶ មានធុរៈអី ? ‶

សមគិតថាប្រសិនបើប្រាប់បុរសនេះ តាមត្រង់ថា ខ្លួនមករកពឹងពាក់លោកយ៉េងនោះ បុរសនេះមុខជាបដិសេធដោយអាងថា លោកគ្មានពេលទំនេរទទួលភ្ញៀវដូចរូបសមនេះឡើយ ។ ដូច្នោះសម ចំបាច់ត្រូវកុហកបុរសនោះថា

‶ លោកផ្ដាំអោយ ខ្ញុំ មកជួបនិងលោក ‶

‶បើអញ្ចឹងចាំបន្តិចទៅ ចាំខ្ញុំទៅជំរាបលោកសិន ‶

និយាយចប់ហើយបុរសនោះ ក៏ឡើងទៅលើផ្ទះវិញបាត់ទៅ ។ មួយសន្ទុះក្រោយមកបុរសមាន វ័យកណ្ដាលម្នាក់ក៏ដើរមកចេញពីក្នុងផ្ទះ ។

បុរសនេះស្លៀកខោពណ៌ស ពាក់អាវស៊ឺមីព្រៃស ហើយចងក្រវាត់ ។ សភាពបុរសនេះគឺលោកយ៉េងសមាជិកសភាតំណាងរាស្ត្រនុះឯង ។ នៅពេលដែលអ្នកបំរើទៅជំរាបលោកថាមានបុរសម្នាក់មកសុំជួប ដោយលោកផ្ដាំអោយជួបនោះលោកយ៉េងក៏ដូចជារកនឹកមិនឃើញថាបានផ្ដែផ្ដាំអ្នកណា អោយមកជួបលោកសោះឡើយតែលោកនឹកស្មានថាប្រហែលជាពួកកម្មករត្រីចក្រយានដែលត្រូវយកប្រាក់កក់មកជូនលោក ។ លោកយ៉េង ភ្ញាក់ព្រឺតក្នុងខណៈដែលលោកបានឃើញមុខសម ។ លោកនៅចាំមុខអតីតប្រធានសមាគមកម្មករ បុរសសំខាន់ដែលជួយឃោសនារកសំលេង ជួយលោកបានជាច្រើន ដោយមិនបាននូវគុណបំណាច់អ្វីបន្តិចបន្តួចពីលោកសោះឡើយ ។ឥឡូវនេះពាក្យសន្យានោះបានក្លាយទៅជាខ្យល់ហើយ តែវាមានប្រយោន៍សំរាប់លោកយ៉េងដែលគ្រាន់តែទុកបោកបញ្ឆោតពួកអ្នកក្រអោយជឿតែប៉ុណ្ណោះ ។ ខណៈនោះលោកយ៉េងដឹងភ្លាមថាសមមុខជាមករកពឹងពាក់អ្វីលោកជាមិនខាន លោកក៏ក្លែងធ្វើជាមិនស្គាល់ហើយសួរថា ៖មានធុរៈអី ឬអូនប្រុស ?

‶ ព្រះតេជគុណ ! ‶ សមលើកដៃសំពះ ហើយនិយាយឡើង ‶ ព្រះតេជគុណភ្លេច ខ្ញុំបាទហើយ ឬ ទានប្រោស ? ‶ លោកយ៉េងជ្រួញចញ្ចើមចូលគ្នាហើយធ្វើឫកហាក់ដូចជារកនឹក

‶ អើគ្មាដូចជាភ្លេចហើយ ហ្នឹងនែ ឯងធ្លាប់ស្គាល់គ្មាមកពីមុន ឬ ‶

សមញញឹមទាំងឃ្នាន់ឃ្នាញ់ ហើយគិតថាខ្លួននឹកស្មានមកពីមុនមិនខុសថាមុខជានិងទទួលនូវ អាការៈបែបនេះពីលោកយ៉េងដែលអួតខ្លួតថាជាតំណាងអ្នកក្រនោះជាមិនខាន។

" ខ្ញុំបាទឈ្មោះសមទានប្រោស! " សមនិយាយពីគ្រាអតីត " ខ្ញុំបាទជាប្រធានសមាគមកម្មករដែលបានជួយឃោសនារកសមលេងក្នុងការបោះឆ្នោតជូនព្រះតេជៈគុណ ហើយព្រះតេជៈគុណបានមានប្រសាសន៍ផ្តែផ្តាំថា បើមានទុកធុរៈអីអោយខ្ញុំបាទមករកជួបនឹងព្រះតេជៈគុណមករកបានជួបគ្រប់ពេលវេលាព្រះតេជៈគុណធានាថា នឹងជួយទុក្ខធុរៈ អ្នកក្រដោយព្រះតេជៈគុណធ្វើជាភ្នែកត្រចៀករបស់អ្នកក្រទានប្រោស... "

តំណាងអ្នកក្រញញឹមស្ញើៗ ក្នុងកាលដែលត្រូវសមនិយាយដាក់ផ្លែផ្កាអោយដូច្នោះ ។ " អើ អូនប្រុស ! "លោកយ៉េងនិយាយតឡើង " ពេលនោះមានពួកកម្មករជាច្រើនបានជួយជ្រោមគ្នាមែនតែក្រោយមកនៅពេលដែលគ្នាបានធ្វើតំណាងរាស្ត្រ ហើយគ្នាក៏បានតបគុណអ្នកទាំងនោះ ដោយការ អោយប្រាក់កាសម្នាក់ៗពីរបី រយរៀលរួចទៅហើយ "

" ឪ អញ្ចឹង ឬទានប្រោស ! " សមឆ្លើយឡើងដោយការមិនពេញចិត្ត " តែខ្ញុំបាទមិនដែលបានទទួលអំពីព្រតេជៈគុណសោះ-កាលដែលខ្ញុំ បាទមកសុំជួបនឹងព្រតេជៈគុណនេះមិនមែនបៀតបៀនរុកគួន ប្រតេជៈគុណក្នុងរឿងប្រាក់កាសអីទេទានប្រោស ខ្ញុំបាទគ្រាន់តែមកសុំជួលស៊ីក្លូយកមកធាក់តែប៉ុណ្ណោះ "

" បាន អូនប្រុសបាន ! មានទាស់អី " លោកយ៉េងឆ្លើយឡើងភ្លាម " តែគ្នាប្រញាប់ទៅប្រជុំបន្តិច- នុះហ្ន៎ ! ឯងទៅខាងណោះទៅ ហើយប្រាប់ស្មៀនរបស់ខ្ញុំភ្លាមថា ឯងត្រូវការជួលស៊ីក្លូយកទៅធាក់ ហើយស្អែកនេះ ឯងយកប្រាក់មួយរយហាសិបរៀលមកកក់នៅពេលដែលឯងយកស៊ីក្លូចេញទៅធាក់នោះផងណ៎ា "

សម សំលឹងមើលមុខលោក យ៉េងដោយការឃ្នាន់ខ្នាញ់ ហើយប្រឹងញញឹមទាំងមិនពេញចិត្ត " ព្រះតេជៈគុណទានសប្រោស ! សមនិយាយឡើង

"ខ្ញុំគ្មានប្រាក់សំរាប់យកកក់សោះទានប្រោស ក្នុងឋានៈដែលខ្ញុំបាទធ្លាប់បានជួយព្រះតេជៈគុណក្នុងការឃោសនាបោះឆ្នោតនោះសុំព្រះតេជៈគុណមេត្តាជួលស៊ីក្លូអោយខ្ញុំបានដោយមិនបាច់កក់ប្រាក់ម្តងទៅទានប្រោស "

" ទេមិនបានទេ ! "តំណាងរាស្ត្រគ្រវីក្បាល ហើយឆ្លើយកាត់ឡើង គ្នាជួយឯងរបៀបនេះមិនបានទេស៊ីក្លូថ្លៃណាស់ បើឯងធាក់ទៅបុកឡានឬក៏មិនបង់ថ្លៃឈ្នួលបួនប្រាំថ្ងៃយកស៊ីក្លូគ្នាទៅជួលឯណាទៅ ហើយឯងរត់បាត់ទៅតើអោយគ្នាធ្វើយ៉ាងម៉េច !"

" តែសុំព្រះតេជៈគុណាមេត្តានឹងខ្ញុំថា ខ្ញុំបាទធ្លាប់បានជួយព្រះតេជៈគុណាទានប្រោស ហើយព្រះតេជគុណាបានសន្យាថា នឹងជួយខ្ញុំបាទវិញ..."

" ឆ្កួត ! "លោកយ៉េងគំហាក ហើយផ្លាស់ទឹកមុខទៅជាក្រញូវ " ឯងមករំលើកបើកកកាយគុណអញ៉ឹងមិនកើតទេឯងក៏ដឹងស្រាប់ហើយថាការបោះឆ្នោតវាជាករណីយកិច្ចរបស់ឯងជាពលរដ្ឋគ្នាឥតបានបង្ខំឯងថា អោយបោះឆ្នោតអោយគ្នាឯណាឥឡូវ ឯងមកនិយាយអីឆ្កួតៗអញ៉ឹងទៅ " ចេញទៅវិញទៅគ្នាមិនត្រូវការមនុស្សរបៀបឯងអញ៉ឹងទេ "

" ព្រះតេជេៈគុណា ! " សមនិយាយឡើង ដោយលែងមានការកោតក្រែងឥឡូវខ្ញុំបាទបានដឹងច្បាស់ហើយថាពួកខ្ញុំបាទចាញ់បោកព្រះតេជៈគុណាជាងមួយឆ្នាំមក ហើយពួកកម្មករ មិនដែលបានទទួលប្រយោជ៏អំពីព្រះតេជៈគុណាសោះ ពេលឃោសនាបោះឆ្នោត ព្រះតេជៈគុណាសន្យានឹងពួកកម្មករថាព្រះតេជៈគុណាធ្វើជាតំណាងឬធ្វើជាភ្នែកត្រចៀករបស់អ្នកក្រ តែព្រះតេជៈគុណាមិនដែលជួយតវ៉ា អោយពួកអ្នកក្របានធូរថយសោះ មិនតែប៉ុណ្ណោះគ្រាន់តែខ្ញុំបាទសុំជួលសុំក្លូព្រះតេជៈគុណាយកទៅធាក់ប៉ុណ្ណឹង ព្រះតេជៈគុណាចាំទាយកប្រាក់កក់ ហើយព្រតេជៈគុណាធ្វើជាមិនស្គាល់ខ្ញុំបាទទៀតផង "

" ទៅ ! ចេញពីផ្ទះគ្នាអោយឆាប់ទៅ ! លោកយ៉េងបណ្តេញសមចេញព្រមទាំងគំហាកយ៉ាងខ្លាំងៗ បើឯងនៅតែហ៊ាននិយាយដាក់គ្នាអញ៉ឹងទៀត គ្នានឹងហៅមនុស្សម្នារបស់គ្នាអោយចាត់ការឯងឥឡូវហ្នឹង ឯងដឹងឬទេថាខណៈនេះឯងមានកំហុសយ៉ាងធ្ងន់ក្នុងឋានៈ ដែលឯងហ៊ានរុករានទន្ទ្រានទីចូលមកប្រមាទមើលងាយគ្នា!ប្រយ័ត្នគ្នាហៅប៉ូលីសអោយមកធ្វើសសៃអោយរ៉ុំកុំនិយាយរបៀបហ្នឹងទៀត "

និយាយស្ទើតែមិនទាន់ផុតពាក្យ លោកយ៉េងតំណាងអ្នកក្រ ក៏ឡើងទៅលើផ្ទះរបស់លោកដោយសេចក្តីមួម៉ៅ ។

ពេលនោះសមនឹងចង់ស្រែកប្រកាសប្រាប់គេឯងអោយបានដឹងពុតទៅថា ពួកកម្មករអ្នកក្រល្ងង់ខ្លៅអើយ ! រាល់ៗពេល ដែលមានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រពួកម្មករនេះឯង ដែលខំខ្នះខ្នែងជួយជ្រោមជ្រែងគេក្នុងការបោះឆ្នោតជ្រើសរើសយកបេក្ខជនណាម្នាក់ អោយធ្វើជាតំណាងរាស្ត្រដើម្បីជាភ្នែកជាច្រមុះសំរាប់ជួយតវ៉ាអោយខ្លួនបានធូរស្បើយ តែថាលោកអើយ!

មានតំណាង រាស្ត្រណាមួយដែលបដិបត្តិតាមពាក្យសន្យានោះ-ពួកកម្មករអ្នកក្រគឺជាអាហារដ៏មានឱជារសរបស់ពួកអ្នកនយោបាយស្តមព្រោះពីមុនពេលដែលគេបានធ្វើជាតំណាងរាស្ត្រនោះពួកកម្មករអ្នកក្រខំប្រឹងប្រែងធ្វើការងូតញើសត្រាំទឹកនោះមានសភាពយ៉ាងណាឥឡូវនេះដល់គេបានធ្វើជាតំណាងរាស្ត្រហើយ ពួកកម្មករអ្នកក្រទាំងនោះ ក៏នៅតែមានសភាពដដែលគ្មានអ្វីប្រែប្រួល ព្រោះមិនដែលឃើញឬថា មានអ្នកនយោបាយណាមួយមកឈឺឆ្អាលមកទាមទារតវ៉ា ឬរកច្រកចេញដើម្បីលើកកំរិតជីវភាពរបស់កម្មករអ្នកក្រសោះឡើយ ។ ត្រីចក្រយានភាគច្រើនក្នុងរាជធានី ច្រើនតែជារបស់នាយទុនបរទេសពួកកម្មករត្រូវង្គុយធាក់នៅលើកែប បែកញើសប៉ុនៗគ្រាប់ពោតដែលតំណក់ញើសទាំងនោះស្ទើតែក្លាយទោជា ដំណក់ឈាមតែប្រាក់កាសស្ទើរតែចិញ្ចឹមជីវិតអោយរស់នៅធ្វើជាពលរដ្ឋ ដូចគេតទៅទៀតមិនបាន - ទោះបីពួកកម្មករអ្នកក្រលំបាកវេទនាយ៉ាងនេះក៏ពួកអ្នកនយោបាយទាំងនោះមិនដែលជួយអើពើឈឺ ឆ្អាល ឬយកភ្នែកមើលឡើយ . . . ពួកគេគិតតែស្រវាវេចយកប្រយោជ៍ផ្ទាល់ខ្លួន ធ្វើមានធ្វើបានតែខ្លួនគេ . . .ឱពួកលោកអ្នកនយោបាយ ! ឥឡូវខ្ញុំដឹងច្បាស់ហើយថាពួកលោកបានក្លាយខ្លួនទៅជាអ្នកនយោបាយបោកហើយ . . . ។

ꕥꕥ ꕥꕥ

## ភាគទី១៣ ជាប់ឃុំព្រោះអនាថា

ថ្ងៃ ខែចេះតែកន្លងផុតទៅ. . . សេចក្តីទុកលំបាករបស់កម្មករដែលគ្មានទីពឹងក៏ចេះតែទ្វេរឡើងតាមលំដាប់នៃ ថ្ងៃខែនោះដែរ ។ សមនៅតែរកត្រីចក្រយានសំរាប់ធ្វើជាឧបករណ៍ក្នុងការចិញ្ចឹមជីវិតមិនទាន់បាន ។ ជីវិតរបស់សម ហាក់ដូចជាត្រូវចាប់យកទៅសន្ទប់ជាប់ជិត ។ នៅក្នុងគុហារដ៏ងងឹតគ្មានអ្វីជាទីសង្ឃឹម ។ ឥឡូវសមបានក្លាយខ្លួនទៅជាមនុស្សអនាថាហើយ ។ សមត្រូវម្ចាស់គេបណ្តេញចេញពីកូនខ្ទម ដែលជាទីជំរកនៃភ្លៀងផ្គរនិងកំដៅថ្ងៃ ព្រោះគ្មានប្រាក់ឈ្នួលអោយគេ សមត្រូវដើរសាត់អណ្តែតទូទៅក្នុងព្រះរាជធានីដើម្បីស្វះស្វែងរកការងារធ្វើ តែគ្រប់ៗទីកន្លែងសុទ្ធសឹងតែមាន កម្មករធ្វើគ្រប់ចំនួនអស់ហើយ ។យប់នោះមហាមេឃបានបង្អុរភ្លៀងធ្លាក់ជោកជាំព្រះធរណី ប្រហែលជាមួយម៉ោង២១ សមអង្គុយអោបក្បាលជង្គង់នៅក្នុងសំយាបវិហារនៃវត្តព្រះពុទ្ធមានបុណ្យ ដែលមានសុនខពីរបីដេកសន្ធឹងខ្លួនដោយការខ្ជឹលច្រអូសនៅជិត។មើលៗទៅទីវត្តអារាមហាក់បីដូចជាទីជំរកពិសេសសំរាប់ទទួលនូវអ្នកកំសត់ទុរគតគ្រប់ប្រភេទ ។ ពេលល្ងាចនេះសមត្រូវអត់អាហារ ព្រោះគ្មានប្រាក់ទិញ។សមអង្គុយរំពឹងគិតដល់ជីវិតរបស់ខ្លួនដែលកំពុងតែជួបប្រទះនិងវិបត្តដ៏ធ្ងន់ធ្ងរ ជោគវាសនា មិនបានជួយសមសោះឡើយ ហើយវត្ថុសក្តិសិទ្ធិទាំងឡាយហាក់ដូចជាគ្មានត្រាប្រណីសមដែរ ។ ធម្មជាតិគ្រប់យ៉ាងដែលធម្មតាបានបង្កើតមកសំរាប់មនុស្សលោកទូទៅនោះ ហាក់ដូចជាសំរាប់តែអ្នកមាន មិនមែនដំរាប់អ្នកក្រដែលមានរូបសម្បូរមចំណែកនៅ

ក្នុងនោះផងដែរ ។ ពេលនេះសមគ្មានអ្វីនៅជាប់នឹងខ្លួនក្រៅពីខោអាវមួយចង្កេះនោះឡើយ។ការរំពឹងគិតរបស់សមបានត្រូវស្ងូន្យនៅពេលដែលមានពន្លឺភ្លើងពិលមួយ បានបញ្ចេញរស្មីភ្លឺភ្លែតមកចំមុខរបស់សម។ខណៈនោះភ្នាក់ងារប៉ូលីសពីរនាក់ បានដើរតំរង់មករកសម។

"នែ៎គាត់នេះ!" ភ្នាក់ងារប៉ូលីសម្នាក់សួរឡើងដោយសមឡេងក្រអរ"មក អង្គុយកន្លែងឯងឹតអញ្ចឹងធ្វើអីហ្នឹង?"

សមមិនបាននឹកភិតភ័យអ្វីឡើយ ព្រោះយល់ថាខ្លួនជាមនុស្សល្អបរិសុទ្ធ

"បាទលោក!"សមឆ្លើយឡើង "មកអង្គុយជ្រកភ្លៀង"

"បើអញ្ចឹងក្រោកឡើង" ភ្នាក់ងារប៉ូលិសម្នាក់ទៀតសួរ"ផ្ទះឯងនៅឯណា?"

សមនឹកឡើងភ្លាមថាខ្លួនគេអាចត្រូវភ្នាក់ងារប៉ូលីសចោទថាជាមនុស្សអនាថាបាន ហើយអាចត្រូវប៉ូលីសចាប់យកទៅឃុំខ្លួនបានសមក៏ប្រញាប់ឆ្លើយ ឡើងថា៖

"បាទ! នៅទួលតាពូង"

ភ្នាក់ងារប៉ូលីសបាននាំគ្នាស្ទាបឆែកឆេរមើលតាមហោប៉ៅខោអាវ និងចង្កេះខោរបស់សម ហើយក៏សួរតទៅទៀតថា"ឯងនៅដល់ទួលតាពូង ម៉េចក៏មកអង្គុយធ្វើអីនៅឯណេះទៅវិញ? ទៅ! ទៅបកសិន!"

ពេលនោះសមផ្លាស់ទឹកមុខ ហើយសួរទៅភ្នាក់ងារប៉ូលិសវិញថា៖

" ខ្ញុំបាទមានរឿងអីទានប្រោស?"

"មិនបាច់សួរទេ" ភ្នាក់ងារប៉ូលីសម្នាក់ឡើងឆ្លើយ

" គេប្រាប់ថាអោយទៅបកត្រូវតែទៅម៉េចឮទេ!"

"ខ្ញុំចាប់អ្នកឯងនេះក្នុងឋានៈដែលខ្ញុំសង្ស័យថាឯងរត់ចេញមកពីគុក" ភ្នាក់ ងារម្នាក់ទៀតនិយាយ " ខ្ញុំមានអំណាចអាចចាប់ឯងបាន ឬបើមិនដូច្នោះទេឯងមកចាំលួចអីវ៉ាន់គេ ព្រោះមុខមាត់ឯងគួរអោយសង្ស័យណាស់ទៅឆាប់ឡើងបើរឹងទទឹងគ្នាដាក់ខ្នោះឥឡូវហ្នឹង"

"ចុះខ្ញុំបាទនឹងត្រូវជាប់គុកទេឬទានប្រោស" សមនិយាយឡើងទាំងមួម៉ៅ

"អ្នកក្រដែលស្លៀកពាក់ខោអាវរហែករយីរយ៉ៃ ហើយអង្គុយនៅត្រង់កន្លែង ស្ងាត់ៗលោកបែរជាគិតថារត់ចេញមកពីគុកឬមកចាំលួចអីវ៉ាន់គេ ចុះពួកអ្នកជិះ ឡានម៉េចក៏លោកមិនទៅអញ្ជើញគេអោយទៅបកក្នុងឋានៈ ដែលលោកសង្ស័យ ថាលបរត់ចេញពីគុកឬបើកឡានទៅរកប្លន់ទៅទានប្រោស!..."

"អេហ្ន៎! អានេះចំណាប់មែន"ភ្នាក់ងារប៉ូលីសម្នាក់និយាយកាត់ឡើង" វាចេះ និយាយមុតប្រាយដូចពួកអ្នកកាសែតអញ្ចឹងផងហ្ន៎! ទៅឆាប់ឡើងកុំត្រេះត្រុះអី ឯងដឹងទេថារាជការកំពុងចាត់វិធានការដើម្បីបំបាត់មនុស្សអនាថា"

" បើអញ្ចឹងម៉េចក៏រាជការមិនរកការងារអោយរាស្ត្រក្រីក្រធ្វើផងទានប្រោស" សមនិយាយឡើងទាំងទឹកមុខស្មើៗ" ហើយរាជការម៉េចក៏មិនរកផ្ទះជួលអោយ រាស្ត្រដោយតំលៃថោកៗផង... មនុស្សយើងសុទ្ធតែចង់បានផ្ទះនៅចង់មាន ការងារធ្វើដូចគ្នាទាំងអស់ទានប្រោស"

ភ្នាក់ងារប៉ូលីសម្នាក់យារដៃឡើងធ្វើទំនងដូចជាចង់ទះកំផ្លៀង តែក៏មិន ហ៊ានទះព្រោះរបបវាយដំច្រំធាក់មនុស្សក្នុងពេលឥឡូវមិនសូវមានអ្នកហ៊ានប្រព្រឹត្តិប៉ុន្មានឡើយ។

ភ្នាក់ងារប៉ូលីសម្នាក់ទៀតចាប់ដៃសមទាញកន្ត្រាក់ ហើយគំហកថា៖

"នែអានេះ! កុំមាត់រឹងពេក ទៅ! ទៅ មក!"

សមខាំធ្មេញក្រឹតដោយសារអត់សង្កត់ចិត្ត ហើយមិននិយាយថាអ្វីទៀតព្រមទាំងដើរទៅជាមួយនឹងភ្នាក់ប៉ូលីសដោយស្រួល។ សមត្រូវភ្នាក់ងារប៉ូលីស នាំខ្លួនទៅស្នងការប៉ូលីសក្នុងឋានៈដែលគេសង្ស័យ។ ជីវិតរបស់អ្នកក្រតែងប្រព្រឹត្តទៅយ៉ាងនេះគឺនៅស្ងៀមៗ ក៏ត្រូវគេចាប់យកទៅឃុំឃាំង ហើយទំរាំនឹង រកភស្តុតាងបង្ហាញអោយឃើញថាជាមនុស្សល្អត្រឹមត្រូវនោះក៏ត្រូវរងទុក្ខវេទនានៅក្នុងកន្លែងឃុំឃាំងអស់ពីរបីថ្ងៃទទេៗ។

ការស៊ើបសួរខាងប៉ូលីសមិនប្រាកដថាសម មានរឿងអាជ្ញាធរជាប់នៅនឹងខ្លួន។ហេតុនោះក្រោយពេល ដែលប៉ូលីសបានចាប់យកទៅឃុំឃាំងអស់ពីរថ្ងៃ ខាងមន្ទីរស្នងការប៉ូលីសក៏បានដោះលែងសម អោយមានឥស្សរភាពវិញ ព្រម ទាំងដាស់តឿនសមថា៖អោយរកការងារធ្វើ អោយមានមុខរបរ បើមិនដូច្នេះទេគឺ បើនៅតែដើរសាត់ត្រាត់តែលតោលទៅទៀត...គេនឹងចាប់យកទៅឃុំឃាំងទៀត។

សមបានអធិប្បាយប្រាប់ប៉លីសវិញ នេះវាជាពេលទាល់ច្រករបស់ខ្ញុំបាទ

ទានប្រោសបើព្រះតេជគុណអាណិតអាសូរបងប្អូនមនុស្សរួមជាតិនោះ សុំព្រះ តេជគុណមេត្តាយកខ្ញុំបាទធ្វើជាអ្នកបំរើម្នាក់ផងទៅចុះទានប្រោស ខ្ញុំបាទពេញ ចិត្តនឹងតបស្នងសងគុណព្រះតេជគុណយ៉ាងពេញចិត្ត សមត្ថភាព ឯប្រាក់ខែ ប្រាក់ស្រេចតែព្រះតេជគុណអាណិតប្រទានអោយខ្ញុំបាទទេទានប្រោស ខ្ញុំបាទ សុំតែមួយរស់ប៉ុណ្ណោះ។

ខ្ញុំជួយសង្គ្រោះអីអ្នកឯងមិនបានទេ! លោកភូឈ្មួយអធិការប៉ូលីសនិយាយ ពាក្យសំដីទន់ភ្លន់ដែលសំដែងនូវការអាណិតអាសូរ" ខ្ញុំក៏បានប្រាក់ខែតែបន្តិចបន្តួចតែចិញ្ចឹមប្រពន្ធកូនគ្រប់គ្រាន់ប៉ុណ្ណោះ ខ្ញុំក៏អាណិតឯងណាស់ដែរតែមិន ដឹងធ្វើយ៉ាងម៉េចទេ កុំអន់ចិត្តអី នេះជាកម្មរបស់ឯងដែលកើតមកជាអ្នកក្រ សុំ ឯងខិតខំប្រឹងប្រែងខ្លួនឯងទៅចុះ..."

សមចេះតែដើរខ្វាត់ភ្លាត់ទៅទៀតគ្រប់ទីកន្លែង។ សមតែងត្រូវគេស្រែក បណ្តេញ ចេញ មកវិញ ក្រៅពីនេះសមនៅត្រូវបានទទួលនូវពាក្យសំដី ដែល សង្កៀរដល់ត្រចៀកទៀត ព្រោះតែខោអាវរហែកនរយីររយ៉ៃនុះឯង ដែលធ្វើអោយ សមទទួលនូវការរង្កៀស និងការមើលងាយមើលថាកពីអ្នកធំ និងអ្នកមានភាគ ច្រើន...។

## ភាគទី១៤ សីលធម៌និងជុំបាយ

១-២-៣ ថ្ងៃបានកន្លងផុតទៅដោយសេចក្តីទុក្ខវេទនាសំរាប់រូបសំ៕ ថ្ងៃនោះសមត្រូវតស៊ូនិងសេចក្តីស្រេកឃ្លាន ដែលមានអានុភាពដ៏លើសលប់សំរាប់ជីវិតមនុស្សដោយបានត្រឹមទឹកម៉ាស៊ីននៅចិញ្ចើមថ្នល់ដើម្បីជាការទំងន់ពោះតែប៉ុណ្ណោះ៕ សេចក្តីស្រេកឃ្លានបានរីកទ្វេឡើងគ្រប់ៗវិនាទីហើយវាមានអានុភាពធ្វើអោយសមងងឹតមុខស្ទើតែនឹងក្លាយទៅជារោគខ្យល់គច្រើនដងច្រើនគ្រាណាស់មកហើយ៕

យប់នេះសមបានដើរទៅឈរនៅខាងមុខហាងលក់ម្ហូបអាហារមួយនៅផ្សារចាស់៕ សមសំលឹងមើលទៅក្នុងហាងឃើញសុភាពបុរស ៤-5 នាក់កំពុងតែអង្គុយផឹកស្រានិងស៊ីអាហារយ៉ាងឆ្ងាញ់ ម្ហូបអាហារគេហៅអោយចិនធ្វើនោះ មានច្រើនមុខពេញតុ ដែលសមសំលឹងមើលទៅបុរស ៤-៥នាក់នោះបេរិភោគមិនអស់ឡើយ៕ បុរសទាំងនោះមានសេចក្តីរីករាយយ៉ាងខ្លាំងតែថាវាជាទុក្ខរបស់សមដែល

ឈរសំលឹងមាត់គេយ៉ាងខ្លាំងដែរ៕ សមឈរសំលឹងមើលមាត់គេដោយសេចក្តីស្ទើរតែដាច់ខ្យល់ស្លាប់ ដែលមានទឹកមុខស្រពោនក្រៀមក្រំ ៕

ការចាំបាច់ក្នុងការស្រេកឃ្លានមានអានុភាពអាចបង្ខំចិត្តមនុស្សយើងបាន អាចធ្វើអ្វីបានគ្រប់យ៉ាងដោយលែងនឹកនាដល់សីលធម៌ ហើយសេចក្តីស្រេចឃ្លាននេះមានអានុភាពអាចបង្ខំចិត្តមនុស្សអាចរើបំរាស់ឡើង ដើម្បីជួយជីវិតអោយផុតពីកណ្តាប់ដៃនៃមច្ចុរាជ។ សមចោលកន្ទុយភ្នែកក្រឡេកមើលទៅទូកញ្ចក់ដេលតាំងនៅជិតទ្វារហាងឃើញមាន់-ទាខ្ញៃនៅក្នុង ដែលធ្វើអោយសមលេបទឹកមាត់ក្អឺកៗដោយការស្រេកឃ្លានរឹងរឹតតែខ្លាំងទៀត។

សមនឹកចង់ចូលទៅអង្គុយក្នុងហាងនេះ ហើយនិងហៅអោយចិនយកម្ហូបអាហារមកបរិភោគអោយស្កប់ស្កល់ តាមសេចក្តីស្រេចឃ្លានលុះឆ្អែតហើយក៏ដើរចេញទៅវិញស្ងៀមៗបើរទុកជាចិនធ្វើអ្វីក៏មិនខ្លាចដែរ តែសមឈ្ងោកមុខមកមើលសភាពតែងខ្លួនរបស់ខ្លួន សមក៏បែជាគិតថា បើទុកជាយ៉ាងណាចិនក៏មិនធ្វើម្ហូបអាហារអោយខ្លួនដែរ ព្រោះរូបកាយនិងសំលៀកបមពាក់របស់ខ្លួនមិនសមគួរចូលទៅអង្គុយនៅក្នុងហាងលក់ម្ហូបអាហារនេះសោះឡើយ។

ខណះសុភាពបុរសហ៊ឺហាម្នាក់បានដើរចេញមកពីក្នុងហាងដោយលក្ខណះពេញទៅដោយភាពព្រដើនកោងកាច។ បុរសនេះឈប់ឈរឈប់ឈរទ្រឹងក្នុងខណះដែលឃើញសមឈរទឹសផ្លូវចេញចូល ហើយក៏យកដៃច្រានដើមទ្រូងសម ធ្វើអោយសមខ្ទាតចេញ។

ចៀសចេញទៅ! បុរសនោះនិយាយ រូបរាងរឹងប៉ឹងអញ្ចឹងកោតតែដើរមកសុំទានហ្ន!។

រួចហើយសភាពបុរសនោះក៏ដើរតម្រង់ទៅរករថយន្តយីហោអាមេរិករបស់គេដែលចតចាំនៅចិញ្ចើមថ្នល់ជិតហាងនោះ។ អ្នកបើករថយន្តបានបើកទ្វារជូនបុរសនោះ។ សមខាំមាត់ហើយដើរក្តាប់ដៃណែន។ សមគិតថាខោអាវរហែករយីរយ៉ៃធ្វើអោយអ្នកដ៏ទៃគិតថាខ្លួនជាស្មូមយាចក ទាំងដែលខ្លួនមិនដែលសុំទានអ្នកណាសោះ >>>>ឪហ្ន! មនុស្សយើងនោះគេមិនវាស់នៃអំពើល្អទេ គេវាស់នូវកំរិតល្អដោយមាស់ប្រាក់កែវកង និងសំពត់អាវសាវស្បែបើទុកជាអ្នកនោះប្រព្រឹត្តិអាក្រក់យ៉ាងណាក៏ដោយ។

"អើហ្ន!" សមគិតទាំងមួរមៅ "អញធ្វើជាមនុស្សល្អយូរយារណាស់មកហើយ តែសេចក្ដីល្អនោះមិនដែលអោយផលអីដល់អញសោះ អញត្រូវតែជួយខ្លួនអញរួចផុតពីសេចក្ដីស្លាប់ក្នុងគ្រានេះម្ដងសិន"។

សេចក្ដីស្រេចឃ្លានបានបង្ខំចិត្ត គំនិតរបស់សមអោយប្រែប្រួលផ្លាស់ប្ដូរពីបាតដៃទៅជាខ្នងដៃភ្លាម។ ភ្នែកទាំងពីររបស់សមប្រែទៅជាក្រហមហើយស្រវាំងព្រិលៗសមបានដើរចេញពីកន្លែងនោះ ហើយបានទៅដល់មុខរោងភាពយន្តតារាដោយទឹកមុខស្រពោនក្រៀមក្រំ។ពេលនោះគាប់ជួនជាភាពយន្តដល់ពេលចប់រឿង។ មនុស្សម្នាទាំងឡាយប្រជ្រាតគ្នាចេញពីរោងភាពយន្ត។ សមក្រឡេកឃើញបុរសស្ត្រីក្នុងវ័យកណ្ដាលពីរនាក់កំពុងប្រជ្រៀតគ្នចេញមកពីក្នុងរោងភាពយន្តដែរ។ បុរស និង ស្ត្រីទាំងពីរតែងខ្លួនរៀបរយស្រគត់ស្រគំ មានបែបភាពបង្ហាញអោយដឹងថាជាអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ។

ស្ត្រីមានរូបរាងធាត់បន្តិច ហើយនាងកាន់កាបូបស្បែកក្រពើនៅដៃ។ ខណៈនោះសមកាន់ចិត្តប្រព្រឹត្តិនូវការទុច្ចរិតភ្លាម ដោយនឹកជឿជាក់ថានៅក្នុងកាបូបស្បែកក្រពើនោះ បើហោចណាស់ក៏គង់មានប្រាក់ល្មមនឹងជួយជីវិតខ្លួនអោយបានជួយជីវិតខ្លួនអោយរួចផុតពីការដាច់ពោះស្លាប់បានមួយពេលដែរ។

អំណាចនៃសេចក្ដីអាក្រក់ ថោកទាបបានកើតឡើងដល់ចិត្តគំនិតរបស់សមហើយ សមដើរសរសៀរចូលទៅជិត ហើយក៏កញ្ឆក់កាបូបស្បែកក្រពើចេញពីដៃនៃស្ត្រីនោះភ្លាម។

"ជួយផង! ជួយផង" ស្ត្រីនោះស្រែកថា "ចោរឆក់!"

សមរត់យ៉ាងលឿនចូលទៅក្នុងសរះមន្ទីជាតិ....កសមកំពុងតែប្រថុយខ្លួននឹងគុកច្រវាក់ព្រោះតែការស្រេកឃ្លាន អ្នករត់ទាំងឡាយគេរត់ប្រណាំងប្រជែងគ្នាយករង្វាន់ តែសមរត់ព្រោះឆក់ប្រាក់ដើម្បីយកទៅទិញអាហារបរិភោគដែលប្រែសេចក្ដីថា រត់ប្រណាំងនឹងការដាច់ពោះស្លាប់។ គ្រានេះជាគ្រាដំបូងបំផុតក្នុងជីវិតដែលសមបើកឆាកនៃការប្រព្រឹត្តិទុច្ចរិតខុសគន្លងច្បាប់។

ប្រជាជន និងភ្នាក់ងារប៉ូលីសបានដេញតាមពីក្រោយសម។ សមបានរត់កាត់ទៅខាងក្រោយសារះមន្ទីរជាតិឆ្លងទៅដល់សាលារចនា។ សភាពងងឹតបានជួយអោយសមគិចខ្លួនពីការចាប់ចង

យ៉ាងគួរព្រឺខ្លួន។ សមបានចូលទៅសំងំពួននៅជិតរោងថៃវខាងក្រោយសាលារចនា ហើយបើកកាបូបហូតរបស់ទាំងអស់មកដាក់ក្នុងហោប៉ៅអាវ។ ក្រោយពេលបោះកាបូបចោលហើយ សមក៏ដើរចេញពីកន្លែងនោះភ្លាម។ សមបានរួចខ្លួននៅពេលដែលបានហែករបង អំពិលទឹកខាងជើងដើរចេញទៅ។

សមនឹកខ្មាស់ខ្លួនឯងយ៉ាងខ្លាំង ព្រោះនឹកដល់កំហុសដ៏ធ្ងន់របស់ខ្លួន.........សមធ្លាប់បានប្តេជ្ញាចិត្តថា បើទុកជាក្រលំបាកយ៉ាងណាក៏សុខចិត្តតែពីប្រកាន់ខ្ជាប់នូវសីលធម៌មិនប្រព្រឹត្តអំពើអាក្រក់តែពេលនេះសមត្រូវធ្វើជាចោរឆក់របស់គេ ក៏ព្រោះសេចក្តីស្រេចឃ្លានយ៉ាងខ្លាំងដែលធ្វើអោយសមអត់ទ្រាំមិនបាន...អ្នកដែលមិនធ្លាប់អត់បាយ រមែងមិនដឹងថាសេចក្តីស្រេចឃ្លាននោះវាមានអានុភាពយ៉ាងណាឡើយ...។

សមខំដើរយ៉ាងលឿនចេញពីកន្លែងនោះ ហើយមួយសន្ទុះក្រោយមកសមក៏បានដើរទៅដល់បរិវេណផ្សារចាស់ ដែលពោរពេញទៅដោយតូបលក់ម្ហូបអាហាររបស់ពួកចិនយួនតាំងនូវរៀងៗគ្នា។ សមចូលទៅអង្គុយនៅត្រង់គុនៃតូបមួយដែលនៅទីនោះ ហើយហូតយករបស់ចេញពីហោប៉ៅមកមើល។ សមភ្ញាក់ព្រើតក្នុងខណៈដែលឃើញក្រដាស់ប្រាក់១០០រៀលជាង៣០សន្លឹក ក្រដាស់ប្រាក់១០រៀល និង៥រៀល៧-៨សន្លឹក ព្រមទាំងរបស់ឯទៀតជាច្រើន។

សមស្រែកហៅចិនអោយធ្វើបបរសាមចូកមួយចាន និងទឹកតែ ទឹកកកមួយកែវ។ ក្លិនអាហារក្នុងផ្សារចាស់បានរុកកួចច្រមុះរបស់សមជាខ្លាំង....ស្ទើរតែរងចាំមិនលើកបបរយកមកអោយមិនបាន។ សមបរិភោគបបរសាមចូកដោយមិនរវីរវល់នឹងអ្នកណា ព្រោះសេចក្តីស្រេចឃ្លានដែលបានអត់បាយមួយថ្ងៃមកហើយ គិតថាបបរបែបនេះប្រហែលជា៥ចានទៀតទើបឆ្អែត....សមស្រែកហៅចិនអោយយកបបរមួយចានថែមទៀត។

សមបាត់អស់កំលាំងរសេះរសោះ ហើយបានប្រែទៅជាមានកំលាំងពលំគ្រាន់បើឡើង...សមនឹកគ្រេកអរនឹងព្រះជាម្ចាស់និងវត្ថុសក្តិសិទ្ធិទាំងឡាយ ដែលបានជួយឃុំគ្រងខ្លួនអោយបានរួចផុតពីការចាប់ចងឃុំឃាំងនៃម្ចាស់ និងភ្នាក់ងារប៉ូលីសហើយជាពិសេសបានជួយខ្លួនអោយរួចផុតពីការដាច់ពោះស្លាប់។

ប្រហែលជា២០នាទីក្រោយមកគឺក្រោយពេលដែលបបរចានទីពីរបានចូលទៅក្នុងពោះ ហើយ សមក៏បានឆ្អែតស្កប់ស្កល់ដែលប្រែសេចក្ដីថា សមបានរួចខ្លួនពីសេចក្ដីស្លាប់ហើយ សមបាន ហៅចិនអោយយកបារីស្កុស និងឈើគូសមកអុជជក់បង្ហុយផ្សែងហុយទ្រលោមហាក់ដូចជាបន្ទូរ អារម្មណ៍អោយអនណ្ដែតត្រសែតលើអាកាស់ជាមួយផ្សែងបារីនោះ ហើយសមនឹកដល់ម៉ីដែល កំពុងតែដេកឈឺនៅនឹងកន្ទេលមិនអាចប្រកបការងាររកស៊ីចិញ្ចឹមជីវិតបាន។ ក្រោយពេលអោយ ប្រាក់ចិនរួចហើយ សមក៏ឡើងជិះត្រីចក្រយាន្តយន្តធ្វើដំណើរទៅផ្ទះម៉ី ពេលជិះត្រីចក្រយាន្តទៅ តាមផ្លូវ សមបានលូកហោប៉ៅអាវទាញយករបស់ទាំងអស់មកមើល...សមឃើញទឹកអប់មួយដប តូចនឹងម្សៅមួយប្រអប់។ តែលុះដកប្រអប់មួយទៀតយកមកមើល សមដូចជាភ្ញាក់ព្រើត...។

នៅប្រអប់តូចនេះមានចិញ្ចៀនពេជ្រពីរវង់ និងបន្ដោងពេជ្រមួយ។ ពន្លឺពេជ្របានចាំងរស្មីភ្លែ តៗសមបានបិទប្រអប់នោះ ហើយដាក់ក្នុងហោប៉ៅអាវវិញភ្លាម។ ក្នុងមួយជីវិតនេះសមមិនដែល មានពេជ្រមួយគ្រាប់ឡើយតែសមក៏អាចដឹងថាពេជ្រនោះមានតំលៃយ៉ាងណាដែរ។

សមគិតថាពេជ្រនៅក្នុងប្រអប់នេះ មានតំលៃច្រើនម៉ឺនរៀលម្ល៉េះសមម្ចាស់គេយំសោកស្ដាយ ជាខ្លាំងហើញមិនដឹងជាជេរប្រតិចផ្ដាសាខ្លួនយ៉ាងណាឡើយ។

សមមិនហ៊ានរើពិនិត្យមើលអ្វីនៅក្នុងហោប៉ៅទៀតឡើយដោយគ្រាន់ដៃស្ទាបមើលជរើយៗ ដើម្បីអោយដឹងថារបស់ទាំងនោះមិនជ្រុះបាត់ទៅណាឡើយ។

លុះត្រីចក្រយាន្ត បាននាំទៅដល់គោលបំណង គឺផ្ទះរបស់ម៉ីហើយសមក៏ចុះដើរចុះទៅរកម៉ី យ៉ាងរុសរាន់។ សមបានឃើញកំពុងបីកូនទាំងឈឺនៅត្រង់ទ្វារផ្ទះ ហើញម៉ីបានសួរសមដោយការ រួសរាយថា:

"អើសមឬ?មកសមចូលមក!ឯងរកស៊ីក្លូបានធាក់ហើញឬនៅសម?"

សមចូលទៅអង្គុយជិតម៉ីហើយនិយាយឡើងទាំងទឹកមុខញញឹមថា

"នៅតែរកមិនបានអញ្ចឹងបងម៉ី តែដែលខ្ញុំនៅមិនទាន់ដាច់ពោះស្លាប់នេះរាប់ថាជាគុណ បុណ្យណាស់ទៅហើយ" សមនិយាយផងសំលឹងមើលទៅក្នុងផ្ទះផង "ចុះបងម៉ុំគាត់ទៅណាហើ ញបង?""វាទៅលក់នំហើញសម វាទុកកូនអោយគ្នាមើល" ម៉ីដកដង្ហើមវែងហើយឆ្លើយឡើង ពួក

យើងមិនគ្រោះចង្រៃអ្វីទេសមឯងរកស៊ីក្លូមិនទាន់បានធាក់ ឯគ្នាត្រូវដេកឈឺ "អើសម!ឯងមានការអី ឬបានជាមករកគ្នាអញ្ចឹង?"

សមងាកមើលមុខក្រោយមិនឃើញមានមនុស្សនៅជិតទើបឡើងនិយាយ

"បងម៉ី! ខ្ញុំមានជោគវាសនាល្អណាស់ដែលកើតឡើងពីការអាក្រក់របស់ខ្ញុំទៅបងម៉ីចូលទៅនិយាយគ្នាក្នុងផ្ទះបន្តិច ព្រោះខ្ញុំមានការធំណាស់"។

គ្រាន់តែសមនិយាយប៉ុណ្ណោះ ម៉ីក៏ល្មមដឹងបានថាមុខជាប្រព្រឹត្តនូវអំពើទុច្ចរិតជាមិនខាន។ ម៉ីសំលឹងមើលមុខសមដោយការនឹកប្លែកក្នុងចិត្ត ព្រោះម៉ីគិតថាមនុស្សដូចរូបសមនេះស្អប់ខ្ពើមអំពើទុច្ចរិត

ទីបំផុត តែហេតុអ្វីក៏ងាកមកសួរសមសោយការចង់ដឹង។

"ស្អីទៅសម ជោគវាសនាដែលកើតឡើងពីការអាក្រក់របស់ឯងនុះ? មើលនិយាយអោយគ្នាស្តាប់ផងមើល"បងម៉ី? សមចាប់និយាយអោយម៉ីស្តាប់ "ខ្ញុំដឹងថាបងមុខជាជៀលខ្ញុំជាមិនខាន ក្នុងការដែលខ្ញុំចាបាច់ត្រូវប្រព្រឹត្តនូវអំពើអាក្រក់ជាគ្រាដំបូងបំផុតក្នុងជីវិតខ្ញុំ ដើម្បីជួយខ្លួនអោយរួចផុតពីសេចក្តីស្លាប់"។

"ពុទ្ធោអើយ!"ម៉ីឧទានដោយការស្លុតរន្ធត់ក្នុងចិត្ត "បើឯងក្រវាយ៉ាងម៉េច ម៉េចក៏ឯងមិនមករកគ្នាសម គ្នាបានប្រាប់ឯងហើញថាអោយមកនៅជាមួយគ្នា ម៉េចក៏ឯងមិនមក"។

"បងម៉ី!"សមនិយាយឡើងដោយការឃើញចិត្តឃើញថ្លើម "បងងោយឃើញខ្ញុំមករុកគួនប

ងដល់ណាទៀត ឪបង! សេចក្តីស្រែកឃ្លានបង្ខំចិត្តអោយខ្ញុំឆក់គេដែលមិនគួរនឹងធ្វើអញ្ចឹងសោះតែវាជាកសរចាំបាច់ដែលខ្ញុំត្រូវតែធ្វើណាបង"។

"ឆក់គេ!" ម៉ីបើកភ្នែកធំៗ ហើយសួរបញ្ជាក់ដោយសំលេងខ្សាវៗ "ឯងឆក់គេឬសម?"

"ហ្នឹងហើយបង !"សមសារភាពតែម្តង "ខ្ញុំឆក់របស់គេនៅក្បែររោងកុនតារា ខ្ញុំរៀបនឹងដាច់ពោះស្លាប់ព្រោះសេចក្តីស្រែកឃ្លាន ក៏ស្រាប់គេឃើញស្ត្រីម្នាក់ដើរចេញពីរផងកុន ខ្ញុំក៏ចូលទៅឆក់យកកាបូបប្រាក់របស់គេ ហើយរត់ចូលទៅសាលារចនា"។

ម៉ីអង្គុយស្តាប់ដោយការជួយភ័យជួស។ សមលូកហោប៉ៅអាវដកយករបស់ទាំងអស់មកដាក់ចំពោះមុខម៉ី។

"ស្លាប់ហើយ !..."ម៉ីទានឡើង "នេះមិនមែនប្រាក់តិចតួចទេសមស្លាប់ហើយម្ល៉េះប្រហែលជាម្ចាស់គេទៅប្តឹងហើយមើលទៅ"។

សមទាញក្រដាស់ប្រាក់មួយដុំយកមកមើល។ នោះគឺជាលិខិតសន្យាក្នុងការខ្ចីប្រាក់២ម៉ឺនរៀល ហើញក្រដាស់មួយសន្លឹកទៀតជាលិខិតបញ្ចាំផ្ទះមានតំលៃមួយសែនរៀល។ ឯប្រាក់នោះមានចំនួនអស់ជាង៣ពាន់រៀល។ខណះនោះទឹកមុខរបស់សមបានប្រែទៅជាសស្លាំង ដោយគិតឃើញដល់ការសោកស្តាយនៃម្ចាស់ទ្រព្យ។ សមងើបមុខឡើងសំលឹងមើលមុខម៉ីហើញនិយាយថាៈ

"បង !សេចក្តីត្រូវការរបស់ខ្ញុំ គឺបាយត្រឹមតែមួយឆ្អែតប៉ុណ្ណោះ ហើញបាយ

មួយឆ្អែតនេះ បានធ្វើអោយម្ចាស់ទ្រព្យគេសោកស្តាយក្តៅក្រហាយជាខ្លាំង...បើអញ្ចឹងយើងគិតធ្វើយ៉ាងម៉េចទៅបង"។

ម៉ីមិនឆ្លើយថាអ្វី តែបានហុចនាមប័ណ្ណ៤-៥សន្លឹក ដែលបានយកចេញពីក្រោមលិខិតផ្សេងៗទៅអោយសមមើលព្រមទាំងនិយាយតិចៗថាៈ

"សម !រឿងនេះ ឯងគិតយ៉ាងម៉េចស្រួល ក៏ស្រេចតែឯងទៅចុះគ្នាក៏មិនហ៊ានអាកាត់ថាម៉េចដែរ"។

សមសំលឹងមើលនាមប័ណ្ណ ដោយការស្ងប់ស្ងៀម ហាក់ដូចជាគិតដោះស្រាយនូវបញ្ហានោះ។ នាមប័ណ្ណនេះជារបស់ម្ចាស់ទ្រព្យ ដែលដាក់ជាប់នឹងកាបូបហើយមានសេចក្តីខ្លីៗថាៈ

| |
|---|
| ឧកញ៉ាសំបូរសម្បត្តិ |
| ១២៣ វិថីវេរដេង |
| ភ្នំពេញ |

"បងម៉ី! សមនិយាយឡើងទាំងក្រៀមក្រំ "ខ្ញុំនឹងយករបស់ទាំងអស់នេះទៅអោយម្ចាស់វិញឥឡូវហ្នឹងបង" ប្រាក់របស់គេ ខ្ញុំចាយអស់ជាង៥០រៀលប៉ុណ្ណោះ "ខ្ញុំសុខចិត្តទទួលកំហុសហើយប្រាប់គេតាមត្រង់ថា ការដែលខ្ញុំឆក់កាបូបគេនោះ ក៏ព្រោះតែខ្ញុំអត់ទ្រាំនឹងសេចក្តីស្រេចឃ្លានមិនបាន បើខ្ញុំធ្វើអញ្ចឹងប្រហែលជាគេឃើញចិត្តឃើញថ្លើមខ្ញុំជាមិនខានកាល ហើញជូនគេនឹងអោយរង្វាន់ចំពោះសេចក្តីល្អរបស់ខ្ញុំ ដែលខ្ញុំដឹងនូវកំហុសរបស់ខ្លួនក៏មិនដឹង បើខ្ញុំធ្វើអញ្ចឹង តើបងឯងយល់យ៉ាងម៉េច?

"បើឯងគិតងញ្ចឹងក៏ល្អថើយសម !" ម៉ីសំលឹងមើលមុខសមហើយឆ្លើយ គ្នាមិនជួយត្រេកអរសារ ទរចំពោះលាភរបស់ឯង ដែលកើតឡើងក្នុងផ្លូវអាក្រក់នោះ ការដែលគ្នាស្រលាញ់រាប់អានឯងក៏ព្រោះឯងជាកម្មករដែលប្រព្រឹត្តសុចរិតដូចរូបគ្នាសម ! គ្នាក៏យល់ចិត្តថ្លើមឯងណាស់ដែរ ដែលឯងត្រូវឆក់ទ្រព្យគេដើម្បីជួយជីវិតខ្លួនឯងអោយរួចផុតពីសេចក្តីស្លាប់តែហេតុផលនេះក៏នូវតែស្តាប់មើលទៅដូចជាមិនចូលត្រចៀកគ្នាសោះ ព្រោះគ្នានៅតែជាមិត្តភក្តិដ៏ល្អរបស់ឯង ការបើឯងអត់ឃ្លាន ហេតុអ្វីក៏ឯងមិនមករកគ្នា គ្នាក៏នូវមានបាយល្មមអោយឯងស៊ីបានដែរទំរាំឯងរកការងារបានធ្វើទៅសម ! ឯងគួរយករបស់ទាំងអស់ទៅអោយម្ចាស់គេវិញទៅ ទៅ!ទៅឥឡូវទៅសម គ្នាគិតថាម្ចាស់ទ្រព្យគេមិនរករឿងរ៉ាវអីទេមើលទៅ គេមុខជាសប្បាយចិត្តហើញស្រលាញ់ទឹកចិត្តឯង ដែលឯងដឹងកំហុសរបស់ខ្លួន ជូនកាលគេអាចជួយជ្រំជ្រែងឯងអោយមានការងារធ្វើ បើហោចណាស់ ក៏ជួយរកស៊ីក្លូអោយឯងធាក់បានដែរសម។

សមដកដង្ហើមវែង នឹកអរផងភ័យផង ហើយក៏និយាយឡើងកាត់ថាៈ

បើអញ្ចឹងខ្ញុំនឹងយកទៅអោយម្ចាស់របស់គេវិញ។

និយាយចប់ហើញសមក៏ចាត់ចែងខ្ចប់របស់ទាំងអស់នឹងកូនកន្សែង ដើម្បីយកទៅអោយម្ចាស់គេវិញ។ សមបានចុះចេញពីផ្ទះម៉ីទៅ ដោយការកាត់ចិត្តប្រថុយនឹងគុកច្រវាក់ព្រោះការដឹងកំហុសរបស់ខ្លួន។

ឲឲឲឲ៚៚៚៚

**ភាគទី១៥** **ជាប់គុកព្រោះស្មោះត្រង់**

ការដើររកផ្ទះលោកឧញ្ញាសំបូរសម្បត្តិនោះ មិនជាការលំបាកអ្វីឡើយ ព្រោះផ្ទះទាំងអស់ដែលស្ថិតនៅតាមវិថីវែរដេងសុទ្ធសឹងតែមានលេខរៀងទាំងអស់។ សមឈរវេរានៅខាងមុខមាត់ទ្វាររបង ហើយសំលឹងមើលទៅក្នុងពន្លឺអគ្គិសនីក្នុងផ្ទះនៅភ្លឺច្រាលរន្ទាលនៅឡើយ ហើយមានមនុស្សបំរើ ដើរចុះឡើងទៅមក។ អាណាខែត្រនៃផ្ទះនេះធំទូលំទូលាយ ហើយគឺផ្ទះសង់ទាន់សម័យ។

ឈរវេរាមួយសន្ទុះ សមក៏កាត់ចិត្តដើរចូលទៅក្នុងផ្ទះ។ សមបានជួបនឹងស្រីបំរើម្នាក់ក្នុងខណៈពេលនោះដែលដើរទៅដលមាត់ជណ្តើរ។ សមលើកដៃសំពះហើយសួរនាងដោយពាក្យសំដីរាបសារថា៖

"អត់ទោសអ្នក !លោកឧញ្ញានឹងលោកស្រីនៅឬទេ?"

"ចាសនៅ ! លោកទើបនិងត្រលប់មកដល់ផ្ទះអំបាញ់មិញនេះឯងបងឯងមាការអី ឬ?"

"សុំអ្នកទៅជំរាបលោកបន្តិចបានឬទេថា ខ្ញុំមកសុំជួបនឹងលោកដោយមានធុរះផ្ទាល់ខ្លួន"

"មើលទៅលោកដូចជាមិនអោយជួបទេ" ស្រីបំរើនោះនិយាយឡើង ព្រមទាំងសំលឹងមើលមុខនិងខោរអាវរបស់សំ លោកកំពុងតែមួរម៉ៅខ្លាំងណាស់ ព្រោះលោកត្រូវចោរឆក់យកបានកាបូបប្រាក់បានពីល្ងាចមិញនេះឯង។

"បើអញ្ចឹងស្រួលហើយ !"សមនិយាយហើយសើចឡើង "សុំអ្នកចូលទៅជំរាបលោកថា អ្នកលេងដែលបានឆក់យកកាបូបប្រាក់របស់លោកនោះគឺរូបខ្ញុំហ្នឹងហើយ"។

ស្រីបំរើឈរស្រឡាំងកាំងហើយសំលឹងមើលមុខសមដោយសេចក្តីងឿងឆ្ងល់។ មួយសន្ទុះក្រោយមក ទបនាងពោលថា៖

"ចាស ! បើអញ្ចឹងស្រួលហើយ ខ្ញុំនិងចូលទៅជំរាបលោកឥឡូវហ្នឹង"។

ស្រីបំរើនោះក៏ឡើងទៅលើផ្ទះវិញយ៉ាងរូសរាន់ ។ ខណៈនើលោក ឧកញ្ញានិងលោកស្រីដែលតើបត្រលប់មកពីមន្ទីរស្នងការក្រុមព្រះនគរបាលវិញនោះកំពុងតែអង្គុយសំរាកកាយ ដោយការនឹកមួរម៉ៅក្តៅក្រហាយស្តាយទ្រព្យដែលបានបាត់បង់នោះ។ ស្រីបំរើដើរបន្ទន់ខ្លួនចូលទៅកាន់លោកទាំងពីរដោយការគោរព។

"លោកស្រី !" ស្រីបំរើជំលោកស្រី "អ្នកលេងដែលបានឆក់កាបូបលោកស្រីនោះ ឥឡូវនេះវាមកសុំជួបនឹងលោកស្រីវាប្រាប់ថា វានាំយករបស់ទាំងអស់នោះមកប្រគល់លោកស្រីវិញ"។

លោកឧញ្ញា និងលោកស្រី ហាក់ដូចជស្រឡាំងកាំងដោយការងឿងឆ្ងល់ ព្រោះលោកមិនដែលឃើញចោរណាមួយលួចយកទ្រព្យគេហើយៗយកមកប្រគល់អោយម្ចាស់ដើមគេវិញឡើយ។

"ឯងនិយាយថាម៉េច ?"លោកឧញ្ញាសួរបញ្ជាក់ដោយការចង់ដឹង "អាចោរដែលវាឆក់កាបូបនោះ វាយកអ៊ីវ៉ាន់មកអោយវិញឬ?"។

"ចាស !" ស្រិបំរើឆ្លើយឡើង "វាយកអ៊ីវ៉ាន់មកជូនវិញឥឡូវវាឈរនូវមាត់ជណ្តើរ"។

លោកឧកញ្ញា និងលោកស្រីស្ទុះក្រោកឡើង ហើយនាំគ្នាដើរចេញទៅមើលសមដោយការរួសរាន់ ។ លោកទាំងពីឈប់ឈរ សំលឹងមើលមុខសមដោយការពិនិត្យពិច្ច័យ ។លោកស្រីចេះតែស្រម៉ៃៗថាហាក់ដូចជានូវចាំមុខនូវឡើយ។

សមបានបន្ទាបខ្លួនចុះ ហើយលើកដៃសំពះលោកឧញ្ញា និងលោកស្រីដោយសេចក្តីគោរពនូវត្រង់មាត់ជណ្តើរនោះឯង។

"ឯងឈ្មោះអី ?"លោកស្រីសួរឡើង "នៅឯណា?"

"សូមលោកស្រីមេត្តាអត់ទោសផងចុះតានប្រោស !"

សមឆ្លើយឡើង ព្រមទាំងលើកដៃសំពះ "ខ្ញុំបាទជាអ្នកឆក់កាបូបលោកស្រីតានប្រោស"។

"អញដឹងហើយ ព្រោះអញនូវចាំមុខឯងបាន"

លោកស្រីនិយាយកាត់ឡើង៖

"គេអញចង់ដឹងថា ឯងឈ្មោះអី ? នៅឯណា ?

"ខ្ញុំបាទឈ្មោះសមទានប្រោស"

"ឈ្មោះសម"លោកស្រីឧទានឡើងតិចៗ "រូបរាងមុខមាត់ឯងដូចជាគ្រាន់បើដែរ តែហេតុអីក៏ឯងរកស៊ីលួចឆក់គេអញ្ចឹង"

"នៅគ្រប់ចំនួនទាំងអស់ទានប្រោស ! "សមឆ្លើយឡើងហើយជូនរបស់ទាំងអស់ទៅលោកឧញ៉ាសំបូរសម្បត្តិ ប្រាក់ខ្ញុំបាទចាយអស់តែ៥០រៀលប៉ុណ្ណោះ ឯកាបូបនោះខ្ញុំចាំបាច់ត្រូវគ្រវែងចោលបាត់ទៅហើយទានប្រោស។

លោកឧញ៉ាបានហៅសមអោយឡើងទៅលើផ្ទះ ហើយយករបស់ទាំងអស់ទៅពិនិត្យមើលជាមួយលោកស្រី។

លុះឃើញថារបស់ទាំងអស់នៅសល់គ្រប់ចំនួនហើយលោកឧញ៉ាក៏ញញឹមស្រស់ឡើងភ្លាម។តែលោកបែទៅសំលឹងសមមើលមុខសមដូចជាចង់ស៊ីសាច់ ហើយនិយាយឡើងថា៖

"កាបូបស្បែកក្រពើរបស់អញថ្លៃជាងមួយពាន់ណាមិនមែនលេងផេងទេ"

សមខំប្រឹងញញឹមទាំងមុខក្រៀម ហើយនិយាយឡើងដោយគោរពថា៖

"សុំទោសទៅចុះលោកស្រី !កាបូបនោះខ្ញុំបានក្រវាត់ចោលទៅហើយ ព្រោះខ្ញុំបាទក្រែងគេចាប់បាន ខ្ញុំបាទសុំឆ្លៀតយកឱកាស់នេះចូលមកជំរាបដើម្បីទទួលនូវកំហុសរបស់ខ្ញុំបាទដែលខ្ញុំបាទបានជាប្រព្រឹត្តខុសជ្រុលទៅហើយ ខ្ញុំបាទមិនធ្លាប់លួចប្លន់គេ មកពីមុនសោះទានប្រោស ខ្ញុំបាទជាអ្នកធាក់ស៊ីក្លូ តែខ្ញុំបាទរកស៊ីក្លូធាក់មិនបានថ្ងៃនេះ ខ្ញុំបាទអត់បាយពេញមួយថ្ងៃសេចក្ដីស្រេកឃ្លានបានបង្ខំចិត្តខ្ញុំបាទ អោយហ៊ានឆក់កាបូបលោកស្រីដើម្បីយកប្រាក់ទៅទិញបាយទទួលទានតែលុះខ្ញុំបាទឃើញប្រាក់ និងរបស់របរមានតំលៃជាច្រើន ព្រមដោយនាមប័ណ្ណ ខ្ញុំបាទក៏ប្រញាប់ប្រញាល់យកមកជូនលោកស្រី ខ្ញុំបាទសង្ឃឹមថាព្រះតេជគុណនិងលោកស្រី មុខជាអាណិតអាសូរ ខ្ញុំបាទហើយអត់ទោសអោយខ្ញុំបាទជាមិនខាន..."។

"អើពួកអាឯងនេះ វាអញ្ចឹង" លោកឧកញ៉ានិយាយផងសើចផងដោយការហួសចិត្តហួសថ្លើម "កំហុសរបស់អាឯងនេះវាធ្ងន់ណាស់ អញអត់អោនអោយមិនបានទេហេតុផលដែលអាឯងអាងថាការរដែលអាឯងធ្វើចោរលួចឆក់ព្រោះសេចក្ដីស្រេកឃ្លាននោះអញស្ដាប់ដូចជាមិនចូលត្រចៀកសោះ"។

ខណះនោះ ទឹកមុខសមឡើងដូចជាអត់ឈាមភ្លាម ព្រោះសមមិនបាននឹកនាថា លោកឧគានឹងនិយាយពាក្យនេះឡើយ ។ បើតាមធម្មតាមនុស្សទាំងឡាយ ដែលលើកលែងទោសអោយ

មនុស្សទុច្ចរិតកនុងពេលដែលជននោះដឹងនូវកំហុសរបស់ខ្លួន ព្រោះក្រៅពីបានទ្រព្យមកវិញហើយ ជនទុច្ចរិតនោះបានដឹងនូវកំហុសរបស់ខ្លួន ដែលគួរតែបានទទួលនូវសេចក្តីមេត្តាប្រណីពីម្ចាស់ទ្រព្យទៀតផង ។ មុនពេលដែលសមនិយាយថា អ្វីទៅទៀត លោកស្រីក៏និយាយឡើងឡូឡាថាៈ

"អញស្តាយកាបូបអញណាស់ ឯងយករបស់អញទៅលាក់ទុកនៅឯណាទេដឹង"។

"ទេលោកស្រី ! សមឆ្លើយឡើង "បើខ្ញុំបាទលាក់ទុកកាបូបនោះខ្ញុំបាទចាំនាំមាស់ប្រាក់នោះមកជូនលោកស្រីវិញ ធ្វើអ្វីទានប្រោស"។

ពេលនោះលោកស្រី ស្រែកហៅអ្នកបំរើរបស់លោក អោយចូលមកជិតហើយលោកបង្គាប់ទៅអ្នកបំរើអោយនាំខ្លួនសមយកទៅអោយប៉ូលីស ។ សមភិតភ័យជាខ្លាំងនៅពេលដែលបានឮពាក្យបង្គាប់របស់លោកស្រីនេះ។

"អានេះ គឺជាចោរដែលឆក់កាបូបអញពូកែងនាំវាយកទៅប្រយ័ត្នកុំអោយវារត់រួចណារបស់របរអីអញ យកពីវាអស់ហើយ" ។

មុនពេលអ្នកបំរើ និងអ្នកបើកបររថយន្តនាំយកខ្លួនទៅប្រគល់ខ្លួនអោយប៉ូលីស សមបានក្រាបសំពះអង្វរករសុំទោសលោកឧញ្ញាសំបូរសម្បត្តិ និងលោកស្រីម្តងទៀតៈ

"ព្រះតេជៈគុណ ! លោកស្រី ! សុំមេត្តាអត់ទោសអោយខ្ញុំបាទម្តងទៅចុះទានប្រោស បើយកខ្ញុំបាទទៅអោយប៉ូលីស ខ្ញុំបាតមុខជាជាប់គុកហើយ...។

"ឪ ឯងដឹងថាជាប់គុកដែរ" លោកស្រីនីតាគោងឡើងដោយការខឹងសម្បារ "បើអាឯងខ្លាចជាប់គុកអញ្ចឹងអាឯងធ្វើចោរធ្វើអ្វីអញអត់ទោសអោយអាឯងមិនបានទេស្រេចតែលើប៉ូលីសទៅចុះ" ។

សមងើបមុខឡើង សម្លឹងមុខលោកឧញ្ញា និងលោកស្រីដោយក្រសែភ្នែកដែលសំដែងនូវការអង្វរករ។

"លោកស្រី! គួរតែអាណិតចោរ ដែលដឹងនូវកំហុសរបស់ខ្លួនហើយលែងទោសអោយគ្នាផងទានប្រោស"។

"ទេ ! អញមិនអាណិតទេ" លោកស្រីគ្រវីក្បាល ហើយនិយាយឡើងខ្លាំងៗ "អញអត់ទោស អោយចោរមិនបានទេ អាឯងធ្វើចោរ អាឯងត្រូវតែជាប់គុក" លោកស្រីបែមុខខាងអ្នកបំរើ និងអ្នកបើករថយន្ត ដែលឈរនៅជិតៗលោក "ទៅ ! ពួកឯងនាំវាយកទៅបកទៅ នៅបង្អែរបង្អង់ដល់ណាទៀតហាស។

ពាក្យថាគុក ជាពាក្យដែលមនុស្សទាំងឡាយខ្លាចហោយមិនចង់ដើរជិត។ ឯសមក៏ខ្លាចគុកដូចអ្នកដ៏ទៃដែរ។កាលបើពាក្យអង្វរករបានក្លាយទៅជាខ្យល់ហើយសមក៏ស្ទុះក្រោកឈរឡើង ហើយសើចតិចៗ ដោយសេចក្ដីក្រាវក្រោធ។

"លោកស្រី !" សមនិយាយឡើងដោយពាក្យសំដីធម្មតា គ្មានការគោរព "ខ្ញុំបានដឹងច្បាស់ថាក្នុងពេលនេះថា សេចក្ដីល្អវាគ្មានប្រយោជន៍អ្វីនោះទេ បើដឹងថាងញ្ចឹងខ្ញុំបាទក៏មិនយករបស់ទាំងនេះមកជូនលោកស្រីវិញដែរ តែខ្ញុំបាទស្មានថាលោកស្រីមុខជាអាណិតអាសូរដល់ចោរម្នាក់ ដែលបានឆក់លោកស្រី ព្រោះសេចក្ដីស្រេកឃ្លាន..."។

លោកស្រីគំហកអោយអ្នកបំរើទៀតៈ

"ទៅ ! នាំវាយកទៅ"

សមបានកាត់ចិត្តក្នុងខណះនោះភ្លាម ក្នុងការប្រុងប្រៀបចាំប្រយុទ្ធតស៊ូនិងពួកអ្នកបំរើរបសលោកឧញ្ញាសំបូរសម្បត្តិ។ផាំង ! ដៃស្ដាំរបស់សមបានក្ដាប់ជាមុននោះបានដាល់ចមថ្គាមរបស់អ្នកបើករថយន្ត ដែលចូលមកចាប់តាមពាក្យបញ្ជារបស់លោកស្រី ហើយធ្វើអោយអ្នកបើកបររថយន្តនោះដួលព្រូសទៅលើឥដ្ឋ។ អ្នកបំរើម្នាក់ទៀតស្ទុះចូលមកប្រឡូកនិងសមភ្លាម លោកស្រី និងលោកឧញ៉ាបានស្រែកហៅមនុស្សម្នានៅក្នុងផ្ទះអោយចូលមកជួយចប់សមទៀត។ហើយសមកម្មករអភ័ព្វដែលភ្ញាក់រលឹកក្នុងកំហុសរបស់ខ្លួនក៏ត្រូវអ្នកបំរើរបស់លោកឧញ្ញាសំបូរសម្បត្តិប្រហែលជាងដប់នាក់ចូលមកចាប់វាយដំច្រំធាក់ម្នាក់មួយដៃមួយជើង។ លោកឧញ្ញា និង លោកស្រីឈរសំលឹងមើលដោយការភ័យក្រែងសមរត់រួច។

សមខំប្រឹងតស៊ូដើម្បីរត់ ចុះចេញពីផ្ទះនោះ តែពួកអ្នកបំរើបានចោមរោមជុំវិញខ្លួនដើម្បីស្ទាក់ផ្លូវ។ ខណះនោះ ជើងរបស់អ្នកណាមួយបានធាក់ត្រង់ពោះសមពេញមួយទំហឹងធ្វើអោយសមដួលចុះ

ភ្លាម។ ក្នុងពេលដួលចុះនេះ សមត្រូវពួកគេចោមផាក់ទាត់តាមចិត្តទាល់តែលោកឧញ្ញាស្រែកឃាត់។

"ល្មើយប៉ុណ្ណឹងបានហើយ តិចលោវាងាប់ទៅនាំអោយពិបាកដល់អញ អើអានេះវាគ្រាន់បើណាស់ផង វាដាល់អាគុណាដួលពីរបីត្រឡប់ ទៅ ! នាំគ្នាជួយលើកវាឡើងហើយយកវាទៅបកទៅបន្តិចទៀតអញទៅតាមក្រោយ"។

សមឈឺចាប់គ្រាំគ្រាពេញរាងកាយ.......ពួកអ្នកបំរើចាប់ទាញកន្ត្រាក់អាវអោយសមក្រោកឡើង។ រង្វង់មុខរបស់សមហើមពោរឡើង ចិញ្ចើម និងបបូរមាត់បែកឈាម ...សមត្រូវអ្នកបំរើអូសចេញពីផ្ទះទាំងកំលាំង ហាក់ដូចជាគ្មានអាណិតអាសូរមេត្តាប្រណីអ្វីបន្តិចបន្តួចសោះឡើយ។

ក្នុងពេលម៉ោងជាមួយគ្នានោះ សមក៏បានទៅជ្រកនៅក្នុងទីឃុំឃាំងរបស់ប៉ូលីស ពិតណាស់បើទុកជាយ៉ាងណាក៏ដោយ សមក៏មុខជាត្រូវតុលាការកាត់ទោសដាក់គុកក្នុងឋានៈជាចោរលួចឆក់ជាមិនខាន តែសមក៏សុខចិត្តទទួលនូវបាបកម្មដ៏ធ្ងន់នោះដោយការចាំបាច់ដែរ។

ការនេះជាទារុណកម្មនៃម្ចាស់ទ្រព្យដែលមិនអាណិតអាសូរ ឬមេត្តាប្រណីដល់សមដែលជាមនុស្សធ្វើខុសហើយ ព្រមទទួលកំហុសនោះសោះ។ ដូច្នោះកម្មករអ្នកមានបាបកម្មគួរអោយអាណិត ក៏ត្រូវក្រុមប៉ូលីសបញ្ជូនខ្លួនទៅតុលាការតាមពាក្យចោទរបស់អយ្យការចោទក្នុងឋានៈជាអ្នកលួចឆក់ទ្រព្យសម្បត្តិរបស់គេ។ចំលើយព្រមទទួលសារភាពតាមពាក្យចោទទាំងអស់ ដោយឥតមានប្រកែកតវ៉ាអ្វីឡើយ ហើយបានជំរាបតុលាការដែលហេតុនាំអោយឆក់ទ្រព្យរបស់គេនោះក៏ព្រោះគេស្រេកឃ្លាន ប៉ុន្តែចំលើយបានសុំនូវសេចក្តីអនុគ្រោះពីតុលាការ សុំអោយតុលាការមេត្តាបន្ធូបន្ថយទោសប៉ុណ្ណោះ។មើលៗទៅហាក់ដូចជាថា តុលាការក៏បានអនុគ្រោះដល់ចំលើយខ្លះដែរ...លោកចាងហ្វាងបានវិនិច្ឆ័យ កាត់សេចក្តីដាក់គុកសមចំនួន៦ខែ។

សមត្រូវឈានជើងចូលទៅកាន់គុកធំនៃក្រុងភ្នំពេញម្តងទៀត...។

ថ្ងៃខែបានកន្លងផុតទៅ ដោយសេចក្តីទុក្ខលំបាកខ្លាំងទាំងរាងកាយនិងចិត្ត។ជីវិតក្នុងគុកធំរបស់សមម្តងនេះ គ្មានមិត្តភក្តិណាចូលទៅសាកសួរសុខទុក្ខសោះឡើយសមត្រូវគេប្រើអោយធ្វើ

ការធ្ងន់ ហើយរស់នៅដោយអាហារអាក្រក់ៗក្នុងមួយថ្ងៃៗតែ៤-៥ម៉ាត់ប៉ុណ្ណោះ។ ៦ខែនៅក្នុងគុកធំ សមបានស្រកសាច់ឈាមចុះជាច្រើនទាល់តែខុសពីប្រក្រតីស្ទើរតែមើលមុខមាត់មិនយល់។

សម ខំខាំធ្មេញមនះអត់ធន់ទទួលទោស ......អត់ធន់តស៊ូនឹងសេចក្ដីទុក្ខវេទនានៅក្នុងគុកធំ...ទីបំផុតឥស្សរភាពជាទីស្នេហា ក៏បានវិលត្រឡប់មករកសមវិញ។ ព្រឹកនោះលោកចាងហ្វាងរងនៃពន្ធនាគារ បានហៅសមអោយចូលទៅជួប ហើយប្រាប់ដំណឹងថាសមត្រូវរួចទោសហើយ ព្រោះតុលាការបានចេញដីកាបង្គាប់អោយដោះលែងខ្លួន។

"គុកគេធ្វើឡើងសំរាប់ដាក់មនុស្សខូច មនុស្សអាក្រក់អ្នកទោសទាំងអស់គឺជាមនុស្សទុច្ចរិតប្រព្រឹត្តខុសគន្លងច្បាប់"លោកចាងហ្វាងរងបានអោយ ឪវាទដល់សមដោយទឹកមុខញញឹមញញែមហាក់ដូចជាជួយត្រេកអរក្នុងការដែលសមបានរួចទោស "ឯងគួរតែប្រែចិត្តគំនិតត្រឡប់ខ្លួនមកធ្វើជាពលរដ្ឋដ៏ល្អវិញ មុខមាត់ឯងមិនគួរជាអាជ្ញាករសោះ ខ្ញុំសុំអោយពរសព្វសារធុការដល់ឯង សុំអោយឯងបានជួបប្រទះតែនឹងសេចក្ដីសុខសេចក្ដីល្អតរៀងទៅ ហើយសុំកុំត្រឡប់មកអោយខ្ញុំឃើញមុខវិញទៀត....។

"សាធុ ! សាធុ ! សមលើកដៃសំពះទទួលពរសព្វសាធុការ" នេះរាប់ថាជាព្រះគុណដ៏ធំធេងលើសលប់ ដែលព្រះតេជៈគុណមេត្តាដាស់តឿនក្រើនរំលឹក ហើយអោយពរសព្វសាធុការដល់ខ្ញុំបាទ ខ្ញុំបាទនឹងខំតាំងចិត្តតាំងថ្លើម ធ្វើអោយខ្លួនបានទៅជាពលរដ្ឋដ៏ល្អរៀងទៅ...។

## <u>**ភាគទី១៦**</u> **ទីពឹងថ្មី**

ចេញផុតចាកអាណាខេត្តនៃគុកធំ សមដូចជារកប្រាប់ខ្លួនឯងមិនត្រូវងានឹង ទៅណាព្រោះសមគ្មានផ្ទះសំបែង គ្មានប្រាក់កាស សមត្រូវដើរត្រឹកទៅ តាមវិថីនានាដោយគ្មានគោលបំណងនិងសេចក្ដីសង្ឃឹមឡើយ ។

ក្នុងទីបំផុតសមក៏កាត់ចិត្តចូលទៅក្នុងហាងជំនួញមួយ ហើយដើរសំដៅទៅរកបុរសមានវ័យកណ្ដាលម្នាក់ ដែលតែងខ្លួនហ៊ឺហាអង្គុយធ្វើការនៅត្រង់តុមួយ។

"សុំប្រណិប័តន៍ព្រះតេជៈគុណ!" សមលើកដៃសំពះ ហើយសួរដោយគោរព "កន្លែងនេះត្រូវការគូលីធ្វើការទេឬទានប្រោស ខ្ញុំបាទមកសុំការព្រះតេជៈគុណធ្វើ" ។

បុរសនោះ សំលឹងមើលមុខសមទាំងកំហឹង ហាក់ដូចជាសត្រូវស៊ីសាច់ហុតឈាមនឹងគ្នាកាលពីមួយពាន់ឆ្នាំមកហើយៗ យកដៃទះតុយ៉ាងខ្លាំង។

"អ្នកណាអោយឯងចូលមកអញ្ចឹង !" បុរសនោះស្រែកគំហក "ចេញទៅវិញទៅ មុខមាត់ដូចអ្នកសុំទានអញ្ចឹង មិនដឹងជាមករកការធ្វើឆ្កួតអីទេ នៃស្មៀន ! ដេញអាឆ្កួត នេះ ចេញទៅវិញទៅ" ។

សមខំប្រឹងញញឹមទាំងមិនពេញចិត្តហើយឡើងថាៈ

មិនចាំបាច់បណ្ដេញទេទានប្រោស ខ្ញុំបាទចេញទៅវិញឥឡូវហ្នឹងហើយ ខ្ញុំបាទគ្រាន់តែចូលមកសុំធ្វើការប៉ុណ្ណោះ ព្រោះខ្ញុំបាទទីទាល់ក្រ បើព្រះតេជៈគុណមិនអោយទេក៏វារួចគ្នាទៅហើយទានប្រោស។

ទៅ! ចេញទៅ កុំនិយាយច្រើន គ្មានការអីអោយឯងធ្វើទេ ក្រមានយ៉ាងម៉េច មករ៉ាយរ៉ាប់ប្រាប់អញធ្វើអ្វី វាជារឿងរបស់ឯងទេតើ។

កម្មករពោះម៉ាយខាំធ្មេញក្រឹត ហើយដើរចេញពីទីនោះមកវិញ ដោយទឹកមុខក្រៀមក្រំ អនិច្ចាអើយ! ខ្មែរដូចគ្នា! បងប្អូនមនុស្សដូចគ្នា ! មិនគួរណាជារង្កៀសព្ទស្អប់ខ្ពើមគ្នាដល់ប៉ុណ្ណឹងសោះឡើយ ។

ចំហាយនៃព្រះអាទិត្យ ក្នុងពេលរសៀលបានបាចជះនូវកំដៅទ្វេរឡើងជាលំដាប់ សមបានដើរខ្វាត់ខ្វែង ទៅតាមវិថីនានា ក្នុងព្រះរាជធានី ។ សមអង្គុយសំរាកកាយក្រោមម្លប់ឈើម្ដងៗ ក្នុងកាលហត់នឿយ ។ ទិដ្ឋិមានៈរបស់សម ដែលបានតាំងចិត្តថានឹងមិនពឹងពាក់ ម៉ីដែលជាមិត្តភក្តិកម្មករចាស់នោះ ឥឡូវនេះត្រូវរលាយសូន្យទៅ ហើយព្រោះសមសំលឹងមើលទៅ ដូចជាគ្មានអ្នកណាពឹងពាកបានក្នុងពេលលំបាកក្រៅពីម៉ីសោះឡើយ។ ដូច្នេះសមក៏កាត់ចិត្ត ទៅរកជួបម៉ីម្ដងទៀត ។

ប៉ុន្តែនៅពេលទៅដល់ទីនោះ សមបានឃើញផ្ទះរបស់ម៉ីមានមនុស្សថ្មីមកនូវ ឯផ្ទះដែលកម្មករខ្មែរនៅ ៤ទៅ៥ នាក់ មកជួលនៅជិតៗផ្ទះម៉ីនោះ ក៏ក្លាយទៅជាចិនយួនអស់។ សមបានសាកសួរយាយ

ចាស់ម្នាក់ ដែលអង្គុយលក់នំក្រោមដើមឈើមួយដើម នៅក្បែរនោះ។ យាយចាស់នេះសំលឹងមើលមុខសម ហើយក៏ឆ្លើយមកវិញព្រមទាំងគ្រវីក្បាល។

ឪ ម៉ី នាងម៉ុម នោះឬ ? វាលែងនូវជាងមួយខែហើយចៅ ព្រោះម្ចាស់ផ្ទះគេមកសុំប្រាក់៥០០ រៀល ដើម្បីជួសជុលផ្ទះ តែម៉ីគ្មាន ម្ចាស់ផ្ទះគេបណ្តេញលែងអោយនៅទៅហើយ ឥឡូវគេយកផ្ទះនោះមកជួលអោយចិន បានទឹកប្រាក់ដល់ទៅមួយពាន់រៀល ឯថ្លៃជួលបានមួយខែបីរយរៀលមើលចុះចៅអើយ មុំនេះសុទ្ធតែចិនយួន ស្ទើរតែទាំងអស់ ព្រោះចិនយួនវាមានប្រាក់ទឹកតែអោយម្ចាស់ផ្ទះណាចៅ ។

ឪលោកយាយ! មនុស្សយើងបូជាប្រាក់ដូចព្រះ! សមដកដង្ហើមវែងៗ ហើយនុយាយទាំងឃ្នាន់ខ្នាញ់ ខ្ញុំ ស្មានមើលទៅថា មិនយូរប៉ុន្មានទេ ពួកខ្មែរយើងមុខជារត់ទៅនៅព្រៃផ្សៃអស់ហើយៗ ទុកទីផ្សារអោយចិនយួននៅ ព្រោះអ្នកមានផ្ទះជួលខិតខំរកវិធីដេញពួកខ្មែរ ដើម្បីទុកផ្ទះជួលអោយចិនយួនយកប្រាក់ទឹកតែ។

សមបានមកពីកន្លែងនោះវិញ ហើយចេះតែដើរសាត់អណ្តែតទៅ ក្នុងឋានៈជាកម្មកររកការងារធ្វើមិនបានម្នាក់។ ទីបំផុត ការម៉្យាងដែលជាការពិតនោះ គឺសមត្រូវចាប់ផ្តើមអត់អាហារទៀតហើយ សមមិនមែនអត់អាហារដើម្បីធ្វើទុក្ខកិរិយាកម្មកូដកម្ម ដើម្បីទាមទារសិទ្ធសិរីភាពឡើយ តែសមអត់ព្រោះគ្មានអាហារបរិភោគ។ដូចជាសាកសព ដែលអាចកំរើកខ្លួនបាន សមចេះតែដើរសាត់អណ្តែតទៅដោយគ្មានគោលបំណង ឬទីដៅអ្វីឡើយ សមមានទឹកមុខខ្មៅជាំខុសធម្មតាមានប្រស្រីភ្នែកដែលគ្មានរស្មីនៃសេចក្តីរីករាយ ហើយមានសំលៀកបំពាក់ នឹងខ្លួនប្រាណមិនខុសគ្នាពីពួកស្មូមយាចក តាំងពីថ្ងៃត្រង់រហូតដល់រសៀល រហូលដល់ពេលល្ងាច សេចក្តីស្រេកឃ្លានបានធ្វើទុក្ខបុកម្នេញសមជាខ្លាំង។ សមដូចជាស្រយុតស្រយ៉ុងរោយស្រពោនទន់អស់ទាំងកាយ។ហើយក្នុងវេលាប្រហែលជាម៉ោង១៧ កន្លះ សមក៏បានជួបនឹងឧប្បទ្វហេតុ ដែលគួរអោយព្រឺខ្លួន ក្នុងខណ:ដែលបានឆ្លងកាត់វិថីដោយគ្មានអារម្មណ៍អណ្តែតអណ្តូង ហើយមិនឃើញរថយន្តមួយ ដែលលូនចូលមកក្នុងរយ:ដ៏ជិត អ្នកបើកបរខំជាន់ប្រាំងបញ្ឈប់រថយន្តនោះ ក៏បុកកម្មករពោះម៉ាយ ដែលគួរអោយអាណិតនោះ ដួលដេកនៅលើវិថីនាកណ្តាលសំលេងស្រែកភ្លាមៗមាត់ភ្លាត់ករបស់ស្រីៗ២ - ៣នាក់ដែលបានឃើញហេតុការណ៍ដ៏គួរខ្លាចនោះ។

គ្រោះថ្នាក់បែបនេះ រាប់ថាជាគ្រោះអាក្រក់សំរាប់អ្នកមានតែថាវាជាគ្រោះល្អសំរាប់អ្នកក្រដូចរូបសម ព្រោះគ្រោះថ្នាក់នេះជាហេតុធ្វើអោយសមមានការងារធ្វើសុភាពបុរសកម្លោះម្នាក់ដែលអង្គុយនៅលើរថយន្តខាងក្រោយនោះ ជារដ្ឋមន្ត្រីនៃក្រសួងមួយ ដែលលោកទើបនឹងត្រឡប់មកពីប្រទេសបារាំងកាលពីឆ្នាំទៅ ហើយលោកទើបនឹងត្រូវជ្រើសតាំងជារដ្ឋមន្ត្រីកាលពីប៉ុន្មានខែមុននេះ។ដោយសារការភ័យនឹកអាណិតអាសូរ លោករដ្ឋមន្ត្រីកំលោះក៏បើកទ្វាររថយន្តចុះទៅមើលភ្លាម។

ខណ:នោះអ្នកបើករថយន្តស្ទុះទៅត្រកងបីសមឡើង។ តែគ្រោះថ្នាក់នេះក៏មិនជាធ្ងន់អ្វីប៉ុន្មាន គឺគ្រាន់តែបែកក្បាលជង្គង់ និងគ្រេចកជើងខាងស្តាំ ប៉ុណ្ណោះលោករដ្ឋមន្ត្រីជួយលើកសមហើយពិនិត្យមើលដោយក្រសែភ្នែក ដែលសំដែងនូវសេចក្តីអាណិតអាសូរ។

"លើកដាក់លើឡានទៅ !" លោកមន្ត្រីបង្គាប់អោយអ្នកបើកបររថយន្ត "ហើយនាំគាត់យកទៅពេទ្យ ហើយលោកអោនសួរទៅសមដោយសេចក្តីមេត្តា" ម្តេចទៅបងត្រូវត្រង់ណាខ្លះ?

មិនអីទេទៀនប្រោស! សមឆ្លើយយ៉ាងតិចៗ ត្រូវបន្តិចបន្តួចប៉ុណ្ណោះ ហើយការនោះវាជាកំហុសរបស់ខ្ញុំបាទ ដែលដើរឆ្លងកាត់ផ្លូវដោយការប្រហែសធ្វេសពេកមិនងាកមើលឆ្វេងស្តាំជាមុន សុំព្រះតេជ:គុណមេត្តាដាក់ខ្ញុំ បាទទៅវិញចុះរបួសបន្តិចបន្តួចប៉ុណ្ណោះមិនចាំបាច់ទៅពេទ្យទេទានប្រោស។

"បើអញ្ចឹងខ្ញុំនឹងជូនបងទៅផ្ទះ" លោកមន្ត្រីនិយាយឡើយដោយទឹកមុខញញឹម "ចុះផ្ទះបងនៅដល់ណាទៅ?"

" ខ្ញុំបាទជាមនុស្សអនាថា ជាកម្មករដែលគ្មានការងារធ្វើទេទានប្រោស។"

លោករដ្ឋមន្ត្រីក្មេងងក់ក្បាលទទួលស្តាប់ពាក្យសំដីរបស់សម ដោយការអាណិតអាសូរ។ លោកពេញចិត្តចំពោះការសុភាពរាបសារបស់សមជាខ្លាំងសមជាអ្នកក្រមានសំលៀកបំពាក់មិនសមរម្យក៏ដោយ តែសមក៏មានឫកពារ និងពាក្យសំដីគួរអោយស្រលាញ់ និងអាណិតដែរ។

"បង!" លោករដ្ឋមន្ត្រីនិយាយឡើយដោយពាក្យផ្អែមល្ហែម អាណិតបងឯងណាស់ក្នុងការដែលបងឯងត្រូវទទួលគ្រោះថ្នាក់ ដោយសារឡានរបស់ខ្ញុំនេះ ខ្ញុំសូមជូនបង៥០០រៀល ជាសោហ៊ុយខូចខាត បើបងមានការអីសូមអញ្ជើញទៅរកខ្ញុំចុះ ហើយលោកហុចប្រាក់ព្រមទាំងនាមប

ណ្ណ មួយសន្លឹកទៅអោយសម "សុំបងទៅរកខ្ញុំកុំខានណា" ពាក្យសំដី ដែលពោរពេញដោយសេចក្តីមេត្តាករុណា របស់លោករដ្ឋមន្ត្រីនេះ បានធ្វើអោយសមកោតសរសើរ និងគោរព ហើយនិយាយតិចៗថា ៖

ព្រះតេជៈគុណមេត្តាខ្ញុំបាទនោះ សុំព្រះតេជៈគុណកុះអោយប្រាក់ខ្ញុំបាទធ្វើអ្វីទានប្រោស សុំព្រះតេជៈគុណមេត្តាជួយរកការងារធ្វើ ការអីក៏បានដែរទានប្រោស អោយខ្ញុំបាទធ្វើវិញទៅល្អជាជាង ហើយនិយាយតិចៗថា ៖

ព្រះតេជៈគុណមេត្តាខ្ញុំបាទនោះ សុំព្រះតេជៈគុណកុះអោយប្រាក់ខ្ញុំបាទធ្វើអ្វីទានប្រោស សុំព្រះតេជៈគុណមេត្តាជួយរកការងារធ្វើ ការអីក៏បានដែរទានប្រោស អោយខ្ញុំបាទធ្វើវិញទៅល្អជាជាង ហើយនិយាយតិចៗថា ៖

" ព្រះតេជៈគុណមេត្តាខ្ញុំបាទនោះ សុំព្រះតេជៈគុណកុះអោយប្រាក់ខ្ញុំបាទធ្វើអ្វីទានប្រោស សុំព្រះតេជៈគុណមេត្តាជួយរកការងារធ្វើ ការអីក៏បានដែរទានប្រោស អោយខ្ញុំបាទធ្វើវិញទៅល្អជាជាង ព្រោះខ្ញុំបាទកំពុងដើររកការងារធ្វើ ការអីក៏បានដែរអោយតែជាការងារសុចរិត ខ្ញុំបាទធ្វើបានទាំងអស់ ដោយមិនរើសអើងថាធ្ងន់រឺស្រាលឡើយ។"

"ខ្ញុំជាអ្នករាជការ មិនមែនជាអ្នកជំនួញទេ តែខ្ញុំ ពេញចិត្តនិងជួយបងតាមសមត្ថភាព ខ្ញុំត្រូវនាំបងទៅពេទ្យសិន ហើយសុំនាំបងឯងទៅឯផ្ទះខ្ញុំ បងឯងមិនរើសអើងការងារមែនរឺទេ?"

សមខំប្រឹងញញឹមទាំងដែលមានរាយកាយកំពុងឈឺចាប់ព្រោះការត្រេកអរលើសលន់ពន់ប្រមាណ។

ខ្ញុំបាទមិនរើសអើងទេទានប្រោសអោយតែឈ្មោះថាការងារ ខ្ញុំបាទធ្វើបានទាំងអស់សុំអោយតែការងារនោះជាការងារសុចរិត។

រថយន្តបានលូនចេញពីកន្លែងកើតឧប្បទ្វហេតុនោះសន្សឹមៗ ។ សមបានអង្គុយជិតលោករដ្ឋមន្ត្រីត្រង់បាំងខាងក្រោយ។ លោករដ្ឋមន្ត្រីបានសំលឹងពិនិត្យមើលសមដោយការគិតវែងឆ្ងាយ។ រថយន្តបានបើកបរសំដៅទៅឱសថាល័យព្រះអង្គឌួង។

" បង! លោករដ្ឋមន្ត្រីនិយាយប្រាប់សមតាមផ្លូវ ដោយការអាណិតអាសូរ ខ្ញុំនឹងអោយបងថែទាំផ្ទះសំបែងខ្ញុំ ដើម្បីអោយបងងាមានការធ្វើ ហើយមិនពិបាកតទៅទៀត "។

សូមអរគុណព្រះតេជៈគុណណាស់ហើយទានប្រោស! សមលើកដៃសំពះហើយឆ្លើយឡើងស្រេចតែព្រះតេជៈគុណមេត្តាខ្ញុំទៅចុះទានប្រោស។មនុស្សយើង ត្រូវតែពឹងពាក់គ្នាទៅវិញទៅមកណាបង លោកមន្ត្រីសំឡឹងមើលមុខសមហើយនិយាយោឡើងយឺតៗ មនុស្សត្រូវមានសិទ្ធស្មើគ្នាតែសិទ្ធសេរីភាពនោះត្រូវមានព្រំដែន ខ្ញុំរីករាយណាស់ ក្នុងការដែលខ្ញុំបានជួយជ្រោមជ្រែងមនុស្សដែលមានទុក្ខលំបាក សុំទោសចុះបង បងឈ្មោះអី?

" ខ្ញុំបាទឈ្មោះ សម ទានប្រោស "។

" បងឯងមានបងប្អូន ឪពុកម្តាយឬទេបង?"

" ទេទានប្រោស ... "។

" បើអញ្ចឹងក៏ស្រួលដែរ ខ្ញុំនឹងជួយបងឯងអោយបានស្រួល ខ្ញុំមិនត្រូវការអីក្រៅពីសេចក្តីស្មោះត្រង់សុចរិតរបស់បងឯងទេបង "។

" បាទទានប្រោស! ខ្ញុំបាទនឹងធ្វើជាអ្នកបំរើ ព្រះតេជៈគុណដោយសេចក្តីស្មោះត្រង់តរៀងទៅ "។

ជីវិតរបស់សម បានវិលវល់ផ្លាស់ប្តូរទៅតាមយថាកម្ម ... ។

សមបានទទួលនូវសេចក្តីសុខកាយសប្បាយចិត្តគ្រាន់បើបន្តិច នៅក្រោមម្លប់ដំបូលផ្ទះរបស់លោករដ្ឋមន្ត្រីកំលោះដែលមានចិត្តទូលំទូលាយចំពោះជនរួមជាតិទូទៅ។

ႺႺႺႼႼႼ

## <u>**ភាគទី១៧**</u> **កសិករថ្មី**

ដោយសារកិរិយាមាទដ៏សុភាពរាបសាររបស់សម លោករដ្ឋមន្ត្រីក៏អាណិតអាសូរនិងស្រលាញ់សមជាខ្លាំងសមមានជ្រកកោននៅក្រោមម្លប់នៃដំបូលផ្ទះរបស់លោករដ្ឋមន្ត្រីដោយសេចក្តីសុខសាន្ត។

ប៉ុន្តែសមសម្លឹងមើលឃើញថា ការរស់នៅក្នុងឋានៈជាកម្មករនៅរាជធានីមិនមែនជាការសុខកាយសប្បាយចិត្តរស់ដោយមានកិត្តិយសថ្កុំថ្កើង,រស់នៅដោយការចំរើនលូតលាស់ឡើយ ការរស់នៅក្នុងក្រុងចំនួនប៉ុន្មានឆ្នាំមកនេះ ជីវិតរបស់សមត្រូវរិចរិលបន្តិចម្តងៗ ដូចជាបុប្ផាដែលគេយកទៅដាំនៅក្នុងផើងគ្មានជីរជាតិហើយដែលកាន់តែស្វិតស្រពោនមួយថ្ងៃបន្តិចៗ...

ក្នុងកាលដែលប្រទេសកម្ពុជាបានឯករាជបរិបូរណ៍ ហើយដោយសារស្នាព្រះហស្ថរបស់ព្រះបាទសម្តេចព្រះ នរោត្តម-សីហនុ ជាព្រះមហាក្សត្រ ដ៏ឆ្នើមក្នុទំព័រប្រវត្តិសាស្ត្រខ្មែរ ព្រះរាជាណាចក្រទាំងមូល ដែលធ្លាប់ជួបប្រទះនូវអសន្តិសុខ ដែលជាមហន្តរាយយ៉ាងសំបើមដោយ សារពួកឧទ្ទាមនោះឥឡូវក៏បានប្រែក្លាយទៅជាមានសន្តិសុខយ៉ាងពិតប្រាកដ។

ប្រជារាស្ត្រខ្មែរគ្រប់ជាន់ថ្នាក់ ទោះនៅក្នុងទីក្រុងក្តី ស្រុកស្រែចំការក្តី ក៏បានទទួលនូវ សេចក្តីសុខក្សេមក្សាន្តឥតមានភ័យបារម្ភណ៏ចំពោះអសន្តិសុខទៀតឡើយ។

សមបានសំឡឹងមើលទៅឃើញនូវការដ៏សំខាន់ម្យ៉ាង ដែលអាចនាំឲ្យជីវិតគេ ឲ្យមានជំហានឈានឆ្ពោះ ទៅកាន់សេចក្តីចំរើនរុងរឿងទៅអនាគតនោះគឺសមបាននឹកឃើញដល់វាលស្រែដ៏ធំធេង តែគ្មានអ្នកភ្ជួររាស់។ វាលស្រែស្រុកសមអាចនឹងក្លាយទៅជាគំនរ ទ្រព្យសម្បត្តិ យ៉ាងវិសេសបាន ប្រសិនបើមានកសិករខិតខំកាប់គាស់សំរុកភ្ជួរ រាស់ជាថ្មីគួរឲ្យស្តាយណាស់! ស្តាយស្រែភ្លឺដែលជាគកវ័មរតកពីបុព្វបុរសបានសាងទុកឲ្យមក ហើយសមបានបោះបង់ចោលនូវមតិដែលមានតំលៃនោះអស់ចំនួនច្រើនឆ្នាំណាស់មកហើយ!......តែការបោះបង់ចោលនោះ ក៏មិនមែនប្រែសេចក្តីថាសមខ្ពើមអើមចំពោះការរកស៊ី ដោយកំលាំងកាយដ៏សុចរិតនោះឡើយ។ កាលដែលសមបោះបង់ស្រែចំការចោលហើយមកនៅទីក្រុងនេះ វារិតតែធ្វើឲ្យសមមានសភាពដុនដាបជាងនៅស្រុកស្រែចំការទៀត។ សមបោះបង់ស្រែចំការចោលក៏ព្រោះអសន្តិសុខ។

ឥឡូវនេះព្រះអាទិត្យថ្មីបានរះនៅលើផែនដីចាស់ ហើយគឺរះនៅលើផែនដីនៃអណានិគមបារាំង ហើយនឹងផែនដីនៃ អ្នកនយោបាយបោកប្រាស់ព្រះអាទិត្យថ្មីបានយកនូវស្មើនៃ សន្តិភាពមកបាចជះនៅលើផែនដីចាស់ ! សមបានតាំងចិត្តយ៉ាងម៉្រង ត្រូវតែត្រឡប់ទៅលីចប នង្គ័ល រនាស់នៅស្រុកកំណើតដូចជាពេលមុនវិញ ………។

សមសប្បាយរីករាយណាស់ ក្នុងកាលដែលនឹកឃើញដល់ជីវភាពនៃកសិកររបស់ខ្លួនពី អតីត ដែលពោរពេញទៅដោយឥស្សរភាពនិងសុខដុមរមនាសមក៏កាត់ចិត្តថា ត្រូវតែត្រឡប់ទៅកាន់ជីវភាពចាស់នោះវិញ។

សមនៅចាំបានទៀត ក្នុងថ្ងៃនក្ខត្តនប្ញក្សមួយនោះព្រះមហាវីរក្សត្រ ព្រះបិតាឯករាជ្យជាតិ ទ្រង់បានថ្លែងព្រះរាជសុន្ទរកថា ទៅកាន់ជនរួមជាតិ ដើម្បីដាស់តឿនប្រជាពលរដ្ឋឲ្យនឹក រលឹកដល់វាលស្រែយើង ព្រោះវាលស្រែនេះហើយជាឫស ព្រោះសមយល់ថាវាលស្រែ ខ្មែរគឺ ជាជង្រុកមាសពេជ្រ សេដ្ឋកិច្ចក៏បានលូតលាស់។ ហេតុនេះក្នុងឋានៈជាពលរដ្ឋខ្មែរស្នេហា ជាតិម្នាក់ សមក៏បានប្ដេជ្ញាចិត្តថា ត្រូវតែត្រឡប់ទៅកាន់ស្រុកកំណើតវិញ ដើម្បីពួតដៃគ្នាជាមួយកសិករខ្មែរ ទាំងឡាយកសាងយឿនសេដ្ឋកិច្ច ដែលបានទ្រុឌទ្រោមរេចរិលក្នុងសម័យអាណានិគមនិយម ឲ្យបានខ្ពស់ត្រដែតឡើងវិញ…………………….

សមគិតថាត្រូវយក នង្គ័ល រនាស់ ចបកាប់ ចបជីក កណ្ដៀវមកធ្វើជាគ្រឿងឧបករណ៍ នៃអាជីកម្មថ្មី ដោយត្រូវត្រឡប់ទៅកសាងជីវភាព "កសិករថ្មី" ដោយរួសរាន់……

ពិតដូចគំនិតមែន សមត្រឡប់ទៅប្រកបការងារកសិកម្មវិញដោយចិត្ត តែអស់ពេលបីឆ្នាំ មកហើយការធ្វើស្រែ ពុំទាន់បានផលល្អមកឲ្យសមនៅឡើយ ព្រះសមត្រូវធ្វើស្រែប្រវាស់នឹង មេឃ បើមេឃបង្អុរភ្លៀងចុះមក កសិករទាំងឡាយមានសមជាដើម ក៏មានសង្ឃឹម សមនិង កសិករខ្មែរភាគច្រើនធ្វើស្រែមិនសូវបាចំរើនសោះ។ សមនិងកសិករឯទៀតៗត្រូវធ្លាក់ចុះក្នុងសេចក្ដីអស់សង្ឃឹម …

ប៉ុន្តែការអស់សង្ឃឹមរបស់កសិករមានសមជាដើមនោះ ពុំមែនបិតនៅអស់មួយជីវិតទេ នុះហ្ន! កសិករទាំងនោះត្រូវបានរីករាយឡើងវិញហើយ…… ជីវភាពកសិករដែលកំពុងតែក្រៀម ក្រំស្វិតស្រពោននោះឥឡូវក៏ប្រែទៅជាស្រស់ប្រកបដោយសេចក្ដីសង្ឃឹមយ៉ាងធំទូលាយឡើងវិញហើយ….

សង្ឃឹមអ្វី? សង្ឃឹមលើការធ្វើស្រែចំការប្រវាស់នឹងមេឃនោះឬ?

មិនមែនទេ ! សមឈប់សង្ឃឹមលើមេឃទៀតហើយ តែសមបែរជាមានសង្ឃឹមទៅលើ " នយោបយទឹក" ទៅវិញ…

ចាប់តាំងពីសម័យសង្គមរាស្ត្រនិយមកើតឡើងហើយកាន់កាប់ប្រទេសក្រោមការដឹកនាំ ដ៏ភ្លឺស្វាងរបស់សម្តេចព្រះនរោត្តម សីហានុ មកប្រទេសកម្ពុជាបានឈានមួយជំហានយ៉ាងវែង ទៅកាន់សម័យថ្មី " សម័យកសាង" ។

រាជរដ្ឋាភិបាលបានជួយយឹតយោងលើកកំរិតជីវភាពប្រជារាស្ត្រដោយប្រគល់ វិធីហើយ ជាពិសេសគឺ " ផែនការប្រចាំឆ្នាំ" ដែលនៅក្នុងនោះ មានការ "ហត្ថកម្ម" ជាដួងព្រលឹងរបស់កសិករ ….

សព្វថ្ងៃនេះ សមលែងសង្ឃឹមលើមេឃទៀតហើយ ព្រោះសមមានទំនប់ទឹក មានស្រះ មានអណ្តូងប្រើប្រាស់គ្រប់គ្រាន់ កាលពេលមុន សមត្រូវអុចធូបបន់ព្រះសំពះទេវតាសុំទឹកភ្លៀង តែឥឡូវទោះបីបើគ្មានភ្លៀងសមក៍មិនអស់សង្ឃឹមដែរ ព្រោះក្នុងស្រុករបស់សម ដែលកាលពីដើមគ្មានទំនប់ទឹក គ្មានស្រះ គ្មាន អណ្តូងឥឡូវក៍បានប្រែក្លាយទៅជាសំបុកទឹកឥតខ្វះខាត…

រាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម បានដឹកនាំប្រជារាស្ត្រស្ថាបនាទំនប់ទឹកឲ្យជីកស្រះ ជីកអណ្តូង ជាច្រើននៅក្នុងស្រុករបស់សម។ កសិករទាងឡាយមានសមជាដើមក៍បានខិតខំជួយកសាងដោយសេចក្តីរីករាយ…

កសិករទាំងឡាយមានសមជាដើម លែងមានសេចក្តីព្រួយបារម្ភណ៍ពីរឿងទឹកសំរាប់ ប្រើប្រាស់នឹងធ្វើស្រែចំការទៀតហើយ ជាពិសេសដីស្រែចំការរបស់សមដែលកាលពីមុនៗមក បានផ្តល់ផលយ៉ាងតិចតួចស្តួចស្តើងនោះ ឥឡូវក៍បានហុចផលយ៉ាងសំបើមដល់កសិករថ្មីនេះ។

សមនឹកពេញចិត្តចំពោះនយោបាយទឹក គឺហត្ថកម្មលើទំនប់ទឹករកអ្វីប្រៀបគ្មាន ស្រែ សមបានចំរើន ស្រែរបស់កសិករឯទៀតក៍បានចំរើន ហើយវាលស្រែគ្រប់ជនបទ ក្នុងព្រះរាជាណាចក្រទាំងមូលក៍បានចំរើនដែរ កាលបើកសិកម្មបានចំរើនដូច្នេះសេដ្ឋកិច្ចជាតិក៏បានលូតលាស់យ៉ាងពិតប្រាកដ…

ក្រៅពីនេះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម បានជួយឃើតយោងកសិករមួយផ្លូវទៀតគឺ ជួយលើកតំកើងផលិផលដែលកើតឡើងក្នុងប្រទេសយើង អាស្រ័យហេតុនេះផលិតផលខ្មែរក៏ត្រូវមានជំហររឹងប៉ឹងនឹងថ្លៃថ្នូរក្នុងផ្សារក្នុងប្រទេស និងផ្សារបរទេស…

មិនមែនមិនបាច់ពព្រួយតែអំពីរឿងខ្វះទឹកធ្វើស្រែទេសមត្រូវមិនបាច់ព្រួយបារម្មណ៍អំពីការខ្វះខាតពូជដំណាំ ការបំផ្លាញនៃសត្វចង្រៃ ដែលតែងតែស៊ីបំផ្លញនូវដំណាំផ្សេងៗទៀតផង

សព្វថ្ងៃនេះ នៅក្នុងស្រុករបស់សម ក៏ដូចជានៅគ្រប់តបន់នៃព្រះរាជាណាចក្រដែរគឺ រាជរដ្ឋាភិបាលបានបង្កើតក្រសួងកសិកម្មសំរាប់ធ្វើគំរូដល់កសិករ ក្នុងការបណ្តុះពូជព្រមទាំងសំរាប់ការពារផលដំណាំរបស់កសិករទៀតផង។

សមបានទទួលនូវកាតពន្យល់ហ្វឹកហាត់គ្រប់ផ្នែកមានការធ្វើដីឲ្យមានជីវជាតិ ការបណ្តុះពូជារ។ល។ អំពីភ្នាក់ងារនៃក្រសួងកសិកម្ម។ សមរឹតតែសប្បាយចិត្តចំពោះកិច្ចការរបស់ខ្លួនណាស់ទៅទៀត។

ពេលមួយនោះសត្វចង្រៃបានស៊ីបំផ្លាញស្រូវ របស់សមនឹងអ្នកស្រុងឯទៀត។សមបាន ទៅប្តឹងក្រសួងកសិកម្ម ដើម្បីឲ្យជួយប្រយុទ្ធនឹងសត្វចង្រៃ។ ក្រសួងនេះក៏បានចាត់ភ្នាក់ងារឲ្យ ចេញទៅប្រតិបត្តិការបាចថ្នាំកំចាត់សត្វចង្រៃតាមពាក្យសុំរបស់សម… សមបានឃើញច្បាស់ និងភ្នែកថាក្នុងសម័យបច្ចុប្បន្ន គឺជាសម័យកសាងរបស់សង្គរាស្ត្រនិយម មិនមែនដូចសម័យ អាណានិគមរាំងឬក្នុងសម័យឯករាជ្យក្លែងក្លាយនោះឡើយ។

សម័យសង្គមរាស្ត្រនិយម គឺជាសម័យដែលរាជរដ្ឋាភិបាល បានជួយជ្រោមជ្រែងកសិករ ក្នុងការធ្វើស្រែចំការ ហើយថែមទាំងលើកតំកើងកសិករ ឲ្យក្លាយទៅជាពលរដ្ឋដ៏មាន តំលៃក្នុងសង្គមជាតិ កសិករសម័យព្រះសីហានុមិនមែនរាប់អោន ឬ ថោកទាបដូចសម័យមុនៗ ឡើយ…

សមស្រលាញ់សង្គមរាស្ត្រនិយមស្មើដោយជីវិត...សព្វថ្ងៃសេចក្តីស្មោះត្រង់ដែលហូរចេញពីដួងចិត្តដ៏បរិសុទ្ធនោះ សមបានបូរជាចំពោះសង្គមរាស្ត្រនិយមដោយសេចក្តីគោរព...

សមបានឃើញច្បាស់នឹងភ្នែកថា ព្រះបិតាឯករាជ្យជាតិព្រះអង្គទ្រង់មិនប្រកាន់ព្រះរាជឋានៈឡើយ...ព្រះអង្គតែងយាងចេញទៅប្រតិបត្តិការហត្ថដោយផ្ទាល់ព្រះហត្ថកម្មហើយ ឲ្យចេះអាណិតអាសូរស្រលាញ់រាស្ត្រ···

សម័យសង្គមរាស្ត្រនិយម មន្ត្រីរាជាការគ្រប់រូបត្រូវបោះបង់នូវដងប៉ាកាចោល មួយពេលមួយគ្រា ដើម្បីទៅចាប់ ,រនាស់, ចប, បង្គី ជួយធ្វើស្រែរាស្ត្រនឹងដើម្បីបង្ហាត់ចិត្តគំនិតរបស់មន្ត្រីរាជការឲ្យដឹងសុខទុក្ខ និងជីវភាពរបស់ប្រជារាស្ត្រ។

សមហ៊ាននិយាយថា ក្នុងទំព័រប្រវត្តិសាស្ត្រខ្មែរ គ្មានព្រះមហាក្សត្រអង្គណា ឬ វីរជនរូបណាដែលចេញទៅធ្វើការហត្ថកម្ម ដោយព្រះហស្ត ឫដៃដូចសម្តេចព្រះនរោត្តមសីហនុនោះ ឡើយ។ ក្នុងពេលថ្មីៗ នេះ សម្តេចព្រះឧបយុវរាជទ្រង់បានស្តេចយាងទៅប្រតិបត្តិការហញដោយផ្ទាល់ ព្រះហស្តរបស់ព្រះអង្គនៅជិតស្រុកភូមិរបស់សម។ ដោយសារការស្រឡាញ់ពេញចិត្តព្រោះឃើញច្បាស់ថាសង្គមរាស្ត្រនិយមក្រោមការដឹកនាំដ៏ភ្លឺស្វាងរបស់សម្តេចព្រះឧបយុវរាជនរោត្តមសីហនុពិតជាធ្វើផលប្រយោជន៍ឲ្យប្រជារាស្ត្រដោយជាក់ស្តែងនោះ សមបានខិតខំប្រឹងប្រែងដើរបញ្ចុះបញ្ចូលអ្នកស្រុកអ្នកភូមិឲ្យយល់ដល់តំលៃនៃការហត្ថកម្មស្រឡាញ់ហត្ថកម្ម ហើយនាំគ្នាស្ម័គ្រចិត្តចូលទៅជួយរួបរួមក្នុងការហត្ថកម្មនោះ···ការហត្ថកម្មនោះក៏បានសម្រេចផលគួរជាទីពេញចិត្ត···

សមបានយកកំលាំងកាយនិងកំលាំងចិត្តបូជាចំពោះសង្គមរាស្ត្រនិយម ដោយឥតខ្លាចនឿយហត់សោះឡើយ។ មិនយូរប៉ុន្មានប្រជារាស្ត្រក្នុងស្រុកភូមិ ក៏ស្រឡាញ់ គោរពសមនិងស្តាប់បង្គាប់សម ហើយទុកសមដូចជាមេកើយរបស់ខ្លួន...

ដោយសារសេចក្តីស្មោះត្រង់របស់សមចំពោះជាតិ,សាសនា,ព្រះមហាក្សត្រគិនិងសេចក្តីប្រឹងប្រែងចំពោះការងារគ្រប់បែប មានការដឹកនាំប្រជារាស្ត្រអោយធ្វើការហត្ថកម្មជាដើមដែលជាការជួយដោយបានសម្រេចនូវគោលបំណងរបស់សង្គមរាស្រនិយមនោះរាជរដ្ឋាភិបាលក៏ពេញចិត្តចំពោះអកប្បកិរិយារបស់សមជាខ្លាំង ហើយបានសរសើរសមដោយរង្វាន់និងគ្រឿងឥស្សរយសផ្សេងៗដ៏គួរពេញចិត្ត។

មិនយូរប៉ុន្មានសមត្រូវបានប្រជារាស្ត្រស្រុកភូមិបោះឆ្នោតជ្រើសរើសតាំងឲ្យធ្វើជាប្រធានកម្មាធិការក្នុងឃុំនៃសង្គមរាស្ត្រនិយម...

កាលដែលបានធ្វើជាប្រធានហើយ សមក៏រឹងរិតតែប្រឹងប្រែងធ្វើការណាស់ទៅទៀត...សមបានដឹកនាំអ្នកស្រុកឲ្យដើរតាមក្រោយរបស់សម្តេចសហជីវិនគឺដឹកនាំឲ្យចេះស្រលាញ់ការងារ,ពួតដៃគ្នាជីកស្រះអណ្តូងលើកថ្នល់,សង់ស្ពាន សង់សាលារៀន។ល។ក្រៅពីនេះសមដឹកនាំអ្នកស្រុកឲ្យចេះស្រលាញ់ករណីយកិច្ចនៃពលរដ្ឋដ៏ល្អមានការកម្ចាត់ទុច្ចរិតជាដើម។

ជាពិសេសបំផុតសមបាដឹកនាំអ្នកស្រុកឲ្យស្គាល់ពីតំលៃនៃសមាជជាតិពេលសមាជម្តងៗ អ្នកស្រុកសមតែងតែនាំគ្នាមករួបរួមប្រជុំជាច្រើន។

អ្នកស្រុកសមកាលពីដើមល្ងង់ខ្លៅ ឥលូវបានប្រែទៅជាមនុស្សចេះដឹងនិងយល់ការណ៍

ស្រុកសមដែលតែងជួបប្រទះនូវទុរ្ភិក្សកាលពីដើមនោះ ឥលូវក៏ប្រែក្លាយទៅជាស្រុកសម្បូរសប្បាយ...អ្នកស្រុកសមកាលពីដើមមានភាពដុនដាបនោះ ឥលូវក៏ប្រែក្លាយទៅជាមានភាពធូរធារជាងមុនជាច្រើន...។

ឈឈឈៈៈៈ

**<u>ភាគទី១៨</u>** **សមាជជាតិលើកទី៩**

រថអ័យបានលូនចូលចតនៅស្ថានីយ៍ភ្នំពេញហើយ...អ្នកដំណើរទាំងឡាយមានសេចក្តីរីករាយសប្បាយជាខ្លាំង ក្នុងការដែលខ្លួនបានមកដល់ទីដៅដោយសុវត្ថិភាព។ស្ថានីយ៍ភ្នំពេញនៅពេលម៉ោង១២នោះ មានភាពអ៊ូអរខុសប្រក្រតី ដោយសារប្រជាជនមករង់ចាំទទួលបងប្អូនញាតិមិត្តដែលធ្វើដំណើរមកកាន់ព្រះរាជធានីដើម្បីចូលរួមក្នុងសមាជជាតិលើកទី៩ដែលនឹងត្រូវធ្វើនៅថ្ងៃស្អែកនេះ។សំលែងស្រែកហៅថា និយាយគ្នាបានលាន់លឺឡើងកងរំពង...អ្នកដំណើរទាំងឡាយខំប្រឹងប្រជ្រៀតចុះពីរថអ័យដោយប្រញាប់ប្រញាល់។

ក្រោយពេលបានចុះពីរថអ័យហើយដើរចេញពីស្ថានីយ៍រថអ័យមក សមបានឡើងជិះត្រីចក្រយានទៅសំណាក់នៅសណ្ឋាគារលំហែរអាកាស។

ចាប់តាំពីវិនាទីដែលបានឈានជើងចូលមកជាន់ទឹកដីនៃទីក្រុងភ្នំពេញសមបានសង្កេតឃើញព្រះរាជធានីមានទិដ្ឋភាពអ៊ូអរកុះករខុសពីសម័យ៧-៨ឆ្នាំមុន...នៅតាមវិថីនានារថយន្ត

ទោចក្រយាន,ត្រីចក្រយាន។ល។តែងធ្វើដំណើរទៅឥតឈប់ឈរ ដែលញ៉ាំងឲ្យមានសកម្មភាពរស់រវើកជានិច្ចក្នុងចរាចរ ដ៏មានរបៀបរៀបរយនៃព្រះរាជធានី...

ល្ងាចនៃថ្ងៃនេះសមបានជិះត្រីចក្រយានដើរមើលទីក្រុង ដែលទុកដូចជាមុខមាត់នៃប្រទេស។សមបានសង្កេតឃើញច្បាស់នឹងភ្នែកថា ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះរាជធានីភ្នំពេញបានប្រែរូបភាពខុសប្លែកពីដើមឆ្ងាយណាស់គឺគេហដ្ឋានកាន់តែរីកចំរើនឡើង ហើយកាន់តែមានកំពស់ឡើងរហូតដល់ទៅ ៧-៨ជាន់។ រោងភាពយន្តក៏កាន់តែមានចំនួនច្រើនឡើង ឯផ្លូវថ្នល់ក៏ត្រូវបានពង្រីកធំៗជាងមុនស្ទើរតែទាំងអស់…នៅតាមសង្កាត់នានា ដែលកាលពីដើមគ្មានការចំរើនទាល់តែសោះនោះ ឥឡូវបានប្រែក្លាយទៅជាមានផ្លូវថ្នល់ មានទឹកម៉ាស៊ីន និងភ្លើងអគ្គីសនីប្រើប្រាស់គ្រប់គ្រាន់…ស្ពានកូនកាត់កាលដើមជាកន្លែងសំរាប់ហិតក្លិនទឹកសំអុយនោះ ឥឡូវស្រាប់តែមានប្រាសាទមួយផុតឡើងយ៉ាងល្អវិចិត្រមិនខុសគ្នាពីវិមាននៃប្រាសាទអង្គរវត្ត។ នុះគឺអនុស្សាវរីយ៍ឯករាជ្យ…ហើយចាប់តាំងពីវិមានថ្មីនេះ ត្រង់ទៅខាងកើតផ្សារកាប់គោ ឆៀងទៅដល់មុខវត្តកែវព្រះភ្លើងឥឡូវបានប្រែរូបភាពទៅជាទំនើប…ផ្លូវទំនប់ទឹកពីស្ពានព្រះមុនីវង្សរហូតទៅដល់ស្ពានយមរាជ ( គ.មលេខ ៤ កន្លះផ្លូវកំពត ) កាលពីដើមជាកន្លែងស្ងាត់គ្មានអ្នកណាហ៊ានដើរតែម្នាក់ឯងនោះឥឡូវមានផ្លូវដ៏ស្អាតមានផ្ទះសំបែងកុះករ ដែលសង់ដោយមានរបៀបរៀបរយ…នៅតាមវិថីព្រះមុនីវង្សចំខាងលិចផ្សារធំថ្មីកាលពីដើមសុទ្ធតែជារង្គសាលនិងផ្ទះស្លឹកតូចៗ ហើយជាជំរកនៃពួស្រីពេស្យាឥឡូវបានប្រែរូបទៅគ្រឹះស្ថាននិងសណ្ឋាគារធំៗខ្ពស់ត្រដូចត្រដឹម…ខាងលិចចន្លោះទៅគឺចំការចិន ដែលកាលពីដើមជាចំការរបស់ពួកចិន ប្រសិនបើដើរមិនប្រយ័ត្នវង្វេង ហើយមានក្លិនអសោចនោះឥឡូវ ក៏បានក្លាយទៅជាសង្កាត់ ជំនួញដែលមានគ្រឹះស្ថានធំៗដែរ…ភូមិ ព្រែក កាលពីដើមជាជំរករបស់ពួកស្រីពេស្យានិងពួកអ្នកលេងឥឡូវបានប្រែរូបទៅជាសាលាភូមិន្ទវិជ្ជាពេទ្យ រោងវារីចក្រនិងមន្ទីរទេព្យកាល់ម៉ែត្រ...ឃើញវត្តភ្នំកាលដើមឡើយ ជាកន្លែងសំរាប់ពួកចោរចាំស្ទាក់ប្លន់ពួកអ្នក លេងចាំស្ទាក់និងជាកន្លែងសំរាប់ពួកនោះជុះអាចម៍ ឥឡូវបានប្រែក្លាយទៅជាកន្លែងសំរាប់ប្រជាជនដកកង្ហើមយកខ្យល់អាកាសដ៏ល្អបរិសុទ្ធនៅពេលល្ងាចត្រជាក់…

នៅតាមជួរមាត់ទន្លេសមបានឃើញជំរកកម្មករលីសែងមួយ…ព្រះពុទ្ធមានបុណ្យសមបានឃើញជំរកកម្មករត្រីចក្រយានមួយកន្លែងទៀត ហើយក្នុងពេលនោះ សមបានឃើញពួកកម្មករត្រីចក្រយានកំសត់ទាំងឡាយ កំពុងជ្រកនៅក្នុងទីនោះដោយសេចក្តីរីករាយសប្បាយយ៉ាងក្រៃលែង…

សមនឹកស្តាយណាស់…ស្តាយកាលដែលខ្លួននៅជាកម្មករកាលពី៧-៨ឆ្នាំមុនខ្លួនគ្មានទីពឹង គ្មានជំរកដើរដេកតាមសំយាបផ្ទះចិនឬក្រោមដើមឈើ…ឥឡូវពួកកម្មករសម័យថ្មីបានជួបប្រទះនូវវាសនាយ៉ាងធំ គឺបានទទួលនូវការឧបត្ថម្ភយ៉ាងកក់ក្តៅពីរាជរដ្ឋាភិបាល ដែលជួយសង្គ្រោះអោយមានកន្លែងសំរាប់ជ្រក អាស្រ័យដើម្បីការពារនូវភ្លៀងផ្គរនិងកំដៅនៃព្រះអាទិត្យ…

តពីនោះមកសមបានប្រទះឃើញនូវអច្ឆរិយវត្ថុជាច្រើនទៀត ដែលទើបតែនឹងផុសឡើងក្នុងសម័យសង្គមរាស្ត្រនិយមនោះ…

សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ មហាវិទ្យាល័យ បានផុសឡើងជាច្រើនជំនួសវង្គសាលកាលពី៧-៨ឆ្នាំមុន…មន្ទីរពេទ្យព្រះមហាក្សត្រយានីកុសុមៈសំរាប់ព្រះសង្ឃ មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតឱសថាល័យគ្រប់សង្កាត់ មន្ទីរសម្ភព ហើយនិងគ្រឹះស្ថានទំនើបៗទាំងឡាយក្នុងមន្ទីរពេទ្យចាស់នាសម័យអាណានិគមនិយមបារាំង គឺមន្ទីរពេទ្យព្រះកេតុមាលាឥឡូវក៏បានប្រែរូបភាពទៅជាស្អាតស្អំ…

សមបានសង្កេតឃើញនូវការចំរើនលូតលាស់ យ៉ាងសំបើមខាងផ្លូវសាធារណៈសុខាភិបាលនាសម័យបច្ចុប្បន្ន ដោយសាររាជរដ្ឋាភិបាលបានគិតដល់វិធីការពារសុខភាពប្រជារាស្ត្រ មិនបណ្តោយអោយប្រជាជនក្រីក្រលំបាកវេទនាឈឺថ្កាត់ដោយឥតទីពឹងដូចសម័យមុនឡើយ…រាជរដ្ឋាភិបាលបានចាត់វិធានការធ្វើអោយប្រជារាស្ត្រតូចតាចមានទីពឹងដ៏កក់ក្តៅខាងផ្លូវសុខាភិបាល…មិនតែប៉ុណ្ណោះសមបានសង្កេតឃើញថា នៅគ្រប់ជនបទក្នុងព្រះរាជណាចក្រទាំងមូលក៏មានការចំរើនខាងផ្លូវសុខាភិបាលដូចគ្នានឹងការចំរើននៅព្រះធានីដែរ…

ឃើញដូច្នោះ សមនឹកស្តាយណាស់…ស្តាយកាលខ្លួនធ្វើជាកម្មករនៅទីក្រុងខ្លួនគ្មានទីពឹងលើមន្ទីរពេទ្យ ឥឡូវប្រជាជនទូទៅមានទីពឹងដ៏កក់ក្តៅ…សមនឹកស្តាយខ្មោចប្រពន្ធជាខ្លាំង…ស្តាយកាលពី ៧-៨ឆ្នាំមុននេះមន្ទីរពេទ្យមិនមែនជាទីពឹងរបស់សប្រជារាស្ត្រដូចសព្វថ្ងៃនេះ ម្ល៉េះសយប្រពន្ធខ្លួនមិនស្លាប់បាត់បង់ជីវិតឡើយ ហើយអាចមានជីវិតរស់នៅមើលឃើញនូវការចំរើនលូតលាស់របស់ប្រទេសជាតិជាមិនខាន…

សមបានសង្កេតឃើញនូវរថយន្តទំនើបៗ គ្រប់បែបដែលកាន់តែបង្កើតចំនួនច្រើនឡើងៗជាលំដាប់…នៅក្នុងពេលយប់សមបានឃើញពន្លឺភ្លើងអគ្គិសនីភ្លឺព្រោងព្រាតដូចពេលថ្ងៃ…នៅតាមវិថីនានា នៅតាមគ្រឹះស្ថានជំនួញ ឬរោងភាពយន្តទាំងឡាយសុទ្ធតែមានចង្កៀងអគ្គីសនីពណ៌ក្រហមខៀវ លឿង ភ្លឺព្រោងព្រាតគួរអោយចង់ទស្សនាយ៉ាងក្រៃលែង…

ការទាំងនេះសអោយឃើញថា ប្រទេសកម្ពុជាកាន់តែមានការរីកចំរើនលូតលាស់ជាលំដាប់។ ផ្ទុយពីនេះទៅវិញ សមបានសង្កេតឃើញថា រង្គសាលកាន់តែវិនាសបាត់បង់ទៅជាលំដាប់ដែរ សមនៅចាំច្បាស់ថាកាលពី ៧-៨ឆ្នាំមុននេះ គឺមុនពេលដែលប្រទេសយើងបានឯករាជ្យសម្បូណ៌ មករាជធានីភ្នំពេញសម្បូរកុះករដោយរង្គសាលទាំងឡាយមានបារសហាករណ៍ បារហិមាឡាយ៉ បារខុចនិល បាររាត្រីក្បាលថ្នល់។ល។ លុះមកដល់សម័យឥឡូវរង្គសាលទាំងនោះបានបិទទ្វារស្ទើរអស់រលីង មាននៅសល់ខ្លះដែរតែជាចំនួនតិចតួច ហើយមិនសូវមានជាបាររាំច្រៀងផង…ការទាំងនេះសអោយឃើញថាប្រជាពលរដ្ឋខ្មែរគ្រប់ជាន់ថ្នាក់សព្វថ្ងៃ បានកែប្រែចិត្តគំនិតជាថ្មី គឺលះបង់ចោលនូវការសប្បាយ ដែលចាយវាយប្រាក់កាសចោលឥតប្រយោជន៍ជាច្រើន ហើយគិតតែពីខិតខំធ្វើការរកស៊ីតែម៉្យាង ដើម្បីលើកស្ទួយកំរិតជីវភាពនិងប្រទេសជាតិរបស់ខ្លួនអោយបានចំរើនរុងរឿងសមតាមព្រះរាជបំណងដឹកនាំសម្តេចព្រះនរោត្តមសីហនុព្រះបិតាឯករាជ្យជាតិជាទីគោរពនិងបូជារបស់ប្រជាជនខ្មែរ…ម៉្យាងទៀតសមបានសន្និដ្ឋានថាក្នុងសម័យដែលប្រទេសយើង បិតនៅក្រោមនឹមដែក របស់ចក្រព្តិអាណានិគមនិយមបារាំងនិងក្រោមអំណាចគ្រង់គ្រងកិច្ចការរដ្ឋរបស់អ្នកនយោបាយបោកប្រាស់រូបខ្លះនោះ មន្ត្រីរាជការភាគច្រើនតែងប្រព្រឹត្តិអំពើទុច្ចរិផ្សេងៗ…លុះបានប្រាក់កាសច្រើនហើយ ប្រាក់កាសទាំងនោះបានមកដោយងាយផង គេដំនាំគ្នាយកទៅជះចោលនៅលើរង្គសាលនានា ដោយចំនាយចោលទៅលើស្រីកន្តាំង ទៅលើស្រីកូនកាត់ គ្មានស្តាយស្រណោះសោះ ម្ល៉ោះហើយរង្គសាលក៏ត្រូវប្រណាំងប្រជែងគ្នាផុសឡើងដូចផ្សិត…

ចុះសម័យឥឡូវ ហេតុអ្វីក៏បានជារង្គសាលទាំងនោះបិទទ្វារ? អ្នកណាបង្ខំអោយបិទទ្វារ?

សំនួរនេះសមអាចដោះស្រាយរួចដោយខ្លួនឯងដោយមិនចាំបាច់សួរអ្នកណា!...សមសន្និដ្ឋានឃើញថាចាប់តាំងពីពេលដែលប្រទេសយើងបានឯករាជ្យសំប្បូណ៌មករាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម ដែលមានអង្គសម្តេចព្រះឧបយុវរាជជាព្រះអគ្គមគ្គុទ្ទេសក៏ ដំរាងវៃនិងភ្លឺស្វាងជាប្រធាននោះ បានខិតខំធ្វើការយ៉ាងពេញទំហឹង ដើម្បីស្វែងរកប្រយោជន៍ជូនជាតិមាតុភូមិពិតៗ ព្រោះរាជរដ្ឋាភិបាលបានខំជួយឃើតយោងប្រជាពលរដ្ឋតូចតាចខ្សត់ខ្សោយដោយគ្រប់វិធី…បានដាក់បញ្ញតិយ៉ាងតឹងរឹង ដល់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់មិនអោយធ្វើបាបរាស្ត្រជិះជាន់រាស្ត្រសង្កត់សង្កិនរាស្ត្ររំលោភលើរាស្ត្រ ឬ ប្រព្រឹត្តិអំពើទុច្ចរិផ្សេងៗ។ល។ ដោយបានបង្កើតអោយមានក្រសួងបោសសំអាតទូទៅ សំរាប់បោសសំអាតមន្ត្រីរាជការទុច្ចរិត ម្ល៉ោះហើយមន្ត្រីរាជការដែលធ្លាប់ប្រព្រឹត្តិអំពើទុច្ចរិតកាលពីជំនាន់មុន គឺធ្លាប់បានរិបជាន់រាស្ត្រសង្កត់ករស្ត្រ ដើម្បីយកទៅចំណាយចោលទៅលើរង្គសាលនានាកាលពីដើមនោះ ឥឡូវក៏ត្រូវខានបានបន្តសកម្មភាពរបស់ខ្លួនតទៅទៀត ព្រោះការដែលរាជរដ្ឋាភិបាលបានដាក់បទបញ្ញត្តិដ៏តឹងរឹងយ៉ាងនោះ ខានពុំបានប្រាក់ចំណូល

ក្រៅហើយ តើគេបានអ្វីសំរាប់យកទៅចិញ្ចឹមស្រីកន្លាំង ឬស្រីកូនកាត់? ព្រោះប្រាក់បៀវត្សរបស់មន្ត្រីរាជការទាំងនោះល្មមតែចាយវាយគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់គ្រួសាររបស់ខ្លួនតែប៉ុណ្ណោះ ម្ល៉ោះហើយរង្គសាលនានាក៏ត្រូវគ្មានភ្ញៀវ ដែលជាការចាំចាច់ត្រូវតែបិទទ្វារដោយឯងៗ ដោយគ្មានអ្នកណាបង្ខិតបង្ខំ…

រាត្រីនេះ នៅសណ្ឋាគារលំហែអាកាស សមបានដេករំពឹងគិតដល់ការចំរើនគ្រប់ផ្នែកក្នុងព្រះរាជអាណាចក្រ ដោយសារការកសាងរបស់សង្គមរាស្ត្រនិយមក្រោមដឹកនាំរបស់សម្តេចព្រះឧបយុវរាជ ដែលជាព្រះអគ្គមគ្គុទេសក៏ដ៏ឆ្នើមរបស់ប្រជាជាតិខ្មែរ…

សមបាននឹកដល់របៀបវារៈ នៃសមាជជាតិ…របៀបវារៈនៃខមួយនោះបានទាក់ទាញអារម្មណ៍របស់សមជាខ្លាំង។ នុះគឺ ខ១២ដែលស្នើរដោយសហាជីវិននៃខេត្តកំពង់ស្ពឺ…

សមនឹកទើសចិត្តនឹងរបៀបវារៈនោះជាខ្លាំង ព្រោះថាសម័យដែលប្រជាខ្មែរគ្រប់ជាន់ថ្នាក់កំពុងតែរួបរួមគ្នាដើម្បីកសាងជាតិ មិនគួរនឹងមានមនុស្សដែលអួតខ្លួនថា ជាអ្នកចេះគិតតែពីស្រវារវេចនៅក្រោយខ្នងគេឡើយ…។

ꕥꕥꕥ

## **ភាគទី១៩ សមាជជាតិលើកទី៩**

ម៉ោង ៨ កន្លះហើយ ព្រះអារុណនៃថ្ងៃថ្មីបានបញ្ចេញរស្មីត្រចេះត្រចង់នៅលើផ្ទៃមេឃពណ៌ពងក្រសានាទិសបូព៌ សហាជីវិន សហាជីវិនី ជាសមាជិកនៃសមាជទាំងឡាយបានមកជួបជុំគ្នានៅក្នុងបរិវេណនៃវាលព្រះមេរុ…

ពេលនោះគណៈរដ្ឋមន្ត្រី សមាជិកនៃសភាទាំងពីរព្រះរាជវង្សានុវង្ស មន្ត្រីរាជការគ្រប់តំណែង បានស្តេចយាងនឹងអញ្ជើញមកដល់។ បន្ទាប់មកទៀតសម្តេចព្រះឧបយុវរាជព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រយានីក៏បានស្តេចយាងមកដល់ដែរ…

ក្នុងព្រះឋានៈ ជាព្រះរាជធិបតីនៃសមាជព្រះករុណាជាអង្គម្ចាស់ជីវិតលើត្បូងទ្រង់បានថ្លែងព្រះរាជសុន្ទរកថាបើកពិធីសមាជ។ ក្រោយពីនោះមកសម្តេច ព្រះឧបយុវរាជទ្រង់បានថ្លែងព្រះអង្គថា ស្វាគមន៍ចំពោះសមាជិកសមាជដោយព្រះភក្រ័ញញឹមប្រិមប្រិយ។ រួចហើយព្រះអង្គទ្រង់ថ្លែងរៀបរាប់អំពីការចំរើនគ្រប់ផ្នែកក្នុងវិស័យនានានៃនយោបាយក្នុងប្រទេស និងក្រៅប្រទេស ដែលជាលទ្ធផលនៃការកសាងជាតិរបស់សង្គមរាស្ត្រនិយមពីពេលសមាជជាតិលើកទី៨ មកដល់សមាជ

ជាតិលើកទី៩នេះ។ សមាជិកសមាជទាំងឡាយខំផ្ទៀងផ្ទាត់ស្តាប់ដោយយកចិត្តទុកដាក់…សម្តេចទ្រង់បានគូសបញ្ជាក់ថា ចាប់តាំងពីពេលសមាជជាតិនៃរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមបានចំរើនគួរពេញចិត្ត ដែលមានសមិទ្ធិធំៗដូចតទៅនេះ ៖

ការរៀបចំផែនការ ៥ឆ្នាំការស្ថាបនារោងចក្រធ្វើក្រដាស រោងចក្រវាយនភណ្ឌ រោងចក្រធ្វើក្តារបន្ទះ ការស្ថាបនាមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ការបង្កើតអង្គការរដ្ឋសហគ្រាស ដើម្បីប្រមូលផ្តុំថៃទាំប្រើប្រាស់ដោយលក្ខណៈល្អនូវគ្រឿងសំភារៈសំរាប់អាជីវកម្មដែលរាជរដ្ឋាភិបាលបានទទួលពីមហាប្រទេសថាមិត្តនានាឫជាសម្បត្តិរបស់ខ្លួន ការអប់រំ ឧបត្ថម្ភគាំពារយុវជនដែលមានសមានចិត្តចំពោះបច្ចេកទេសនឹងផលិតផលនិងការបើកទ្វារការងារមុខរបរថ្មីដែល ជាប្រយោជន៍ជាតិអោយដល់យុវជន ដែលក្នុងពេលមុនបិតនៅក្នុងស្ថានភាពពិបាកឫតែលតោល ការសន្សំសំចៃហិរញ្ញវត្ថុជាតិដែលកាលពេលមុនត្រូវបង់ខាតជាច្រើនដោយសហគ្រាសឯកជននិងការស៊ីសំណូក ឫ សមគំនិត ការបង្ហំល្បឿននិងវាតអោយធំទូលាយជាងដើមនូវចលនាផលិតកម្មជាតិ ការនាំទឹកអោយបានប្រើប្រាស់គ្រប់គ្រាន់អោយក្រុងភ្នំពេញការធ្វើរួចនឹងសម្ភោធមហាថ្នល់មិត្តភាពខ្មែរអាមេរិកាំង ការចាប់ផ្តើមស្ថាបនានៃស្ពានធំនៅលើទន្លេសាប ការពន្លូតអោយវែងនូវយន្តហោះនៃពោធិចិនតុង។

ការស្ថាបនាគោមបំភ្លឺផ្លូវនាវា នៅកោះរុង សំឡៃមដោយជំនួយបារាំង ការស្ថាបនាហើយសម្ភោធមន្ទីរពេទ្យថ្មីដែលមានគ្រែដេក ១២នៅភ្នំពេញសំរាប់កងខេមរមេភូមិន្ទ ការបង្កើតមហាវិទ្យាល័យអក្សរសាស្ត្រ និងវិទ្យាល័យខ្មែរ អង់គ្លេស ការស្ថាបនារួចស្រេចនឹងសម្ភោធនូវបណ្តាញប្រឡាយបញ្ចូលទឹកនៅសៀមរាប បារាយណ៍ដោយជំនួយអាមេរិកាំង។ ការស្ថាបនានូវទំនប់ទឹកឈូកសនិងលំពូ និងការស្ថាបនាទំនប់ទឹកបេតុងដែកនៅទឹកឆា…

ព្រះអង្គទ្រង់បានថ្លែងរៀបរាប់អំពីការលូតលាស់ នៃការកសាងជាតិនៅក្នុងក្របខណ្ឌនៃក្រសួងនានារបស់ជាតិហើយទ្រង់បានធ្វើសេចក្តីសន្និដ្ឋានដោយកំណត់សំគាល់ថា ៖

កាលសម័យរវាងសមាជជាតិលើកទ៨ និង ៩នេះប្រទេសកម្ពុជាបានជួបប្រទះនូវប្រព្រឹត្តិការណ៍សំខាន់ៗ ដែលជួយគ្នាតែដែលបញ្ចេញអោយឃើញកាន់តែច្បាស់នូវកំលាំងសាមគ្គីធម៌ និងអព្យាក្រិតភាពរបស់ជាតិយើង ដែលម៉្យាងព្យុះសង្ឃរាសំបើមយ៉ាងណាក៏ពុំអាចធ្វើអោយរលំអោយអន្តរាយបាន ម៉្យាងទៀតដែលជាកងចក្រវិលដឹកនាំប្រទេសកម្ពុជាយើងអោយទៅកាន់ស្ថានភាពដ៏ចំរើនលូតលាស់ជាលំដាប់ជឿនលឿនទៅមុខច្រើនក្នុងផ្លូវអារ្យធម៌។

ព្រឹត្តិការណ៍សំខាន់គឺ ចលនាឧក្រិដ្ឋរបស់ខ្មែរក្បត់ជាតិឯងនិងចលនាប្រទុស្តភាពដ៏អសប្បុរសអស្វារ្យនៃរដ្ឋាភិបាលនៃប្រទេសខ្លះដែលកគេបានបង្កើត គេបានពង្រីក គេបានបង្ហំ

ល្បឿនធ្វើអោយឯកភាព សន្តិភាពបូរណភាពរបស់ខ្មែរ ដែលមានអព្យាក្រិតភាពជាមូលដ្ឋានទ្រទ្រង់ រលាយសាបសូន្យទៅ ដើម្បីកម្ពុជជួជំនួសវិញនូវទាសភាព ការបែកបាក់គ្នា អនាធិបតេយ្យ អសន្តិសុខការបង់ខាតនូវទឹកដីនិងសង្គ្រាមចម្បាំង។

តែកុសលផលបុណ្យព្រះរតនត្រ័យ និងទេវតា ព្រមទាំងការស្នេហាជាតិ និងសាមគ្គីធម៌របស់ប្រជាជាតិយើងបានធ្វើជាប៉ោងមិនអោយវាញ៉ាំញីកម្ពុជាដូចបំណងរបស់វាទៅកើត។

ដោយសារកុសលនេះ យើងមានឪកាសបន្តការកសាងជាតិអោយបានចំរើននៅគ្រប់វិស័យ។

ព្រះអង្គទ្រង់បានបញ្ជាក់ទៀតថា យើងត្រូវរកជោគជ័យអោយទាល់តែបានចំពោះការស៊ីសំណូក ការគៃបាត់ លួចប្រាក់ ឬ ហិតប្រយោជន៍ជាតិនឹងរាជការ។

ជាទីបញ្ចប់ព្រះអង្គបានសំដែងនូវសេចក្តីព្រួយបារម្មណ៍យ៉ាងធំ ចំពោះវិវត្តន៍នៃព្រឹត្តិការណ៍អន្តរជាតិក្នុងភូមិភាគសាកលលោក ដែលមានប្រទេសកម្ពុជាឋិតនៅក្នុងភូមិភាគនោះផងដែរ។

ម៉្យាងទៀតអសន្តិសុខនៅជិតខាងប្រទេសយើងមានកាន់តែខ្លាំងឡើងហើយភ្លើងអសន្តិសុខនេះអាចរោលរាលឆាបមកដល់សំយាបផ្ទះខ្មែរយើងក្នុងអនាគតឆាប់ៗនេះ។

មិនតែប៉ុណ្ណោះរដ្ឋាភិបាលបរទេសខ្លះដែលពើបប្រទះនឹង ព្រឹត្តការណ៍នៅប្រទេសខ្លួនកាន់តែពិបាកតោកយ៉ាកទៅ គេកាន់តែស្រែកបរិហារឲ្យសម្ពន្ធមិត្តគេលឺហើយជឿថាបរិយាកាសដែលកាន់តែចង្អៀតចង្អល់ឡើងនិងគ្រោះថ្នាក់ព្រឹត្តការណ៍អកុសលទាំងអម្បារមានដែលប្រទេសគេពើបប្រទះសព្វថ្ងៃនេះបណ្តោយមកតែអំពីឈ្មោះនរោត្តម-សីហនុនិងអព្យាក្រិតខ្មែរ។

នៅជើងមេឃនៃអនាគតប្រទេសយើងមានពពកខ្មៅងងឹតដែលបណ្តាលឲ្យយើងបារម្ភក្រៃងអស់មានសន្តិភាពគ្រប់គ្រាន់ ដើម្បីកសាងជាតិយើងឲ្យបានចំរើនល្ងតលាស់នឹងគេតទៅមុខទៀត ព្រោះគ្រោះថ្នាក់ដែលយើងជួបពើបប្រទះពុំមែនមានតែម្ខាងមួយទិសនោះទេ គឺអាចបក់បោកមកលើប្រទេសជាតិយើងអំពីទិសទាំងពីរ។ ប្លុកទាំងពីរហាក់ដូចជាចង់បង្ខំល្បឿនចំបាំងត្រជាក់សង្គ្រាមសម្ងាត់របស់គេនៅក្នុងផ្ទៃលើផែនដីខ្មែរយើង ដោយគ្មានត្រាប្រណីដល់សិទ្ធិជាតិនិយមនិងអព្យាក្រិតភាពយើងសោះ។

ដោយគេសម្លុតខ្ញុំ (សម្តេច) ពេកអំពីអព្យាក្រិត និងអំពីការប្រាស្រ័យទាក់ទងដោយមិត្តភាពរវាងប្រទេសយើងនឹងប្រទេសសង្គមនិយម ជាពិសេសរវាងប្រទេសយើងចិនប្រជាមានិត ខ្ញុំក៏បានខំគន់គូរមើលថា តើបើយើង ហើយព្រមលះបង់អព្យាក្រិតទៅចូលនៃនឹងប្រទេសខាងលិចមាន

ប្រទេសសៀមជាដើម រាស្ត្រយើងប្រទេសយើងអាចទទួលនូវសេចក្ដីសុខសួស្ដីបានទេ? គន់គូរយូរទៅលេខឆ្លើយតែម្យ៉ាងគឺថា ទេ!ច្បាស់ជាមិនបានទេ ក្រែងវាកាន់តែហិនហោចទៅទៀត!

សរុបសេចក្ដីទៅឃើញថា កម្ពុរដ្ឋយើងមានផ្លូវតែមួយទេ ដែលជាមធ្យោបាយសំរាប់គាំពារឯករាជ្យបរិសុទ្ធ សាមគ្គីធម៌ជាតិនិងការពារជាតិយើង ដើម្បីចៀសវាងបាននូវមហន្តរាយ គឺការស្លាប់វិនាសបាត់បង់ ឈ្មោះអំពីផែនដីសាកលលោក។ ផ្លូវនោះមធ្យោបាយនោះ គឺអព្យាក្រិតភាពលទ្ធិជាតិនិយមនេះឯង។

ជាទីបំផុតសម្ដេចបានទ្រង់ដាស់តឿនប្រជាពលរដ្ឋជាកូនជាកូនចៅថាយើងទាំងអស់គ្នាត្រូវតែរឹតជួរឲ្យកៀកគ្នា(serer les rangs) គឺពង្រឹងការរួបរួមគ្នាយ៉ាងមាំបំផុតហើយបំពេញពលិកម្មទាំងឡាយដែលជាការចាំបាច់ ដើម្បីមាតុភូមិយើងរស់ជីវិតក្នុងកិត្តិយសនិងសេរីសួស្ដី។ បណ្ដាលសមាជិកសមាជទាំងឡាយ បានខំផ្ទៀងស្ដាប់ដោយយកចិត្តទុកដាក់...

តពីនោះមក សម្ដេចទ្រង់បានលើកយករបៀបវារៈមកដាក់សមាជពិភាក្សាម្ដងមួយៗ។ សមាជិកសមាជទាំងឡាយ ក៏បានឡើងលើវេទិកាថ្លែងយោបល់ដោះស្រាយនូវបញ្ហាជាតិដ៏ធំៗដោយអាកប្បកិរិយាថ្លៃថ្នូរ...

សមក៏ដូចសមាជិកនៃសមាជឯទៀតៗ ដែរគឺអ្នកទាំងអស់គ្នាមានចិត្តសប្បាយរីករាយយ៉ាងក្រៃលែងក្នុងបរិយាកាសដ៏ត្រជាក់ត្រជុំនៃសមាជជាតិលើកទី៩នេះ...

សមាជជាតិបានប្រព្រឹត្តទៅអស់ពេលបីថ្ងៃកន្លះ...សមាជិកនៃសមាជទាំងឡាយក៏បាននាំគ្នាថ្លែងយោបល់ពិភាក្សា ដោះស្រាយនូវបញ្ហាធំៗ ជាប្រយោជន៍ជាតិជាច្រើន ដោយឥតមានសេចក្ដីធុញទ្រាន់សោះឡើយ...។

## អវសាន

រថយន្តបានបោលយ៉ាងលឿនចេញពីស្ថានីយ៍ ភ្នំពេញសំដៅទៅកាន់ក្រុងបាត់ដំបងដោយសន្លឹកដ៏ខ្វះខ្វារ...។

អ្នកដំណើរស្ទើរទាំងអស់ ដែលជិះរថយន្តក្នុងថ្ងៃនេះ ជាអ្នកមករួបរួមក្នុងពិធីសមាជជាតិលើកទី៩ ហើយធ្វើដំណើរត្រឡប់ទៅកាន់គេហដ្ឋានរៀងៗខ្លួនវិញ។ ក្នុងចំណោមអ្នកដំណើរតាមរថយន្តទាំងនេះ សមក៏បានធ្វើដំណើរត្រឡប់ទៅស្រុកវិញដែរ។

សមអង្គុយបឺតបារីនៅក្នុងទូហើយចោលភ្នែកក្រឡេកមើលទេសភាពទាំងឡាយនៅតាមដងផ្លូវអយស្ម័យានដោយអារម្មណ៍យ៉ាងអណ្តែតអណ្តូង...។

សមនឹកដល់អតីតកាល...នឹកដល់ភាពនៃការរីកចំរើនលូតលាស់របស់ជាតិក្នុងបច្ចុប្បន្ន...នឹកដល់ព្រះបន្ទូលនៃសម្តេចដែលប្រកបដោយទឹកព្រះភក្ត្រដ៏ញញឹមប្រិមប្រិយ···នឹកដល់បញ្ហាជាតិដ៏ធំដែលសមាជិកសមាជបានពិភាក្សាដោះស្រាយ···។

សមនឹកពេញចិត្តចំពោះការចំរើនលូតលាស់គ្រប់ផ្នែកក្នុងព្រះរាជាណាចក្រយ៉ាងក្រៃលែង··· សមនឹកថានឹងខំប្រឹងប្រែងបន្តការប្រកបការងារជាកសិករតទៅទៀត ព្រោះការនេះ ជាការជួយកសាងជាតិឲ្យបានចំរើនលូតលាស់មួយផ្នែកដែរ···សមគិតថានឹងខំឆ្លៀតពេល ដើម្បីមកចូលរួមក្នុងសមាជជាតិលើកទី១០ទៀត។

គ្រប់ទីកន្លែងនៅតាមដងផ្លូវនៃអយស្ម័យយានសមបានសង្កេតឃើញក្ងួរស្រូវដីធំៗទុំក្រហមឆ្អៅពាសពេញវាលស្រែ ដែលជាទីពេញចិត្តនៃកសិករយ៉ាងក្រៃលែង...។

សមបានសង្កេតមើលធម្មជាតិ ដែលចំរើនឡើងដោយសារស្នាដៃរបស់កសិករហើយគិតថាធម្មជាតិទាំងនេះហាក់ដូចជាមានសេចក្តីសប្បាយរីករាយចំពោះការដែលកសិករជួយកសាងឲ្យបានចំរើនឡើងនៅលើផែនដីចាស់ ដែលធ្លាប់តែស្រពោនក្រៀមក្រំ ព្រោះគ្មានពន្លឺនៃព្រះអាទិត្យថ្មី គឺរស្មីនៃគំនិតកសាងរបស់កសិករទាំងឡាយដែលមានសម្តេចព្រះឧបយុវរាជ នរោត្តម-សីហនុព្រះបិតាឯករាជ្យជាតិជាព្រះអគ្គមគ្គុទេសក៏ដ៏ឆ្នើមនឹងរាងរៃ...។

សមគិតថា ចំពោះគំនិតរបស់ប្រជាជនខ្មែរគ្រប់ជាន់ថ្នាក់ ទោះបីអ្នកណាគិតដូចសម្តេចក៏ដោយ តែសមនៅតែគិតថា "**ព្រះអាទិត្យថ្មីបានរះនោះលើផែនដីចាស់**"ហើយ។

**ចប់**

វាយបញ្ចូលជា eBook ដោយ

មួន ធីម ប្រាក់ ភានី លន ធីណា វ៉ៃ ជាភិរម្យ ជួន សុគន្ធា

ក្រោមការឧបត្ថម្ភពីសំណាក់ **ខ្លៅ ឃុន សំរ៉េង**

ដើម្បីបម្រើប្រយោជន៍ជាសាធារណ: ដោយមិនគិតកម្រៃ

ខែ មករា ឆ្នាំ ២០១៣

មូលនិធិខ្មែរសំរាប់ការសិក្សា